71

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អភិបាលកិច្ចល្អ និង គោលការណ៍ចាត់ចែង

# GOOD GOVERNANCE AND PRINCIPALE OF MANAGERMENT

## សម្រាប់បណ្តុះបណ្តាលស្មៀនឃុំ - សង្កាត់

FOR COMMUNE-SANGKAT CLERK TRAINING

សហការរវាង ក្រសួងមហាផ្ទៃ

និង

វិទ្យាស្ថានកម្ពុជាដើម្បីសិទ្ធិមនុស្ស

JOINTLY ORGANIZED BY THE MINISTRY OF INTERIOR
AND
THE CAMBODIAN INSTITUTE OF HUMAN RIGHTS

FUNDED BY: NEW ZEALAND

បោះពុម្ពផ្សាយដោយ វិទ្យាស្ថានកម្ពុជាដើម្បីសិទ្ធិមនុស្ស Published by the Cambodian Institute of Human Rights

library.ncdd.gov.kh
015578

# អភិបាលកិច្ចល្អ និង គោលការណ៍ចាត់ចែង

# Good Governance
*and*
# Principle of Management

រៀបចំដោយ

វិទ្យាស្ថានកម្ពុជាដើម្បីសិទ្ធិមនុស្ស សហការជាមួយក្រសួងមហាផ្ទៃ

*Jointly Organized by*

The Cambodian Institute of Human Rights

*and*

The Ministry of Interior

354-968 MAN-CLE-2001
sh: Training

CCSP
Commune Council Support Project

# មាតិកាអត្ថបទ

==========

ទំព័រ

**លក្ខណៈអភិបាលកិច្ចល្អ** ..................................................... ១
ការវិវឌ្ឍន៍ថ្មីៗនៃអភិបាលកិច្ចល្អ ..................................................... ៤
បទពិភាក្សា ..................................................... ៩
មាគ៌ាព្រះពុទ្ធ ..................................................... ១៦
លក្ខណៈនៃអភិបាលកិច្ចល្អ ..................................................... ១៧
ការរីកចំរើនថ្មីៗក្នុងវិស័យអភិបាលកិច្ចល្អ ..................................................... ១៩
ចរិកជាចៅហ្វាយ និងចរិកជាអ្នកដឹកនាំ ..................................................... ២៣
ឧទាហរណ៍មួយនៃការិយាធិបតេយ្យស្មុគស្មាញ ..................................................... ២៤
រូបភាព
ការចូលរួមរបស់ប្រជាពលរដ្ឋ នៅក្នុងសង្គមប្រជាធិបតេយ្យ..................................................... ២៥
ក្រមប្រតិបត្តិសម្រាប់មន្ត្រីនៃរដ្ឋាភិបាល ..................................................... ២៧
ការសិក្សាអំពីករណីនៃការប្រកាន់ខ្ជាប់ខ្ជួន ..................................................... ៣១
ច្បាប់រដ្ឋធម្មនុញ្ញ ..................................................... ៣២
ទំនាក់ទំនងគ្នារវាងរាស្ត្រ និងមន្ត្រីរាជការ ..................................................... ៣៨
រដ្ឋាភិបាលប្រជាធិបតេយ្យ ..................................................... ៤១
**សីលធម៌គ្រប់គ្រង** ..................................................... ៥៤
រំកិលខ្លួនចូលកាន់ដំណែងតាមគន្លងសីលធម៌ ..................................................... ៦០
**សិទ្ធិមនុស្ស ប្រជាធិបតេយ្យ និងវប្បធម៌សន្តិភាព**
អំពីវិទ្យាស្ថាន ..................................................... ៧០
សេចក្ដីថ្លែងការណ៍ជាសកល ..................................................... ៧០
បទដ្ឋានអប្បបរមានៃការប្រតិបត្តិសិទ្ធិមនុស្ស ..................................................... ៧៣
សិទ្ធិមនុស្សតាមបែបព្រះពុទ្ធសាសនា ..................................................... ៧៣
និយមន័យសិទ្ធិមនុស្ស ..................................................... ៧៤
សិទ្ធិជាមូលដ្ឋានគ្រឹះចម្បង៣ ..................................................... ៧៥
សីលធម៌សិទ្ធិមនុស្សក្នុងព្រះពុទ្ធសាសនា ..................................................... ៧៥
ប្រៀបធៀបការប្រតិបត្តិសីល៥ និងសិទ្ធិមនុស្ស ..................................................... ៧៦

គោលការណ៍ព្រះពុទ្ធសាសនាក្នុងវិស័យសិទ្ធិមនុស្ស ........ ៧៨

ខ្លឹមសារសង្ខេបនៃធម៌ជ័យន្តោ ........ ៧៨

អត្ថន័យពិស្តារនៃធម៌ជ័យន្តោ ........ ៧៩

សិទ្ធិមនុស្សមានពីរប្រភេទ ........ ៨០

ការរំលោភសិទ្ធិមានពីរប្រភេទ ........ ៨០

កាតព្វកិច្ចចម្បងរបស់ពលរដ្ឋ ........ ៨២

សិទ្ធិ - ច្បាប់ ........ ៨២

ច្បាប់និងសិទ្ធិ ត្រូវមានសក្ដានុពលពេញលេញដូចគ្នា ........ ៨៣

ទំនាក់ទំនងរវាងសិទ្ធិ និងច្បាប់ ........ ៨៤

ព្រំដែននៃសិទ្ធិ និងច្បាប់ ........ ៨៤

កិច្ចការចម្បងក្នុងវិស័យសិទ្ធិមនុស្ស ........ ៨៥

កិច្ចការដែលអ្នកការពារក្តី ........ ៨៥

ពិនិត្យពន្ធនាគារ ........ ៨៦

ជាតិខ្មែរមានវប្បធម៌ថ្លៃថ្នូរ ........ ៨៦

លទ្ធិប្រជាធិបតេយ្យ ........ ៨៧

លទ្ធិប្រជាធិបតេយ្យគឺរឹតទាបបំផុត ........ ៨៨

ឯករាជភាពនៃអង្គចៅក្រម ........ ៨៨

ប្រជាធិបតេយ្យពេញលក្ខណ: ........ ៨៩

ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល... ........ ៨៩

សិទ្ធិមនុស្ស - ប្រជាធិបតេយ្យ ........ ៩២

សិទ្ធិកាតព្វកិច្ច និងស្មារតីរបស់ពលរដ្ឋ ក្នុងសង្គមប្រជាធិបតេយ្យ ........ ៩២

សិទ្ធិមនុស្ស ........ ៩៤

និតិរដ្ឋ ........ ៩៥

បទពិចារណា ........ ៩៨

ការបោះឆ្នោតមានផលប៉ះពាល់ដល់មន្ត្រីថ្នាក់ណាខ្លះ? ........ ៩៩

គោលការណ៍ប្រតិបត្តិសម្រាប់ភ្នាក់ងារប៉ូលីស ........ ១០០

គោលការណ៍ប្រតិបត្តិ១០ប្រការ ក្នុងកិច្ចប្រតិបត្តិការសឹក ........ ១០២

សប្បាយល្ងាចថ្ងៃសៅរ៍ ........ ១០៣

ឧត្តមគតិកុលបុត្រខ្មែរ ........ ១០៤

នឹកបង្គងចាស់ ............ ១០៥
វប្បធម៌សន្តិភាព ............ ១០៦
រូបភាព " អំពើពុករលួយ " ............ ១០៧
**សិទ្ធិមនុស្ស (បកស្រាយសង្ខេប)** ............ ១០៨
សិទ្ធិនយោបាយទាក់ទងនឹងការបោះឆ្នោត ............ ១៣០
ទិវាបុណ្យអន្តរជាតិ សម្រាប់សិទ្ធិមនុស្ស ............ ១៣៤
ប្រជាធិបតេយ្យជាអ្វី? ............ ១៣៦
គ្រឿងផ្សំសំខាន់ ៤យ៉ាង... ............ ១៣៨
ព្រះពុទ្ធសាសនា និងលទ្ធិប្រជាធិបតេយ្យ ............ ១៣៩
មគ្គសច្ចៈទាំង៤... ............ ១៤៣
មាគ៌ាណែនាំនៃព្រះពុទ្ធ ព្រះបរមគ្រូ ............ ១៤៥
សំដីអ្នកដឹកនាំរដ្ឋាភិបាលអាមេរិកកាំង... ............ ១៤៧
**អ្វីខ្លះជាការរំលោភសិទ្ធិ**
សេចក្តីថ្លែងការណ៍ជាសកលស្តីអំពីសិទ្ធិមនុស្ស ............ ១៤៨
**ការបោះឆ្នោត** ............ ២១០
ក្រមសីលធម៌នៃការបោះឆ្នោតសេរីនិងយុត្តិធម៌ ............ ២៣៧
**ការយល់ដឹងអំពីយេនឌ័រ** ............ ២៩៣
ការយល់ដឹងអំពីខ្លួនឯង ............ ២៩៦
ការស្គាល់យេនឌ័រ ............ ២៩៧
ការបែងចែកការងារ ............ ២៩៩
ការទទួលបាន និងការត្រួតត្រាលើធនធាន និងផលប្រយោជន៍ ............ ២៦១

# លក្ខណៈនៃអភិបាលកិច្ចល្អ

មានគោលការណ៍ជាមូលដ្ឋានយ៉ាងតិច៦ប្រការ ដែលគួសបញ្ជាក់ពីអភិបាលកិច្ចល្អ ។

## ១. គិតអំពីសេចាសាធារណៈ

នេះគឺជាទស្សនៈដែលចែងថារដ្ឋាភិបាលកើតឡើងដើម្បីបម្រើពលរដ្ឋ ពុំមែនសម្រាប់ប្រើអំណាចត្រួតត្រាពលរដ្ឋទេ ។ *ការបម្រើ* (ឬផ្តល់សេវា) គឺមិនមែនជាការប្រើអំណាចត្រួតត្រាទេ ។ គោលនយោបាយឬសកម្មភាពណាមួយ ដែលធ្វើដោយរដ្ឋាភិបាលអាចឬត្រូវតែបានវិនិច្ឆ័យថាល្អ ឬអាក្រក់ ដោយឆ្លើយទៅនឹងសំណួរថា "*តើការនេះផ្តល់អត្ថប្រយោជន៍ដល់ពលរដ្ឋដែរឬទេ* " ?

សំណួរនេះអាចនាំទៅរកការផ្លាស់ប្តូរនៅក្នុងសកម្មភាពរបស់រដ្ឋាភិបាល ។ មានកិច្ចការខ្លះត្រូវបានធ្វើឡើងដោយពុំមានគោលបំណងល្អសោះ ។ ការខ្លះទៀតពុំអាចមានអត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋឡើយ ឬអាចមានគ្រោះថ្នាក់ថែមទៀត ។

## ២. ការចូលរួមរបស់ប្រជាពលរដ្ឋ

នៅក្នុងលទ្ធិប្រជាធិបតេយ្យពលរដ្ឋមានសិទ្ធិចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចការមួយចំនួនរបស់រដ្ឋាភិបាល ។ នេះគឺជាខ្លឹមសារនៃលទ្ធិប្រជាធិបតេយ្យ ។ គេចូលរួមបោះឆ្នោត ។ គេអាចឈរឈ្មោះបោះឆ្នោត ។ ពលរដ្ឋអាចធ្វើការប្រជុំជាសាធារណៈ និងបង្កើតសមាគម ដើម្បីពិភាក្សាបញ្ហានានាដែលពាក់ព័ន្ធដល់សាធារណជន ។ គេអាចតវ៉ានឹងរដ្ឋាភិបាលដោយផ្ទាល់មាត់ ឬដោយលាយល័ក្ខអក្សរ ដើម្បីទាមទារឲ្យរដ្ឋាភិបាលគិតគូរដល់បញ្ហារបស់គេ ។ គេអាចបោះពុម្ពផ្សាយអត្ថបទនានានៅក្នុងកាសែត និយាយតាមវិទ្យុ ។ល។ តាមរយៈនៃការចូលរួមរបស់គេ ។ ពលរដ្ឋធ្វើការណែនាំរដ្ឋាភិបាល ដោយប្រាប់រដ្ឋាភិបាលនូវអ្វីៗដែលមានសារសំខាន់ដល់ពលរដ្ឋ ។ រដ្ឋាភិបាលក៏បានទទួលអត្ថប្រយោជន៍ ពីព្រោះរដ្ឋាភិបាលដឹងពីអ្វីដែលជាគំនិតរបស់ពលរដ្ឋម្នាក់ៗ ហើយអាចចាត់ចែងគោលនយោបាយរបស់ខ្លួនដើម្បីតម្រូវចិត្តពលរដ្ឋនោះ ។ ក្នុងឋានៈជាមន្ត្រីរដ្ឋាភិបាល លោកត្រូវតែស្វាគមន៍ និងរំពឹងទុកជាមុនថា អ្វីៗដែលរដ្ឋាភិបាលធ្វើ ពលរដ្ឋតែងតែចាប់អារម្មណ៍ជានិច្ច ។

## ៣. ការបើកឱកាសជូនសាធារណជន

ទិដ្ឋភាពមួយនៃការចូលរួមរបស់ពលរដ្ឋ គឺការបើកឱកាសជូនសាធារណជន ។ ពលរដ្ឋត្រូវការចង់ជួបអ្នកដោយផ្ទាល់ ឬជាក្រុមដើម្បីសំដែងពីទស្សនៈ និងការព្រួយបារម្ភរបស់គេ ។ គេត្រូវការចង់ដឹងពីអ្វីដែលរដ្ឋាភិបាលកំពុងធ្វើ ឬមិនធ្វើនៅលើវិស័យដែលជាប្រយោជន៍ដល់ពួកគេ ។ គេធ្វើបែបនេះគឺជាការត្រឹមត្រូវ និងសមស្រប ។ ទោះបីជាត្រូវចំណាយពេលវេលាច្រើនក៏ដោយមន្ត្រីរាជការត្រូវតែជួបជាមួយពលរដ្ឋ និងក្រុមប្រជាពលរដ្ឋ ។ ពួកគេអាចជួយអ្នកឲ្យមានការយល់ដឹងយ៉ាងច្បាស់ពីអ្វីដែលពួកគេត្រូវការ និងចង់បាន ។ អ្នកត្រូវតែធ្វើការពិគ្រោះយ៉ាងសកម្មជាមួយសាធារណជន ស្តីពីបញ្ហាសំខាន់ៗ មុននឹងធ្វើសេចក្តីសម្រេចជាចុងក្រោយ ។

## ៤. តម្លាភាព (ភាពឥតលាក់លៀម)

តម្លាភាពមានន័យថា ភាពបើកចំហ -សាធារណជនត្រូវតែអាចឃើញ-ដឹង-ឮ នូវអ្វីដែលរដ្ឋាភិបាលកំពុងធ្វើ ។ ជាទូទៅ ការងាររដ្ឋាភិបាល គឺជាការងាររបស់ពលរដ្ឋ ហើយមិនត្រូវមានការលាក់បាំងទេ ។ រដ្ឋាភិបាលត្រូវតែបើកចំហជូនពលរដ្ឋធ្វើអធិការកិច្ច ហើយផ្សព្វផ្សាយពត៌មានអំពីអ្វីដែលរដ្ឋាភិបាលកំពុងធ្វើ ។ ការនេះអាចឲ្យពលរដ្ឋមើលឃើញថា តើអ្វីៗដែលកំពុងតែធ្វើគឺធ្វេក្នុងនាមរបស់ពលរដ្ឋ ហើយឆ្លើយតបទៅនឹងផលប្រយោជន៍របស់ពលរដ្ឋឬទេ ។ រដ្ឋាភិបាលអនុវត្តនយោបាយតម្លាភាព ដោយផ្តល់ពត៌មានទៅឲ្យសារពត៌មាន ដោយការឆ្លើយតបដោយចេតនាទៅនឹងសំណួរ ឬសំណើសុំពត៌មានពីសំណាក់អ្នកកាសែត, ពីសំណាក់សមាជិកសភា និងពីសំណាក់សាធារណជន ហើយនិងដោយការបោះពុម្ពផ្សាយឯកសារជាច្រើន ដែលពន្យល់អំពីអ្វីដែលរដ្ឋាភិបាលកំពុងធ្វើ ។

## ៥. ការទទួលខុសត្រូវ

ការទទួលខុសត្រូវមានន័យថា រដ្ឋាភិបាលត្រូវតែពន្យល់ និងបញ្ជាក់ពីសកម្មភាព និងសេចក្តីសម្រេចរបស់ខ្លួនជូនសាធារណជន ។ រដ្ឋាភិបាលត្រូវទទួលខុសត្រូវចំពោះសាធារណជនពីអ្វីដែលខ្លួនបានធ្វើ ហើយថាតើរដ្ឋាភិបាលចំណាយប្រាក់របស់ពលរដ្ឋយ៉ាងណាខ្លះ ។ មន្ត្រីទាំងឡាយក៏ទទួលខុសត្រូវផ្ទាល់ខ្លួនចំពោះអ្វីដែលគេបានធ្វើដែរ ។

## ៦. ការចាត់ចែងល្អ

ការចាត់ចែងល្អ គឺជាប្រធានបទទាំងមូលសម្រាប់ធ្វើការសិក្សាដ៏យូរអង្វែង ។ ប៉ុន្តែនិយាយដោយសង្ខេប ការចាត់ចែងល្អមានលក្ខណៈដូចគ្នា ទោះរដ្ឋាភិបាលក្តី អង្គការឯកជនក្តី ។

នេះមានន័យថា រដ្ឋាភិបាលមានប្រព័ន្ធមួយសម្រាប់ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងមានភាពស័ក្តិសិទ្ធិ គឺថាបាន**ទទួលលទ្ធផលល្អទាន់ពេល** និងមិនខ្ជះខ្ជាយធនធាន ។

# ការវិវឌ្ឍន៍ថ្មីៗនៃអភិបាលកិច្ចល្អ

ជាច្រើនឆ្នាំកន្លងមកនេះ គំនិតថ្មីៗជាច្រើនត្រូវបានគេយកមកសាកល្បង និងយកទៅប្រើប្រកបដោយជោគជ័យនៅក្នុងប្រទេសជាច្រើន ដើម្បីឲ្យធ្វើការគ្រប់គ្រងមានលក្ខណៈកាន់តែល្អឡើង ។ នេះជាគំនិតប្រសើរបំផុតបន្ថែមទៅលើគំនិតនានា ដែលយើងធ្លាប់បានបង្ហាញជូនរួចហើយ ។ គ្រប់ផ្នែកទាំងអស់របស់រដ្ឋាភិបាល ឬមន្ត្រីគ្រប់រូបពុំអាចយកគំនិតទាំងអស់នេះទៅប្រើទាំងអស់ទេ ប៉ុន្តែលោកអាចជ្រើសរើសយកគំនិតខ្លះទៅអនុវត្តបានយ៉ាងល្អនៅក្នុងកិច្ចការរបស់លោក ។ យើងសុំឲ្យលោកពិនិត្យមើលគំនិតទាំងនោះ ហើយពិចារណាមើលក្រែងគំនិតទាំងនោះខ្លះអាចមានប្រយោជន៍សម្រាប់ការងាររបស់លោក ។

## " ចង្អុលទិសដៅគ្រាន់បើជាងចូកចែវ (ដោយខ្លួនឯង) "

នេះមានន័យថា មន្ត្រីរដ្ឋាភិបាលថ្នាក់ខ្ពស់ ត្រូវចំណាយពេលវេលាឲ្យតិចក្នុងការបំពេញភារកិច្ចប្រចាំថ្ងៃរបស់រដ្ឋាភិបាល ហើយត្រូវចំណាយពេលឲ្យច្រើនក្នុងការរៀបចំការដឹកនាំកិច្ចការ។ ការនេះមានលក្ខណៈដូចជាអ្នកកាច់ចង្កូតទូក ដែលដឹងពីទីកន្លែងដែលគាត់ចង់ទៅ ជាងអ្នកដែលអុំទូក ។ របៀបដឹកនាំតាមការកាច់ចង្កូតតម្រូវឲ្យមានការប្រមើលមើលជាមុន ហើយត្រូវរកវិធីបង្ការបញ្ហាទាំងនោះជាមុន ប្រសើរជាងបណ្តោយទុកឲ្យបញ្ហានោះ ក្លាយទៅជាបញ្ហាដែលធ្វើឲ្យមានការឈឺក្បាលយ៉ាងខ្លាំង ។ ប្រការនេះតម្រូវឲ្យមានផែនការជាក់លាក់ជាមុន ។

## មានបេសកកម្មជាក់លាក់

លោកត្រូវតែមានបេសកកម្មមួយដែលជាគ្រឹះជាក់លាក់មានប្រៀបលើទិសដៅដទៃៗទៀត ។ បេសកកម្មនេះត្រូវតែមានចែងជាលាយល័ក្ខអក្សរយ៉ាងច្បាស់លាស់ ។ បេសកកម្មមិនគ្រាន់តែធ្វើតាមបទបញ្ជាឬនីតិវិធីឬបំពេញភារកិច្ចដដែលៗនោះទេ ប៉ុន្តែត្រូវធ្វើឲ្យសម្រេចភារកិច្ចជាគោលដៅជាក់ស្តែងដ៏សំខាន់មួយ ។ នេះគឺជាការទទួលខុសត្រូវខ្ពស់បំផុតរបស់អ្នកចាត់ចែងក្នុងការកំណត់បេសកកម្មជាក់លាក់ដោយធ្វើការពិគ្រោះជាមួយអ្នកដទៃថា តើបេសកកម្មនោះជាអ្វី ហើយធ្វើយ៉ាងណាឲ្យមនុស្សគ្រប់រូបនៅក្នុងស្ថាប័នប្រាកដជាយល់ច្បាស់អំពីបេសកកម្មដើម្បីអនុវត្តបេសកកម្មនោះឲ្យបានជោគជ័យ ។

ឧទាហរណ៍, ភោជនីយដ្ឋានមួយដែលយើងស្គាល់បានប្រកាសថា បេសកកម្មរបស់គេគឺធ្វើ និងបម្រើម្ហូបត្រីដែលមានរសជាតិឆ្ងាញ់បានយ៉ាងឆាប់រហ័សនៅក្នុងបរិស្ថានដ៏ស្អាត ។ គេត្រូវដាក់សេចក្តីប្រកាសនៃបេសកកម្មនេះនៅលើតុនីមួយៗ ។

## **បម្រើអតិថិជនរបស់អ្នក**

ត្រូវចាត់ទុកប្រជាពលរដ្ឋដែលចូលមកទាក់ទងជាមួយរដ្ឋាភិបាលថាជាអតិថិជន ដូចគ្នាទៅនឹងពាណិជ្ជករដែលមានអតិថិជនដែរ ។ នេះមានន័យថា ត្រូវផ្តល់សេវាដ៏ល្អដល់អតិថិជន និងដើម្បីធ្វើឲ្យអតិថិជនពេញចិត្តចំពោះស្នាដៃនៃកិច្ចការរបស់អ្នក ។

ដែលយើងគិតថារដ្ឋាភិបាលមាន "*អតិថិជន*" គឺមានលក្ខណៈច្បាស់លាស់ជាងការដែលគ្រាន់តែបម្រើសាធារណជន ។ ភ្នាក់ងាររដ្ឋាភិបាលភាគច្រើនតែងតែមានមនុស្សដែលខ្លួនត្រូវធ្វើការទាក់ទងដោយផ្ទាល់ --ជនទាំងនោះគឺជាអតិថិជន ។ ជនទាំងនោះអាចអញ្ជើញមកជួបអ្នក គេអាចទូរស័ព្ទមកសុំឲ្យជួយ ឬសុំសេវាបែបណាមួយ ។ អ្នកអាចអញ្ជើញទៅរកអ្នកទាំងនោះ, ប្រសិនបើអ្នកជានគរបាលចរាចរដែលចាត់ចែងចរាចរនៅទីកន្លែង ដែលមានមនុស្សច្រើន ឬអភិបាលខេត្តដែលធ្វើអធិការកិច្ចលើគម្រោងអភិវឌ្ឍន៍មួយ ។

មានទិដ្ឋភាពជាច្រើនក្នុងការចាត់ទុកប្រជាពលរដ្ឋជាអតិថិជន ។ ប្រសិនបើគេត្រូវការសេវាដូចជាការអនុញ្ញាតឲ្យចាប់ផ្តើមធ្វើអាជីវកម្មមួយ គេត្រូវតែបានទទួលសេវានោះយ៉ាងឆាប់រហ័ស និងយ៉ាងគួរសម ដោយពុំមានក្រដាសស្នាមច្រើនហួសហេតុ ឬការពន្យារទេ ។ ប្រជាពលរដ្ឋនោះត្រូវតែអាចជួបជាមួយមន្ត្រីនៅក្នុងរដ្ឋាភិបាលយ៉ាងងាយស្រួល នៅពេលដែលគេចង់ជួបដើម្បីដោះស្រាយបញ្ហានានារបស់គេ ហើយមិនត្រូវដើរពីការិយាល័យមួយទៅការិយាល័យមួយទៀត ហើយមិនត្រូវចំណាយពេលវេលាច្រើនទេ ។

**តើត្រូវធ្វើយ៉ាងណាដើម្បីឲ្យដឹងថាអតិថិជន** (ពលរដ្ឋ) **ពេញចិត្តចំពោះសេវា** (ឬកិច្ចការ) **របស់អ្នក?**

### ត្រូវពិគ្រោះជាមួយពលរដ្ឋ !

ត្រូវពិគ្រោះជាមួយពលរដ្ឋថាតើគេត្រូវការសេវាអ្វីខ្លះ ឬត្រូវកែលំអរបៀបយ៉ាងដូចម្តេចសេវាយ៉ាងណាខ្លះ ។ ការពិគ្រោះទាំងនោះអាចមានទម្រង់ផ្សេងៗគ្នា :

**១. ការប្រមូលពត៌មានផ្លូវការ ឬក្រៅផ្លូវការ**, អ្នកអាចប្រមូលពត៌មានតាមការសម្ភាសន៍ពលរដ្ឋ ឬឆ្លើយនឹងសំណួរទាំងឡាយស្តីអំពីកិច្ចការរបស់អ្នក ។

**២. ការជួបប្រជុំជាសាធារណៈ** . ការប្រជុំធំជាសាធារណៈ ឬការប្រជុំតូចជាសាធារណៈ អាចផ្តល់មតិលើសេវានានាដែលគេចង់បាន ឬដែលគេត្រូវការ ។

**៣. ក្រុមប្រឹក្សាផ្តល់យោបល់** . ស្ថាប័នរដ្ឋាភិបាលខ្លះ មានក្រុមប្រឹក្សាផ្លូវការ ឬជាពលរដ្ឋឆ្នើម ដែលយកចិត្តទុកដាក់ ហើយដែលធ្លាប់ស្គាល់ការងាររបស់ស្ថាប័នរដ្ឋាភិបាល ។

**៤. ការសាកល្បង** . នៅមុនពេលអ្នកផ្លាស់ប្តូរសេវាមួយ ឬបន្ថែមសេវាថ្មីមួយ អ្នកអាចធ្វើការសាកល្បងសេវានោះជាមួយពលរដ្ឋ ឬអតិថិជនមួយចំនួនតូច ។ ការនេះអាចឲ្យអ្នកយល់ដឹងនូវប្រតិកម្មរបស់អតិថិជនមុននឹងធ្វើការផ្លាស់ប្តូរ ។

## ការវាស់លទ្ធផល

ដើម្បីដឹងថាសេវាថ្មីៗមានលក្ខណៈល្អ ឬអាក្រក់ អ្នកត្រូវវាស់ឬវាយតម្លៃសេវានោះ ។ នេះមានន័យថា វាស់លទ្ធផលពិតប្រាកដ ។ ឧទាហរណ៍ ប្រសិនបើអ្នកជាម្ចាស់មន្ទីរព្យាបាលរោគ អ្នកអាចធ្វើការវាស់ថា តើអ្នកជំងឺត្រូវរង់ចាំអស់រយៈពេលប៉ុន្មាន មុននឹងបានជួបគ្រូពេទ្យ ហើយតើលទ្ធផលមានអ្វីខ្លះ --មានប្រជាពលរដ្ឋប៉ុន្មាននាក់បានមកព្យាបាល តើមានស្លាប់ប៉ុន្មានភាគរយ ? ការនេះអាចវាស់អំពីអ្វីៗខ្លះដែលមានសារសំខាន់ចំពោះអតិថិជន ។ ឧបមាថាអ្នកជំងឺជាច្រើនត្រូវស្លាប់ នោះបានន័យថាអ្នកមិនបានធ្វើការងាររបស់អ្នកឲ្យបានត្រឹមត្រូវល្អទេ ។

## ការផ្តល់អំណាចខ្លះៗឲ្យបុគ្គលិក

បើអ្នកចង់ឲ្យបុគ្គលិករបស់អ្នកមានការទទួលខុសត្រូវកាន់តែច្រើនឡើង អ្នកត្រូវអនុញ្ញាតឲ្យបុគ្គលិកទាំងនោះចូលរួមក្នុងការដោះស្រាយបញ្ហានានា ។ ជារឿយៗបុគ្គលិករបស់អ្នកនឹងយល់បញ្ហាល្អជាងអ្នក ហើយអាចរិះរកដំណោះស្រាយដ៏ល្អៗ ។ បុគ្គលិកទាំងនោះ គួរតែត្រូវបានលើកទឹកចិត្តឲ្យធ្វើបែបដូច្នេះ ។

**ការធ្វើវិមជ្ឈការ និងការចែករំលែកអំណាច** --ប្រសិនបើសេចក្តីសម្រេចទាំងអស់ទាំងតូចទាំងធំក្តីត្រូវសម្រេចដោយមន្ត្រីថាខ្ពស់ សេចក្តីសម្រេចទាំងនោះនឹងត្រូវយឺតយ៉ាវឬខ្វះប្រសិទ្ធិភាព។ មន្ត្រីថ្នាក់ខ្ពស់នឹងជាប់រវល់ដោះស្រាយបញ្ហាតូចៗរាប់ពាន់ដែលមានជារៀងរាល់ថ្ងៃ

ពុំមានពេលគិតគូរ ឬធ្វើផែនការធំៗទេ ។ ដូច្នេះ ចូរផ្ដល់អំណាចទៅឲ្យអ្នកក្រោមបង្គាប់ឲ្យគេមានសិទ្ធិធ្វើសេចក្ដីសម្រេចលើបញ្ហាតូចតាចទាំងនោះ ហើយធ្វើការវាស់ស្ទង់ និងចាត់ចែងភារកិច្ចរបស់គេដោយប្រុងប្រយ័ត្នដើម្បីធានាគុណភាពការងារ ។

ការកាត់បន្ថយការិយាធិបតេយ្យ

ដើម្បីធ្វើកិច្ចការនានាឲ្យបានសម្រេច អ្នកត្រូវការបុគ្គលិកគ្រប់គ្រាន់និងនីតិវិធីមួយចំនួន ។ ប៉ុន្តែអ្នកមិនត្រូវមានការងារក្រដាសស្នាម ឬនីតិវិធីដ៏ស្មុគ្រស្មាញពេកទេ ។ អតិថិជនរបស់អ្នក --ប្រជាពលរដ្ឋ --ហើយនិងបុគ្គលិករបស់អ្នក នឹងអរគុណអ្នក ប្រសិនបើអ្នកប្រើប្រាស់នីតិវិធី និងការងារបែបបទងាយស្រួល ។

## របាយការណ៍ការងារ

របាយការណ៍ការងារ គឺជាសេចក្ដីរាយការណ៍ដ៏ខ្លីមួយ (ដែលមានតែមួយវគ្គ ឬពីរវគ្គ ឬប្រហែលតែមួយទំព័រប៉ុណ្ណោះ) ដែលបូកសរុបតួនាទី ឬគោលបំណងរបស់ស្ថាប័ន ឬកម្មវិធី / គំរោងរបស់អ្នក ។ គឺជាការរៀបរាប់ពីការងារ ភារកិច្ចដែលស្ថាប័ន ផ្នែក ឬក្រុមរបស់អ្នកធ្វើ ។ សូម្បីតែកម្មវិធី ឬគំរោងក៏ត្រូវមានរបាយការណ៍ការងារដែរ ។ វាធ្វើឲ្យបុគ្គលិកទាំងអស់ធ្វើការរួមគ្នាក្នុងទិសដៅតែមួយ និងជួយឲ្យបុគ្គលិកព្រមព្រៀងគ្នាលើកិច្ចការដែលពួកគេកំពុងអនុវត្តនោះ ។ វាអាចចូល ជាបាវចនារបស់ស្ថាប័នដែរ ។

បុគ្គលិកគ្រប់រូបត្រូវតែដឹងពីការងារ ភារកិច្ចរបស់ស្ថាប័នរបស់គេ ។ មានអ្នកជំនាញការជាច្រើននិយាយថា ចំណុចដែលសំខាន់បំផុតសម្រាប់ស្ថាប័ន គឺត្រូវមានគោលបំណង ឬបេសក-កម្មច្បាស់លាស់ ។ ដូចនេះរបាយការណ៍ការងារ គឺតំណាងឲ្យគំនិតនោះឯង ។

របាយការណ៍ការងារ ត្រូវបញ្ជាក់ឲ្យច្បាស់ពីតួនាទី ឬគោលបំណងរបស់ស្ថាប័ន ។ វាអាចបញ្ជាក់យ៉ាងច្បាស់ពីគោលដៅសំខាន់ៗរបស់ស្ថាប័ន ។ វាក៏អាចបញ្ជាក់ពីចំណុចជាច្រើនដូចខាងក្រោមនេះ :

ការងារអ្វីដែលអ្នកប្រាកដជាធ្វើបានល្អ ហើយត្រូវចាំថាអ្នកមិនអាចធ្វើការងារគ្រប់មុខបានឡើយ ។ ត្រូវផ្ដោតទៅលើការងារណាដែលសំខាន់ចំពោះអ្នក ។ ឧទាហរណ៍ដូចជា:

+ ការងារដែលអ្នកមានមោទនភាព
+ ការងារណាដែលអ្នកចង់អោយគេដឹង
+ ការងារណាដែលស្ថាប័នអ្នកមានជំនឿលើ
+ អ្នកដែលជាអតិថិជនរបស់អ្នក

+ សេវាដែលអ្នកត្រូវផ្តល់ឲ្យ

+ តើអ្នកពូកែដូចម្តេចខ្លះក្នុងការផ្តល់សេវា

វាជាការសមរម្យណាស់ បើយើងព្យួរបាយការណ៍ការងារនៅលើជញ្ជាំងខាងមុខក្នុងការិយាល័យ ឬកន្លែងផ្សេងទៀតដែលអាចឲ្យបុគ្គលិក ឬអតិថិជនអាចមើលឃើញ ។

## បទពិសោធន៍ : ប្រវត្តិនៃប្រទេសពីរ

(ខាងក្រោមនេះ គឺជាប្រទេសពីរពិតប្រាកដ ហើយពុំមែនកម្ពុជាទេ)

## នគរកូលាប

ប្រទេសដែលយើងឲ្យឈ្មោះថានគរកូលាបមានទំហំតូច ជាកោះក្រីក្រមួយ ។ សេចក្តីសម្រេចនានាត្រូវបានធ្វើនៅក្នុងរដ្ឋាភិបាល ដោយមនុស្សម្នាក់ឬមនុស្សមួយក្រុមតូចដោយសម្ងាត់បំផុត ។ សេចក្តីសម្រេចទាំងនោះត្រូវបានផ្សព្វផ្សាយទៅឲ្យប្រជាពលរដ្ឋដោយក្រឹត្យ ។ ជួនកាលអ្នកដឹកនាំរដ្ឋាភិបាលចង់ធ្វើអ្វីមួយឲ្យមានលក្ខណៈជាវិជ្ជាមានសម្រាប់ប្រជាពលរដ្ឋ ។ គំនិតជាវិជ្ជមានខ្លះត្រូវបានស្នើឡើង ។ តាមធម្មតាគឺពុំមានផែនការទេ ហើយអ្នកដឹកនាំពុំចាំបាច់មានគំនិតច្បាស់លាស់ពីអ្វីដែលនឹងកើតមានឡើង ដែលជាលទ្ធផលនៃបញ្ជារបស់អ្នកដឹកនាំទាំងនោះ ។ ក្រឹត្យខ្លះដែលបានចេញផ្សាយត្រូវបានគេប្រតិបត្តិតាម ប៉ុន្តែក្រឹត្យខ្លះទៀតត្រូវបានគេទុកចោលធ្វើមិនដឹង ។ រដ្ឋាភិបាលពុំមានការត្រួតពិនិត្យមន្ត្រីថ្នាក់ក្រោមរបស់ខ្លួនទេ ។ ការនោះបានផ្តល់សេរីភាពយ៉ាងច្រើនដល់មន្ត្រីទាំងនោះ ក្នុងការធ្វើអ្វីដែលគេចង់ធ្វើ ។

រដ្ឋាភិបាលមានមុខងារសំខាន់ៗតិចតួច ។ រដ្ឋាភិបាលប្រមូលពន្ធដារ និងបើកប្រាក់ខែឲ្យបុគ្គលិក ។ យោធា និងនគរបាលរបស់រដ្ឋាភិបាលទប់ស្កាត់មិនឲ្យមានការប្រឆាំងណាមួយឡើយ។ ស្ថាប័នឯកជនបានផ្តល់សេវាយ៉ាងច្រើន ហើយមានតម្លៃយ៉ាងខ្ពស់ជំនួសស្ថាប័នរដ្ឋដែលត្រូវផ្តល់សេវាទាំងនោះជូនពលរដ្ឋដោយឥតគិតថ្លៃ ឬដោយគិតតម្លៃតិចតួច ។ ការនេះប្រសើរណាស់សម្រាប់ពលរដ្ឋដែលមានប្រាក់ច្រើន ។ សេវារដ្ឋាភិបាលមានកម្រិត ។ មន្ទីរពេទ្យរដ្ឋាភិបាលមានថ្នាំពេទ្យ ឬសម្ភារៈតិចតួច ឬពុំមានសម្ភារៈ ឬថ្នាំពេទ្យទេ ។ ថ្នាំពេទ្យនិងសម្ភារៈទាំងនេះត្រូវបានផ្តល់ឲ្យដោយស្ថាប័នឯកជន ហើយជួនកាលក្នុងតម្លៃខ្ពស់ ។ សាលារៀនរបស់រដ្ឋពុំសូវមានទេ ។ សាលារៀនភាគច្រើនជាសាលាឈ្នួល ។ ផ្លូវថ្នល់សេវាសាធារណៈ ពុំមានលក្ខណៈល្អទេ ។ ផ្លូវថ្នល់ ឬសេវាសាធារណៈទាំងនោះមិនសូវបានជួសជុលឲ្យបានជិតដល់ទេ ដោយរដ្ឋាភិបាលខ្វះថវិការ ។ ជាធម្មតារដ្ឋមន្ត្រីនឹងមន្ត្រីខ្លះបានយកលុយរបស់ក្រសួងទៅប្រើជាប្រយោជន៍ផ្ទាល់ខ្លួន ហើយលុយកាក់ដែលនៅសល់តិចតួចណាស់ សម្រាប់ធ្វើសេវាសាធារណៈ។ មន្ត្រីទាំងនោះកាន់តែមានសម្បត្តិច្រើនឡើង ។ ជាធម្មតាមន្ត្រីទាំងនោះពុំត្រូវបានផ្តន្ទាទោសចំពោះចរិយាមិនល្អរបស់គេឡើយ ។ តុលាការឋិតនៅក្រោមឥទ្ធិពលអ្នកមានអំណាច និងការស៊ីសំណូក ហើយយឺតយ៉ាវណាស់ ក្នុងការបើកសវនាការនានា ។ ច្បាប់ខ្លះត្រូវបានដាក់ឲ្យ

អនុវត្ត ប៉ុន្តែក៏មានច្បាប់ជាច្រើនក៏មិនត្រូវបានអនុវត្ត ។ ដោយហេតុនេះពលរដ្ឋជាច្រើនមិនចូលចិត្តប្រើប្រព័ន្ធច្បាប់ទេ ។ ជម្លោះជាច្រើនត្រូវបានដោះស្រាយដោយកម្លាំង ឬដោយការគំរាមកំហែងនៃអំពើហិង្សា ដោយជន ឬអង្គការដែលមានអំណាច ។

រដ្ឋាភិបាលមានបុគ្គលិកជាច្រើនពាន់នាក់ អ្នកខ្លះបានមកបង្ហាញខ្លួនដើម្បីធ្វើការ អ្នកខ្លះមិនបានមកបង្ហាញខ្លួនទេ ។ អ្នកដែលមកបង្ហាញខ្លួនខ្លះពុំសូវមានការងារធ្វើទេ ។ អាគារនានារបស់រដ្ឋាភិបាលពុំមានលក្ខណៈល្អ ហើយពុំសូវមានសម្ភារៈ ឬការផ្គត់ផ្គង់គ្រប់គ្រាន់ដើម្បីធ្វើការងារទេ ។ ការផ្គត់ផ្គង់ និងសម្ភារៈរបស់រដ្ឋាភិបាលត្រូវបានលួចយកចេញពីការិយាល័យជារឿយៗ ។ ប្រាក់បៀវត្សរ៍របស់រដ្ឋាភិបាលមានកម្រិតទាប លើកលែងតែជនថ្នាក់លើ ។

អ្នកផ្តល់ជំនួយបរទេសឈប់ផ្តល់ប្រាក់ដល់រដ្ឋាភិបាលពីព្រោះគេខ្លាចប្រាក់នោះនឹងត្រូវយកទៅប្រើខុសទិសដៅ ឬត្រូវលួច ។ ការធ្វើអាជីវកម្មបរទេសមិនមានធ្វើវិនិយោគច្រើនតទៅទៀតទេនៅក្នុងនគរកូលាប ពីព្រោះគេត្រូវបង់ប្រាក់សំណូកជាច្រើនដល់មន្ត្រីនានា ហើយបន្ទាប់មកមន្ត្រីមានអំណាចអាចធ្វើការរឹបអូសអាជីវកម្មរបស់ពួកគេ ។ សេដ្ឋកិច្ចប្រទេសចុះថយជាលំដាប់ ប៉ុន្តែបុគ្គលមួយចំនួនមានប្រាក់កាសនឹងទ្រព្យសម្បត្តិកើនឡើង ។ មន្ត្រីទាំងនោះមានផ្ទះវិឡា និងរថយន្តជាច្រើន ប៉ុន្តែមន្ត្រីទាំងនោះមានចំនួនតិចទេ ។

ពលរដ្ឋភាគច្រើននៅក្នុងនគរកូលាបជាអ្នកក្រីក្រ ។ អ្នកក្រីក្រទាំងនោះស្តីបន្ទោសរដ្ឋាភិបាល និងពលរដ្ឋអ្នកមាន ដែលធ្វើឲ្យខ្លួនមានការលំបាក ។ យូរៗម្តង អ្នកក្រីក្រទាំងនោះបានធ្វើការបះបោរ ហើយផ្តួលរំលំរដ្ឋាភិបាលដោយកម្លាំងជារឿយៗពីរបីឆ្នាំម្តង ។ នៅពេលមានការផ្តួលរំលំរដ្ឋាភិបាល មន្ត្រីរដ្ឋាភិបាលបានបាត់បង់អ្វីៗទាំងអស់ ។ ផ្ទះរបស់មន្ត្រីទាំងនោះត្រូវកំទេចចោល និងត្រូវលួចប្លន់ ។ អ្វីៗទាំងអស់ត្រូវបានលួចអស់ សូម្បីតែបំពង់ទឹកក៏ត្រូវលួចដែរ ។ មន្ត្រីថ្នាក់ខ្ពស់ៗ បើមិនត្រូវគេសម្លាប់ទេ ក៏ត្រូវនិរទេសខ្លួនដែរ ។

# នគរចំប៉ី

នៅនគរចំប៉ី ប្រជាពលរដ្ឋបោះឆ្នោតរើសប្រធានាធិបតី រើសនាយករដ្ឋមន្ត្រីនិងរើសសភាជាតិ ក៏ដូចជារើសមន្ត្រីរដ្ឋាភិបាលថ្នាក់ខេត្តនិងថ្នាក់មូលដ្ឋាន ។ មន្ត្រីទាំងអស់នោះធ្វើការដោយផ្ដល់សេវាសាធារណៈ ដើម្បីបំពេញចិត្តប្រជាពលរដ្ឋ ហើយដើម្បីឲ្យពួកគេបានជាប់ឆ្នោតជាថ្មីម្ដងទៀត ។ មុននឹងចេញសេចក្ដីសំរេចអ្វីមួយពួកគេតែងតែលើកយកមកជជែកគ្នា និងការពិភាក្សាគ្នាជាសាធារណៈជាពិសេសគឺបញ្ហាសាធារណៈសំខាន់ៗ ។

ផ្លូវថ្នល់នៃនគរចំប៉ីពុំមានគ្រលុកក្រហេងក្រហូងទេ ហើយមានការជួសជុលយ៉ាងល្អត្រឹមត្រូវ ។ គ្មានចោលសំរាមរហេតរហូតទេ ។ ទីក្រុងនិងភូមិទាំងអស់សុទ្ធតែមានសាលារៀនយ៉ាងល្អ ប្រកបដោយគ្រូដែលមានការហ្វឹកហ្វឺនយ៉ាងត្រឹមត្រូវ ហើយមានការផ្គត់ផ្គង់សាលា និងសៀវភៅយ៉ាងគ្រប់គ្រាន់ ។ មានមន្ទីរពេទ្យនិងការថែទាំសុខភាពសម្រាប់ប្រជាពលរដ្ឋគ្រប់ៗរូប ។ អ្នកក្រីក្រត្រូវគេជួយសង់ផ្ទះ ឲ្យជួយផ្ដល់ម្ហូបអាហារ និងជួយផ្ដល់បរិក្ខារប្រើប្រាស់ផ្សេងៗ ។ រដ្ឋាភិបាលប្រមូលប្រាក់ពន្ធដារបានយ៉ាងច្រើន ដើម្បីបង់ចំណាយសម្រាប់សេវាទាំងនោះ ហើយជនគ្រប់រូបដែលមានប្រាក់ចំណូលមធ្យម ឬច្រើនត្រូវតែបង់ពន្ធដារ ។ ពលរដ្ឋខ្លះចាត់ទុកថានេះគឺជាបន្ទុកមួយដ៏ធ្ងន់ ។

មន្ត្រីភាគច្រើនជាមន្ត្រីស៊ីវិល។មន្ត្រីទាំងនោះមានមោទនភាពក្នុងការផ្ដល់សេវាសាធារណៈឲ្យបានល្អ ។ គេធ្វើការច្រើន ទទួលប្រាក់បៀវត្សរ៍ច្រើន ហើយគោរពប្រតិបត្តិយ៉ាងហ្មត់ចត់តាមក្រមប្រតិបត្តិដែលតម្រូវឲ្យមន្ត្រីទាំងនោះប្រព្រឹត្តល្អនិងឥតលំអៀង ។ មន្ត្រីទាំងនោះពុំត្រូវបានអនុញ្ញាតឲ្យធ្វើអ្វីដោយសេរីតាមចិត្តគេចង់ទេ ។ គេត្រូវតែគោរពច្បាប់ និងបទបញ្ជានានា ។ មន្ត្រីទាំងនោះត្រូវទទួលខុសត្រូវចំពោះប្រាក់ដែលការិយាល័យបានទទួល និងការចាយវាយ ។ មានយន្តការសំរាប់ត្រួតត្រាពិនិត្យចរិយារបស់មន្ត្រីទាំងនេះ ។ ហើយបើមានមន្ត្រីណាប្រព្រឹត្តអំពើពុករលួយ ឬខិលខូចអួស មន្ត្រីនោះត្រូវផ្លាស់ចេញពីការងារ ហើយជួនកាលត្រូវបញ្ជូនទៅតុលាការទៀត ។

ច្បាប់ត្រូវបានដាក់ឲ្យអនុវត្តយ៉ាងតឹងរឹងបំផុត ហើយប្រព័ន្ធតុលាការបានដោះស្រាយជម្លោះជាច្រើនបានយ៉ាងឆាប់រហ័ស និងយ៉ាងត្រឹមត្រូវ ។

នគរចំប៉ី គឺជាប្រទេសដែលមានការចំរើនជឿនលឿន ។ រដ្ឋាភិបាលរបស់នគរចំប៉ី មានស្ថេរភាពល្អ ។

## ការពិភាក្សា

ចូរពិភាក្សា និងប្រៀបធៀបប្រទេសទាំងពីរនេះ ។ តើអ្នកមានមតិបែបណាចំពោះប្រទេសនីមួយៗ ?

តើរដ្ឋាភិបាល និងប្រព័ន្ធដឹកនាំបែបណា ដែលអ្នកចង់បានសម្រាប់ប្រទេសរបស់អ្នកផ្ទាល់?

===========================================

## បទពិភាក្សាទី២

## ពេលបោះឆ្នោត

អ្នកជាមន្ត្រីថ្នាក់ខ្ពស់នៅក្នុងខេត្តមួយនៃប្រទេសរបស់អ្នក ។ ការបោះឆ្នោតរើសសមាជិកសភានឹងប្រព្រឹត្តទៅនៅក្នុងរយៈពេលមិនដល់មួយខែទៀតទេ ។ យុទ្ធនាការឃោសនាបោះឆ្នោតមានសភាពតានតឹងណាស់ ហើយមានព្រឹត្តិការណ៍រំជើបរំជួលមួយចំនួនបានកើតមាននៅក្នុងខេត្តរបស់អ្នក។ មានការគំរាមកំហែង និងការវាយប្រហារជាច្រើនទៅលើបេក្ខជនតំណាងរាស្ត្រខ្លះ ហើយអ្នកខ្លះមានការសង្ស័យថាភាគីខ្លះនឹងបានឈ្នះដោយសារការបោកបញ្ឆោត ។ អ្នកជាសមាជិកមួយរូបនៃគណបក្សទន្លេសាប ប៉ុន្តែអ្នកក៏ជាមន្ត្រីសាធារណៈដែរ ។

ព្រឹកមួយមានតំណាងម្នាក់នៃគណបក្សអ្នកបានមកជួបអ្នក ។ អ្នកតំណាងនោះនិយាយថា «លោកក៏ជាសមាជិកនៃគណបក្សទន្លេសាបដូចខ្ញុំដែរ ។ ខ្ញុំបារម្ភខ្លាចក្រែងគណបក្សយើងចាញ់ឆ្នោតក្នុងខេត្តនេះ ។ ដូច្នេះខ្ញុំស្នើសុំឲ្យលោកជួយ ខ្ញុំដឹងថាលោកអាចធ្វើបាន» ។ គាត់បាននិយាយថា «ខ្ញុំចង់ឲ្យលោកធ្វើការងារដូចតទៅនេះ» : «ចូរពាក់ផ្លាកគណបក្សរបស់យើងគ្រប់ពេលវេលាទាំងអស់ ហើយណែនាំមន្ត្រីរដ្ឋាភិបាលទាំងអស់ឲ្យបោះឆ្នោតឲ្យគណបក្សទន្លេសាបយើង ។ លោកត្រូវធ្វើសុន្ទរកថាមួយក្នុងនាមគណបក្សទន្លេសាប នៅចុងសប្តាហ៍នេះ។ យើងបានទទួលការគំរាមកំហែងធ្ងន់ៗពីគណបក្សមេគង្គដែលជាអ្នកប្រឆាំងដ៏ធំរបស់យើង ។ ចូរបញ្ជូននគរបាល និងយោធាបន្ថែមដើម្បីការពារបេក្ខជន និងអ្នកឃោសនារបស់យើង ។ ជាមួយគ្នានេះដែរ ខ្ញុំសុំស្នើលោកឲ្យចាប់មេគណបក្សទន្លេមេគង្គ គឺលោក Bob និងលោក Jim ដែលបាននិយាយរឿងអាក្រក់ពីគណបក្សទន្លេសាបយើង ហើយដែលបានញុះញង់ប្រជាពលរដ្ឋឲ្យប្រឆាំងនឹងយើង» ។

«ជាបន្ថែមទៀត ខ្ញុំជឿជាក់ថាគណបក្សមេគង្គ បានទិញប្រជាពលរដ្ឋឲ្យបោះឆ្នោតឲ្យបេក្ខជនរបស់គេ ហើយពួកគេក៏មានផែនការផ្តល់ឲ្យអ្នកបោះឆ្នោតនូវប័ណ្ណសំគាល់ខ្លួនក្លែងក្លាយ ដើម្បីបោះឆ្នោតពីរឬបីដងក្នុងម្នាក់ៗនៅថ្ងៃបោះឆ្នោត ។ លោកត្រូវតែបញ្ឈប់អ្នកទាំងនោះ» ។

អ្នកសន្យាថានឹងឆ្លើយនៅពេលក្រោយចំពោះសំណើរបស់អ្នកតំណាងនោះ ។

ក្រោយមកទៀតអ្នកក៏បានជួបបងប្រុសអ្នកដែលជាតំណាងគណបក្សទន្លេមេគង្គ ។ អ្នកតំណាងនេះ និយាយថា :

«បងដឹងថាឯងជាសមាជិកគណបក្សទន្លេសាប ប៉ុន្តែឯងក៏ជាប្អូនប្រុសរបស់បង ។ ដូច្នេះបងសង្ឃឹមថាឯងនឹងជួយបងនៅក្នុងការបោះឆ្នោតនេះ ព្រោះវាមានលក្ខណៈលំបាកបំផុត ។ បុណ្យសក្តិ និងឋានៈជីវភាពរបស់បងពឹងផ្អែកទៅលើជោគជ័យរបស់គណបក្សមេគង្គយើង» ។

«កាសែតខ្លះបានបោះពុម្ពផ្សាយប្រវត្តិនានាដែលបណ្តាលឲ្យមានអំណោយផលដល់គូប្រឆាំងរបស់យើងគឺគណបក្សទន្លេសាប ហើយនិយាយតែពីរឿងអវិជ្ជមានពីគណបក្សមេគង្គ ។ តើឯងអាចប្រាប់កាសែតទាំងអស់នោះឲ្យឈប់អនុវត្តបែបនេះបានដែរឬទេ? »

«គណបក្សយើងបានទទួលការគំរាមកំហែងជាច្រើនពីគណបក្សទន្លេសាប ។ យើងបារម្ភខ្លាចក្រែងតែកន្លែងបោះឆ្នោតនឹងត្រូវវាយប្រហារនៅថ្ងៃបោះឆ្នោត ។ តើឯងអាចផ្តល់នគរបាល និងយោធាបន្ថែមដើម្បីការពារបានឬទេ ? ប៉ុន្តែសុំកុំផ្តល់កិច្ចការពារណាមួយនៅក្នុងភូមិទាំងឡាយដែលនៅតាមដងទន្លេ - ភូមិទាំងនោះគឺពោរពេញទៅដោយអ្នកបោះឆ្នោតឲ្យគូប្រឆាំងរបស់យើង គឺគណបក្សទន្លេសាប ។ នៅទីនោះអាចនឹងមានចលាចលនៅថ្ងៃបោះឆ្នោត ប៉ុន្តែអ្នកមិនត្រូវធ្វើការជ្រៀតជ្រែកទេ» ។

«និយាយអញ្ចឹង , រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានផ្ញើលិខិតអបអរសាទរ ហើយឯកភាពជាមួយខ្ញុំថាវិធានការទាំងអស់នោះត្រូវតែបានប្រកាន់យក» ។

## WHAT DOES GOOD GOVERNANCE MEAN ?

# តើអភិបាលកិច្ចល្អមានន័យដូចម្តេច?

គឺការប្រើប្រាស់វិធីសាស្ត្រ និង

បច្ចេកទេសល្អបំផុត ដើម្បីគ្រប់គ្រងឲ្យបានល្អ

==============================



# ធ្វើជាអ្នកកាច់ចង្កូត ប្រសើរជាងធ្វើជាអ្នកចែវ

# STEERING RATHER THAN ROWING

# BENEFITS OF GOOD GOVERNANCE
# ផលចំណេញពីអភិបាលកិច្ចល្អ

* ប្រជាពលរដ្ឋពេញចិត្ត
* មានភាពរុងរឿងជាទូទៅ
* ប្រទេសមានសន្តិសុខ
* មន្ត្រីរដ្ឋាភិបាលទទួលបាននូវការគោរពស្រឡាញ់ និងរង្វាន់
* ថ្នាក់អ្នកដឹកនាំ ត្រូវបានពលរដ្ឋបោះឆ្នោតឲ្យទៀត ហើយមានចិត្តរីករាយ

# មាគ៌ាព្រះពុទ្ធ

## ស្តីអំពីអភិបាលកិច្ចល្អ

ព្រះមហាក្សត្រនៃនគរមគធៈចង់វាយប្រហារ និងកម្ទេចប្រទេសវជ្ជី ។ តាមរយៈបេសកជនរបស់ព្រះអង្គ ព្រះអង្គបានសួរទៅព្រះពុទ្ធ ថាតើព្រះអង្គអាចមានជោគជ័យឬទេ ?

ព្រះពុទ្ធបានទាញការយកចិត្តទុកដាក់របស់បេសកជននោះទៅលើមាគ៌ាល្អៗ ដែលប្រទេសវិជ្ជី (Vajjes) បានគ្រប់គ្រងខ្លួនប្រកបដោយភាពចុះសម្រុងគ្នា និងយ៉ាងត្រឹមត្រូវ មានការគោរពគោលការណ៍លទ្ធិប្រជាធិបតេយ្យ គោរពច្បាប់ និងប្រពៃណី គោរពចាស់ព្រឹទ្ធាចារ្យ ស្ត្រីនិងសាសនា ហើយព្រះអង្គមានពុទ្ធដីកាថា:

" ដរាបណាគេបានប្រព្រឹត្តក្នុងមាគ៌ាដ៏ល្អនេះ (ស្របទៅតាមគោលការណ៍នៃអភិបាលកិច្ចល្អ), គេអាចមានសេចក្តីចំរុងចំរើនរុងរឿង ហើយមិនត្រូវបំផ្លិចបំផ្លាញវាយប្រហារប្រទេសនេះទេ " ។

# លក្ខណៈនៃអភិបាលកិច្ចល្អ

១. ផ្តល់សេវាជូនសាធារណៈ

២. មានការចូលរួមរបស់ប្រជាពលរដ្ឋ

៣. ផ្តល់ឱកាសជូនសាធារណៈ

៤. តម្លាភាព / ភាពមិនលាក់លៀម

៥. មានការទទួលខុសត្រូវ

៦. មានការចាត់ចែងល្អ

" ខ្ញុំត្រូវធ្វើតាមឆន្ទៈប្រជាពលរដ្ឋ ។ តើខ្ញុំមិនមែនជាអ្នកដឹកនាំគេទេឬ? "

-- Benjamin Disraeli, British Prime Minister



# តម្លាភាព Transparency



## តើទីផ្សារនេះមានអ្វីខុសបានជាគ្មានសកម្មភាព ?

What is Wrong With This Marketplace ?

# ការរីកចំរើនថ្មីៗក្នុងវិស័យអភិបាលកិច្ចល្អ

១. «ការកាច់ចង្កូតទូក គ្រាន់បើជាងការចែវទូក» ។

២. ត្រូវមានបេសកកម្មមួយច្បាស់លាស់ ចូរកំណត់ពីគោលបំណងជាមូលដ្ឋាននៃការងាររបស់អ្នក ។

៣. បម្រើអតិថិជនរបស់អ្នក ចូរបំពេញចិត្តប្រជាពលរដ្ឋដែលអ្នកបម្រើ ។

៤. វាស់លទ្ធផលពិតប្រាកដ ចូររកឲ្យឃើញច្បាស់នូវអ្វីដែលកំពុងធ្វើ ។

៥. ផ្តល់អំណាចដល់និយោជិក ឬបុគ្គលិកក្រោមបង្គាប់ទាំងឡាយ ចូរពិគ្រោះជាមួយនិយោជិក ឬបុគ្គលិកក្រោមបង្គាប់, ចូរឲ្យអ្នកទាំងនោះមានការទទួលខុសត្រូវ ។

៦. ការកាត់បន្ថយការិយាធិបតេយ្យ ចូរជៀសវាងការងារក្រដាសស្នាមដែលមិនចាំបាច់ និងការខិតខំឥតប្រយោជន៍ ។



# សម្រួលកិច្ចការការិយាធិបតេយ្យ

## Simplifying Bureaucracy

====================================

| ប្រយោជន៍ឯកជន<br>**Private Interest** | ភារកិច្ចក្នុងក្រសួង<br>**Official Duty** |
| --- | --- |



# គោរពប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ , ច្បាប់ និងបទបញ្ជានានា

## Adherence to the Constitution Laws and Regulations

==================================

CODE OF CONDUCT

គោលការណ៍ទូទៅនៃក្រមប្រតិបត្តិសម្រាប់បុគ្គលិករដ្ឋាភិបាល

១. សេវាសាធារណៈ គឺជាការទុកចិត្តរបស់សាធារណៈ ។

២. ចូរខិតខំគ្រប់ជ្រុងជ្រោយ ។

៣. ចូររក្សាភាពឥតលំអៀង និងយុត្តិធម៌ ។

៤. ចូរប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងបទបញ្ជានានា ។

៥. ចូរគោរពផលប្រយោជន៍សាធារណៈ ទៅផលប្រយោជន៍ផ្ទាល់ខ្លួន ។

៦. ចូរជៀសវាងអំពើពុករលួយ ។

៧. ចូរជៀសវាងការខ្ជះខ្ជាយ និងការចាត់ចែងមិនត្រឹមត្រូវ ។







ខ្ញុំត្រូវធ្វើតាមឆន្ទៈប្រជាពលរដ្ឋ ,

តើខ្ញុំមិនមែនជាអ្នកដឹកនាំគេទេឬ ?

==========================================================



តើអ្នកដឹងទេ ថាតើអ្នកត្រូវទៅទិសណា ?

**Do You Know Where You Are Going?**

# ចរិកជាចៅហ្វាយ និង ចរិកជាអ្នកដឹកនាំ

ចៅហ្វាយ បង្ខំកូនចៅរបស់ខ្លួនឱ្យធ្វើការ,

អ្នកដឹកនាំ លើកទឹកចិត្តអ្នកក្រោមបង្គាប់របស់ខ្លួនឱ្យធ្វើការ ។

ចៅហ្វាយ យកអំណាចជាធំ,

អ្នកដឹកនាំ យកឆន្ទៈល្អជាធំ ។

ចៅហ្វាយ តែងតែចង់ឱ្យគេខ្លាច,

អ្នកដឹកនាំ តែងតែខំធ្វើការឱ្យគេស្រឡាញ់ ។

ចៅហ្វាយ ពោលពាក្យថា " ខ្ញុំ ឬ អញ "

អ្នកដឹកនាំ ពោលពាក្យថា " យើងខ្ញុំ ឬ ពួកយើង " ។

ចៅហ្វាយ លើកឡើងអំពីអ្នកធ្វើខុស,

អ្នកដឹកនាំ លើកឡើងអំពីអ្វីដែលខុស ។

ចៅហ្វាយ (គ្រាន់តែ) ដឹងថា កិច្ចការអ្វីមួយត្រូវបានគេធ្វើយ៉ាងដូចម្តេច,

អ្នកដឹកនាំ ចេះនូវរបៀបធ្វើកិច្ចការនោះ ។

ចៅហ្វាយ ទាមទារឱ្យគេគោរពខ្លួន,

អ្នកដឹកនាំ មានលក្ខណៈសម្បត្តិគួរឱ្យគេគោរព ។

ដូច្នេះ ចូរធ្វើជា**អ្នកដឹកនាំ**,

កុំធ្វើជា**ចៅហ្វាយ** ។

# ឧទាហរណ៍មួយនៃការិយាធិបតេយ្យស្មុគស្មាញ




ចំណាយពេលវេលា និងធនធានមនុស្សច្រើនពេក គឺជាការខ្ជះខ្ជាយ ហើយពុំសូវមានប្រសិទ្ធភាព ។


ផលិតផល
PRODUCTION



6
ផលិតផល
PRODUCTION
នាយក

# ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងសង្គមប្រជាធិបតេយ្យ

ក្នុងរបបប្រជាធិបតេយ្យរដ្ឋាភិបាលមានភារកិច្ចបម្រើប្រជាពលរដ្ឋ ។ ប៉ុន្តែរដ្ឋាភិបាលក៏មិនអាចធ្វើដូច្នេះបានដែរ ប្រសិនបើប្រជាពលរដ្ឋមិនបានបំពេញការតព្វកិច្ចរបស់ខ្លួនជាប្រជាពលរដ្ឋ ដោយចូលរួមចំណែកយ៉ាងសកម្ម នៅក្នុងបញ្ហាដែលពាក់ព័ន្ធនឹងកិច្ចការសាធារណៈទេនោះ ។

ក្នុងសង្គមប្រជាធិបតេយ្យប្រជាពលរដ្ឋមានសិទ្ធិគ្រប់គ្នារួមទាំងសិទ្ធិចូលរួមដោះស្រាយបញ្ហាដែលពាក់ព័ន្ធកិច្ចការសាធារណៈ ។ សិទ្ធិទាំងនេះអនុវត្តទៅលើមន្ត្រីថ្នាក់ខ្ពស់ ទៅលើពាណិជ្ជករធំៗ និងទៅលើប្រជាពលរដ្ឋដែលរស់នៅក្នុងទីក្រុង និងភូមិស្រុកផងដែរ ។

## ប្រជាពលរដ្ឋអាចចូលរួមនៅក្នុងកិច្ចការសាធារណៈតាមរបៀបច្រើនយ៉ាង :

មធ្យោបាយសំខាន់បំផុតនៃការចូលរួមរបស់ប្រជាពលរដ្ឋ គឺតាមរយៈការបោះឆ្នោត ។ ប្រជាពលរដ្ឋបោះឆ្នោតឲ្យគណបក្ស ឬបុគ្គលដែលខ្លួនគិតថាអ្នកទាំងនោះនឹងបំពេញការងារល្អបំផុតជូនប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋបោះឆ្នោតរើសសភាជាតិហើយបន្ទាប់មកបោះឆ្នោតរើសក្រុមប្រឹក្សាឃុំ ។ សន្លឹកឆ្នោតរបស់អ្នកស្រុក អ្នកភូមិម្នាក់ មានតំលៃស្មើសន្លឹកឆ្នោតរបស់មន្ត្រីមួយរូប ។

តាមរបៀបនេះប្រជាពលរដ្ឋអាចធ្វើការត្រួតពិនិត្យមើលនូវអ្វីដែលរដ្ឋាភិបាលកំពុងធ្វើ ។ បើគេពិនិត្យឃើញថារដ្ឋាភិបាលកំពុងតែប្រព្រឹត្តខុសឆ្គង ពួកគេអាចបោះឆ្នោតរើសរដ្ឋាភិបាលមួយថ្មីទៀតនៅអណាគតក្រោយ ។

## ប្រជាពលរដ្ឋក៏អាចចូលរួមក្នុងគណបក្សនយោបាយ ហើយក៏អាចឈរឈ្មោះឱ្យគេបោះឆ្នោតបានដែរ

ប្រជាពលរដ្ឋអាចធ្វើញ្ញត្តិស្នើសុំឲ្យរដ្ឋាភិបាលជួយដោះស្រាយបញ្ហារបស់គេផងដែរ ។ ទង្វើនេះអាចមានរូបភាពជាលិខិតដែលមានជាលាយលក្ខណ៍អក្សរ ឬស្នើសុំជួបមន្ត្រីផ្ទាល់តែម្តង។

ប្រជាពលរដ្ឋអាចរួមគ្នាជាសមាគមដើម្បីជួយកែលំអការងារសាធារណៈ ឬដើម្បីអនុវត្តគម្រោងរួមគ្នា ។

និយាយរួមរបបប្រជាធិបតេយ្យគឺអាស្រ័យលើប្រជាពលរដ្ឋរបស់ខ្លួនដោយចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចការសាធារណៈដែលពាក់ព័ន្ធនឹងខ្លួនគេផ្ទាល់ ។ បើសិនជាអ្នកចូលរួមចំណែក

យ៉ាងសកម្ម អ្នកអាចជួយរដ្ឋាភិបាលឲ្យធ្វើអ្វីៗបានត្រឹមត្រូវ ។ ប្រសិនបើអ្នកសង្កេតឃើញថា គណបក្សនយោបាយ ឬបេក្ខជនណាមួយមានលក្ខណសម្បត្តិល្អបំផុតនោះ ហើយបោះឆ្នោតតាមការពិចារណាត្រឹមត្រូវនោះអ្នកនឹងទទួលបានរដ្ឋាភិបាលមួយដ៏ល្អ ។ ប្រសិនបើអ្នកផ្តល់យោបល់ល្អៗជូនទៅរដ្ឋាភិបាលអំពីអ្វីដែលជាគោលនយោបាយត្រូវអនុវត្ត រដ្ឋាភិបាលនឹងទទួលបាននូវការយល់ដឹងដ៏ប្រសើរមួយកម្រិតបន្ថែមទៀតនូវអ្វីដែលម្ចាស់ឆ្នោតចង់បាន ហើយរដ្ឋាភិបាលអាចជួយដោះស្រាយបញ្ហានេះជូនបាន ។

ប្រសិនបើអ្នកមិនចូលរួមនៅក្នុងកិច្ចការសាធារណៈទេនោះ រដ្ឋាភិបាលអាចទៅជាខ្ជិលច្រអូសនិងការងារ ហើយអាចប្រព្រឹត្តិអំពើខុសឆ្គងទៀតផង ។ រដ្ឋាភិបាលអាចប្រព្រឹត្តនូវអំពើបែបនេះ ក៏ដោយសារតែប្រជាពលរដ្ឋមិនផ្តោតការយកចិត្តទុកដាក់ ហើយនិងមិនបានដាក់បង្ខំឲ្យរដ្ឋាភិបាលទទួលខុសត្រូវក្នុងការអនុវត្តិឲ្យបានសមរម្យ ។ អ្នកត្រូវតែតាមដានលើកិច្ចការរដ្ឋាភិ-បាល ។

## សេចក្តីសង្ខេប

ការចូលរួមរបស់ប្រជាពលរដ្ឋមានសារសំខាន់ណាស់ដើម្បីធ្វើឲ្យដំណើរការរបស់រដ្ឋាភិបាលបានល្អត្រឹមត្រូវ ។

ការចូលរួមរបស់ប្រជាពលរដ្ឋអាចមានទម្រង់ផ្សេងៗ :

- បោះឆ្នោត
- ចូលរួមក្នុងគណបក្សនយោបាយ
- ឈរឈ្មោះបោះឆ្នោត
- បង្កើតសមាគម
- ធ្វើញត្តិស្នើសុំទៅរដ្ឋាភិបាល

# ក្រមប្រតិបត្តិសម្រាប់មន្ត្រីនៃរដ្ឋាភិបាល

រដ្ឋាភិបាលសម័យទំនើបមានក្រមប្រតិបត្តិ ឬក្រមចរិយាធម៌សម្រាប់មន្ត្រីរបស់ខ្លួន ។ ក្រមទាំងនោះកំណត់ពីចរិយាត្រូវ និងខុស ហើយតម្រូវឲ្យមន្ត្រីទាំងនោះប្រកាន់យកតែចរិយាល្អ។ ថ្នាក់លើត្រូវត្រួតពិនិត្យមើលមន្ត្រីរបស់ខ្លួន ដើម្បីឲ្យដឹងច្បាស់ថាគេទាំងនោះគោរពតាមបទដ្ឋានទាំងនោះឬទេ ។ ការរំលោភដ៏ធ្ងន់ធ្ងរទៅលើក្រមចរិយាធម៌ត្រូវទទួលទោសផ្នែកវិន័យ ដោយរួមមានទាំងការបណ្តេញចោល ឬនៅក្នុងករណីធ្ងន់ធ្ងរជាច្រើនទៀតត្រូវប្តឹងចោទប្រកាន់ពីបទឧក្រិដ្ឋ ។

គោលការណ៍ទាំងនេះ គឺជាការណែនាំផ្ទាល់ខ្លួនសម្រាប់មន្ត្រីទាំងអស់ ។ គោលការណ៍ទាំងនេះមានគោលបំណងរក្សាបទដ្ឋាននៃចរិយាល្អទូទៅ ផ្តល់សេវាល្អដល់សាធារណជន ហើយជៀសវាងការបាត់បង់នានាដែលបណ្តាលមកពីអំពើពុករលួយ ឬការគ្មានប្រសិទ្ធភាព ។

ក្រមប្រតិបត្តិជាមូលដ្ឋានសម្រាប់មន្ត្រីរដ្ឋាភិបាលប្រកាន់យកគោលការណ៍ប្រហាក់ប្រហែលគ្នានៅក្នុងប្រទេសទាំងអស់ ។

## ១. សេវាសាធារណៈ គឺជាទំនុកចិត្តរបស់សាធារណជន

នេះគឺជាគោលការណ៍មូលដ្ឋានដ៏សំខាន់បំផុត ដែលគូសបញ្ជាក់ពីចរិយាជាផ្លូវការ ។ មានន័យថាអ្នកកំពុងធ្វើការងាររបស់អ្នកក្នុងនាមប្រជារាស្ត្រ ។ ដើម្បីវិនិច្ឆ័យថាអ្នកកំពុងធ្វើអ្វីមួយត្រឹមត្រូវឬទេនោះ អ្នកអាចសួរខ្លួនអ្នកថា តើខ្ញុំកំពុងតែបម្រើសាធារណជនដោយស្មោះត្រង់ឬទេ? នេះគឺជាខ្នាតគំរូដែលអ្នកត្រូវតែប្រតិបត្តិ ។

## ២. ធ្វើការខិតខំអស់ពីសមត្ថភាព

មន្ត្រីគ្រប់រូបត្រូវបានគេសង្ឃឹមថានឹងធ្វើការយ៉ាងខ្លាំងក្លា និងផ្តល់ការខិតខំយ៉ាងត្រឹមត្រូវចំពោះការងារ ។

## ៣. រក្សាភាពឥតលំអៀង និងត្រឹមត្រូវ

មន្ត្រីរដ្ឋាភិបាលត្រូវតែផ្តល់សេវានានា ដោយពុំមានការផ្តល់ភាពអនុគ្រោះពិសេសចំពោះមិត្តភក្តិ ញាតិសន្តាន សមាជិករបស់បក្សនយោបាយណាមួយ ផលប្រយោជន៍ពាណិជ្ជកម្ម

ពិសេស ឬអ្វីផ្សេងៗទៀតឡើយ ។ រដ្ឋាភិបាលជារដ្ឋាភិបាលរបស់ប្រជារាស្ត្រទាំងអស់គ្នា ដែលត្រូវតែបម្រើដល់ជនគ្រប់រូប ដោយឥតប្រកាន់បក្សពួក ។

## ៤. ប្រកាន់ខ្ជាប់រដ្ឋធម្មនុញ្ញ ច្បាប់ និងបទបញ្ជានានា

មន្ត្រីគ្រប់រូបត្រូវតែប្រតិបត្តិដោយស្មោះត្រង់តាមរដ្ឋធម្មនុញ្ញ ច្បាប់ និងបទបញ្ជានានា នៅគ្រប់កាលៈទេសៈ ។ មន្ត្រីមិនត្រូវសម្រេចបញ្ហានានាដោយបំពាន ឬដោយទំនើងចិត្តផ្ទាល់ខ្លួនឡើយ ។

## ៥. ផ្តល់ការគួរសមចំពោះសាធារណជន

ប្រជាពលរដ្ឋដែលរដ្ឋាភិបាលអញ្ជើញឲ្យចូលមកធ្វើការប្រាស្រ័យទាក់ទង ត្រូវតែបាន ទទួលស្វាគមន៍ដោយការគួរសម និងភាពថ្លៃថ្នូរ ។

## ៦. ជៀសវាងអំពើពុករលួយ

មន្ត្រីរដ្ឋាភិបាលមិនត្រូវប្រើប្រាស់ការិយាល័យរបស់ខ្លួនដើម្បីទទួលសំណូក មិនត្រូវ ប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋដើម្បីផលប្រយោជន៍ផ្ទាល់របស់ខ្លួន ឬចូលរួមក្នុងការប្រព្រឹត្តិអំពើ ពុករលួយបែបណាមួយឡើយ ។

## ៧. ជៀសវាងការខ្ជះខ្ជាយ ឬការចាត់ចែងមិនត្រឹមត្រូវ

មន្ត្រីរដ្ឋាភិបាលត្រូវទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសម្បត្តិ ឬបរិក្ខារដែលខ្លួនប្រើប្រាស់ ហើយមិនត្រូវប្រើប្រាស់ទ្រព្យសម្បត្តិ ឬបរិក្ខារនោះដោយខុសទិសដៅ ឬដោយខ្ជះខ្ជាយឡើយ ។

## តើត្រូវបង្កើត និងដាក់ឲ្យអនុវត្តក្រមប្រតិបត្តិយ៉ាងដូចម្តេច ?

ក្រមប្រតិបត្តិត្រូវសរសេរជាលាយល័ក្ខអក្សរ ហើយត្រូវអនុម័តជាផ្លូវការថាជាគោល នយោបាយរបស់រដ្ឋាភិបាល ឬរបស់ក្រសួង ឬរបស់ការិយាល័យមួយ ។ ក្រមនេះអាចមាន ប្រការដោយឡែកដែលមានការទាក់ទងទៅនឹងការងារជាក់លាក់របស់ការិយាល័យនីមួយៗ។

ត្រូវធ្វើការផ្សព្វផ្សាយក្រមប្រតិបត្តិឲ្យបានទូលំទូលាយនៅក្នុងចំណោមមន្ត្រី ទាំងជា លាយល័ក្ខអក្សរ និងទាំងនៅក្នុងការប្រជុំពិសមស្រប ។ នៅសហរដ្ឋអាមេរិក រហូតមកដល់ សព្វថ្ងៃនេះ រដ្ឋាភិបាលជាតិបានតម្រូវឲ្យមន្ត្រីម្នាក់ៗរៀនសូត្រអំពីការប្រតិបត្តិផ្នែកសីលធម៌បាន មួយម៉ោងជារៀងរាល់ឆ្នាំ ។

សារសំខាន់គឺមន្ត្រីរបស់អ្នកត្រូវតែដឹង និងជឿថាក្រមនេះត្រូវតែបានអនុវត្តតាមដោយខានមិនបាន ។ ត្រូវមានយន្តការត្រួតពិនិត្យមើលអំពើណាដែលធ្វើដោយធ្វេសប្រហែស ។

ថ្នាក់លើត្រូវតែដឹងអំពីការប្រតិបត្តិមិនត្រឹមត្រូវរបស់មន្ត្រីក្រោមបង្គាប់ ។ ក្រុមអ្នកសង្កេតការប្រតិបត្តិ កាលណាបើឃើញមានការខុសឆ្គង ត្រូវតែធ្វើរបាយការណ៍ពីការប្រព្រឹត្តិខុសឆ្គងនោះ ជាក់ជូនទៅជនណាម្នាក់ ឬការិយាល័យណាមួយ ដែលទទួលបន្ទុកផ្នែកក្រមប្រតិបត្តិ ។ ហើយ ប្រសិនបើចាំបាច់ គឺត្រូវធ្វើរបាយការណ៍ដោយអនាមិក ។

ទីបញ្ចប់ ពេលណារកឃើញការប្រព្រឹត្តិខុសឆ្គង ត្រូវតែផ្តន្ទាទោសឲ្យបានសមស្រប ហើយត្រូវផ្សព្វផ្សាយការផ្តន្ទាទោសនោះជាសាធារណៈ ។ ធ្វើដូច្នេះដើម្បីឲ្យអ្នកប្រព្រឹត្តអាក្រក់រៀងចាល ។

មន្ត្រីភាគច្រើនប្រកាន់យកការប្រតិបត្តិត្រឹមត្រូវ ប្រសិនបើគេដឹងថាមនុស្សនៅជុំវិញខ្លួនគេសុទ្ធតែប្រព្រឹត្តត្រឹមត្រូវ ។ ប្រសិនបើពុំមានទណ្ឌកម្មចំពោះការប្រព្រឹត្តខុសឆ្គងទេ នោះនឹងធ្វើឲ្យមន្ត្រីល្អខូចទឹកចិត្ត ។

លំហាត់ :

## ការសិក្សាអំពីករណីនៃការប្រតិបត្តិតាមក្រមសីលធម៌របស់មន្ត្រីរាជការ

ជនមួយរូបបានចូលទៅក្នុងការិយាល័យរដ្ឋាភិបាល ដើម្បីទទួលយកប័ណ្ណបើកបរ ។ ក្រោយពេលរង់ចាំជាមួយអ្នកដទៃទៀតអស់ពេលយ៉ាងយូរមក គាត់ត្រូវបានអនុញ្ញាតឲ្យធ្វើការប្រឡងសរសេរសាកល្បង ដើម្បីយកប័ណ្ណបើកបរ ។ ជននោះជាជនបរទេសដែលពុំចេះភាសាច្បាស់លាស់ ។ ជាលទ្ធផល គាត់បានធ្វើខុសតិចតួច ដោយសរសេរនៅលើក្រដាសមួយដែលគាត់ពុំអាចសរសេរបាន ។

គាត់បានទៅជួបមន្ត្រីដែលជាអ្នកដាក់ពិន្ទុលើការប្រឡងសាកល្បងរបស់គាត់ ។ មន្ត្រីនេះស្តីបន្ទោសជននោះយ៉ាងច្រើន ចំពោះការដាក់ជាសញ្ញានៅលើក្រដាសប្រឡងសាកល្បង មិនបានត្រឹមត្រូវល្អ ។ ជននោះត្រូវបានគេបង្គាប់ឲ្យចេញ ហើយមិនឲ្យត្រឡប់មកវិញក្នុងរយៈពេលមួយសប្តាហ៍ ។ ជនបរទេសបានសុំទោសអស់ពេលយ៉ាងយូរ ប៉ុន្តែមន្ត្រីនោះមិនប្តូរគោលជំហររបស់គាត់ទេ ។ ថ្នាក់លើរបស់មន្ត្រីនោះក៏បានយល់ស្របតាមមន្ត្រី ហើយតាមការពិត បានប្រាប់ជនបរទេសនោះកុំឲ្យត្រឡប់មកវិញ ក្នុងរយៈពេលពីរសប្តាហ៍ទៀត ។

***សំណួរ :***

តើមន្ត្រីនោះបានប្រព្រឹត្តល្អ ឬអាក្រក់ ? តើថ្នាក់លើបានប្រព្រឹត្តល្អឬអាក្រក់ ? បើល្អព្រោះអ្វី ? បើអាក្រក់ពីព្រោះអ្វី ?

ក្នុងឧទាហរណ៍នេះ តើគោលការណ៍នៃការប្រតិបត្តិក្រមសីលធម៌ណាខ្លះ ដែលត្រូវបានប្រតិបត្តិតាម ហើយតើគោលការណ៍ណាខ្លះដែលមិនត្រូវបានប្រតិបត្តិតាម ?

# ការសិក្សាអំពីករណីនៃការប្រកាន់ច្បាប់ខ្ជាប់ខ្ជួន

=============

លោក ក បានធ្វើការសម្ដែង និងស្រែកយ៉ាងខ្លាំងនៅទីសាធារណៈ ។ គាត់បានកាន់កូនសៀវភៅតូចៗ ដែលនិយាយបរិហារថាបក្សនយោបាយ ខ មានលក្ខណៈមិនល្អចំពោះប្រជារាស្ត្រ ។ មន្ត្រី ដ៏សំខាន់ម្នាក់បានដើរចូលមកជិត ហើយមានការមិនសប្បាយចិត្តចំពោះអាកប្បកិរិយាបែបនេះ ។ មន្ត្រីនោះបានប្រាប់នគរបាលឲ្យចាប់លោក ក ពីព្រោះលោក ក កំពុងតែរំលោភច្បាប់ និងរដ្ឋធម្មនុញ្ញ ។ នគរបាលបានធ្វើតាមដូច្នោះមែន ។ នគរបាលទាំងនោះក៏បានរឹបអូស និងបំផ្លាញកូនសៀវភៅរបស់លោក ក ចោល ។

ក្រោយពីពេលដែលនគរបាលបានចាប់លោក ក ហើយយកគាត់ទៅដាក់ពន្ធនាគារ នគរបាល និងព្រះរាជអាជ្ញាពុំអាចរកឃើញថាមានច្បាប់ជាក់លាក់ណាមួយ និងពុំមានអ្វីទាំងអស់នៅក្នុងរដ្ឋធម្មនុញ្ញ ដែលថាលោក ក បានប្រព្រឹត្តរំលោភច្បាប់ ។ ដូច្នេះ ជាយថាហេតុ លោក ក ត្រូវបានដោះលែង ។

*សំណួរ :*

តើអ្នកយល់យ៉ាងដូចម្ដេចពីអាកប្បកិរិយារបស់លោក ក ? តើអាកប្បកិរិយានេះត្រឹមត្រូវ ឬពុំត្រឹមត្រូវតាមច្បាប់ ? តើអ្នកយល់យ៉ាងណាពីរបៀបដែលមន្ត្រីដ៏សំខាន់ និងនគរបាលបានប្រព្រឹត្តនៅក្នុងរឿងនេះ ? តើអ្នកជឿថាមន្ត្រីនោះ ហើយនិងនគរបាលបានប្រព្រឹត្តត្រឹមត្រូវ និងស្របតាមច្បាប់ដែរឬទេ ? តើសំណើរបស់មន្ត្រីនោះមានហេតុផលគ្រប់គ្រាន់ ដើម្បីចាប់អ្នកណាមួយនោះឬទេ ? តើការរឹបអូស និងការបំផ្លាញទ្រព្យសម្បត្តិមានលក្ខណៈដូចម្ដេចដែរ ? ឬថាតើការប្រកាន់ច្បាប់ខ្ជាប់ខ្ជួនមានសារសំខាន់ជាង ? តើមានការផ្ដន្ទាទោសចំពោះការរំលោភរដ្ឋធម្មនុញ្ញដែរឬទេ ? តើការប្រកាន់ច្បាប់ខ្ជាប់ខ្ជួននៅក្នុងករណីនេះមានន័យដូចម្ដេច ?

# ច្បាប់រដ្ឋធម្មនុញ្ញ

**តើរដ្ឋធម្មនុញ្ញជាអ្វី ?**

រដ្ឋធម្មនុញ្ញគឺជាច្បាប់កំពូល ។ ច្បាប់ បទបញ្ជា ឬការណែនាំទាំងអស់ត្រូវតែគោរពតាមរដ្ឋធម្មនុញ្ញ ។ " កំពូល " មានន័យយ៉ាងដូច្នេះ :

ច្បាប់រដ្ឋធម្មនុញ្ញផ្តល់ការណែនាំទូទៅ តើរដ្ឋាភិបាលត្រូវបានបង្កើតឡើង និងត្រូវដំណើរការរបៀបណា? ។ ច្បាប់រដ្ឋធម្មនុញ្ញកំណត់ពីទំនាក់ទំនងរវាងប្រជារាស្ត្រ និងរដ្ឋាភិបាល ។ នេះគឺជាការណែនាំសម្រាប់ជនគ្រប់រូប ។

នៅក្នុងប្រទេសភាគច្រើន ច្បាប់រដ្ឋធម្មនុញ្ញត្រូវបានទុកជាទីសក្ការៈ ។ ច្បាប់នេះឆ្លុះបញ្ចាំងឲ្យឃើញពីគោលការណ៍មូលដ្ឋាន និងតម្លៃរបស់សង្គម និងប្រជារាស្ត្រ ។ នៅក្នុងសម្បថចូលកាន់មុខតំណែងរបស់មន្ត្រីនានានៅក្នុងប្រទេសជាច្រើន ពួកគេបានស្បថដើម្បីលើកដំកើងរដ្ឋធម្មនុញ្ញ ។

ហេតុដូចម្តេចបានជារដ្ឋធម្មនុញ្ញមានសារសំខាន់ខ្លាំងម្ល៉េះ ? ពីព្រោះច្បាប់រដ្ឋធម្មនុញ្ញបង្កើត និងធានាប្រព័ន្ធនយោបាយមួយដែលផ្តល់នូវសន្តិភាព សន្តិសុខ និងសិទ្ធិមនុស្ស និងសេរីភាព ។ ច្បាប់រដ្ឋធម្មនុញ្ញ គឺជាជំរការដែលជួយថែរក្សាសង្គមឲ្យនៅជាមួយគ្នាយ៉ាងស្អិតល្មួត។

**<u>គោលការណ៍មូលដ្ឋាននៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា</u>**

ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាក៏មានគោលបំណងដូចគ្នា ទៅនឹងច្បាប់រដ្ឋធម្មនុញ្ញផ្សេងៗទៀតដែរ ។ ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាត្រូវបានអនុម័តនៅឆ្នាំ១៩៩៣ ដោយសភាធម្មនុញ្ញនៃអ្នកតំណាងដែលបានជាប់ឆ្នោត ។ ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា គឺជាច្បាប់កំពូលរបស់កម្ពុជា ។ ប្រជាពលរដ្ឋទាំងអស់ត្រូវគោរពច្បាប់រដ្ឋធម្មនុញ្ញឲ្យនៅខ្ពស់ជាងច្បាប់ បទបញ្ជា បក្សនយោបាយ បទបញ្ជា ឬសេចក្តីណែនាំនានា ផ្សេងទៀត ។

ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានបង្កើតប្រព័ន្ធនយោបាយជាព្រះរាជាណាចក្រ ហើយដែលព្រះមហាក្សត្រត្រូវប្រព្រឹត្តតាមរដ្ឋធម្មនុញ្ញ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។ រដ្ឋធម្មនុញ្ញតម្រូវឲ្យកម្ពុជាប្រកាន់ខ្ជាប់នូវនយោបាយអព្យាក្រឹត អចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ ។ នេះ

មានន័យថាមិនត្រូវឲ្យមានមូលដ្ឋានបរទេសនៅលើទឹកដីកម្ពុជាទេ ហើយកម្ពុជាក៏មិនត្រូវចូលជាសម្ព័ន្ធមិត្តអ្វីមួយឡើយ ។

តើ " លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស " មានន័យដូចម្ដេច ?

" លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស " មានធាតុផ្សំចំនួនបី ។

**«សេរី»** មានន័យថាប្រជារាស្ត្រមានសេរីភាព គឺថាសិទ្ធិមនុស្ស និងសេរីភាព

**«ពហុបក្ស»** មានន័យថាបក្សនយោបាយច្រើនដែលមានទស្សនៈខុសៗគ្នា អាចកើតមាន និងចាត់តាំងបេក្ខជនសម្រាប់មុខតំណែងនានា ។

**«ប្រជាធិបតេយ្យ»** មានន័យថារដ្ឋាភិបាលកើតឡើងដោយប្រជារាស្ត្រ ។ ប្រជារាស្ត្រជ្រើសរើសតំណាងរបស់ខ្លួនតាមរយៈការបោះឆ្នោតដោយសេរីនិងយុត្តិធម៌ ហើយបានចូលរួមនៅក្នុងរដ្ឋាភិបាល ។

ព្រះមហាក្សត្រមានតួនាទីជានិមិត្តរូបយ៉ាងសំខាន់ ប៉ុន្តែព្រះអង្គមិនកាន់អំណាចឡើយ ។ ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជជាតិ អធិបតីភាព និងបូរណភាពទឹកដី ។ ព្រះមហាក្សត្រទ្រង់ជាអ្នកធានាការគោរពសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ ។ ព្រះអង្គក៏មានករណីយកិច្ចដោយឡែក ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ដូចជាព្រះអង្គជាអាជ្ញាកណ្ដាល ហើយព្រះអង្គទ្រង់តែងតាំងមន្ត្រីខ្លះៗ ។

## <u>សិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋ</u>

រដ្ឋធម្មនុញ្ញធានាសិទ្ធិមនុស្ស និងសេរីភាពយ៉ាងទូលំទូលាយសម្រាប់ប្រជាពលរដ្ឋរបស់ខ្លួន ដោយរួមទាំងសិទ្ធិសេដ្ឋកិច្ច និងសេដ្ឋកិច្ចទីផ្សារ ។

គោលសំខាន់ៗរួមមាន :

- ភាពស្មើគ្នាចំពោះមុខច្បាប់សម្រាប់មនុស្សគ្រប់រូប
- សិទ្ធិរស់រានមានជីវិត
- សិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត
- ការមានសិទ្ធិទទួលអត្ថប្រយោជន៍ខាងសង្គមកិច្ច
- សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី

- ការហាមឃាត់អំពើទារុណកម្ម ឬប្រព្រឹត្តិកម្មមិនត្រឹមត្រូវទៅលើជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ
- ជនជាប់ចោទត្រូវចាត់ទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ
- ជនជាប់ចោទមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ
- សិទ្ធិប្តឹងទារសំណងពីរដ្ឋ
- សេរីភាពនៃការធ្វើដំណើរ និងតាំងទីលំនៅ
- ការមិនអាចរំលោភលើលំនៅឋាន និងអាថ៌កំបាំងនៃការឆ្លើយឆ្លង រួមទាំងតាមទូរស័ព្ទ
- ការនែកនេរត្រូវធ្វើឲ្យស្របតាមបញ្ញត្តិច្បាប់
- សេរីភាពខាងការបញ្ចេញមតិ សេរីភាពខាងសារពត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ និងសេរីភាពខាងការប្រជុំ ។ ច្បាប់រដ្ឋធម្មនុញ្ញដាក់កម្រិតខ្លះ ទៅលើសេរីភាពទាំងនេះ ដូចជា: ប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិ ។
- សិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ
- សេរីភាពខាងផ្លូវសាសនា
- សិទ្ធិជាម្ចាស់កម្មសិទ្ធិ
- ការគាំពារមិនឲ្យមានការរើសអើងប្រឆាំងនឹងស្ត្រីភេទ ប្រឆាំងការបង្ខំឲ្យធ្វើពេស្យាចារ ការងារដូចគ្នាទទួលប្រាក់កម្រៃស្មើគ្នា ជួយស្ត្រីនៅតំបន់ជនបទក្នុងការរស់នៅ ។
- កុមារមានជីវិតរស់នៅយ៉ាងត្រឹមត្រូវ សិទ្ធិទទួលការអប់រំ ទទួលកិច្ចការពារក្នុងពេលមានសង្គ្រាម ។ ការធ្វើអាជីវកម្មកុមារតាមផ្នែកសេដ្ឋកិច្ច ឬតាមផ្លូវភេទត្រូវបានហាមឃាត់ ។

នេះពុំមែនជាបញ្ជីនៃសិទ្ធិ និងសេរីភាពទាំងស្រុងនោះទេ ។ អ្នកត្រូវអានជំពូក៣ នៃរដ្ឋធម្មនុញ្ញ សិទ្ធិនិងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ហើយត្រូវឈ្វេងយល់ដើម្បីអាចធ្វើការពិភាក្សាពីសិទ្ធិទាំងនេះ ។

## ករណីយកិច្ចរបស់ប្រជាពលរដ្ឋ

ផ្នែកដដែលនៃរដ្ឋធម្មនុញ្ញ ជំពូក៣ ចែងពីករណីយកិច្ចរបស់ប្រជាពលរដ្ឋ ករណីយកិច្ចទាំងនោះរួមមាន :

- ចិញ្ចឹមបីបាច់រក្សាកូនរបស់ខ្លួនយ៉ាងត្រឹមត្រូវ
- កូនត្រូវចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតារបស់ខ្លួនដែលចាស់ជរា
- គោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់
- រួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ
- គោរពអធិបតេយ្យជាតិ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស
- គោរពទ្រព្យសម្បត្តិសាធារណៈ និងទ្រព្យសម្បត្តិឯកជន ។

រដ្ឋធម្មនុញ្ញផ្តល់ឲ្យរដ្ឋាភិបាលមានការទទួលខុសត្រូវដ៏ធំធេងចំពោះបរិស្ថាន និងធនធានធម្មជាតិ ជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច អប់រំវប្បធម៌ និងសុខុមាលភាពសង្គម ។

## រចនាសម្ព័ន្ធរបស់រដ្ឋាភិបាល

រដ្ឋធម្មនុញ្ញកំណត់រចនាសម្ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានចែកជាផ្នែកនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងផ្នែកតុលាការ ។

រដ្ឋធម្មនុញ្ញបង្កើតរដ្ឋសភាមួយមានតំណាងរាស្ត្រចំនួន១២២រូប ដែលត្រូវជ្រើសតាំងដោយការបោះឆ្នោតដោយសម្ងាត់ រៀងរាល់៥ឆ្នាំម្តង ។ រដ្ឋសភាជាអ្នកធ្វើច្បាប់ ។ រដ្ឋសភាជាតំណាងរបស់ប្រជារាស្ត្រ ហើយអាចចោទបញ្ហានានាទៅរដ្ឋាភិបាល ។ នេះគឺជាអង្គនីតិបញ្ញត្តិ ។

ព្រះមហាក្សត្រទ្រង់តែងតាំងមេដឹកនាំមួយរូប មកពីបក្សដែលឈ្នះនៅក្នុងការបោះឆ្នោតដើម្បីបង្កើតរដ្ឋាភិបាល ។ មេដឹកនាំនេះដែលតាមធម្មតាក្លាយទៅជានាយករដ្ឋមន្ត្រី ត្រូវរៀបចំគណៈរដ្ឋមន្ត្រី ដាក់ជូនអង្គសភាបោះឆ្នោតជាផ្លូវការ ។ នេះគឺជាផ្នែកនីតិប្រតិបត្តិរបស់រដ្ឋាភិបាល។

រដ្ឋសភាអាចទម្លាក់គណៈរដ្ឋមន្ត្រីដោយសម្លេងពីរភាគបី ។ ការនេះធ្វើឲ្យរាជរដ្ឋាភិបាលទទួលខុសត្រូវចំពោះតំណាងប្រជារាស្ត្រដែលជាប់ឆ្នោត ។

រដ្ឋធម្មនុញ្ញបង្កើតអំណាចតុលាការឯករាជ្យមួយដើម្បីធានា និងលើកកំពស់ភាពឥតលំអៀង ហើយនិងការពារសិទ្ធិនិងសេរីភាពរបស់ប្រជាពលរដ្ឋ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើកសេចក្ដីស្នើថ្វាយព្រះមហាក្សត្រ អំពីការតែងតាំងចៅក្រម និងដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា ។

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេចលើករណីវិវាទ ដែលទាក់ទងទៅនឹងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ហើយនិងបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់នានា ។

ក្រុមប្រឹក្សាធម្មនុញ្ញអាចពិនិត្យលើធម្មនុញ្ញភាពនៃច្បាប់ ។ ប្រសិនបើច្បាប់មានលក្ខណៈផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញ ច្បាប់នោះត្រូវចាត់ទុកជាមោឃៈ ។

សមាជជាតិត្រូវបានបង្កើតឡើងដើម្បីជូនពត៌មានដល់ប្រជារាស្ត្រដោយផ្ទាល់ អំពីកិច្ចការផ្សេងៗដែលជាផលប្រយោជន៍ជាតិ និងលើកបញ្ហា និងសំណូមពរជូនរដ្ឋដើម្បីដោះស្រាយ ។

រដ្ឋធម្មនុញ្ញអាចត្រូវធ្វើវិសោធនកម្ម ឬត្រូវសើរើដោយសំឡេងពីរភាគបីនៃចំនួនសមាជិកសភាទាំងមូល ។ រដ្ឋធម្មនុញ្ញហាមឃាត់ការផ្លាស់ប្ដូររបបរាជានិយម ឬប្រព័ន្ធលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

## សេចក្ដីសង្ខេប

- រដ្ឋធម្មនុញ្ញបង្កើតលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស
- រដ្ឋធម្មនុញ្ញការពារសិទ្ធិរបស់បុគ្គល
- រដ្ឋធម្មនុញ្ញអនុវត្តលទ្ធិប្រជាធិបតេយ្យតាមរយៈការបោះឆ្នោតជ្រើសរើសសភាជាតិដែលជាអ្នកធ្វើច្បាប់
- បក្សដែលឈ្នះឆ្នោតនៅក្នុងរដ្ឋសភាបង្កើតរាជរដ្ឋាភិបាល
- រាជរដ្ឋាភិបាលត្រូវទទួលខុសត្រូវចំពោះប្រជារាស្ត្រ
- រដ្ឋធម្មនុញ្ញបង្កើតតុលាការឯករាជ្យមួយដើម្បីសម្រេចសេចក្ដីពីរឿងវិវាទ ដោយត្រឹមត្រូវនិងឥតលំអៀង ។

រដ្ឋធម្មនុញ្ញបានទទួលជោគជ័យក៏ពីព្រោះតែប្រជារាស្ត្រប្រតិបត្តិតាមរដ្ឋធម្មនុញ្ញនោះដែលជាឆន្ទៈរួមទាំងអស់គ្នា ។ ពីព្រោះអ្វី ? ពីព្រោះប្រជារាស្ត្រមើលឃើញថា ជនគ្រប់រូបគោរពតាមបទបញ្ជាកំណត់ដោយរដ្ឋធម្មនុញ្ញ ជនគ្រប់រូបនឹងទទួលបាននូវការគាំពារយ៉ាងត្រឹមត្រូវ និងមានអត្ថប្រយោជន៍ ។ នៅក្នុងន័យនេះ រដ្ឋធម្មនុញ្ញមានលក្ខណៈដូចសាសនាព្រះពុទ្ធដែរ ។ អ្នកប្រតិបត្តិតាមសិក្ខាបទ ពីព្រោះអ្នកជឿថានៅទីបញ្ចប់ការប្រតិបត្តិនេះមានលក្ខណៈល្អណាស់សម្រាប់រូបអ្នក ។

និយាយដោយសង្ខេប រដ្ឋធម្មនុញ្ញមានធាតុផ្សំជាមូលដ្ឋានទាំងអស់ដែលត្រូវការ សម្រាប់ប្រជារាស្ត្ររស់នៅរួមគ្នា ហើយនិងគ្រប់គ្រងដោយខ្លួនឯងផ្ទាល់ក្នុងសន្តិភាព ភាពសុខដុមនិងការគោរពសិទ្ធិរបស់អ្នកដទៃ--ប្រសិនបើរដ្ឋធម្មនុញ្ញត្រូវបានគោរព និងប្រតិបត្តិដោយយកចិត្តទុកដាក់ ។

# ទំនាក់ទំនងរវាងរាស្ត្រ និងមន្ត្រីរាជការ

ក្នុងរបបប្រជាធិបតេយ្យ ទំនាក់ទំនងជាមួយមន្ត្រីមានលក្ខណៈខុសប្លែកឆ្ងាយជាងនៅក្នុងរបបផ្តាច់ការ ។ ក្នុងរបបប្រជាធិបតេយ្យ រដ្ឋាភិបាលធ្វើការដើម្បីបម្រើផលប្រយោជន៍ប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋអាចបោះឆ្នោតជ្រើសរើសរដ្ឋាភិបាលមួយផ្សេងទៀត បើសិនណាជាពួកគេមិនពេញចិត្តនឹងរដ្ឋាភិបាលដែលមានស្រាប់នោះ ។ ក្នុងរបបផ្តាច់ការ រដ្ឋាភិបាលមិនយកត្រចៀកស្តាប់អ្នកនិយាយ ឬជួយដោះស្រាយបញ្ហាអ្នកឡើយ ។ មេដឹកនាំធ្វើជាម្ចាស់រដ្ឋាភិបាល។ ចំណែកឯនៅក្នុងរបបប្រជាធិបតេយ្យវិញ ប្រជាពលរដ្ឋធ្វើជាម្ចាស់រដ្ឋាភិបាល ។

ឥឡូវនេះ មន្ត្រីរាជការជាច្រើននៅក្នុងព្រះរាជាណាចក្រកម្ពុជាទើបតែបានយល់ជ្រួតជ្រាបអំពីលទ្ធិប្រជាធិបតេយ្យដូចអ្នកដែរ ។ ដូច្នេះហើយ គ្មានរឿងអ្វីគួរឲ្យភ្ញាក់ផ្អើលនោះទេ ជួនកាលមន្ត្រីទាំងនោះប្រព្រឹត្តអំពើរតាមរបៀបចាស់ ។ ហេតុនេះអ្នកត្រូវតែជួយពួកគេឲ្យប្រតិបត្តិតាមលក្ខណៈប្រជាធិបតេយ្យឲ្យកាន់តែប្រសើរឡើង ។

ក្នុងរបបប្រជាធិបតេយ្យ ប្រជាពលរដ្ឋមិនរួញរានឹងធ្វើការទាក់ទងជាមួយរដ្ឋាភិបាលនៅពេលណាដែលគេត្រូវការរដ្ឋាភិបាលឲ្យជួយ ។ គេមានសិទ្ធិនឹងធ្វើញត្តិតវ៉ាទៅរដ្ឋាភិបាលតាមរយៈលិខិត ឬចាត់អ្នកតំណាងឲ្យទៅជួបផ្ទាល់តែម្តង ។ រដ្ឋាភិបាលត្រូវតែទទួលយកយោបល់ទាំងនោះពីប្រជាពលរដ្ឋយ៉ាងយកចិត្តទុកដាក់បំផុត ។

ដូច្នេះ បើសិនជាអ្នកមានបញ្ហា ឬរឿងរ៉ាវអ្វីមួយ អ្នកមានសិទ្ធិរករដ្ឋាភិបាលឲ្យជួយបំភ្លឺថាតើត្រូវដោះស្រាយបញ្ហានោះយ៉ាងណា ?

ជាបឋម អ្នកត្រូវតែស្គាល់មន្ត្រីរាជការ ឬមន្ត្រីទាំងឡាយដែលមានភារៈទទួលខុសត្រូវក្នុងភូមិ ឬតំបន់របស់អ្នកឲ្យបានច្បាស់ ។ បើសិនជាគេពុំស្គាល់អ្នកទេ ពួកគេក៏មិនអាចជួយអ្វីដល់អ្នកបានដែរ ។ បើកាលណាគេយល់ពីស្ថានភាពរបស់អ្នកកាន់តែច្រើនឡើង ពេលនោះគេនឹងជួយអ្នកកាន់តែខ្លាំងឡើងដែរ ។

ធ្វើការទាក់ទងដោយគោរព ។ បើសិនជាអ្នកចូលត្រង់ៗទៅតែម្តង ហើយទាមទារឲ្យជួយដោះស្រាយបញ្ហាជាច្រើន ឬធ្វើការទិតៀន ទង្វើនេះនឹងនាំឲ្យមន្ត្រីនោះខឹងច្រឡោត ។ គាត់ជាអ្នកបម្រើការជូនសាធារណជន មិនមែនជាទាសកររទេ ។

ត្រូវជួយផ្ដល់ដំណោះស្រាយជាវិជ្ជមាន មិនត្រូវលើកបញ្ហាណាមួយដល់មន្ត្រីឲ្យជួយដោះស្រាយដោយគ្មានផ្ដល់ជាគំនិតថា តើត្រូវរកមធ្យោបាយដោះស្រាយតាមរបៀបណានោះទេ ។ ប្រការនេះនឹងត្រូវផ្ដោតការយកចិត្តទុកដាក់របស់ខ្លួនលើដំណោះស្រាយបញ្ហានោះ មិនមែនគ្រាន់តែព្រួយបារម្ភអំពីបញ្ហានោះទេ ។

មិនត្រូវសុំ ឬសង្ឃឹមថានឹងបានទទួលការអនុគ្រោះពិសេសឡើយ ។ រដ្ឋាភិបាលត្រូវផ្ដល់ការយកចិត្តទុកដាក់ដល់ប្រជាពលរដ្ឋឲ្យបានស្មើៗគ្នា ។ ដោយសារតែអ្នកជាមិត្តភក្តិ ឬញាតិសន្ដានការសុំឲ្យមានការអនុគ្រោះពិសេស នឹងបង្កើតជាបញ្ហាកាន់តែច្រើនឡើងដល់មន្ត្រីរដ្ឋាភិបាល ។

ត្រូវសរសើរលើកទឹកចិត្ត បើសិនណាជាមន្ត្រីនោះដោះស្រាយបញ្ហាជូនអ្នក ។ ត្រូវប្រាកដក្នុងចិត្តថា អ្នកត្រូវនិយាយតែពាក្យណាល្អៗអំពីគាត់ជូនទៅមន្ត្រីថ្នាក់លើរបស់គាត់ ។ មនុស្សគ្រប់រូបតែងតែត្រូវការឲ្យគេសរសើរអំពីខ្លួន ។

មធ្យោបាយដោះស្រាយតាមលក្ខណៈបច្ចេកទេសដទៃទៀតដូចជា ការបង្កើតសមាគម ការសរសេរញត្តិតវ៉ាជាលាយលក្ខអក្សររបស់មហាជន និងការផ្សព្វផ្សាយអំពីបញ្ហារបស់អ្នក ព្រមទាំងសេចក្ដីត្រូវការរកដំណោះស្រាយ តាមរយៈសារពត៌មាន និងវិទ្យុ មានសារសំខាន់ណាស់ ប៉ុន្តែក៏អាចមានគ្រោះថ្នាក់ណាស់ដែរ ជួនកាលធ្វើឲ្យមន្ត្រីរាជការទាំងនោះប្រឆាំងតបតមកវិញយ៉ាងមានៈ នូវអ្វីដែលអ្នកចង់ធ្វើ ។ ដូច្នេះជាការប្រសើរបំផុតនោះ យើងត្រូវធ្វើការទំនាក់ទំនងចាប់ផ្ដើមពីលក្ខណៈងាយៗ ជាមិត្តភាព និងផ្ទាល់ខ្លួន ។ ត្រៀមបម្រុងទុកមធ្យោបាយខ្លាំងៗដ៏មានប្រសិទ្ធភាពដទៃទៀត នៅពេលណាដែលយើងមើលឃើញច្បាស់ថា រដ្ឋាភិបាលនឹងស្ដាប់តែសម្លេងស្រែកខ្លាំងៗពីប្រជាពលរដ្ឋតែប៉ុណ្ណោះ ។

## សេចក្ដីសង្ខេប

ក្នុងរបបប្រជាធិបតេយ្យ អ្នកមានសិទ្ធិសុំរដ្ឋាភិបាលឲ្យផ្ដល់សេវា ។

ប៉ុន្តែមិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលទេ ប្រសិនបើមន្ត្រីមួយចំនួនប្រព្រឹត្តអំពើតាមរបៀបចាស់នោះ ពីព្រោះពួកគេកំពុងតែឈ្វេងយល់អំពីលទ្ធិប្រជាធិបតេយ្យ ។ ដូច្នេះ យើងត្រូវធ្វើការអប់រំពួកគេតាមលក្ខណៈប្រជាធិបតេយ្យ ។

ចំណុចសំខាន់ៗមួយចំនួនក្នុងការដោះស្រាយជាមួយមន្ត្រីរាជការ គឺ :

- ត្រូវស្គាល់មន្ត្រីរាជការឲ្យបានច្បាស់
- ត្រូវសម្តែងការគោរព
- ត្រូវផ្ដល់ដំណោះស្រាយលើបញ្ហានោះ មិនមែនគ្រាន់តែបង្កើតជាបញ្ហាទេ

- ត្រូវបង្កលក្ខណៈងាយស្រួលដើម្បីជាប្រយោជន៍ដល់អ្នក ដោយអនុវត្តតាមគោលនយោបាយរបស់រដ្ឋាភិបាល
- មិនត្រូវសុំការអនុគ្រោះពិសេសទេ
- ត្រូវចេះសំដែងការសរសើរលើកទឹកចិត្ត ។

# រដ្ឋាភិបាលប្រជាធិបតេយ្យ

( ទ្រឹស្តី និងប្រតិបត្តិជាក់ស្តែង )

យោង : មាត្រា៥១ (រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា )

ព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។ ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។

I- ទម្រង់ និង មុខងាររបស់រដ្ឋាភិបាល :

ក- អ្វីខ្លះដែលជាមុខងារសំខាន់ៗរបស់រដ្ឋាភិបាល ?

១. ការពារសង្គម និងរក្សារបៀបរៀបរយ

ក. រដ្ឋាភិបាលមានភារកិច្ចធ្វើពង្រាងច្បាប់លើគ្រប់វិស័យ ដាក់ជូនសភាពិនិត្យពិភាក្សា និងអនុម័ត ។

ខ. បង្កើតប្រព័ន្ធតុលាការឯករាជ្យ ដើម្បីដោះស្រាយជម្លោះរវាងប្រជាពលរដ្ឋ ដោយយោងតាមច្បាប់ជាធរមាន ។

គ. បង្កើតមធ្យោបាយសម្រាប់អនុវត្តច្បាប់ឲ្យមានប្រសិទ្ធភាព

ឃ. ការពារពលរដ្ឋឲ្យផុតពីគ្រោះថ្នាក់

២. ផ្តល់សេវាជូនសាធារណៈ

៣. ជំរុញសមភាព

៤. រដ្ឋាភិបាលត្រូវថ្លឹងថ្លែងរវាង ៖

ក. (រវាង) សេរីភាព និងសណ្តាប់ធ្នាប់

ខ. (រវាង) សេរីភាព និងសមភាព

ខ- ទម្រង់នៃរដ្ឋាភិបាល :

១. បិតុធិបតេយ្យ ឬមាតុធិបតេយ្យ (ការអភិបាលជាបែបគ្រួសារ)

២. សម្បូរណាញាសិទ្ធិរាជាធិបតេយ្យ ឬ រាជានិយម (កាលណាអំណាចរដ្ឋាភិបាលទាំងអស់ស្ថិតនៅក្នុងដៃរបស់មនុស្សតែម្នាក់ )

៣. អភិជនាធិបតេយ្យ ឬអប្បជនាធិបតេយ្យ(កាលណាអំណាចរដ្ឋាភិបាលស្ថិតនៅ

ក្នុងដៃមនុស្សមួយក្រុមតូច )

៤. ប្រជាធិបតេយ្យ (កាលណាអំណាចរដ្ឋាភិបាលស្ថិតនៅក្នុងដៃប្រជាពលរដ្ឋហើយ អនុវត្តដោយប្រជាពលរដ្ឋទាំងមូល តាមរយៈការបោះឆ្នោតត្រឹមត្រូវសុចរិតនិងទៀងទាត់តាមពេលកំណត់ ដោយបេក្ខជនប្រកួតប្រជែងដោយសេរី ដើម្បីយកសំឡេង ហើយដែលមនុស្សពេញវ័យមានសិទ្ធិបោះឆ្នោត)។

ក. ក្នុងរបបប្រជាធិបតេយ្យដោយផ្ទាល់ ពលរដ្ឋគ្រប់រូបបានទទួលឱកាសដើម្បីបោះឆ្នោតលើរាល់សេចក្ដីសម្រេចរបស់រដ្ឋាភិបាល ។

ខ. ក្នុងរបបប្រជាធិបតេយ្យតំណាងពលរដ្ឋជ្រើសរើសតំណាងរបស់ខ្លួនដែលជាអ្នកបោះឆ្នោតចំពោះសេចក្ដីសម្រេចរបស់រដ្ឋាភិបាល ។ ប្រភេទនៃរបបប្រជាធិបតេយ្យ ដែលគេឃើញមានជាទូទៅ គឺប្រជាធិបតេយ្យតំណាង ។ អ្វីដែលយើងនិយាយថា «ប្រជាធិបតេយ្យ»នៅក្នុងជំពូកនេះ គឺសំដៅដល់របបប្រជាធិបតេយ្យតំណាងនេះឯង ។

## II- គោលការណ៍មូលដ្ឋាននៃរបបប្រជាធិបតេយ្យ

១. បុរស និងស្ត្រីគ្រប់រូប មានសេរីភាពធ្វើអ្វីៗតាមដែលគេជ្រើសរើសចង់ធ្វើ ។ មនុស្សគ្រប់រូបសុខចិត្តលះបង់សេរីភាពខ្លះរបស់គេ ដើម្បីកែលំអជីវភាពរបស់គេ ។

២. អំណាចនយោបាយចុងក្រោយបំផុតជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋ ផ្ទេរអំណាចនេះខ្លះឲ្យទៅតំណាងជាប់ឆ្នោតរបស់ខ្លួនដែលជាអ្នកបង្កើតជារដ្ឋាភិបាល។

៣. អំណាចរបស់រដ្ឋាភិបាលមានកំរិតព្រំដែនត្រឹមតែការព្រមព្រៀងរវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល ។កិច្ចព្រមព្រៀងនេះជាទូទៅគេហៅថារដ្ឋធម្មនុញ្ញ ។

៤. ពលរដ្ឋគ្រប់រូបមានសេរីភាពនឹងបញ្ចេញមតិរបស់ខ្លួនអំពីបញ្ហាសាធារណៈ។ ពលរដ្ឋគ្រប់រូបមានសេរីភាពដើម្បីចូលរួមក្នុងជីវភាពនយោបាយរបស់រដ្ឋ តាមរយៈការបោះឆ្នោតនិងឈរឈ្មោះជាបេក្ខជន សម្រាប់តំណែងក្នុងរដ្ឋាភិបាល ។

៥. សេចក្ដីថ្លៃថ្នូររបស់មនុស្ស និងសិទ្ធិមនុស្សត្រូវបានគោរព និងគាំពារដោយរដ្ឋាភិបាល ហើយមិនអាចដកហូតបានដោយសំឡេងភាគច្រើនដាច់ខាតនោះទេ ។

> *< កាលណាឲ្យអំណាចទាំងអស់ដល់អ្នកភាគច្រើន ពួកគេនឹងសង្កត់សង្កិនអ្នកភាគតិច ។*
> *កាលណាឲ្យអំណាចទាំងអស់ដល់មនុស្សមួយក្តាប់តូចពួកគេនឹងសង្កត់សង្កិនអ្នកភាគច្រើន >*
>
> *អាឡិចសាន់ឌឺ ហាមីលតុន ថ្លែងក្នុងសភាសហរដ្ឋអាមេរិក ឆ្នាំ១៧៨៨*

៦. ចរិយា និងការប្រព្រឹត្តិដែលអាចទទួលយកបានត្រូវកំណត់ដោយប្រព័ន្ធច្បាប់ ។ ច្បាប់ទាំងនេះត្រូវបានកំណត់ដោយតំណាងជាប់ឆ្នោតរបស់ប្រជាពលរដ្ឋ ។ មនុស្សរាល់រូប ដោយរួមបញ្ចូលទាំងមេដឹកនាំរដ្ឋាភិបាលផង ត្រូវគោរពច្បាប់ទាំងនេះ ។

> *< ច្បាប់ដែលបានបង្កើតរួចហើយ ដែលបានដោះស្រាយជម្រះស្រឡះ និងដែលបានទទួលស្គាល់ ត្រូវទទួលនិងអនុញ្ញាតឲ្យប្រើដោយការយល់ព្រមរួម ដើម្បីជាបទដ្ឋាននៃអ្វីដែល ខុសនិងត្រូវ និងធ្វើជារង្វាស់រួម ដើម្បីសម្រេចគ្រប់រឿងវិវាទកម្មទាំងអស់...>*
>
> *ចន ឡុក ទស្សនវិទូនយោបាយអង់គ្លេស ឆ្នាំ១៦៩០*

## II- លក្ខណៈនៃរបបប្រជាធិបតេយ្យ

១. រដ្ឋធម្មនុញ្ញដែលចែងយ៉ាងច្បាស់នូវសិទ្ធិជាមូលដ្ឋាននៃពលរដ្ឋម្នាក់ៗ ។

២. ច្បាប់ដែលពង្រឹកភាពលំអិតនៃសិទ្ធិទាំងនេះនិងបង្កើតក្របខ័ណ្ឌនៃស្ថាប័ននានាដើម្បីឲ្យបានសម្រេចសិទ្ធិទាំងនេះដោយពេញលេញ ។

៣. អត្ថិភាពជាក់ស្តែងនៃក្របខ័ណ្ឌនោះគឺ ប្រព័ន្ធតុលាការសម្រាប់ការពារសិទ្ធិរបស់បុគ្គលម្នាក់ៗ ។

៤. ការយល់ដឹងរបស់ពលរដ្ឋអំពីសិទ្ធិរបស់គេ ។

៥. កម្លាំងប៉ូលីសដែលគោរពសិទ្ធិរបស់ពលរដ្ឋនិងផ្តល់កិច្ចការពារដ៏មានប្រសិទ្ធភាពទល់នឹងអំពើឧក្រិដ្ឋ ។

៦. មានទីប្រឹក្សាច្បាប់ដែលមានគុណសម្បត្តិ ដើម្បីជួយពលរដ្ឋក្នុងការទាមទារសិទ្ធិរបស់គេនៅក្នុងតុលាការ ។

៧. ចៅក្រមដែលមានសមត្ថភាព និងគុណសម្បត្តិល្អ ដើម្បីសម្រេចរឿងក្តីឲ្យបានសមរម្យ និងយុត្តិធម៌ ។

៨. បរិយាកាសមួយដែលចៅក្រមអាចធ្វើសេចក្តីវិនិច្ឆ័យរបស់ខ្លួន ដោយគ្មានទទួលឥទ្ធិពល ឬការបំភិតបំភ័យពីកម្លាំងខាងក្រៅ រួមទាំងរដ្ឋាភិបាលផង ។

៩. សង្គមមួយដែលគោរពសាលក្រមរបស់តុលាការ ទោះបីមន្ត្រីរបស់រដ្ឋាភិបាលក៏ត្រូវគោរពសាលក្រមនេះដែរ ។

## IV- រដ្ឋធម្មនុញ្ញនៃរបបប្រជាធិបតេយ្យ

ជាច់ខាតត្រូវមានចែងពីគោលសំខាន់ៗ តទៅនេះ :

១. សិទ្ធិជាមូលដ្ឋានរបស់ពលរដ្ឋ ដើម្បីរស់រានមានជីវិត សេរីភាពនិងសុភមង្គល ។

២. ការទទួលខុសត្រូវរបស់រដ្ឋាភិបាលដើម្បីការពារសិទ្ធិទាំងនោះ ។

៣. ការកំរិតព្រំដែនអំណាចរបស់រដ្ឋាភិបាល ។

៤. វិស័យនានានៃជីវភាពរបស់ពលរដ្ឋ ដែលរដ្ឋាភិបាលមិនអាចជ្រៀតជ្រែកបាន ។

៥. នីតិវិធី ដែលគេអាចផ្លាស់ប្តូររដ្ឋាភិបាលបាន ដោយមានការយល់ព្រមពីពលរដ្ឋ ។

V- សារប្រយោជន៍នៃរបបប្រជាធិបតេយ្យ

ក. ប្រជាធិបតេយ្យជួយជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច

ខ. ប្រជាធិបតេយ្យជួយទប់ស្កាត់សង្គ្រាម

គ. ប្រជាធិបតេយ្យលើកស្ទួយសន្តិភាព និង សន្តិសុខក្នុងប្រទេស

ឃ. ប្រជាធិបតេយ្យការពារទប់ទល់អំពើពុករលួយ

ង. ប្រជាធិបតេយ្យធ្វើសេចក្តីសម្រេចបានប្រសើរជាងលទ្ធិនានា

IV- តើរបបប្រជាធិបតេយ្យមានដំណើរការបែបណា ?

ក. ការបោះឆ្នោត (ការបោះឆ្នោតរើសតំណាង)

១. ក្នុងរបបប្រជាធិបតេយ្យតំណាង

សេចក្តីសម្រេចតែងតែធ្វើដោយតំណាងដែលជ្រើសរើសដោយប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសបេក្ខជន ហើយបេក្ខជនដែលជាប់ឆ្នោតបញ្ចេញមតិរបស់ខ្លួនលើសេចក្តីសម្រេចរបស់រដ្ឋាភិបាល ។

ជាមូលដ្ឋានមានប្រព័ន្ធពីរយ៉ាងសម្រាប់ជ្រើសរើសតំណាង ៖

ក-ប្រព័ន្ធឯកត្តនាម : (មានពីរបែប)

**បែបទី១:** ឈ្នះដោយមានសម្លេងច្រើនជាងគេ ( Majorité Relative ) នៅក្នុងការបោះឆ្នោតដែលមានបេក្ខជនច្រើន បេក្ខជនណាដែលមានសំឡេងច្រើនជាងគេ ជាអ្នកឈ្នះឆ្នោត ។

**បែបទី២:** ឈ្នះដោយមានសម្លេងច្រើនជាងគេផង ហើយលើសពីពាក់កណ្តាលនៃសន្លឹកឆ្នោតទាំងអស់ផង ( Majorité Absolute ) ។

ខ-ប្រព័ន្ធសមាមាត្រ : ក្នុងប្រព័ន្ធសមាមាត្រអាចមានតំណាងច្រើនសម្រាប់មណ្ឌលនីមួយៗ ។ គណៈបក្សដែលមានសំឡេងច្រើនជាងគេ គណៈបក្សនោះ មានតំណាងច្រើនជាងគេ ។ គណៈបក្សដែលបានសំឡេងតិចជាង នៅតែមានអ្នកតំណាងរបស់ខ្លួនដែរ តែមិនច្រើនដូចគណបក្សដែលមានប្រជាប្រិយ៍ជាងទេ ។ ប្រព័ន្ធសមាមាត្រធានាថា សូម្បីតែគណបក្សសំឡេងភាគតិចក៏មានតំណាងនៅក្នុងរដ្ឋាភិបាលដែរ ។

(ប្រព័ន្ធនេះ មន្ត្រីជាប់ឆ្នោតយកចិត្តទុកដាក់ចំពោះបក្ស ច្រើនជាងចំពោះពលរដ្ឋ )។

គ-ប្រព័ន្ធចំរុះ : (ឯកត្តនាម +សមាមាត្រ)

ក្នុងប្រព័ន្ធនេះ អ្នកបោះឆ្នោតត្រូវជ្រើសបេក្ខជនតំណាងបក្សផង រើសបេក្ខជនតំណាងរាស្ត្រផង ។ សមាជិកសភាយ៉ាងតិចពាក់កណ្ដាលនៃចំនួនសមាជិកទាំងអស់ ជាអ្នកជាប់ឆ្នោតតាមប្រព័ន្ធសមាមាត្រ ។ អ្នកបោះឆ្នោតត្រូវធ្វើការជ្រើសរើសពីរបែបក្នុងពេលជាមួយគ្នា ពោលគឺគូសជ្រើសរើសបេក្ខជនខាងសមាមាត្រផង ខាងឯកត្តនាមផង នៅលើសន្លឹកឆ្នោតតែមួយ ។ ឧ. ប្រទេសអាល្លឺម៉ង់ (ប្រព័ន្ធនេះមានមន្ត្រីជាប់ឆ្នោតមួយចំនួនយកចិត្តទុកដាក់ចំពោះបក្ស ហើយមួយចំនួនទៀត យកចិត្តទុកដាក់ចំពោះប្រជាពលរដ្ឋ)។

២. (ការបោះឆ្នោតប្រជាមតិ) សេចក្ដីសម្រេចសំខាន់ៗរបស់រដ្ឋាភិបាលត្រូវបានបោះឆ្នោតសម្រេចដោយពលរដ្ឋទាំងអស់ ។ ឧទាហរណ៍: នៅក្នុងប្រទេសខ្លះ រដ្ឋធម្មនុញ្ញថ្មី ឬការផ្លាស់ប្ដូររដ្ឋធម្មនុញ្ញ ត្រូវតែធ្វើដោយការបោះឆ្នោតដោយប្រជាពលរដ្ឋទាំងអស់ (គឺការបោះឆ្នោតប្រជាមតិ)។

៣. (ការបោះឆ្នោតសេរីនិងយុត្តិធម៌)ការបោះឆ្នោតត្រូវតែធ្វើដោយត្រឹមត្រូវ ដើម្បីឲ្យមនុស្សភាគច្រើនទទួលយកបាន ។ មានលក្ខខណ្ឌជាច្រើនដែលត្រូវបំពេញ ៖

ក. ភាពត្រឹមត្រូវ : បេក្ខជនម្នាក់ៗត្រូវមានឱកាសស្មើភាពគ្នាដើម្បីបញ្ចេញទស្សនៈរបស់ខ្លួន ហើយរដ្ឋាភិបាល ឬស្ថាប័នមានអំណាចដទៃទៀត មិនត្រូវបង្អួចបង្អាក់ការបញ្ចេញទស្សនៈរបស់គេឡើយ ក្នុងការធ្វើយុទ្ធនាការឃោសនាបោះឆ្នោតរបស់គេ ។

ខ. សុចរិត : ត្រូវប្រកាន់យកវិធានការដើម្បីធានាថា មានការរាប់សន្លឹកឆ្នោតឲ្យបានត្រឹមត្រូវប្រាកដប្រជា និងពលរដ្ឋម្នាក់ៗអាចបោះបានតែសន្លឹកឆ្នោតមួយសន្លឹក ។

គ. ទៀងទាត់តាមកាលកំណត់: ការបោះឆ្នោតត្រូវកំណត់ធ្វើជារឿយៗ ដើម្បីផ្ដល់ឱកាសឲ្យប្រជាពលរដ្ឋផ្លាស់ប្ដូរគោលនយោបាយដែលគេមិនពេញចិត្ត ។

ឃ. ការប្រកួតប្រជែង : ការបោះឆ្នោតត្រូវបើកឲ្យគណបក្សលើសពីមួយ ឬ

បេក្ខជនលើសពីម្នាក់ចូលប្រកួតប្រជែងយ៉ាងជាក់ស្តែង យកការគាំទ្រពីប្រជាពលរដ្ឋ ។ ប្រព័ន្ធបោះឆ្នោតណាដែលបន្ថយបង្អាក់ដោយគ្មានមូលហេតុត្រឹមត្រូវ ដល់ការចូលរួមក្នុងដំណើរការជ្រើសរើសផ្នែកនយោបាយ មិនមែនជាប្រព័ន្ធប្រជាធិបតេយ្យទេ ។

ង. សេរីភាព : អ្នកចូលរួមស្របច្បាប់ទាំងអស់ត្រូវតែមានសេរីភាព ដើម្បីនិយាយស្តី បោះពុម្ពផ្សាយ ជួបជុំគ្នា និងរួមផ្តុំគ្នាដើម្បីពាំនាំយកពត៌មានដែលគេចង់ផ្សព្វផ្សាយឲ្យបានដល់ប្រជាពលរដ្ឋ ។

ច. មានសិទ្ធិពេញលេញ : មនុស្សទាំងអស់នៅក្នុងសង្គមដែលមានអាយុជានីតិជន ( ពោលគឺអាយុពេញវ័យតាមច្បាប់ ) ត្រូវអនុញ្ញាតឲ្យបោះឆ្នោត ។ ការដាក់លក្ខខ័ណ្ឌដោយផ្អែកលើភេទ ពូជសាសន៍ សាសនា ។ល។ និង ។ល។ គឺមិនស្របនឹងដំណើរការប្រជាធិបតេយ្យទេ ។

ឆ. សន្លឹកឆ្នោតសម្ងាត់ : ដើម្បីចៀសវាងឥទ្ធិពលមិនគប្បី និងការបំភិតបំភ័យនៅក្នុងការបោះឆ្នោតជ្រើសរើសយកបេក្ខជនណាមួយ សង្គមភាគច្រើនបានអនុម័តយកសន្លឹកឆ្នោតសម្ងាត់ ។

៤. រដ្ឋាភិបាលដែលត្រូវបានជ្រើសតាំងដោយសេរី ជារដ្ឋាភិបាលស្របច្បាប់ ពីព្រោះអំណាចរបស់ខ្លួនបានមកពីប្រជាពលរដ្ឋដែលខ្លួនគ្រប់គ្រង។

**រដ្ឋាភិបាលស្របច្បាប់ផ្តល់សារប្រយោជន៍ដល់សង្គមជាច្រើន ៖**

ក- រដ្ឋាភិបាលដែលត្រូវបានជ្រើសតាំងស្របច្បាប់ នឹងទទួលបានការគោរពយ៉ាងកក់ក្តៅពីប្រជាពលរដ្ឋដែលយល់ព្រមឲ្យអំណាចដល់រដ្ឋាភិបាល ។

ខ- រដ្ឋាភិបាលស្របច្បាប់ទំនងជានឹងបានការគាំទ្រពីប្រជាពលរដ្ឋ នៅក្នុងការបំបាត់អំពើឧទ្ទាមកម្មប្រឆាំងនឹងអាជ្ញាធររដ្ឋាភិបាល ។

គ- រដ្ឋាភិបាលស្របច្បាប់ នឹងបានការគាំទ្រពីសហគមន៍អន្តរជាតិក្នុងការអនុវត្តន៍សិទ្ធិរបស់ខ្លួនជារដ្ឋមួយ រួមទាំងសិទ្ធិទទួលជំនួយ ។

ខ- គុណ្យភាពនៃអំណាច :

កាលណាពលរដ្ឋឲ្យអំណាចដល់រាជរដ្ឋាភិបាល ដើម្បីប្រើសិទ្ធិអំណាចប្រមូលពន្ធដារ និងគ្រប់គ្រងកងទ័ព ការនេះអាចមានគ្រោះថ្នាក់ ប្រសិនបើមន្ត្រីរដ្ឋាភិបាលប្រើប្រាស់អំណាចរបស់ខ្លួនមិនត្រឹមត្រូវ ។ មានវិធីផ្សេងៗ ដែលគេបង្កើតឡើងដើម្បីការពារប្រជាពលរដ្ឋឲ្យផុតពីការ

ដែលរដ្ឋាភិបាលប្រើអំណាចមិនត្រឹមត្រូវ ។ វិធីទាំងនេះគេហៅថា " ការត្រួតពិនិត្យ និង ថ្លឹងថ្លែងអំណាច " ។

១. វិធីសម្រាប់កម្រិតអំណាចរបស់អង្គនីតិបញ្ញត្តិ ( សភា )

ក- មានការបោះឆ្នោតជាញឹកញាប់

ខ- ត្រូវឲ្យមានការយល់ព្រមពីប្រមុខរដ្ឋលើសេចក្តីសម្រេចនានា(របស់សភា) ។

គ- មានស្ថាប័ននីតិបញ្ញត្តិពីរផ្សេងគ្នា(គឺសភាជាន់ទាប ហៅថាសភាតំណាងរាស្ត្រ និងសភាជាន់ខ្ពស់ហៅថា ព្រឹទ្ធសភា) ដែលជ្រើសរើសតាមវិធីផ្សេងគ្នា ប៉ុន្តែស្ថាប័នទាំងពីរត្រូវយល់ស្របគ្នាលើសេចក្តីសម្រេចនានា ។

ឃ- មានការពិនិត្យរបស់ (ក្រុមប្រឹក្សាធម្មនុញ្ញ) នូវសេចក្តីសម្រេចរបស់នីតិបញ្ញត្តិ ដើម្បីធានាថាសេចក្តីសម្រេចទាំងនោះពិតជាស្របនឹងរដ្ឋធម្មនុញ្ញ ។

២. វិធីសម្រាប់កម្រិតអំណាចរបស់ប្រមុខរដ្ឋ (ឬនាយករដ្ឋមន្ត្រី)

ក- ការបោះឆ្នោតជាញឹកញាប់ និងកម្រិតចំនួនឆ្នាំដែលប្រមុខរដ្ឋ(ឬនាយករដ្ឋមន្ត្រី) អាចកាន់តំណែង ។

ខ- ត្រូវមានការព្រមព្រៀងពីអំណាចនីតិបញ្ញត្តិ (សភា)ដើម្បីធ្វើសេចក្តីសម្រេចធំៗមួយចំនួន ដូចជាការប្រកាសសង្គ្រាម ការចំណាយប្រាក់របស់រដ្ឋាភិបាល ឬការដំឡើងពន្ធដារ ។

គ- ត្រូវមានការព្រមព្រៀងពីអំណាចនីតិបញ្ញត្តិ ចំពោះការតែងតាំងមន្ត្រីរដ្ឋាភិបាលសំខាន់ៗ ។

ឃ-ត្រូវមានការពិនិត្យរបស់តុលាការ(ឬក្រុមប្រឹក្សាធម្មនុញ្ញ)នូវសេចក្តីសម្រេចនានាដើម្បីធានាថា សេចក្តីសម្រេចទាំងនោះស្របនឹងរដ្ឋធម្មនុញ្ញ ហើយនិងច្បាប់ដែលអនុម័តដោយអង្គនីតិបញ្ញត្តិ ។

ង- ប្រមុខរដ្ឋ (ឬនាយករដ្ឋមន្ត្រី)អាចត្រូវគេដកចេញពីតំណែងតាមរយៈការបោះឆ្នោតរបស់សភា កាលណាប្រមុខរដ្ឋ (ឬនាយករដ្ឋមន្ត្រី)រំលោភច្បាប់ ។

៣. វិធីសម្រាប់កម្រិតអំណាចតុលាការ ៖

ក- ចៅក្រមត្រូវតែងតាំងដោយមន្ត្រីជាប់ឆ្នោត ( គឺសមាជិកសភា )

ខ- ចៅក្រមអាចត្រូវដកចេញពីតំណែង កាលណាប្រព្រឹត្តខុសច្បាប់ ។

៤. វិធីសម្រាប់កម្រិតអំណាចប៉ូលីស ឬយោធា ៖

ក- ការតែងតាំងនាយទាហានត្រូវមានការយល់ព្រមពីអង្គនីតិបញ្ញត្តិ(សភា)។

ខ- ប្រាក់ និងការដំឡើងពន្ធដារសម្រាប់ប្រតិបត្តិការយោធាត្រូវមានការយល់ព្រមពីអង្គនីតិបញ្ញត្តិ ( សភា ) ។

គ- ប្រមុខរដ្ឋ (ឬនាយករដ្ឋមន្ត្រី)ដែលជាប់ឆ្នោតគឺជាអគ្គបញ្ជាការហើយមានអំណាចខ្ពស់បំផុត លើសេចក្ដីសម្រេចយោធា ។

ឃ- សេចក្ដីសម្រេចធ្វើសង្គ្រាមត្រូវតែមានការយល់ព្រមពីអង្គនីតិបញ្ញត្តិ(សភា) ។

៥. វិធីសម្រាប់កម្រិតអំណាចរបស់សំឡេងភាគច្រើន ៖

ក- ការបោះឆ្នោតជាសមាមាត្រ ដែលបង្កលក្ខណៈឲ្យគណបក្សសំឡេងភាគតិចមានតំណាងរបស់ខ្លួន ។

ខ- សិទ្ធិដែលរដ្ឋធម្មនុញ្ញបានទទួលស្គាល់មិនអាចដកហូតបានដោយសំឡេងភាគច្រើនឡើយ ។ សិទ្ធិទាំងនេះ ត្រូវបានការពារដោយតុលាការ និងប្រមុខរដ្ឋ ។

គ- សេចក្ដីតម្រូវឲ្យមានសំឡេងលើសពីភាគច្រើន ចំពោះសេចក្ដីសម្រេចសំខាន់ៗ ។

VIII- <u>រដ្ឋបាលមានកម្រិតច្រើនថ្នាក់</u> ( ថ្នាក់មូលដ្ឋាន "ភូមិ-ឃុំ-ស្រុក-ខេត្ត" និងថ្នាក់ជាតិ )

ក. រដ្ឋបាលទាំងថ្នាក់មូលដ្ឋាន ទាំងថ្នាក់ជាតិ នៅក្រោមរដ្ឋធម្មនុញ្ញមួយដែលកំណត់ ៖

- អំណាចរបស់រដ្ឋបាលថ្នាក់មូលដ្ឋាន, និង
- អំណាចរបស់រដ្ឋបាលថ្នាក់ជាតិ

ខ. តុល្យភាពនៃអំណាចរវាងរដ្ឋបាលមូលដ្ឋាន និងរដ្ឋបាលថ្នាក់ជាតិមានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ។

១ - ជាទូទៅសេចក្ដីសម្រេចនៅតាមមូលដ្ឋានត្រូវធ្វើនៅកម្រិតមូលដ្ឋានដោយមន្ត្រីជាប់ឆ្នោតថ្នាក់មូលដ្ឋាន ពីព្រោះមកពី ៖

ក- ការខុសគ្នាផ្នែកភូមិសាស្ត្រ វប្បធម៌ និងសេដ្ឋកិច្ចរវាងតំបន់មូលដ្ឋាននានា ។

ខ- មន្ត្រីមូលដ្ឋានត្រូវដឹងពីសេចក្ដីត្រូវការ និងចំណង់ចំណូលចិត្តរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ។

គ- ពលរដ្ឋចូលចិត្តសេចក្ដីសម្រេចនៅថ្នាក់មូលដ្ឋានជាង ព្រោះប្រជា-ពលរដ្ឋមូលដ្ឋានមានឱកាសបញ្ចេញមតិរបស់គេ ចំពោះសេចក្ដីសម្រេចនោះ ។

២. សេចក្តីសម្រេចខ្លះធ្វើបានប្រសើរជាងនៅថ្នាក់ជាតិ ពីព្រោះវាមានផលប៉ះពាល់ដល់តំបន់ឬខេត្តច្រើន ។ ការនេះរួមមានសេចក្តីសម្រេចនិងច្បាប់ទាក់ទងនឹង៖

ក- ការការពារជាតិ

ខ- សន្ធិសញ្ញាជាមួយប្រជាជាតិដទៃទៀត

គ- ប្រាក់ និងរបររកស៊ីរវាងខេត្តនានា

៣. សេចក្តីសម្រេចខ្លះធ្វើការប្រសើរជាងនៅថ្នាក់មូលដ្ឋាន

ឧទាហរណ៍ :

ក- វិធានសម្រាប់អាជីវកម្ម ពាណិជ្ជកម្មនៅក្នុងខេត្ត

ខ- វិធានសម្រាប់អាពាហ៍ពិពាហ៍ និងការលះលែង

គ- ការបង្កើតការអប់រំសាធារណៈ

៤. សេចក្តីសម្រេចខ្លះអាចធ្វើរួមគ្នាដោយរដ្ឋបាលមូលដ្ឋាន និងរដ្ឋបាលថ្នាក់ជាតិ ៖

ក- បទដ្ឋានអប្បបរមាសម្រាប់ការពារសិទ្ធិមនុស្សជាមូលដ្ឋាន

ខ- បទដ្ឋានអប្បបរមាសម្រាប់សុខភាព និងសុវត្ថិភាព

គ- ការអនុវត្តន៍ច្បាប់ - ប្រព័ន្ធតុលាការព្រហ្មទណ្ឌ

៥. រដ្ឋធម្មនុញ្ញកំណត់តុល្យភាពនៃអំណាចរវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់មូលដ្ឋាន ។

## VI- ការបង្កើត និងការបន្តប្រជាធិបតេយ្យ

### ក. កត្តាវប្បធម៌:

១. វប្បធម៌មានឥទ្ធិពលយ៉ាងមាំលើការអភិវឌ្ឍន៍ប្រជាធិបតេយ្យ ។ ការជជែកដេញដោលរវាងកត្តាខាងក្រោមនេះ មានសារៈសំខាន់នៅក្នុងការអភិវឌ្ឍន៍ប្រជាធិបតេយ្យ ៖

ក- រវាងសណ្តាប់ធ្នាប់ និងពហុភាព ( ត្រូវមានពហុភាពផង មានសណ្តាប់ធ្នាប់ផង )

ខ- រវាងសហគមន៍ និងឯកត្តជននិយម ( ឯកជន )

គ- រវាងវិធាននៃព្រឹទ្ធាចារ្យ និងវិធាននៃច្បាប់ត្រូវគោរពតាមក្បួនតម្រាតាមប្រពៃណីផង ត្រូវប្រតិបត្តិតាមច្បាប់ផង)។

២. វប្បធម៌ផ្លាស់ប្តូរជានិច្ចដោយសារឥទ្ធិពលនៃ ៖

ក. ការអប់រំ

ខ. ការទទួលវប្បធម៌ដទៃទៀតតាមរយៈប្រព័ន្ធផ្សព្វផ្សាយពត៌មាន

គ. ការពឹងពាក់គ្នាទៅវិញទៅមកខាងសេដ្ឋកិច្ចអន្តរជាតិ

ខ. កត្តាសេដ្ឋកិច្ច :

១. កាលណាការអភិវឌ្ឍន៍សេដ្ឋកិច្ចមានកម្រិតទាប អំណាចគ្រប់គ្រងតែងតែចុះទន់ខ្សោយ ។

២. ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច និងដើម្បីបង្កើតប្រភពធនធានថ្មី និងព្រមទាំងជំរុញអំណាចពលរដ្ឋ រដ្ឋាភិបាលត្រូវការឲ្យពលរដ្ឋចូលរួមកាន់តែទូលាយឡើង ។

៣. ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច និងរក្សាសុខុមាលភាពសេដ្ឋកិច្ចរបស់មនុស្សម្នាក់ៗត្រូវធ្វើយ៉ាងណាឲ្យបុគ្គលម្នាក់ៗមានសន្តិសុខ និងទំនុកចិត្តកាន់តែខ្លាំងឡើងដែលអាចនាំឲ្យបុគ្គលម្នាក់ៗមានសេចក្ដីប្រាថ្នាចង់ឲ្យមានសំឡេងរបស់ខ្លួនកាន់តែច្រើនឡើងនៅក្នុងរដ្ឋាភិបាល ។

៤. ការអភិវឌ្ឍន៍សេដ្ឋកិច្ច តម្រូវឲ្យមានការអប់រំរិតតែល្អឡើងចំពោះពលរដ្ឋ ។ ដោយកម្រិតអប់រំកាន់តែខ្ពស់ឡើង សមត្ថភាពរបស់ពលរដ្ឋម្នាក់ៗក៏កើនទៅតាមនោះដែរ ក្នុងការវាយតម្លៃសេចក្ដីសម្រេចរបស់រដ្ឋាភិបាល ។

៥. ការអភិវឌ្ឍន៍សេដ្ឋកិច្ច ធ្វើឲ្យធនធានកាន់តែមានច្រើនឡើងសម្រាប់ប្រជាពលរដ្ឋព្រោះវាបង្កើតការងារសម្រាប់ប្រជាជនក្រីក្រ និងកំណើនចំណូលដើមទុនចំពោះក្រុមអ្នកមាន។ ប្រសិនបើសេចក្ដីត្រូវការមូលដ្ឋានរបស់សមាជិកសង្គមភាគច្រើនត្រូវបានសម្រេចដូចបំណង នោះការសម្របសម្រួលដែលជាកត្តាចាំបាច់សម្រាប់សង្គមប្រជាធិបតេយ្យ ក៏នឹងងាយបានសម្រេចដែរ ។

គ. តួនាទីរបស់យោធា ( នៅក្នុងសង្គមប្រជាធិបតេយ្យ )

មានអ្នកដើរតួនយោបាយច្រើនប្រភេទ ដែលមាននាទីក្នុងសង្គមប្រជាធិបតេយ្យទំនើប ។ ប្រវត្តិសាស្ត្រថ្មីៗនេះ មានឧទាហរណ៍ជាច្រើនស្តីអំពីតួនាទីសំខាន់របស់យោធា។ ឥទ្ធិពលយោធាលើជីវភាពនយោបាយរបស់ប្រទេសមួយ អាចមានច្រើនសណ្ឋាននៅក្នុងប្រព័ន្ធរដ្ឋាភិបាលប្រភេទផ្សេងៗ ៖

**១. ប្រព័ន្ធរដ្ឋាភិបាលស៊ីវិល (សុទ្ធសាធ)**

ក. យោធាគ្មានការពាក់ព័ន្ធនៅក្នុងការដឹកនាំរដ្ឋាភិបាលទេ

ខ. សមាជិកយោធាមានសិទ្ធិបោះឆ្នោត

គ. បុគ្គលិកយោធាអាចធ្វើជាមន្ត្រីស៊ីវិលបានក្រោយពេលលាឈប់ពីយោធា

ឃ. ទាក់ទិនដល់រឿងសន្តិសុខជាតិ យោធាមានសំឡេងពិសេសនៅក្នុងសេចក្តីសម្រេចរបស់រដ្ឋាភិបាល ។

**២. ប្រព័ន្ធរដ្ឋាភិបាលស៊ីវិល** (ក្រោមឥទ្ធិពលយោធា)

ក. នៅក្នុងករណីជាច្រើន យោធាយល់ឃើញថា ខ្លួនឯងជាអ្នកការពារសណ្តាប់ធ្នាប់ និងគោលការណ៍មូលដ្ឋាន ។ ប្រសិនបើសណ្តាប់ធ្នាប់ឬគោលការណ៍មូលដ្ឋានត្រូវគម្រាមកំហែង រដ្ឋាភិបាលមុខជានឹងពួនូវការជំទាស់ខ្លាំងពីយោធា ;ហើយគម្រាមកំហែងធ្វើរដ្ឋប្រហារ,

ខ. ប្រព័ន្ធបែបនោះ ជារឿយៗយោធាប្រើការគម្រាមកំហែងដើម្បីរុញច្រានរដ្ឋាភិបាលឲ្យដើរទៅតាមទិសដៅណាមួយ ។

**៣. រដ្ឋាភិបាលយោធា គឺជាករណីជ្រុលបំផុតនៃការពាក់ព័ន្ធរបស់យោធា នៅក្នុងរដ្ឋាភិបាល ។**

ក. យោធាមានការពាក់ព័ន្ធទាំងស្រុង ឬយ៉ាងច្រើនក្នុងការដឹកនាំ

ខ. លទ្ធិយោធានិយមគ្របដណ្តប់លើលទ្ធិប្រជាធិបតេយ្យ

**៤. គុណវិបត្តិនៃរបៀបគ្រប់គ្រងយោធា**

ក. យោធាមិនតំណាងឲ្យសង្គមទាំងមូលទេ ដូច្នេះហើយគេចង់បានការកែទម្រង់ណាដែលឲ្យផលកម្រៃជាបឋមដល់គ្រួសារ និងមិត្តភក្តិរបស់យោធា,

ខ. នាយទាហានទទួលការហ្វឹកហ្វឺន គឺដើម្បីធ្វើប្រតិបត្តិយោធាហើយគ្មានឯកទេសក្នុងការគ្រប់គ្រងទេ,

គ. ការទទួលខុសត្រូវក្នុងការចាត់ចែងរដ្ឋាភិបាល ធ្វើឲ្យការយកចិត្តទុកដាក់របស់យោធាឃ្លាតចាកពីភារកិច្ចចម្បង នៃការការពារប្រទេស

ឃ. នាយទាហានទទួលឥទ្ធិពលនយោបាយកាលណាគេធ្លាក់ខ្លួនពាក់ព័ន្ធក្នុងរដ្ឋាភិបាល ដូច្នេះហើយមិនសូវចង់គោរពបញ្ជារបស់ថ្នាក់លើខាងយោធា និងស៊ីវិលរបស់ខ្លួនទេ,

ង. របបយោធាភាគច្រើនតែងតែមានការប្រើកម្លាំងទ័ពដើម្បីបំបាត់គណបក្សប្រឆាំង ហើយប្រព្រឹត្តការរំលោភសិទ្ធិមនុស្ស ។

X- ## ការបោះឆ្នោត

ក. សារប្រយោជន៍នៃការបោះឆ្នោត :

១. ប្រជាធិបតេយ្យដំណើរការ ដោយឈរលើគោលការណ៍នៃវិធានរបស់សម្លេងភាគច្រើន, (ពោលគឺសម្រេចតាមសម្លេងភាគច្រើន)

២. វាស់សម្លេងភាគច្រើន ពោលគឺជ្រើសរើសតំណាង ឬគណបក្សដែលគាំទ្រគោលនយោបាយណាដែលប្រជាពលរដ្ឋភាគច្រើនគាំទ្រ,

៣. ការផ្ទេរអំណាចក្នុងរដ្ឋាភិបាលដោយសន្តិវិធី,

៤. បន្ថយសក្តានុពលនៃការរីករាលក្នុងសង្គម ដោយផ្តល់មធ្យោបាយសន្តិវិធី ដើម្បីបញ្ចេញគំនិតជំទាស់ និងផ្លាស់ប្តូររដ្ឋាភិបាល,

៥. ជាមធ្យោបាយសម្រាប់ធ្វើឲ្យមេដឹកនាំរដ្ឋាភិបាលចេះទទួលខុសត្រូវ ។ (មេដឹកនាំទាំងអស់នេះ ដឹងថាប្រជាពលរដ្ឋនឹងមិនបោះឆ្នោតឲ្យម្តងទៀតទេ បើអំពើរបស់ខ្លួនមិនស្របច្បាប់ គ្មានសីលធម៌ ឬរំលោភឆន្ទៈទូទៅរបស់ប្រជាពលរដ្ឋភាគច្រើន)

៦. យុទ្ធនាការឃោសនាបោះឆ្នោត ផ្តល់ឱកាសឲ្យមានការជជែកដេញដោលជាសាធារណៈ លើសេចក្តីសម្រេចនានាដែលរដ្ឋាភិបាលត្រូវធ្វើ,

៧. ការបោះឆ្នោតជាមធ្យោបាយធ្វើឲ្យបេក្ខជនទិតទំកំណត់នយោបាយ តាមឆន្ទៈប្រជាពលរដ្ឋ,

ខ. តួនាទីរបស់យោធាក្នុងការបោះឆ្នោត :

១- រក្សាសុវត្ថិភាពដល់គ្រប់បេក្ខជនដែលឃោសនាបោះឆ្នោត ( ប្រសិនបើចាំបាច់)

២- រក្សាសុវត្ថិភាពក្នុងថ្ងៃបោះឆ្នោត,

៣- ប្រកាន់ជំហរអព្យាក្រិត,

៤- មិនត្រូវធ្វើការគម្រាមកំហែងដល់អ្នកបោះឆ្នោត,

៥- រក្សាឲ្យបាននូវភាពសម្ងាត់នៃសន្លឹកឆ្នោត,

## សេចក្តីសន្និដ្ឋាន

ក. ប្រជាធិបតេយ្យតំណាងត្រូវបានចាត់ទុកថាជាទម្រង់នៃរដ្ឋាភិបាលមួយដ៏ល្អ ព្រោះវាបើកលទ្ធភាពឲ្យពលរដ្ឋម្នាក់ៗចូលរួមក្នុងសេចក្តីសម្រេចរបស់រដ្ឋាភិបាល ។

ខ. ទម្រង់និងរចនាសម្ព័ន្ធនៃរដ្ឋាភិបាលដែលគេជ្រើសរើស នឹងអាស្រ័យលើលក្ខខណ្ឌ

សេដ្ឋកិច្ច សង្គម និងវប្បធម៌នៅក្នុងប្រទេស ។

គ. ទម្រង់ និងរចនាសម្ព័ន្ធនៃរដ្ឋាភិបាល មានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ។ រដ្ឋធម្មនុញ្ញការពារសិទ្ធិមួយចំនួនរបស់ពលរដ្ឋទាំងអស់ ។

ឃ. រដ្ឋធម្មនុញ្ញត្រូវថ្លឹងថ្លែងឲ្យមានតុល្យភាពរវាងក្រុមផ្សេងៗនៅក្នុងប្រទេស ។

ង. ប្រជាធិបតេយ្យទាមទារឲ្យប្រជាពលរដ្ឋមានចរិតជាអ្នកប្រជាធិបតេយ្យ ពោលគឺបុគ្គលម្នាក់ៗជាច់ខាត និងជានិច្ចជាកាលត្រូវតែមានស្មារតី អត់ធ្មត់ ចំពោះភាពតានតឹងនានា ត្រូវចេះអនុគ្រោះចំពោះការឆ្គាំឆ្គង ត្រូវចេះរកដំណោះស្រាយតាមការសម្របសម្រួល ប្រសិនបើមានទំនាស់រវាងគ្នានឹងគ្នា, ត្រូវមានស្មារតីសហការជានិច្ចក្នុងកិច្ចការនានា និងជាពិសេសទៅទៀត គឺជាច់ខាតត្រូវនិយាយគ្នា ឬជជែកគ្នាដើម្បីឲ្យយល់គ្នាទៅវិញទៅមក មុននឹងធ្វើអ្វីមួយ ។

# សីលធម៌គ្រប់គ្រង

( *Moral governance* )

I. **ស្គាល់ខ្លួនឯងឲ្យច្បាស់** (អាត្មាអញជាអ្នកណា ? Who am I ?)

**ក. ជាមនុស្សប្រភេទណា ?**

១. មនុស្សប្រតិកម្មនិយម (Reactive → Outside-in)

២. មនុស្សទប់ទល់នឹងប្រតិកម្ម (Proactive → Inside-out)

**ខ. ជាខ្មែរអម្បូរអ្វី ?**

១. ខ្មែរដើម (អម្បូរមិលក្ខៈ ឬ មិលក្ខុ)

២. ខ្មែរកាត់ (ឥណ្ឌា + ជ្វា)

៣. ខ្មែរកាត់ ( ចិន + តៃ )

II. **ដឹងឲ្យច្បាស់ពីមូលហេតុ** (ដើម្បីគ្រប់គ្រងអាត្មាគប្បីដឹងថា:)

ក. **អ្វីដែលបណ្ដាលឲ្យអាត្មាប្រព្រឹត្តមិនត្រឹមត្រូវ?**

- **ទំនាញបីគូ :** (Three pairs of Pulling Forces)

១. ស្រេកឃ្លានអាហារនិងតណ្ហា (ក្នុងផ្លូវភេទ)
(Appetites and Passion)

២. ចេះតែមានមោទនចំពោះខ្លួនឯង និងចេះតែធ្វើឫកខ្ពស់លើសពីសមត្ថភាព និងលទ្ធភាព (Pride and Pretension)

៣. ចេះតែបម្រុងខ្លួនដើម្បី . . . និងមហិច្ឆតា
(Aspiration and Ambition)

## ខ. អាត្មារមែងប្រព្រឹត្តអ្វីខ្លះ?

– **បាបកម្មប្រាំពីរយ៉ាង :** (Seven Deadly Sins)

១. មានសម្បត្តិមហាសាល ដោយគ្មានពលកម្ម
(Wealth without Work)

២. សប្បាយដាច់បង្អៀវ ដោយគ្មានសម្បជញ្ញៈ
(Pleasure without Conscience)

៣. វិទ្យាសាស្រ្ត ដោយគ្មានគិតដល់មនុស្សជាតិ
(Science without Humanity)

៤. សេដ្ឋកិច្ច ដោយគ្មានសីលធម៌
(Economic or Business without morality)

៥. ចំណេះដឹងដែលគ្មានជ្រាបចូលជាចរិត
(Knowledge without Characters)

៦. សាសនាដែលគ្មានពលីកម្ម
(Religion without Sacrifices)

៧. នយោបាយដោយគ្មានគោលមូលដ្ឋាន
(Politic without Principles)

# III. គន្លងសីលធម៌

## ក. និយមអដ្ឋង្គិកមគ្គ (Eight Noble Paths)

១. សម្មាទិដ្ឋិ = មានប្រាជ្ញា**យល់ត្រូវ** (Right Understanding)

២. សម្មាសង្កប្បៈ = មានសេចក្តី**ត្រិះរិះត្រូវ** (Right Thought)

៣. សម្មាវាចា = មានការ**និយាយស្តីត្រឹមត្រូវ** (Right Speech)

៤. សម្មាកម្មន្តៈ = មានការ**ប្រព្រឹត្តិត្រូវ** (Right Action)

៥. សម្មាអាជីវៈ = មានការ**ចិញ្ចឹមជីវិតត្រូវ** (Right livelihood)

៦. សម្មាវាយាមៈ = មានសេចក្តី**ព្យាយាមត្រូវ** (Right Effort)

៧. សម្មាសតិៈ = មានការ**ភ្ញាក់រលឹកត្រូវ** (Right Concentration)

៨. សម្មាសមាធិ = មានការ**ដម្កល់ចិត្តត្រូវ** (Right Meditation)

**ខ. និយមច្បាប់ជាមូលដ្ឋាន** (Principles Centered)

**គ. និយមទម្លាប់ប្រាំពីរយ៉ាងរបស់មនុស្សចំណាប់ចំនួន ល្បីល្បាញ** (Seven Habits of Highly Effective People)

១. ពិចារណាទប់ទល់មុននឹងមានប្រតិកម្ម (Be Proactive)

២. ចាប់ផ្តើមអ្វីមួយដោយមានគម្រោងថាត្រូវបញ្ចប់ត្រង់ណា (Begin with the End in Mind)

៣. ទុកដាក់របស់ទី១មុន (តាមលំដាប់) (Put First thing First)

៤. គិតដល់រឿងឈ្នះទាំងគ្រប់ភាគី (Think Win / Win)

៥. ស្វែងយល់អំពីអ្នកដទៃ ឬគូភាគី ទើបឲ្យគេយល់អំពីយើង (Seek to Understand, then to Be Understood)

៦. ទម្លាប់យល់ថា លទ្ធផលពីកិច្ចសហការគ្នា ធំធេងជាងលទ្ធផលពីបុគ្គលម្នាក់ បូកសរុបគ្នា (Synergize)

៧. សំលៀងដុសខាត់ទម្លាប់ទាំង៦នេះ ជានិច្ចកាល(Sharpen the Saw)

**ឃ- គុណសម្បត្តិប្រាំបីយ៉ាង របស់អ្នកដែលមានជោគជ័យ ក្នុងជីវិត** Eight Qualities of Successful People

អ្នកដែលរមែងមានជោគជ័យក្នុងជីវិតជាប្រភេទមនុស្សដូចតទៅ ៖

១- ជាអ្នកព្រមព្រៀងទទួលយកជីវិតតាមដំណើររបស់វា ទោះប្រកប ដោយក្ដីលំបាក និងតឹងតែងយ៉ាងណាក្ដី ។ លោករមែងសម្រប-សម្រួលតាមជាជាងការត្អូញត្អែរអំពីការលំបាកនោះៗ ។ លោកយក ការទទួលខុសត្រូវលើជីវិតរបស់ខ្លួន ជំនួសការបន្ទោសអ្នកដទៃ ឬដោះសារយករួចខ្លួន ។

Successful people accept life as it is, with all its difficulties and challenges. They adapt to it rather than complain about it. They accept responsibility for their own lives instead of blaming or making excuses.

២- ជាអ្នកពង្រីក និងប្រកាន់យកនូវឫកពារថ្លៃថ្នូរសម្រាប់ជីវិត ។ លោកសម្លឹងរកចំណុចល្អៗរបស់អ្នកដទៃ និងនៅក្នុងលោក ហើយ គាត់ច្រើនតែយល់ឃើញថាចំណុចទាំងឡាយនោះល្អមែន ។ លោក ឃើញជីវិតជាកម្រងនៃឱកាស និងលទ្ធភាព ហើយលោកចំរាញ់ចេញ ជាប្រយោជន៍អំពីជីវិតនោះជានិច្ច ។

Successful people develop and maintain a positive attitude toward life : They look for good in others and in the world and usually seem to find it. They see life as a serie of opportunities and possibilities and always explore them.

៣- ជាអ្នកកសាងទំនាក់ទំនងល្អ ។ ជាអ្នកមានចិត្តទន់ចំពោះសេចក្ដី ត្រូវការ និងការរងអារម្មណ៍នៃអ្នកដទៃ ។ ជាមនុស្សគួរឲ្យតម្លៃ និង គួរឲ្យគោរព ។ លោកមានមធ្យោបាយបំផុសចំណុចល្អៗបំផុតឲ្យលេច ចេញពីមនុស្សទាំងឡាយ ។

Successful people build good relationships. They are sensitive to the needs and feelings of other. They are considerate and respectful. They have a way of bringing out the best in other people.

៤- ជាមនុស្សប្រាកដប្រជាលើទិសដៅ និងសេចក្ដីប្រាថ្នា ។ លោក ដឹងប្រាកដថា លោកកំពុងនៅទីណា ។ លោកសំអិតសំអាងបំណង ទាំងឡាយព្យាយាមបំពេញបំណងទាំងនោះ ឲ្យបានរួចរាល់ហើយ

សំរិតសំអាងបំណងថ្មីៗទៀត ។ លោកទទួល និងរីករាយក្នុងការទប់ទល់គ្រប់ឧបសគ្គ ។

Successful people have a sense of direction and purpose - they know where they are. They set goals, accomplish them, and then set new goals. They accept and enjoy challenges.

៥- ជាមនុស្សមានបំណងយ៉ាងខ្លាំងដើម្បីរៀនអំពីជីវិត អំពីពិភពលោក និងអំពីខ្លួនឯង ។ លោកគិតថាការសិក្សារៀនសូត្រជាការសប្បាយ មិនជាកាតព្វកិច្ចឡើយ ។ លោកធ្វើឲ្យជីវិតលោកចេះតែរីកចម្រើនឡើង ដោយការយល់ដឹងពីអ្វីៗដែលថ្មី។ តម្លៃខ្លួនលោកក៏ចេះតែអណ្តែតឡើងដែរ ។ ជានិច្ចកាលលោកជួបគំហើញថ្មីៗ ហើយលោកចេះតែលូតលាស់ ដុះដាលជាលំដាប់ ។

- Successful people have a strong desire to learn about life, the world, and themselves. They think of learning as a joy, not a duty. They continually enrich their lives by learning new things and improving themselves. They are always discovering, always growing.

៦- ជាមនុស្សមានសកម្មភាពតាមទិសផ្ចិតផ្ចង់ ។ លោកបង្ហើយគ្រប់កិច្ចការដោយលោកមិនខ្លាចការលំបាក ហើយលោកមិនចំណាយពេលចោល ។ លោកប្រើពេលក្នុងមធ្យោបាយកសាង ។ លោកមិនមានពេលទទួលភាពសង្កត់សង្កិន ឬការធុញថប់ទេ ព្រោះលោកជាប់រវល់ពេកក្នុងការសម្លឹងរកបទពិសោធន៍ថ្មីៗ ។

- Successful people are action oriented. They get things done because they are not afraid of hard work, and they don't waste time. They use time in constructive ways. They don't get into ruts or become bored because they are too busy looking for news experiences.

៧- ជាមនុស្សប្រកាន់ភាពថ្លៃថ្នូរ តាមអាកប្បកិរិយា ។ លោក ដឹងថាសេចក្តីស្មោះត្រង់ជាគ្រឿងផ្សំដ៏សំខាន់បំផុតក្នុងចរិតល្អនៃមនុស្ស ។ លោកត្រូវបានគេមើលឃើញគួរឲ្យទុកចិត្ត ទាំងក្នុងជីវិតឯកជន ទាំងក្នុងជីវិតសាធារណៈ ។

- Successful people maintain high standards in their personal conduct. They know that honesty is a primary ingredient in the character of a good person. They are consistently truthful in both their private and their public lives.

៨- ជាមនុស្សយល់អំពីភាពខុសគ្នារវាងអត្ថិភាពនៃជីវិត និងការរស់រាន ហើយលោករមែងជ្រើសរើសយកការរស់រាន ។ លោកបានប្រយោជន៍ច្រើនណាស់ចេញពីជីវិត ពីព្រោះលោកយកចិត្តទុកដាក់ច្រើនណាស់ដែរលើវា ។ លោកបានច្រូតកាត់នូវអ្វីដែលលោកបានសាបព្រួស ។ លោកសប្បាយនឹងជីវិតដ៏ពេញពោរ ។

- Successful people understand the difference between existing and living and always chose the latter. They get the most out of life because they put the most into it. They reap what they sow. And They enjoy life to the fullest.

# វិតិលខ្លួនចូលកាន់ដំណែងតាមគន្លងសីលធម៌
## Approaching to the Moral Conducts

I. ដូរចរិតជាមនុស្សឆាប់ច្រឡោតទៅជាមនុស្សស្ងប់ (មិនឆាប់ច្រឡោត)
Change yourself from being Reactive to Proactive.

II. ស្វែងយល់ត្រូវ ច្បាស់លាស់អំពីខ្លឹមសារនៃព្រះពុទ្ធសាសនា (ឬសាសនាផ្សេងៗទៀត)
Seek to Understand Clearly and Rightfully the essence of Buddhism.

III. ស្វែងយល់ដឹងអំពីច្បាប់ និងការបកស្រាយនៃច្បាប់ ដោយសេចក្តីព្រមព្រៀងជ្រះថ្លា
Seek to know and Understand Laws and Civic interpretations with honest agreement.

I. ដូរចរិតជាមនុស្ស ច្រឡោត (Reactive) ទៅជាមនុស្ស ស្ងប់ (Proactive)- ឆ្ពោះទៅរកលទ្ធភាពក្នុងការដូរចរិត

ក- ស្តីពីញាណទស្សនៈ Paradigm

ញាណទស្សនៈគឺ

- ចំណាប់អារម្មណ៍ Perceiving
- ការយល់ដឹង Understanding
- ការបកស្រាយ Interpreting
- ទ្រឹស្តី Theory
- ជាគំរូ Model
- សេចក្តីសន្មតិ Assumption
- ជាគម្រោងសេចក្តីយោង Frame of References.

« ដើម្បីប្តូរស្ថានភាព យើងត្រូវផ្តើមដោយប្តូរខ្លួនយើង ។ ប៉ុន្តែដើម្បីប្តូរខ្លួនយើងៗ ក៏ត្រូវផ្តើមដោយប្តូរចំណាប់អារម្មណ៍របស់យើង (Perceptions) គឺប្តូរញាណទស្សនៈ»

* ដើម្បីឲ្យស្រួលយល់ យើងសម្គាល់ញាណទស្សនៈក្នុងទីនេះជាផែនទី Maps

ខ- ស្តីពីកម្លាំងញាណទស្សន : (Power of a Paradigm)

- យើងម្នាក់ៗមានផែនទីប្រើច្រើនណាស់នៅក្នុងគំនិតរបស់យើង ហើយច្រើនតែផ្សេងៗគ្នាផង ។ តែយើងអាចសរុបបញ្ចូលបានត្រឹមតែពីរផ្នែកគឺ :

- ផែនទីដែលគួរតាមការសន្មតិ ឬការឲ្យតម្លៃ Maps of the way things should be, or values

- ផែនទីដែលគួរតាមប្រាកដភាព Maps of the way thigs are, or realities

- ចរិតរបស់យើងម្នាក់ៗសម្តែងចេញតាមផែនទីដែលយើងប្រកាន់រៀងៗខ្លួននោះឯង ។ ឧទាហរណ៍ - (ធ្វើការពិសោធន៍តាមវិធីបង្ហាញរូប)

យើងច្រើនឃើញអ្វីៗមិនត្រូវតាមប្រាកដភាពនៃអ្វីនោះទេ តែគឺឃើញតាមឥទ្ធិពលពីខាងក្រៅដែលតម្រូវឲ្យយើងឃើញ ។

គ- ស្តីពីកម្លាំងនៃការប្តូរញាណទស្សនៈ ( Power of a Paradigm shift )

(យោងលទ្ធផលនៃការពិសោធន៍)

- ដូរជំនឿ- ដូរទ្រឹស្តី- ដូរទស្សនៈ ដូររបបគ្រប់គ្រង ។ ល ។

ឃ- គោលការណ៍និយមនៃញាណទស្សនៈ ( Principle Centered Paradigm )

- ប្រសិទ្ធភាពនៃមនុស្ស ក្នុងការរស់នៅរីកចម្រើន ត្រូវបានគ្រប់គ្រងតាមគោលការណ៍នៃច្បាប់ធម្មជាតិ ( Natural laws ) ដែលមានប្រាដកភាព និរន្តរភាព មិនអាចផ្លាស់ប្តូរ ឬលើកយកមកជជែកគ្នាបាន ។ ឧទាហរណ៍: ច្បាប់ក្នុងកំណើតវត្ថុ និងសត្វលោក-ច្បាប់ទំនាញផែនដីក្នុងរូបវិទ្យា ។ល។

- ច្បាប់ធម្មជាតិមិនអាចត្រូវគេក្បត់ ឬបំបែកបានទេ ។ គឺមានតែយើងទេ ដែលអាចបែកបាក់ (វង់គ្រោះ) ក្នុងការប្រឆាំងនឹងច្បាប់ធម្មជាតិ ។

- កាលបើបុគ្គលពិនិត្យលើជីវិត និងទំនាក់ទំនងជាប្រក្រតីតាមញាណទស្សនៈ ( Paradigm ) ដែលលេចចេញឡើងពីបទពិសោធន៍ផ្ទាល់ខ្លួនបានមកតាមបញ្ញានៃពិភពខាងក្រៅ ( Ouside - in Conditioning ) បុគ្គលមិនអាចឃើញប្រាកដភាពមួយក្នុងលក្ខណៈជាពុទ្ធិវត្ថុបានទេ ( Objective Reality) បុគ្គលមិនអាចឃើញត្រឹមតែភាពមួយដោយសន្មត់ក្នុងលក្ខណៈជាពុទ្ធិប្រធានឡើយ ( Subjective Reality )

- ប្រាកដភាពក្នុងលក្ខណៈពុទ្ធិប្រធាននេះ ប្រៀបបាននឹងផែនទីដែលយើងព្យាយាមគូរតាងស្រុក ខេត្ត ឬទីតាំងភូមិសាស្ត្រណាមួយ ប៉ុន្តែវាមិនមែនជាទីតាំងភូមិសាស្ត្រនោះឡើយ

( a map is only an attempt to discribe the territory, but it is not the territory itself ) ។

- គិតទៅដល់ច្បាប់ធម្មជាតិ ដែលមានលក្ខណៈជាពុទ្ធិវត្ត គោលការណ៍ ឬច្បាប់ទាំងឡាយត្រូវតែយោង ឬសម្របសម្រួលតាមច្បាប់ធម្មជាតិនោះឯង ។

- គោលការណ៍និយម នៃញាណទស្សនៈ ដែលមិនមែនជាការលាក់លៀម ( Esoteric) មិនមែនជាអាថ៌កំបាំង ( Mysterious ) ហើយមិនមែនជារឿងសាសនា ( Religious ideas ) គឺជាពុទ្ធិវត្ត ដែលប្រាកដឡើងដោយឯកឯង ដូចឧទាហរណ៍តទៅនេះ :

- ការសមហេតុសមផល( Fairness ) - ជាប្រភពនៃគោលការណ៍សមភាព និងយុត្តិធម៌ ( Equity and justice )

- សុចរិត និងស្មោះត្រង់ ( Intergrity and Honesty ) - ជាប្រភពនៃទំនុកទុកចិត្តក្នុងដំណើរអភិវឌ្ឍន៍ សហការ និងការរីកចម្រើននៃទំនាក់ទំនង ។

- សេចក្តីថ្លៃថ្នូររបស់មនុស្ស ( Human dignity ) - ជាប្រភពនៃគោលការណ៍សិទ្ធិនិងសេរីភាព

- សេវាកម្ម ( Service ) ជាប្រភពនាំឲ្យមនុស្សមានគំនិតចេះជួយទុក្ខធុរៈគ្នា និងចែករំលែក ( Contribution )

- គុណសម្បត្តិ ឬប្រណិតភាព ( Quality or Excellance ) - ជាប្រភពនាំឲ្យមនុស្សមានការជ្រើសរើស ។

- សក្តានុពល ( Potential ) - ជាប្រភពនាំឲ្យមនុស្សដឹងខ្លួនថា ខ្លួនមានសក្តានុពលពីធម្មជាតិ ដែលអាចលូតលាស់រីកចម្រើន និងអាចបញ្ចេញអានុភាពទៅពង្រីកទេពកោសល្យឲ្យចម្រើនឡើងដែរ ។ ជិតស្និទ្ធនឹងសក្តានុពលនេះ គឺការកកើតដុះដាលលូតលាស់ធំធាត់នៃជីវិត ( Growth ) ជាដំណើរដែលជាប់ទាក់ទងដល់សេចក្តីត្រូវការ ដើម្បីគោលការណ៍ទាំងឡាយ ដូចជាសេចក្តីអត់ធន់ ការចិញ្ចឹមបីបាច់ និងការបំផុសសេចក្តីក្លាហានជាដើម ( Patience, Nurturance, and Encouragement ) ។

- គោលការណ៍ ឬច្បាប់ វិន័យ ( Principles ) មិនមែនជាកិច្ចប្រតិបត្តិទេ ( Practices) និងមិនមែនជាតម្លៃទេ ( Values ) ។

- គោលការណ៍ជាកម្រងខ្សែបន្ទាត់បង្ហាញទិសដល់ការប្រព្រឹត្តិទៅរបស់មនុស្ស (Guidelines)

ង- <u>គោលការណ៍នៃការរីកចម្រើន និងគោលការណ៍នៃការប្រែប្រួល</u> : ( Principles of Growth and Change )

- ក្នុងមួយអាយុកាលនៃមនុស្ស(សត្វលោក) រមែងមានលំដាប់ពេល ( Sequential stages ) នៃការរីកចម្រើនដែលមិនអាចផ្លោះឬរំលងបានឡើយ ។ ឧទាហរណ៍ : ក្មេងផ្តើមពីការរៀនក្រឡាប់ អង្គុយ វារ ដើរ រត់ ។ ដំណើរចម្រើនឡើងតាមផ្លូវកាយនេះមិនជាការពិបាកនឹងពិចារណាឡើយ ។ តែការរីកចម្រើនប្រែប្រួលក្នុងផ្លូវមនោសញ្ចេតនា ចិត្តគំនិត ប្រាជ្ញាស្មារតីដែលរត់តាមលំដាប់ពេលដែរនោះ ជាការពិបាកក្នុងការឈ្វេងយល់ និងដឹង ។

- បើយើងមិនបានឲ្យលោកគ្រូយើងដឹងនូវកម្រិតយល់ដឹងរបស់យើងដោយប្រើសំណួរ ឬដោយបង្ហាញភាពមិនយល់ដឹងនោះ យើងពិតជាអត់បានរៀន ហើយនិងអត់បានរីកចម្រើនសោះឡើយ ។

- ក្នុងវិស័យអប់រំ ជំហានទីមួយ គឺការទទួលស្គាល់ភាពល្ងិតល្ងង់របស់យើង ។

- ការរីកចម្រើនផ្នែកប្រាជ្ញាស្មារតី តម្រូវឲ្យយើងទទួលស្គាល់ភាពល្ងិតល្ងង់របស់យើង តើយើងអាចរលឹកនឹកឃើញដល់ភាពល្ងិតល្ងង់ម្តេចបាន បើយើងកំពុងប្រើការចេះដឹង និងគិតថាយើងចេះដឹងគ្រប់ពេលវេលាហើយនោះ ។

- ការស្តាប់តម្រូវ ( Involves ) ការអត់ធន់ ( Patience ) ការចំហអារម្មណ៍ ( Openness ) និងការចង់យល់ដឹង ( Desire to Understand )

ច- <u>កំពស់មួយថ្មីនៃសេចក្តីត្រិះរិះ</u> : ( A New Level of thinking )

- លោក Albert Einstein មានប្រសាសន៍ថា « បញ្ហាធ្ងន់ធ្ងរដែលយើងកំពុងប្រឈមមុខមិនអាចដោះស្រាយបានតាមកំពស់នៃការគិតស្មើនឹងកំពស់គំនិត ដែលបង្កើតបញ្ហាឡើងនោះឡើយ» កំពស់មួយថ្មីនេះ គឺជាអ្វីៗដែលស្ថិតក្នុងទម្លាប់ទាំង៧ របស់មនុស្សចំណាប់ចំនួនដោះឯងដែលផ្តើមតាមរបទពីក្នុងចេញក្រៅ ( Inside - Out )

- ពីក្នុងចេញក្រៅ ( Inside - Out → Proactive ) មានន័យថា ត្រូវផ្តើមចេញជាដំបូងពីជម្រៅនៃអាត្មន ( អាត្មា = Self ) ដោយជំនួយពីញាណទស្សនៈរបស់យើងពីចរិតយើង និងពីមូលហេតុយើង ។

- មាគ៌ាប្រតិបត្តិពីក្នុងចេញក្រៅចែងថា « ជោគជ័យបុគ្គល ឬជោគជ័យឯកជនដើរមុនជោគជ័យសាធារណៈ » ឬក៏ថា « ការចេះរក្សា និងបំពេញពាក្យសន្យាបានចំពោះខ្លួនឯងត្រូវដើរមុនការចេះរក្សា និងបំពេញពាក្យសន្យាបានចំពោះអ្នកដទៃ »

* ដើម្បីផ្ដើមការប្ដូរចរិតបាន យើងគប្បីបញ្ច្រាបចំណោះ និងគោលការណ៍ទាំងឡាយនេះ ឲ្យស៊ប់ទៅក្នុងសន្ដានារម្មណ៍ និងក្នុងសរសៃសាច់ឈាមជាមុនសិន ។

II . ស្វែងយល់ត្រូវនិងច្បាស់លាស់អំពីខ្លឹមសារនៃព្រះពុទ្ធសាសនា

Seek to Understand clearly and rightfully the essence of Buddhism

ក- កំណើតសាសនា :

- កាលបើការវិវត្តន៍ ( Evolution ) ក្នុងធម្មជាតិនៃសត្វលោកបានមកដល់ដំណាក់ការជាមនុស្សហើយ មនុស្សនេះឯងជាសត្វលោកខ្ពស់បំផុត ( Man is Ultimate Being ) ។ ប៉ុន្តែមនុស្សគ្មានសម្បទានធម្មជាតិលើរាងកាយដើម្បីគ្រប់គ្រងជីវិតបានដូចសត្វលោកឯទៀតឡើយ ។ ចំណុចត្រង់ហ្នឹងហើយ ដែលជាមូលហេតុដើមនៃសាសនា ។ ដូច្នេះកំណើតនៃសាសនាមានមកតាំងពីពេលដំណាលគ្នានឹងពេលដែលមានមនុស្សមកម្ល៉េះ ។ មនុស្សនិយមសាសនាដើម្បីរក្សាអត្ថិភាពរបស់ខ្លួន ( To Preserve his Existence ) និងដើម្បីការពារជីវិតខ្លួនទប់ទល់នឹងគ្រោះថ្នាក់ ( To Protect his life from Dangers ) ។

ខ- អត្ថន័យនៃសាសនា :

- មែនហើយសាសនាប្រែថា សេចក្ដីប្រៀនប្រដៅ ។ ប៉ុន្តែន័យនេះ វាជាលទ្ធផលនៃការវិវត្តន៍ផ្នែកប្រាជ្ញាស្មារតីមនុស្សរាប់ម៉ឺនសែនឆ្នាំមកហើយទេ ។ ន័យដើមបំផុតនោះ សាសនាគឺអ្វីដែល*អត់ទេ* ហើយមនុស្សពឹងពាក់លើ ឬមួយក៏ថា សាសនា ព្រោះតែការ*មិនដឹង* ។ ឧទាហរណ៍ ក្រោមបាតុភូតធម្មជាតិ ជាព្យុះព្យោមារ ផ្គរ រន្ទះ មនុស្សអត់យល់ដឹងនូវអ្វីក្រៅពីការភ័យរន្ធត់ តក់ស្លុតរត់រកទីជម្រក និងឧទានស្រែករកទីពឹងពំនាក់ប៉ុណ្ណោះ ។ លុះដល់មេឃស្រឡះភ្លឺស្វាងជាប្រក្រតីឡើង គេក៏បានសុខសាន្តជាធម្មតា ពួកគេក៏តាំងគិតថាអ្វីដែលគេនឹកដល់ក្នុងពេលនោះគឺអ្វីនោះហើយដែលជាវត្ថុស័ក្តិសិទ្ធិបានមកជួយការពារគេ ។ ដូច្នេះសាសនាអាចមាននិយមន័យម្យ៉ាងទៀតថាជាការស្មាន ឬជាការសន្មត់ ឬក៏ជាជំនឿលើអ្វីដែល***អត់*** ។

គ- ព្រះពុទ្ធសាសនា :

- ព្រះពុទ្ធជាវរជនអ្នកភ្ញាក់រលឹក ( Awaken one ) -ជាវរជនអ្នកភ្លឺស្វាង ( Enlighten One ) ។
- ចំណេះដឹងរបស់ព្រះពុទ្ធ គឺពុទ្ធិ ( Knowledge ) ។

- ព្រះតេជព្រះគុណ Rahula  អ្នកប្រាជ្ញខាងព្រះពុទ្ធសាសនាជាតិឥណ្ឌាមានសង្ឃដីកាថា « គ្រាន់តែជាមនុស្សម្នាក់ ហើយជាមនុស្សធម្មតាសោះ ក៏អាចជាព្រះពុទ្ធបានដែរ » « A man and a simple man Can be Buddha »

- ដោយសារសេចក្តីភ្ញាក់រលឹក ដោយសារការភ្លឺស្វាង និងប្រកបដោយពុទ្ធិ ព្រះសិទ្ធត្ថទ្រង់បានសម្រេចជាព្រះពុទ្ធ ជាអ្នករកឃើញនូវសច្ចភាព ដែលហៅថាចតុរារិយសច្ចៈ ( Four Noble Truths )

- សច្ចភាពនេះ ស្ថិតស្ថេរជាសច្ចភាពជាងពីរពាន់ប្រាំរយឆ្នាំមកហើយៗ ក៏មានតម្លៃជាសាសនា ។ ដូច្នេះព្រះពុទ្ធសាសនាមិនមែនជាសេចក្តីស្មាន ជាសេចក្តីសន្មតិ ឬជាជំនឿលើអ្វីដែល***អត់*** នោះទេ គឺជាច្បាប់នៃហេតុផល ( Law of Cause- Effect ) ដែលជាសច្ចៈប្រកបដោយប្រាកដភាព ។

- « តថាគតអញ្ជើញអ្នករាល់គ្នាឲ្យចូលមកស្តាប់ មកឮ មកឃើញ មកពិចារណា និងមកយល់ មិនមែនមកជឿ ទេ » ( I invite you to come to Listen, to Hear, to Think, and to Understand... Not to Believe. ) ។

- ជឿ ឬមិនជឿ ពីព្រោះហេតុតែមិនដឹង ( Ignorance )

- ឃើញថាខ្លឹមសារត្រឹមត្រូវច្បាស់លាស់នៃព្រះពុទ្ធសាសនា គឺសេចក្តីណែនាំទូន្មានប្រៀនប្រដៅតាមបែបប្រាកដភាព និងសច្ចភាព ដើម្បីបំបាត់ឲ្យអស់នូវបញ្ហាជឿ និងមិនជឿនោះឯង ។

- មានពួកបស្ចឹមប្រទេសកាន់តែច្រើនឡើងហើយ ដែលគេទទួលស្គាល់ព្រះពុទ្ធសាសនាថាជាផ្លូវ ឬជាមធ្យោបាយនៃជីវិត ( Buddhim is the Way of Life )

- ពុទ្ធសាសនិកជនដែលប្រកាន់យក***នូវជំនឿ ឬមិនមានជំនឿ*** មិនគ្រាន់តែជាការភាន់ច្រឡំទេ ថែមទាំងជាការបំផ្លាញខ្លឹមសារនៃព្រះពុទ្ធសាសនាទៀតផង ។

- ក្នុងគម្ពីរពុទ្ធសាសនា មិនមានពាក្យបាលីណាដែលគួរប្រែថា ***ជឿ*** ទេ ។ មានត្រឹមតែពាក្យសទ្ធា ( សទ្ធាជ្រះថ្លា ) ដែលប្រែថាទំនុកទុកចិត្ត ( Confidence ) ។

- ក្នុងគម្ពីរពុទ្ធសាសនាមានស្ទីអំពីពិធី ( Ceremonies) ប៉ុន្តែព្រះពុទ្ធអង្គមិនបានឲ្យតម្លៃពិធីស្មើនឹងកិច្ចប្រតិបត្តិទេ ។

ឃ. ប្រយោជន៍នៃពុទ្ធសាសនា

- យោងតាមខ្លឹមសារសង្ខេបមកនេះ យើងខ្មែរជាពុទ្ធសាសនិកជន ៩០% ហាក់ដូចជាមានតិចតួចនៅឡើយទេ ដែលយល់ប្រាកដអំពីពុទ្ធសាសនា ។ ព្រោះប្រហែលជាដោយហេតុយ៉ាងនេះហើយ បានជាពុទ្ធសាសនាបំពើៈ

* ផលប្រយោជន៍ពុទ្ធសាសនិកជនខ្មែរ សង្គមខ្មែរ និងជាតិខ្មែរបានតិចតួចស្តួចស្តើងណាស់ (ស្ទើរនិយាយបានថាបំផ្លាញប្រយោជន៍ខ្មែរ) ព្រោះតែអ្នកដឹកនាំក្តី (ព្រះសង្ឃ អាចារ្យ) អ្នកដើរតាមក្តីដែលមិនបានយល់ប្រាកដអំពីខ្លឹមសារ ឬបំណងរបស់ព្រះបរមគ្រូ នាំឲ្យគាត់រាល់គ្នាយល់ច្រឡំយករឿងជំនឿ រឿងរៀបពិធី និងរឿងប្រកួតប្រជែង ជារឿងដែលត្រូវយកចិត្តទុកដាក់បំផុត រហូតដល់បោះបង់កិច្ចប្រតិបត្តិស្ទើរតែអស់រលីងផង ។ ឧទាហរណ៍ : ការធ្វើពិធីបុណ្យដើម្បីបានបច្ច័យកសាងខ្លោងទ្វារ កសាងព្រះវិហារ ឬធ្វើបុណ្យកឋិនទានច្រើនប៉ុណ្ណានោះ ផលបុណ្យទាំងនោះក៏បានច្រើនស្របគ្នានឹងចំនួនទាំងនោះដែរ ។

ភាពភ័ន្តច្រឡំនេះ មិនទាន់ឃើញមានវិធានការណែនាំតម្រែតម្រង់នៅឡើយទេ ។ ផ្ទុយទៅវិញ កំពុងតែផុសផុលឡើង ដែលអាចជាវិនាសកម្មដល់ជាតិមាតុភូមិខ្មែរ ពីព្រោះខ្មែរ ៩៥% និយមព្រះពុទ្ធសាសនា ។

ដើម្បីបានផលប្រយោជន៍ជាក់ស្តែង ទោះបីជាប្រយោជន៍បច្ចុប្បន្នក្តី ប្រយោជន៍អនាគតក្តី ព្រះពុទ្ធសាសនាត្រូវការការរីកដុះដាលតាមប្រព័ន្ធប្រតិបត្តិដ៏សមស្រប ដូចដែលធ្លាប់មានក្នុងសម័យពុទ្ធកាលផង ហើយដែលត្រូវធ្វើការអភិវឌ្ឍន៍ខ្លះផង ។

III . ស្វែងយល់អំពីច្បាប់ និងបកស្រាយនៃច្បាប់ដោយសេចក្តីជ្រះថ្លា :

Seek to Know and Understand Laws and Civic Interpretation with honest agreement.

ក- ផ្នែកធំៗពីរនៃច្បាប់: ច្បាប់ធម្មជាតិ Natural Law និងច្បាប់ចងក្រង Conventional Laws

១. ច្បាប់ធម្មជាតិNatural Law : - អ្វីៗដែលចក្រវាឡ (Galaxies) និងលើពិភពផែនដីយើងនេះ (រួមទាំងចក្រវាឡ និងផែនដីផង) សុទ្ធសឹងតែកើតឡើងរីកចំរើន និងរេចរិលបាត់បង់ទៅវិញ ហើយកើតឡើងទៀតតាមការតាក់តែងនៃធម្មជាតិ ។ ច្បាប់នេះជាសច្ចៈ អត់ប្រែប្រួល ឬថែមថយបានឡើយ ។ ឧទាហរណ៍មនុស្សកើតឡើង ហើយត្រូវតែស្លាប់ ។ តើមនុស្សអាចមិនស្លាប់បានទេ? ឧទាហរណ៍មួយទៀតថា មនុស្សកើតឡើង ហើយត្រូវការីកចំរើនធំធាត់តាមដំណាក់ពេល Sequencial Stages ពីក្រឡាប់ លូន វារ អង្គុយ ឈរ រហូតដល់រត់......។ តើទារកកើតភ្លាមអាចចេះឈរបានទេ? ។ យើងជា ពុទ្ធសាសនិកគួរនឹកឃើញដល់ពាក្យថា «ព្រះធម៌» ជាពាក្យរបស់ព្រះពុទ្ធជាព្រះបរមគ្រូ ។ ព្រះធម៌នេះគឺជាអ្វីៗដែលព្រះពុទ្ធអង្គរកឃើញហើយដែលមាន

សច្ចភាពស្មើនឹងច្បាប់ធម្មជាតិនេះឯង ។ សូមពិចារណាលើលំដាប់ពាក្យបង្ហាញជូននេះ «ធម៌↔ ធម្មជាតិ →ច្បាប់→ធម្មជាតិ» ។ ដូច្នេះច្បាប់ធម្មជាតិទាំងឡាយគឺព្រះធម៌ក៏ដូចជាព្រះធម៌ទាំងឡាយ គឺច្បាប់ធម្មជាតិ ។ ឧទាហរណ៍ : ព្រះធម៌ចែងថា «ជាតិ ជរា ព្យាធិ មរណៈ» ។ ច្បាប់ ធម្មជាតិថា «កើតឡើងហើយត្រូវតែស្លាប់» ។ ឃ្លាទាំងពីរនេះប្លែកគ្នាតែត្រង់ព្រះធម៌បានរៀបរាប់ចន្លោះកើត (ជាតិ) និងស្លាប់ (មរណៈ) តាមដំណើរជាក់ស្តែងនៃជីវិតដែលរមែង ទទួលរងនូវ ជរា និងព្យាធិ មិនអាចគេចផុតឡើយ ហើយដែលឃ្លាក្នុងច្បាប់ធម្មជាតិមិនបានរៀបរាប់ប៉ុណ្ណោះ។ ប៉ុន្តែទាំងពីរនេះពិតជាសច្ចៈ ជាសេចក្តីត្រូវ ជាច្បាប់ដែលមានស្រេចស្រាប់ រកពេលចាប់ផ្តើម និងពេលបញ្ចប់មិនបានឡើយ ។

២. ច្បាប់ចងក្រង Conventional Law : អ្វីៗជាកំណត់លើសេចក្តីព្រមព្រៀងនៃមនុស្សភាគច្រើនដោយផ្ទាល់ក្តី ដោយមានអ្នកតំណាងក្តីដែលសំរេចឡើង ដើម្បីសេចក្តីសុខដុមរមនានៃបុគ្គលម្នាក់ គ្រួសារមួយ សង្គមមួយ ជាតិមួយ រហូតដល់មនុស្សជាតិទូទាំងពិភពលោកនោះ ហៅថា ច្បាប់ ។ ច្បាប់ប្រភេទនេះ ប្រសិនជាល្អវិសេសវិសាលណាស់ គ្រាន់តែបានយូរប៉ុណ្ណោះមិនអាចស្ថិតស្ថេរជាសច្ចៈបានទេ រមែងប្រែប្រួលថែមថយ ឬផ្លាស់ប្តូរតាមកាលៈទេសៈតាមបរិយាកាស តាមព្រឹត្តិការណ៍ តាមស្ថានភាព តាមការវិវត្តន៍នៃការបដិវត្តន៍ តាមរបបនយោបាយ...។ល។ ជាទូទៅច្បាប់ប្រភេទនេះច្រើនកើតឡើង និងប្រើប្រាស់ក្រោមឥទ្ធិពលនៃអំណាច៣គឺ : អំណាចនីតិបញ្ញត្តិ (រដ្ឋសភា) អំណាចនីតិប្រត្តិបត្តិ (រដ្ឋាភិបាល) និងអំណាចតុលាការ (អង្គចៅក្រម) ។ ច្បាប់ដែលជាកំពូល ជាប្រភព ឬជាវិន័យ បទបញ្ជាផ្ទៃក្នុង ។ល។ សុទ្ធសឹងជាច្បាប់ ជាមែកធាង ឬសាខានៃច្បាប់ ។ មានច្បាប់ចងក្រង ឬតាក់តែងមួយផ្នែកទៀត ដែលជាប់ជាប្រពៃណី ឬទំនៀមទំលាប់ ។ ឧទាហរណ៍ : ប្រពៃណីរៀបអាពាហ៍ពិពាហ៍ ច្បាប់ស្រី ច្បាប់បណ្តាំឪពុក ច្បាប់កេរ្តិ៍កាល ។ល។ ច្បាប់តាក់តែងទាំងឡាយរមែងនៅក្នុងទម្រង់ធំៗពីរគឺ : ច្បាប់ក្នុងទម្រង់ផ្តាច់ការ ច្បាប់ក្នុងទម្រង់ប្រជាធិបតេយ្យ ។

- ច្បាប់ក្នុងទម្រង់ផ្តាច់ការ : - ច្បាប់នេះចេញពីសេចក្តីសម្រេចនៃមនុស្សម្នាក់ (Monarchy) ឬមនុស្សមួយចំនួនតូច(Oligarchy) ជាច្បាប់ដែលលុះក្នុងបំណងរក្សាអំណាច ប្រើអំណាចនិងបំបាក់ស្មារតីប្រជាពលរដ្ឋ ។ ក្នុងរបបដែលប្រើច្បាប់ប្រភេទនេះ ទោះរបបកុម្មុយនីស្តក្តី របបរាជានិយមក្តី គេមិនត្រូវការឲ្យមន្ត្រី និងប្រជារាស្ត្រចេះច្រើនទេ ឬក៏គេត្រូវការកំទេចអ្នកចេះដឹងចោល ។ និយាយម្យ៉ាងទៀតថាជាច្បាប់

ប្រើប្រជាពលរដ្ឋ ។ ប្រទេសកម្ពុជា និងប្រជាពលរដ្ឋខ្មែរ រស់ក្រោមអំណាចនៃច្បាប់នេះអស់ពេលជាច្រើនសតវត្សមកហើយ ។

- ច្បាប់ក្នុងទម្រង់ប្រជាធិបតេយ្យ : - ដូចបាននិយាយក្នុងជំពូក «ក» ខ្លះរួចមកហើយ ។ ច្បាប់ប្រភេទនេះចេញពីសេចក្ដីសម្រេចនៃមនុស្សភាគច្រើនដាច់ខាត ។ ជាច្បាប់នៃរដ្ឋាភិបាលរបស់ប្រជាពលរដ្ឋ និងដើម្បីប្រជាពលរដ្ឋ ។ និយាយម្យ៉ាងទៀតថា ជាច្បាប់បំរើប្រជាពលរដ្ឋតាមមធ្យោបាយបង្រៀនឲ្យចេះរស់ និងទទួលខុសត្រូវលើការរស់រាន និងរីកចំរើននៃជីវិតរបស់ប្រជាពលរដ្ឋគ្រប់ៗរូប ។ សហរដ្ឋអាមេរិក និងប្រជាពលរដ្ឋអាមេរិកកាំងរស់ក្រោមច្បាប់នេះជាងពីររយឆ្នាំហើយ ។

ខ-កំណើតនៃច្បាប់ : - (មិននិយាយពីច្បាប់ធម្មជាតិ) បើតាមបំណងជាសកលនិយមដែលបង្កើតឡើងដើម្បីភាពសុខដុមរមនានៃមនុស្សនោះ ច្បាប់កើតចេញពីស្នាដៃតំណាងរាស្ត្រ «រដ្ឋសភា» ដោយយោងលើបាតុភាពទំនាស់ និងបញ្ហាក្នុងសង្គមមនុស្ស ។ ឧទាហរណ៍ : ច្បាប់ភូមិបាលក្រោយពីមានបាតុភាពទំនាស់លើរឿងកម្មសិទ្ធិ និងបញ្ហាកម្មសិទ្ធិកាន់តែច្រើនឡើង ។ ដូច្នេះយើងអាចនិយាយបានថា ប្រភពនៃច្បាប់ គឺបទល្មើស និងបាតុភាពអាក្រក់ៗ ។ បានសេចក្ដីថា បើគ្មានបទល្មើស និងបាតុភាពអាក្រក់ក្នុងសង្គមមនុស្សទេ នឹងគ្មានច្បាប់តាក់តែងនេះឡើយ ។ នេះជាកំណើតនៃច្បាប់ក្នុងទម្រង់ប្រជាធិបតេយ្យ ។

គ- ប្រយោជន៍នៃច្បាប់ : - និយាយពីច្បាប់ធម្មជាតិដែលជាច្បាប់ស្រេចស្រាប់ អត់មានយោង ឬអាស្រ័យលើអ្វីសោះនោះ យើងបានដឹងរួចមកហើយថា ច្បាប់នេះជាសច្ចភាព ដែលគង់វង្សជាអមតៈ ហើយជាប្រភពនៃច្បាប់ នៃទស្សនៈ នៃទ្រឹស្ដី និងនៃសាសនាដ៏មានតម្លៃទាំងឡាយ ។ ច្បាប់ធម្មជាតិ ក៏ដូចជាធម្មជាតិទាំងអស់ដែលមានសម្រាប់ទ្រទ្រង់ជីវិត ។ ប៉ុន្តែបើជីវិតបានយល់ដឹង ឬមិនយល់ដឹង ចេះប្រើ ឬមិនចេះប្រើប្រយោជន៍ក៏គោងអាស្រ័យលើសមត្ថភាពនៃជីវិតនោះឯង ។

- និយាយពីច្បាប់តាក់តែងដែលជាស្នាដៃមនុស្ស យើងក៏បានដឹងរួចមកហើយថា បង្កើតឡើងដើម្បីភាពសុខដុមរមនានៃជីវិត ។ ប៉ុន្តែដោយច្បាប់ប្រភេទនេះជាច្បាប់ដែលសម្រេចយោង ឬអាស្រ័យលើអ្វីៗទៀតនោះ ជួនកាលច្បាប់នេះមិនគ្រាន់តែគ្មានប្រយោជន៍ដល់ជីវិតទេ ថែមទាំងបំផ្លាញប្រយោជន៍ក៏សឹងមាន ។ ដូច្នេះទើបការយល់ដឹងអំពីច្បាប់ និងការបកស្រាយនៃច្បាប់ជាការចាំបាច់ពេកណាស់សម្រាប់មនុស្សគ្រប់រូបក្នុងដំណើរកសាងសេចក្ដីសុខសាន្តផ្ទាល់ខ្លួនក្ដី ដើម្បីគ្រួសារ សង្គម ជាតិ មាតុភូមិក្ដី ។

ឃ- គ្រោះថ្នាក់នៃច្បាប់ : ទោះបីយើងជាខ្មែរក្នុងមាតុភូមិកម្ពុជាមិនសូវបានទទួលរងគ្រោះធម្មជាតិក៏ដោយ ក៏យើងរមែងបានដឹងឮគ្រប់ៗគ្នាអំពីគ្រោះថ្នាក់ប្រភេទនេះ នៅក្នុងពិភពលោក ដែលមាន

កន្លែងខ្លះញ៉ាំកញ្ចាប់ ហើយធ្ងន់ធ្ងរទៀត ដូចជាការរញ្ជួយផែនដី ខ្យល់ព្យុះ ទឹកជំនន់ រាំងស្ងួត ក្ដៅពេក ត្រជាក់ពេក...។ល។ បាតុភាពគួរឲ្យរន្ធត់ តក់ស្លុតទាំងឡាយនេះ យើងអាចស្ដីបន្ទោសធម្មជាតិ ក៏មិនជាការខុសឆ្គងអ្វីដែរ ។ ប៉ុន្តែសេចក្ដីឈឺចាប់ពីគ្រោះថ្នាក់ប្រភេទនេះ នឹងរលត់បាត់ពីអារម្មណ៍ ឬដួងចិត្តយើងរាល់គ្នាក្នុងរយៈពេលមិនយូរឡើយ ។

# អំពីវិទ្យាស្ថាន

- **បាវចនាវិទ្យាស្ថាន** *(Motto)*
  សិទ្ធិមនុស្សដើម្បីសន្តិភាព និងការផ្សះផ្សាជាតិ
  Human Rights for Peace and National Reconciliation
  (សន្តិភាព, អហិង្សា, ការអត់ឱនគ្នា និងគោរពគ្នាទៅវិញទៅមក)

- **ជំនឿរបស់វិទ្យាស្ថាន** *(Conviction)*
  សិទ្ធិមនុស្សមានដំណើរការបាន អាស្រ័យដោយទំនាក់ទំនងល្អរវាងមនុស្ស និងមនុស្ស
  Human Rights Start with Human Relations

- **គោលជំហរវិទ្យាស្ថាន** *(Stance)*
  សហប្រតិបត្តិការ និងលើកកម្ពស់កិត្យានុភាពជាតិ
  Cooperation and Promotion of National Dignity

---

# សេចក្តីថ្លែងការណ៍ជាសាកល

សង្ខេបតាមមាត្រា

មាត្រា១ : មនុស្សរាល់រូបមានតម្លៃស្មើៗគ្នា

មាត្រា២ : ត្រូវចាត់ទុកមនុស្សគ្រប់រូបឲ្យបានស្មើៗគ្នា

មាត្រា៣ : សិទ្ធិមានជីវិតរស់នៅ

មាត្រា៤ : សិទ្ធិការពារមិនឲ្យគេយកទៅធ្វើជាខ្ញុំកញ្ជះ

មាត្រា៥ : សិទ្ធិមិនឲ្យមានទារុណកម្មមកលើខ្លួន

មាត្រា៦ : សិទ្ធិឲ្យគេទទួលស្គាល់ខ្លួនជាមនុស្ស

មាត្រា៧ : សិទ្ធិស្មើគ្នាចំពោះមុខច្បាប់

មាត្រា៨ : សិទ្ធិសុំឲ្យច្បាប់ការពារខ្លួន

មាត្រា៩ : សិទ្ធិមានសេរីភាព

មាត្រា១០ : សិទ្ធិឲ្យមានការកាត់ក្តីត្រឹមត្រូវ

មាត្រា១១ : សិទ្ធិទទួលការកាត់ទោសសមស្របតាមច្បាប់

មាត្រា១២ : សិទ្ធិការពារជីវភាពឯកជនរបស់ខ្លួន

មាត្រា១៣ : សិទ្ធិធ្វើដំណើរទៅមកដោយសេរី

មាត្រា១៤ : សិទ្ធិទៅសុំការជ្រកកោននៅប្រទេសក្រៅ

មាត្រា១៥ : សិទ្ធិមានសញ្ជាតិមួយ

មាត្រា១៦ : សិទ្ធិរៀបចំគូស្រករ និងមានគ្រួសារ

មាត្រា១៧ : សិទ្ធិមានសម្បត្តិកម្មសិទ្ធិ

មាត្រា១៨ : សិទ្ធិមានជំនឿដោយសេរី

មាត្រា១៩ : សិទ្ធិនិយាយស្តី ឬសំដែងមតិដោយសេរី

មាត្រា២០ : សិទ្ធិរួមប្រជុំដោយសេរី

មាត្រា២១ : សិទ្ធិរួមចំណែកក្នុងសកម្មភាពនយោបាយ

មាត្រា២២ : សិទ្ធិមាននីរភ័យសង្គម

មាត្រា២៣ : សិទ្ធិមានការងារធ្វើ

មាត្រា២៤ : សិទ្ធិមានការសម្រាក និងកំសាន្តកាយ

មាត្រា២៥ : សិទ្ធិមានជីវភាពរស់នៅសមរម្យ

មាត្រា២៦ : សិទ្ធិមានការអប់រំ

មាត្រា២៧ : សិទ្ធិទទួលផលក្នុងជីវភាពវប្បធម៌ និងរក្សាសិទ្ធិ

មាត្រា២៨ : សិទ្ធិឲ្យមានច្បាប់ការពារសិទ្ធិរបស់ខ្លួន

មាត្រា២៩ : កាតព្វកិច្ចចំពោះសហគមន៍ និងគោរពសិទ្ធិអ្នកដទៃ

មាត្រា៣០ : កាតព្វកិច្ចការពារខ្លឹមសារនៃសេចក្តីថ្លែងការណ៍នេះ

# សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស (វិភាគ)

- មាន៣០មាត្រា
- ចែកចេញជាបីក្រុម

១. មាត្រា ១-២១ : ស្តីអំពី

ការគ្រប់គ្រងត្រឹមត្រូវ, ការធានាឲ្យមានការគោរពសិទ្ធិនិងសេរីភាពរបស់មនុស្សគ្រប់គ្នា

២. មាត្រា ២២-២៧ : ស្តីអំពី

សិទ្ធិមានការអប់រំ, មានអាហារ, មានសន្តិសុខនៅក្នុងសហគមន៍

៣. មាត្រា ២៨-៣០ : ស្តីអំពី

កាតព្វកិច្ចរបស់មនុស្ស

---

សិទ្ធិមនុស្ស → **មនុស្ស** → អ្នកណាក៏មនុស្ស → ដូចៗគ្នា

មិនរើសអើង :

- ភេទ
- ពណ៌សម្បុរ
- សញ្ជាតិ
- ឋានៈ
- វណ្ណៈសង្គម
- ដើមកំណើត
- សាសនា
- មតិនយោបាយ

។ល។ និង ។ល។

FILENAME \p D:\CIHR-W6\LESS-GG\HR-Demo1.doc

## គោរពសិទ្ធិមនុស្ស

↓

## នយោបាយទ្រទ្រង់សេរីភាព

↓

## សេដ្ឋកិច្ចនិងសង្គមរីកចម្រើន

↓

## គ្រឹះនៃសន្តិភាពរឹងមាំ

---

## បទដ្ឋានអប្បបរមានៃការប្រតិបត្តិសិទ្ធិមនុស្ស
STANDARD MINIMUM REQUIREMENT FOR HUMAN RIGHTS

១_ ត្រូវមានច្បាប់ល្អ និងសណ្តាប់ធ្នាប់ល្អ ( Good Law and Order )

២_ ត្រូវតែដាក់ទណ្ឌកម្មជនល្មើស (មិនត្រូវមាននិរទណ្ឌភាព) ( No impunity )

៣_ ត្រូវមានការទទួលខុសត្រូវពេញលេញ ( Full accountability )

៤_ ត្រូវមានគោលនយោបាយទ្រទ្រង់សេរីភាពគ្រប់បែបយ៉ាង (រួមទាំងសេរីភាពសម្តែងមតិផង)
Policy to uphold all FREEDOMS ( including Freedom of Expressions )

៥_ ស្មើភាពចំពោះមុខច្បាប់ ( Equality before the Law )

---

## សិទ្ធិមនុស្ស : តាមបែបព្រះពុទ្ធសាសនា

លើកស្ទួយ_ការពារនិងគោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស

PROMOTE, PROTECT AND RESPECT FOR HUMAN DIGNITY

### <u>បម្រាមព្រះពុទ្ធបរមគ្រូ</u>

មនុស្សមិនត្រូវមាន :

- លោភៈ (Greed) (លោភលន់ចង់បានអ្វីៗដោយគ្មានការខ្មាសអៀន)

- **ទោសៈ** (Anger) (ប្រទូស្តខឹងគុំគួនស្អប់អ្នកដែលមានគំនិតខុសពីខ្លួន)
- **មោហៈ** (Ignorance) (យល់ខ្មៅជាស ល្អជាអាក្រក់ ,វង្វេងគ្មានដឹងការពិត)

**<u>បណ្តាំព្រះពុទ្ធបរមគ្រូ</u>** (**ព្រហ្មវិហារធម៌ទាំង៤**)

មនុស្សត្រូវមាន :

- **មេត្តា** (Loving-kindness) : ស្រឡាញ់រាប់អានគ្នាដោយស្មោះទៅវិញទៅមក
- **ករុណា** (Compassion) : អាណិតអាសូរអ្នកមានទុក្ខ
- **មុទិតា** (Sympathetic Joy) : ត្រេកអរចំពោះសេចក្តីសុខចំរើនរបស់អ្នកដទៃ
- **ឧបេក្ខា** (Equanimity) : ធ្វើចិត្តជាកណ្តាល មិនលំអៀង

<u>គឺមិនត្រូវមានអគតិទាំង៤</u> : លំអៀងទាំង៤ប្រការ

- ឆន្ទាគតិ : លំអៀងព្រោះស្រឡាញ់
- ទោសាគតិ : លំអៀងព្រោះស្អប់
- មោហាគតិ : លំអៀងព្រោះមិនចេះ-មិនយល់
- ភយាគតិ : លំអៀងព្រោះខ្លាច-ភ័យ

---

## <u>និយមន័យ</u> : សិទ្ធិមនុស្ស

◆ បែបច្បាប់អន្តរជាតិ :

ខ្នាតគំរូអន្តរជាតិ តម្រូវឲ្យរដ្ឋាភិបាលបំពេញការកិច្ចជាចាំបាច់សម្រាប់ប្រយោជន៍រាស្ត្រ និងហាមអាជ្ញាធរមិនឲ្យប្រព្រឹត្តនូវអ្វីៗដែលប៉ះពាល់ដល់រាស្ត្រ ។

◆ របស់វិទ្យាស្ថាន :

អ្វីៗទាំងអស់ដែលមនុស្សត្រូវការចាំបាច់សម្រាប់រស់ក្នុងសេចក្តីថ្លៃថ្នូរជាមនុស្ស (ពោលគឺសិទ្ធិជាមូលដ្ឋានត្រឹះចម្បង៣)

◆ បែបព្រះពុទ្ធសាសនា :

ប្រតិបត្តិ<u>សីលធម៌</u>ជានិច្ច

# សិទ្ធិជាមូលដ្ឋានគ្រឹះចម្បង៣

១. ជិវិត (Life) (មិនត្រូវបំផ្លាញជីវិត , ហើយត្រូវធ្វើអ្វីៗទាំងអស់សម្រាប់ទ្រទ្រង់ជីវិត) ។

២. សេរីភាព (Liberty) (សព្វបែបយ៉ាង) ។

៣. សុភមង្គល (Happiness) (ត្រូវស្វះស្វែងរកសន្តិភាពទាំងផ្លូវកាយ-ទាំងផ្លូវចិត្ត - ប្រកាន់ខ្ជាប់នូវអហិង្សា-អភិវឌ្ឍន៍សព្វបែបយ៉ាង គឺអភិវឌ្ឍន៍សេដ្ឋកិច្ច -អភិវឌ្ឍន៍សង្គម និងអភិវឌ្ឍន៍ធនធានមនុស្ស) ។

## សីលធម៌ គឺ ៖

**សីល + ធម៌**

| ↙ | ↘ |
|---|---|
| មិនធ្វើអាក្រក់ | ធ្វើតែល្អ |
| (ហាមធ្វើអំពើទុច្ចរិត) | (ខំសាងសុចរិត) |

(ទាំងកាយ_វាចា_ចិត្ត)

---

# សីលធម៌សិទ្ធិមនុស្សក្នុងព្រះពុទ្ធសាសនា

**ព្រះពុទ្ធបរមគ្រូ** : បានហាមមិនឱ្យប្រព្រឹត្តអាក្រក់ទាំងកាយ_វាចា_ចិត្ត. ពោលគឺ កុំប្រព្រឹត្តនូវកម្មទាំង១០ រួមមាន ៖

**កាយកម្ម៣** : (ដោយអំពើ)

- មិនត្រូវបំផ្លាញជីវិត (មនុស្ស - សត្វ - រុក្ខជាតិ)
- មិនត្រូវលួច
- មិនត្រូវប្រព្រឹត្តអំពើរំលោភនានា

**វចីកម្ម៤** : (ដោយវាចា)

- មិនត្រូវភូតកុហក
- មិនត្រូវនិយាយញុះញង់ឲ្យគេបែកបាក់ប្រេះឆា
- មិនត្រូវនិយាយទ្រគោះបោះបោកឲ្យកើតការក្រេវក្រោធ
- មិនត្រូវនិយាយពាក្យមិនបានការ

**មនោកម្ម៣** : (ដោយចិត្ត)

- មិនត្រូវសម្លឹងរំពៃចង់បានទ្រព្យគេ
- មិនត្រូវគុំគួនចងអាឃាតព្យាបាទគេ
- មិនត្រូវមានគំនិតយល់ខ្មៅជាស ល្អជាអាក្រក់

---

# ប្រៀបធៀបការប្រតិបត្តិសីល៥ និង សិទ្ធិមនុស្ស

**បាណាតិបាត** (*No Killing*)

(ហាមបំផ្លាញជីវិតមនុស្ស - សត្វ - រុក្ខជាតិ )

⇨ សិទ្ធិមានជីវិតរស់នៅ

⇨ សិទ្ធិមិនឲ្យគេយកធ្វើជាខ្ញុំកញ្ជះ

⇨ សិទ្ធិមិនឲ្យមានទារុណកម្ម (ផ្លូវកាយ-ផ្លូវចិត្ត)

⇨ សិទ្ធិមានសន្តិសុខផ្ទាល់ខ្លួន (មានច្បាប់ការពារបុគ្គល)

⇨ សិទ្ធិរស់នៅក្នុងបរិស្ថានសមស្រប

**អទិន្នាទាន** (*No Stealing*)

(ហាមកាន់យកទ្រព្យ ដែលគេមិនបានឲ្យដោយកាយ ឬវាចា«ហាមលួច»)

⇨ សិទ្ធិមានសម្បត្តិកម្មសិទ្ធិ

⇨ សិទ្ធិការពារជីវភាពឯកជន

⇨ សិទ្ធិមានសន្តិសុខសង្គម (មានច្បាប់ការពារសង្គម)

**កាមេសុមិច្ឆាចារ** *(No Sexual misconduct)*

(ហាមប្រព្រឹត្តរំលោភក្នុងកាមប្បវេណី«ប្រពន្ធ កូនអ្នកដទៃ»)

⇨ សិទ្ធិមានសន្តិសុខក្នុងគ្រួសារ និងក្នុងសង្គម

⇨ សិទ្ធិឲ្យគេទទួលស្គាល់ខ្លួនជាមនុស្ស

⇨ សិទ្ធិមានសេចក្តីថ្លៃថ្នូរ

⇨ សិទ្ធិមានគូស្រករ និងមានគ្រួសារ

⇨ សិទ្ធិលើកម្មសិទ្ធិគូគ្រង (ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ)

**មុសាវាទ** *(No Lying)*

(ហាមពោលពាក្យមិនពិត - ទ្រគោះបោះបោក, ប្រទេចផ្តាសា
- ញុះញង់ សិកសៀត
- ពាក្យឥតប្រយោជន៍)

⇨ សិទ្ធិមានកិត្តិយសនិងសេចក្តីថ្លៃថ្នូរ

⇨ សិទ្ធិមានការជំរះក្តីដោយយុត្តិធម៌

⇨ សិទ្ធិទទួលបាននូវពត៌មានពិតប្រាកដ

**សុរាមេរយ** *(No Alcohol or Drugs)*

(ហាមគ្រេបផឹកទឹកស្រវឹង និងគ្រឿងញៀនគ្រប់ប្រភេទ)

⇨ សិទ្ធិមានសុខភាពផ្ទាល់ខ្លួន

⇨ សិទ្ធិការពារសិទ្ធិរបស់ខ្លួន

⇨ សិទ្ធិមានសេចក្តីថ្លៃថ្នូរប្រចាំកាយ

## គោលការណ៍ព្រះពុទ្ធសាសនាក្នុងវិស័យសិទ្ធិមនុស្ស

១. គោរព និងការពារមនុស្សជាតិ

២. គិតត្រូវ - និយាយស្តីត្រូវ - ធ្វើត្រូវ - បានលទ្ធផលល្អ

៣. បំបាត់អំពើហិង្សា និងការឃោរឃៅ ដែលជាមូលហេតុបំផ្លាញសេរីភាព និងសុភមង្គលរបស់មនុស្ស

៤. ចេះការពារខ្លួនឯង និងការពារអ្នកដទៃ ជួយទប់ស្កាត់ការឈឺចាប់ និងការស្អប់ខ្ពើមគ្នា

---

## ខ្លឹមសារសង្ខេបនៃធម៌ជយន្តោ

១_ ស្រឡាញ់ (ត្រូវចេះស្រឡាញ់រាប់អានគ្នា)

២_ អាណិត (ត្រូវមានចិត្តអាណិតអាសូរគ្នា)

៣_ ចេះជួយគ្នា (ត្រូវចេះជួយគ្នាទៅវិញទៅមក)

៤_ ធ្វើតែល្អ (កាយ-វាចា-ចិត្ត)

៥_ ចេះត្រេកអរ (ចំពោះសេចក្តីសុខចំរើនរបស់អ្នកដទៃ)

* **អ្នកណាប្រតិបត្តិតាមបាន អ្នកនោះនឹងប្រកបដោយ<u>អត្ថប្រយោជន៍</u> និង<u>សេចក្តីសុខចម្រើន</u>**

# អត្ថន័យពិស្ដារនៃធម៌ជយន្តោ

សូមឲ្យមនុស្សទាំងអស់ស្រឡាញ់រាប់អាន និងអាណិតអាសូរគ្នា ហើយចេះជួយគ្នាទៅវិញទៅមកដោយការធ្វើតែអំពើល្អ ហើយចេះត្រេកអរដល់សត្វលោកទាំងអស់គ្នា ។

ព្រះសម្មាសម្ពុទ្ធបង្រៀនយើងថា ពេលណាដែលយើងធ្វើអំពើល្អ ដោយកាយ វាចា ចិត្ត ពេលនោះហើយ ឈ្មោះថាជានក្ខត្តឫក្សល្អ ជាមង្គលល្អ ជាពេលភ្លឺស្វាងល្អ ជាអរុណរះល្អ ជាខណៈល្អ ជាយាមល្អ ។ អំពើល្អដែលយើងធ្វើតែងនាំមកនូវអត្ថប្រយោជន៍ និងសេចក្ដីសុខដល់សត្វលោកទាំងអស់គ្នា ។

### The Meaning of the Venerable monks Recitation

May all human beings have loving kindness & Compassion and help each other in doing good actions and be happy with their good actions, because good actions provide happiness to all beings.

The Lord Buddha teaches us : " In all circumstances, each time our corporal, verbal and mental actions are good, this is the highest blessing, and auspicious time, moments and instants. And good actions always produce good results for the well-beings, the advantages and happiness for all of us and for all beings. "

### Le sens de la Récitation de nos vénérables moines

Que tous les êtres aient l ' amour bienveillant, la compassion et aident les uns les autres, en accomplissant de bonnes actions et savent se contenter de leurs bonnes actions, car les bonnes actions procurent le bonheur pour tous les êtres.

Le Bouddha nous enseigne que : " En toutes Circonstances, chaque fois que nos actions corporelles, verbales et mentales sont bonnes, cela est une grande bénédiction, une bonne augure, un temps béni, éclairé, des bon moments et instants. Et nos bonnes actions apportent toujours des résultats bienfaisants pour le bien, les avantages et le bonheur à tous les êtres. "

ប្រែសម្រួលពីភាសាបាលីដោយ
ព្រះភិក្ខុ យស ហ៊ុត ខេមចារោ

# សិទ្ធិមនុស្សមានពីរប្រភេទ

ក. សិទ្ធិសំរាប់មនុស្សម្នាក់ៗ : **សិទ្ធិបុគ្គល**

ខ. សិទ្ធិសំរាប់មនុស្សច្រើននាក់រួមគ្នា : **សិទ្ធិសាធារណៈ**

(ចុះបើសិទ្ធិទាំងពីរនេះប៉ះទង្គិចគ្នា តើសិទ្ធិណាមានទម្ងន់ជាង?)

ចម្លើយ : សិទ្ធិសាធារណៈមានទម្ងន់ជាង

---

# ការរំលោភសិទ្ធិមានពីរប្រភេទ

ក. រំលោភដោយមិនបានបំពេញតាមកាតព្វកិច្ចដែលត្រូវធ្វើជូនសាធារណជន

ខ. រំលោភដោយការប្រព្រឹត្តិ , អំពើ (គឺការប្រព្រឹត្តិហួសក្របខ័ណ្ឌ ឬការប្រើច្បាប់ដោយរំលោភ)

---




ត្រូវយល់ដឹងពីសិទ្ធិផង និង ករណីយកិច្ចផង នេះគឺដើម្បីតុល្យភាពនៃចំណេះដឹង




ប្រើសិទ្ធិត្រូវមានការទទួលខុសត្រូវជានិច្ច




ពលរដ្ឋត្រូវមានកាតព្វកិច្ចធំៗចំពោះសង្គមជាតិ



ច្បាប់ និង សិទ្ធិ ត្រូវមានសន្តានុពលពេញលេញដូចគ្នា

# ភារកិច្ចចម្បងរបស់ពលរដ្ឋ

(គោរព និងការពារច្បាប់)

ក. គោរពប្រតិបត្តិតាមច្បាប់ និងអនុវត្តច្បាប់

ធ្វើអ្វីៗទាំងអស់ត្រូវតាមលំនាំច្បាប់ជានិច្ច

ខ. ការពារកុំឲ្យមានការរំលោភច្បាប់

១. យល់ដឹងឲ្យច្បាស់អំពីច្បាប់ ដើម្បីជៀសវាងការបំពានច្បាប់
២. ជួយពន្យល់គេឯងឲ្យយល់ដឹងច្បាស់ពីច្បាប់
៣. ណែនាំកុំឲ្យមនុស្សបំពានច្បាប់
៤. ជួយកសាងយន្តការសម្រាប់ទប់ស្កាត់ការរំលោភច្បាប់
៥. រាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ច បើមានការរំលោភច្បាប់

---

# សិទ្ធិ ⇔ ច្បាប់

*អ្វីដែលមនុស្ស ត្រូវតែមានជាចាំបាច់ សម្រាប់រស់ក្នុងសេចក្តីថ្លៃថ្នូរជាមនុស្ស ។*

*អ្វីដែលមនុស្ស ត្រូវតែគោរពជាដាច់ខាត ដើម្បីរស់កើតជាមួយគេឯងក្នុងសង្គមមនុស្ស ។*

**សិទ្ធិ** និង **ច្បាប់** ត្រូវការគ្នាទៅវិញទៅមកជានិច្ច ដើម្បីឲ្យសង្គមមានដំណើរល្អ ។ នេះប្រៀបបានទៅនឹងរទេះគោដែលត្រូវតែឲ្យមានគោមួយនឹមទើបដំណើរការបានល្អ ។

FILENAME \p D \CIHR-W6\LESS-GG\HR-Demo1.doc



# ទំនាក់ទំនងរវាងសិទ្ធិ និង ច្បាប់

# សិទ្ធិ

# កិច្ចការចម្បងក្នុងវិស័យសិទ្ធិមនុស្ស

(MAJOR TASKS)

- អប់រំ - បណ្តុះបណ្តាល
  EDUCATION - TRAINING
- ឃ្លាំមើល ប្រមូលផ្តុំឯកសារ និងផ្សព្វផ្សាយពត៌មាន
  MONITORING DOCUMENTATION & INFORMATION
- សេវាផ្នែកច្បាប់ និងពិនិត្យពន្ធនាគារ
  LEGAL SERVICES & PRISON VISIT
- ជំនួយឧបត្ថម្ភផ្ទាល់
  DIRECT ASSISTANCE
- គាំទ្រ (ខ្លាំង)
  ADVOCACY

---

## កិច្ចការដែលអ្នកការពារក្តីត្រូវធ្វើ

↓

## ពង្រឹងយុត្តិធម៌

ក. ជនល្មើស*ត្រូវតែមានទោសតាមច្បាប់* (មិនត្រូវឲ្យរួចផុតពីទោសទណ្ឌកម្មជាដាច់ខាត)

ខ. ជនគ្មានកំហុស*ត្រូវដោះលែង* (មិនត្រូវដាក់ទណ្ឌកម្មជាដាច់ខាត)

# ពិនិត្យពន្ធនាគារ

១. គ្មានទារុណកម្ម

២. មានអាហារល្មមរស់បាន

៣. កន្លែងដេកនៅសមរម្យ , មានពន្លឺ, ស្អាត

៤. មានសេវាសុខភាព

៥. ក, អ្នកទោសស្ត្រី : នៅដោយឡែកពីបុរស ហើយមានតែឆ្មាំស្រីគ្រប់គ្រង

ខ, អ្នកទោសកុមារ : នៅដោយឡែកពីអ្នកទោសពេញវ័យ ហើយត្រូវមានកម្មវិធីអប់រំណែនាំ

---

# ជាតិខ្មែរមានវប្បធម៌ថ្លៃថ្នូរ គឺការគោរពគ្នាទៅវិញទៅមក

Culture Respect

គោរពសេចក្តីថ្លៃថ្នូរទៅវិញទៅមកតាមការប្រតិបត្តិ៣ប្រការ

## ១_ សុំទោស

គឺ មានមោទនភាពនឹងទទួលកំហុស , កែលំអខ្លួន

## ២_ អរគុណ

គឺ ទទួលស្គាល់មោទនភាពដោយចេះសំដែងអំណរ

## ៣_ សរសើរ

គឺ ផ្តល់មោទនភាព តាមការលើកទឹកចិត្តអ្នកធ្វើល្អ , ធ្វើត្រូវ

# លទ្ធិប្រជាធិបតេយ្យ



**ឯកឧត្តម ស ខេង**

ឧបនាយករដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

*នៅក្នុងរដ្ឋកុម្មុយនីស្តដែលមានបក្សតែមួយ បក្សត្រួតត្រាលើអំណាចទាំងអស់ ។ បក្សជាម្ចាស់កងទ័ព.ម្ចាស់នគរបាល និងម្ចាស់អំណាច ។ ប៉ុន្តែនៅក្នុងក្របខ័ណ្ឌនៃលទ្ធិប្រជាធិបតេយ្យ កងទ័ពជារបស់ជាតិទាំងមូល នគរបាលក៏ជារបស់ជាតិទាំងមូល ហើយរដ្ឋាភិបាលក៏ជារដ្ឋាភិបាលរបស់ជាតិដែរ ។*

*( បទសម្ភាសន៍ក្នុងសារពត៌មានភ្នំពេញបុស្តិ៍)*

In a communist state with a single party, the party controls all power . The party has army, police and power . But in the framework of democracy, **the army belongs to the entire nation, so do the police and the government.**

*(Phnom penh Post, April 18 May 1, 1997)*

---

## ប្រជាធិបតេយ្យមាន៣បែប :

១_ **របបប្រធានាធិបតីនិយម** (មានតែប្រធានាធិបតី. គ្មាននាយករដ្ឋមន្ត្រីទេ)
ដូចប្រទេសអាមេរិក. ប្រទេសហ្វីលីពីន (អំណាចសភានិងរដ្ឋាភិបាលដាច់ពីគ្នា)

២_ **របបសភានិយម** (មានតែនាយករដ្ឋមន្ត្រី. គ្មានប្រធានាធិបតីទេ)
ដូចប្រទេសអង់គ្លេស និងអូស្ត្រាលី (អំណាចសភានិងរដ្ឋាភិបាលរួមគ្នា)

៣_ **របបចម្រុះ** (ប្រធានាធិបតីនិយមផង_សភានិយមផង)
ដូចប្រទេសបារាំង . ប្រទេសរុស្ស៊ី . ប្រទេសចិនដីគោក . ប្រទេសឥណ្ឌា
(មានប្រធានាធិបតីផង និងមាននាយករដ្ឋមន្ត្រីផង)

# លទ្ធិប្រជាធិបតេយ្យកម្រិតទាបបំផុត

ត្រូវមានអ្វីខ្លះយ៉ាងតិច ?

១. រដ្ឋធម្មនុញ្ញ

២. សារពត៌មានសេរី និងឯករាជ្យ

៣. ឯករាជភាពនៃអង្គចៅក្រម

៤. សម្លេងជំទាស់ក្នុងសភា (តំណាងឲ្យសំឡេងភាគតិច)

---

# ឯករាជភាពនៃអង្គចៅក្រម



ឯកឧត្តម ចែម ស្នួន
ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

*រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋាភិបាល និងអំណាចនីតិបញ្ញត្តិ ពុំមានសិទ្ធិចូលរួមនៅក្នុងសេចក្តីសម្រេចរបស់តុលាការឡើយ ។ តុលាការមានបីកម្រិត ហើយកម្រិតនីមួយៗស្ថិតនៅឯករាជ្យដោយខ្លួនឯង ។ បើសិនជាទណ្ឌិតណាមិនយល់ស្របនឹងសេចក្តីសម្រេចរបស់តុលាការ គេអាចស្នើសុំទៅសាលាឧទ្ធរណ៍ដើម្បីពិនិត្យលើសេចក្តីសម្រេចនោះ ។ បើសិនជាគេមិនយល់ស្របតាមសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ គេអាចស្នើសុំទៅតុលាការកំពូលដើម្បីសើបពិនិត្យមើលសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ។*

*ក្រសួងយុត្តិធម៌របស់យើងឃ្លាំមើលពីចម្ងាយលើបទបញ្ញត្តិច្បាប់ដែលតុលាការអនុវត្ត ហើយយើងត្រួតពិនិត្យលើការអនុវត្តបទបញ្ញត្តិទាំងនេះ ដើម្បីឱ្យដឹងថាតើត្រឹមត្រូវ ឬមិនត្រឹមត្រូវ ។*

(បទសម្ភាសន៍ក្នុងសារពត៌មានភ្នំពេញប៉ុស្តិ៍)

*The Minister of Justice, the government and the legislative power have no right to be involved in the decisions of the court.*

*Justice is organized on three levels [and] is independent . . . . If a convict is not in agreement with the court decision, they can ask the Court of Appeals to look at that decision. If they are not content with the Appeals court decision, the Supreme Court can be asked to oversee the Court of Appeals.*

*Our Justice Ministry watches from afar, over the provisions of law that the court uses and we check on the application of the provisions to see if it is correct or incorrect.*

(Phnom Penh Post, November 7-20, 1997)

# ប្រជាធិបតេយ្យពេញលក្ខណៈ

ត្រូវមាន :

១. ការរួមចំណែកពីពលរដ្ឋ
២. ការស្មើភាពគ្នា
៣. ការអនុគ្រោះ
៤. ការទទួលខុសត្រូវ
៥. តម្លាភាព
៦. ការបោះឆ្នោតសេរី និងយុត្តិធម៌ តាមកាលកំណត់
៧. ការយល់ព្រមតាមលទ្ធផលនៃការបោះឆ្នោត
៨. សេរីភាពលើវិស័យសេដ្ឋកិច្ច
៩. យន្តការទប់ស្កាត់ការប្រើអំណាចដោយរំលោភ
១០. កម្រងសិទ្ធិ និងសេរីភាពនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញ
១១. ការទទួលស្គាល់សិទ្ធិឯទៀតៗ
១២. ប្រព័ន្ធពហុបក្ស
១៣. វិធាននៃច្បាប់ «អ្វីៗទាំងអស់ធ្វើតាមច្បាប់»
១៤. មន្ត្រីរាជការ-ទាហាន-នគរបាល ប្រកាន់ជំហរអព្យាក្រឹត ឥតលំអៀង ។

---

# ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

មាត្រា៣៥ :

ត្រូវហាមឃាត់ជាដាច់ខាតដល់អ្នករាជការនូវប្រការខាងក្រោម :

១- យកម៉ោងរដ្ឋបាលទៅប្រកបមុខរបរផ្ទាល់ខ្លួនផ្សេងៗទៀត ។

២- យកឥទ្ធិពលនិងអំណាចនៅក្នុងមុខងាររបស់ខ្លួនទៅប្រើ ដើម្បីទាញយកផលប្រយោជន៍អ្វីមួយ ឬដើម្បីសំឡុត គំរាមកំហែង បំពានសិទ្ធិរបស់ពលរដ្ឋ ។

៣- ប្រកបមុខរបរណាដែលនាំឲ្យប៉ះពាល់ដល់កិត្តិយស និងសេចក្ដីថ្លៃថ្នូរនៃអ្នករាជការ ។

៤- ចូលជាសមាជិកក្នុងក្រុមប្រឹក្សាភិបាល ឬគ្រប់គ្រងក្រុមហ៊ុនឯកជនដោយផ្ទាល់ ឬដោយប្រយោល ។

៥- បោះពុម្ពផ្សាយ ឬធ្វើការផ្សព្វផ្សាយពត៌មានដែលមានពាក់ព័ន្ធនៅក្នុងមុខងារក្រសួង ដោយពុំមានការអនុញ្ញាតជាមុនពីប្រធានស្ថាប័នដែលសាមីខ្លួននៅក្រោមឱវាទ ។

៦- ប្រកបមុខរបរបន្ថែមត្រួតលើមុខងាររបស់ខ្លួនជាអ្នករាជការ ក្នុងករណីដែលលក្ខន្តិកៈដោយឡែកនៃអង្គនីមួយៗហាមឃាត់ ។

អំពើបំពាន និងបទបញ្ញត្តិនៃមាត្រានេះអាចបណ្ដាលឲ្យទទួលទណ្ឌកម្មផ្នែកវិន័យណាមួយដែលមានចែងក្នុងមាត្រា៤០ នៃច្បាប់នេះ ដោយមិនទាន់គិតដល់ការចោទប្រកាន់ជាបទអាជ្ញាដែលអាចកើតមានឡើងទៀតផង ។

<u>មាត្រា៣៧</u> :

មន្ត្រីរាជការត្រូវមានអព្យាក្រឹតភាពក្នុងសកម្មភាពការងារ និងហាមឃាត់ដាច់ខាត នូវការប្រើប្រាស់មុខងាររបស់ខ្លួន និងសម្ភារៈរបស់រដ្ឋដើម្បីបំរើសកម្មភាពនយោបាយ ដូចខាងក្រោម :

១- ធ្វើការដើម្បីផលប្រយោជន៍ដល់បេក្ខជននយោបាយ ឬប្រឆាំងនឹងបេក្ខជននយោបាយណាមួយ ។

២- ធ្វើការដើម្បីផលប្រយោជន៍គណបក្សនយោបាយ ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ។

ការប្រព្រឹត្តិផ្ទុយនឹងមាត្រានេះ ចាត់ទុកជាកំហុសនិងការឆ្គាំឆ្គងក្នុងវិជ្ជាជីវៈ ។

<u>មាត្រា៣៨</u> :

អ្នករាជការទាំងអស់ត្រូវបង្ហាញឲ្យឃើញថា ខ្លួនមានសមត្ថភាពក្នុងវិជ្ជាជីវៈជាដរាប ក្នុងការប្រតិបត្តិមុខងាររបស់ខ្លួន ។ អ្នករាជការទាំងអស់ត្រូវទទួលខុសត្រូវពីកំហុស និងការឆ្គាំឆ្គងក្នុងវិជ្ជាជីវៈ ព្រមទាំងបទល្មើសដែលខ្លួនបានប្រព្រឹត្តក្នុងមុខងាររបស់ខ្លួន ។

<u>មាត្រា៤០</u> :

ទណ្ឌកម្មខាងវិន័យមានដូចតទៅ :

១. ទណ្ឌកម្មថ្នាក់ទី១

ក- ស្តីបន្ទោស

ខ- ស្តីបន្ទោសដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន

គ- ផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ

ឃ- លុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់

២. ទណ្ឌកម្មថ្នាក់ទី២

ក- ស្តីបន្ទោសជាទម្ងន់បណ្តាលឲ្យលុបចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់ បើសិនជាមានចុះឈ្មោះហើយ ឬធ្វើឲ្យយឺតក្នុងការតម្លើងឋានន្តរស័ក្តិ ឬថ្នាក់ ក្នុងថេរៈវេលាមួយមានកំណត់ តែមិនត្រូវឲ្យលើសពី ២ឆ្នាំ ក្នុងការតម្លើងឋានន្តរស័ក្តិ ឬថ្នាក់តាមវេនជ្រើសរើសឬតាមវេនអតីតភាព ។

ខ- ដាក់ឲ្យនៅទំនេរគ្មានបៀវត្ស មិនឲ្យលើសពីមួយឆ្នាំ ។

គ- បន្ថយឋានន្តរស័ក្តិ ឬថ្នាក់មួយថ្នាក់ ឬច្រើនថ្នាក់ ។

ឃ- ដាក់ឲ្យចូលនិវត្តន៍មុនកំណត់ ឬបញ្ចប់ពីការងារដោយបង្ខំ ។

ង- បណ្តេញចេញពីមុខតំណែងរាជការ ។

## សិទ្ធិមនុស្ស

០

**មិនត្រូវអនុគ្រោះជាដាច់ខាត**

ចំពោះបទល្មើសនឹងច្បាប់ :

ត្រូវតែផ្តន្ទាទោសជនល្មើស (បើមិនផ្តន្ទាទោសជនល្មើសទេនោះ មានន័យថា រំលោភសិទ្ធិសាធារណជន)

## ប្រជាធិបតេយ្យ

**ត្រូវតែអនុគ្រោះ**

ចំពោះវិស័យ :

១. នយោបាយ

២. សេដ្ឋកិច្ច

៣. សង្គម

៤. វប្បធម៌

ត្រូវគោរព និងបើកសេរីភាពតាមក្របខ័ណ្ឌច្បាប់ (បើមិនគោរព និងបើកសេរីភាពលើវិស័យទាំង៤នេះទេ នោះមានន័យថា រំលោភសិទ្ធិសាធារណជន)

# សិទ្ធិ ភាគពូកិច្ច និងស្មារតីរបស់ពលរដ្ឋក្នុងសង្គមប្រជាធិបតេយ្យ

**សិទ្ធិ**

១- បោះឆ្នោត (សម្ងាត់)

២- ចូលរួម ឬបង្កើតបក្ខនយោបាយ

៣- ឈរឈ្មោះជាបេក្ខជន

៤- ចូលរួម ឬបង្កើតសមាគម

៥- ទាមទារឲ្យរដ្ឋាភិបាលធ្វើតាមឆន្ទះរបស់ខ្លួន

**ភាគពូកិច្ច**

១- គោរពប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ + ច្បាប់ និងបញ្ញានានា

២- ការពារសិទ្ធិខ្លួនឯង និងគោរពសិទ្ធិអ្នកដទៃ

៣- បោះឆ្នោត + ដឹងពួ និងរួមចំណែកក្នុងកិច្ចការរដ្ឋ

**ស្មារតី**

១- អត់ធ្មត់ (patience)

២- អនុគ្រោះ (tolerence)

៣- សម្របសម្រួល(compromise)

៤- សហការគ្នា(cooperation)

៥- ជជែកវែកញែករកខុសត្រូវ (dialog)

---

FILENAME \p D:\CIHR-W6\LESS-GG\HR-Demo1.doc

# សិទ្ធិមនុស្ស

ពិភពបច្ចុប្បន្នប្រកាន់យកគោលការណ៍ពីរយ៉ាង ៖

គោលការណ៍ទី១

**យើងមិនចាត់ទុកសិទ្ធិមនុស្សថាជា បញ្ហា ទេ !**

**យើងចាត់ទុកសិទ្ធិមនុស្សថាជា ឱកាស ឬលទ្ធភាព**

**សិទ្ធិមនុស្ស គឺជាឱកាស ឬលទ្ធភាព ដើម្បីឱ្យយើងទាំងអស់គ្នា លើកស្ទួយ ការពារ និង គោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស ។**

នេះបានន័យថា រដ្ឋាភិបាល រដ្ឋអំណាច មន្ត្រីសាធារណៈ ឬយើងទាំងអស់គ្នាត្រូវផ្តល់សេវាសព្វមុខ (ឬគ្រប់យ៉ាង) ជូនប្រជារាស្ត្រ (ឬជូនមនុស្សទាំងអស់គ្នា) ។ តើសេវាសព្វមុខមានអ្វីខ្លះ ?

គោលការណ៍ទី២

សិទ្ធិមនុស្ស គឺជាការយកចិត្តទុកដាក់របស់ សាកលលោក ( មិនមែនគ្រាន់តែជារបស់បុគ្គលមួយរូប១ ឬប្រទេសនីមួយ១តែប៉ុណ្ណោះទេ) ។

ដូច្នេះសិទ្ធិមនុស្សនៅក្នុងប្រទេសមួយ ក៏ គឺជាសិទ្ធិមនុស្សរបស់សាកលលោកដែរ ។

សាកលលោក ឬប្រទេសណាមួយក្នុងសាកលលោក អាចជួយឈឺឆ្អាល (ឬជួយកែលំអ) ចំពោះវិស័យសិទ្ធិមនុស្សនៅក្នុងប្រទេសមួយទៀតបាន ។

ទង្វើបែបនេះ

ក) ពិភពលោកសម័យចាស់ចាត់ទុកថាជាការជ្រៀតជ្រែកលើបញ្ហាផ្ទៃក្នុងរបស់ប្រទេសនីមួយ១ ។

ខ) ពិភពលោកសម័យបច្ចុប្បន្នមិនគិតយ៉ាងនោះទេ គេយល់ថាទង្វើនេះគឺត្រឹមត្រូវតាមការយកចិត្តទុកដាក់របស់សាកលលោក ។

នេះបានន័យថា នៅក្នុងសង្គមពិភពលោកសម័យបច្ចុប្បន្ននេះ ប្រទេសនីមួយ១យកចិត្តទុកដាក់លើវិស័យសិទ្ធិមនុស្សក្នុងប្រទេសផង ក្រៅប្រទេសផង។

# នីតិរដ្ឋ

( THE RULE OF LAW )

*(រដ្ឋដែលដំណើរការតាមតែក្របខ័ណ្ឌច្បាប់ ហើយទាំងមន្ត្រីរាជការ ទាំងប្រជាពលរដ្ឋ មានការយល់ដឹងពីច្បាប់បានល្អគ្រប់ៗគ្នា)*

១. នីតិបញ្ញត្តិ (សភា) ធ្វើច្បាប់ (មិនរើសអើង)

២. នីតិប្រតិបតិ (រដ្ឋាភិបាល)

ក- មានអំណាចគ្រប់គ្រាន់

ខ- មានព្រំដែនអំណាច

៣. តុលាការ (មានអង្គចៅក្រមឯករាជ្យ)

៤. នីតិវិធីគ្រប់គ្រងបទល្មើស (នគរបាល និងក្រុមស៊ើបអង្កេតនានា រួមទាំងក្រុមស៊ើបអង្កេតក្រៅរដ្ឋាភិបាល និងក្រុមស៊ើបអង្កេតឯកជនផង)។

*<u>គោលការណ៍ចម្បង៥ប្រការ</u>*

**១. ច្បាប់មិនរើសអើង**

**២. ស្មើភាពគ្នាចំពោះមុខច្បាប់** (គឺពលរដ្ឋទាំងអស់រួមទាំងព្រះមហាក្សត្រ មន្ត្រីរាជការ និងកងប្រដាប់អាវុធ សុទ្ធតែនៅក្រោមច្បាប់)

**៣. អព្យាក្រិតភាពនៃមន្ត្រីរាជការ** (រួមទាំងកងប្រដាប់អាវុធ) បំពេញភារកិច្ចតាមតែគោលនយោបាយជាតិ ហើយប្រកាន់ជំហរអព្យាក្រឹតឥតលំអៀង

**៤. មន្ត្រីនគរបាលមើលការខុសត្រូវក្នុងការគោរពប្រតិបត្តិតាមច្បាប់ ៖**

**៥. អង្គចៅក្រមឯករាជ្យ** (គឺអង្គចៅក្រមដែលបើកសវនាការជំរះក្តី ឬកាត់ទោសដោយពុំមានភាពលំអៀងទាំងបួនប្រការ រួមមាន លំអៀងដោយស្អប់-លំអៀងដោយស្រឡាញ់-លំអៀងដោយខ្លាច និងលំអៀងដោយខ្វះសមត្ថភាព) ។

# សេចក្តីសន្និដ្ឋាន

\+ គួរតែអនុវត្តច្បាប់ដែលមានហើយ ទាំងច្បាប់រដ្ឋធម្មនុញ្ញ ទាំងច្បាប់ដទៃទៀត

\+ គួរដាក់ឱ្យទទួលខុសត្រូវក្នុងការអនុវត្តន៍ច្បាប់ និងក្នុងការមិនអនុវត្តច្បាប់

\+ គួរពង្រឹងប្រព័ន្ធទទួលខុសត្រូវឱ្យបានសមស្រប

\+ ការកែលំអប្រព័ន្ធយុត្តិធម៌ឱ្យបានល្អស្រួចស្រាវជាការចាំបាច់

\+ គួរតែធ្វើឱ្យមានច្បាប់គ្រប់វិស័យ

នីតិរដ្ឋជាបំណងរបស់រដ្ឋមួយ ដែលរដ្ឋប្រជាធិបតេយ្យសេរីប្រាថ្នាចង់បាន ។

រដ្ឋដែលជានីតិរដ្ឋ គឺរដ្ឋដែលដំណើរការតាមច្បាប់ជាគោលការណ៍ ។ រដ្ឋដែលធ្វើអ្វីមួយតាមអនុក្រិត្យដែលមិនស្របតាមគោលការណ៍ច្បាប់ រដ្ឋនោះ មិនមែនជានីតិរដ្ឋទេ ។

# នីតិរដ្ឋ

## ប្រជាធិបតេយ្យក្រោមដំបូលច្បាប់




Wisdom of H.E. Kry BengHong គតិបណ្ឌិតនៃឯកឧត្តម គ្រីយ៍ បេងហុង

# បទពិចារណា

ដល់ពេលបោះឆ្នោតសកលឆ្នាំ១៩៩៨ តើខ្ញុំត្រូវបោះឆ្នោតឲ្យបេក្ខជនប្រភេទណា ?

១. បេក្ខជនដែលអង់អាចក្លាហាន ដូចអ្នកកុលានិយម ប្រើហិង្សាជាមធ្យោបាយ ។

២. បេក្ខជនដែលចេះជួយដោះទុក្ខប្រជារាស្ត្រ និងខំជំរុញអភិវឌ្ឍន៍ ។

៣. បេក្ខជនដែលមានមន្តបីប្រការ ដូចមានចែងក្នុងពុទ្ធឱវាទ ស្តីពីលក្ខណៈសម្បតិរបស់មន្ត្រី។

មន្តទី ១ គឺ : សមត្ថភាព រួមមាន ចំណេះដឹងខ្ពស់ ទាំងថ្នាក់ជាតិ ទាំងថ្នាក់អន្តរជាតិ។

មន្តទី ២ គឺ : សុខភាព រួមមាន សុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្ត (មិនមានជំងឺសរសៃប្រសាទ)។

មន្តទី ៣ គឺ : គុណធម៌ គឺគោរពច្បាប់ គោរពពលរដ្ឋ ស្មោះត្រង់ចំពោះពលរដ្ឋ និងចំពោះខ្លួនឯង ។

៤. បេក្ខជនដែលមានប្រវត្តិតស៊ូកំចាត់បនប្រល័យពូជសាសន៍ប៉ុលពត ។

៥. បេក្ខជនដែលប្រើទឹកប្រាក់ និងប្រើអំណាចជាមធ្យោបាយ ។

៦. បេក្ខជនដែលមានឈ្មួញបរទេសចោមរោមច្រើន ។

៧. បេក្ខជនដែលយកសម្បត្តិសាធារណៈទៅប្រើជាប្រយោជន៍ផ្ទាល់ខ្លួន ឬលក់ឲ្យបរទេស ។

៨. បេក្ខជនដែលជាសមាជិកសភាបច្ចុប្បន្ន ។

៩. បេក្ខជនដែលនិយាយថាខ្លួនស្នេហាជាតិ ប៉ុន្តែចូលចិត្តបរិហារសំអុយកេរ្តិ៍ខ្មែរគ្នាឯង ហើយសុំឲ្យបរទេសកាត់ជំនួយដល់ខ្មែរ ។

# ការបោះឆ្នោតមានផលប៉ះពាល់ដល់មន្ត្រីថ្នាក់ណាខ្លះ?

**នាយករដ្ឋមន្ត្រី** — ក្របខ័ណ្ឌតាមអាណត្តិ (ឬក្របខ័ណ្ឌនយោបាយ)

| | | | |
|---|---|---|---|
| រដ្ឋមន្ត្រី | រដ្ឋមន្ត្រី | រដ្ឋមន្ត្រី | ក្របខ័ណ្ឌតាមអាណត្តិ |
| រដ្ឋលេខាធិការ | រដ្ឋលេខាធិការ | រដ្ឋលេខាធិការ | ក្របខ័ណ្ឌតាមអាណត្តិ |
| អនុរដ្ឋលេខាធិការ | អនុរដ្ឋលេខាធិការ | អនុរដ្ឋលេខាធិការ | ក្របខ័ណ្ឌតាមអាណត្តិ |
| - នាយកការិយាល័យ<br>- ប្រធាននាយកដ្ឋាន<br>- បុគ្គលិកគ្រប់ជាន់ថ្នាក់ | - ឧត្តមសេនីយនគរបាល<br>- នាយនគរបាល<br>- បុគ្គលិកគ្រប់ជាន់ថ្នាក់ | - ឧត្តមសេនីយ៍ទ័ព<br>- នាយទាហាន<br>- បុគ្គលិកគ្រប់ជាន់ថ្នាក់ | ក្របខ័ណ្ឌអចិន្ត្រៃយ៍<br>(ឬក្របខ័ណ្ឌជាតិ) |

- មន្ត្រីក្នុងក្របខ័ណ្ឌតាមអាណត្តិ (ឬក្របខ័ណ្ឌនយោបាយ) ត្រូវប្តូរចេញ ពេលណាបក្សគាត់ចាញ់ឆ្នោត

- មន្ត្រីក្នុងក្របខ័ណ្ឌអចិន្ត្រៃយ៍ គឺជាក្របខ័ណ្ឌជាតិ គេមិនប្តូរចេញទេ ទោះជាបក្សគាត់ចាញ់ឆ្នោតក៏ដោយ ។

# គោលការណ៍ប្រតិបត្តិសម្រាប់ភ្នាក់ងារប៉ូលីស ក្នុងរបបប្រជាធិបតេយ្យ

## ទិសដៅ៣ :

១. រក្សាការពាររបៀបរៀបរយសាធារណៈ

២. លើកគុណភាពជីវិតមនុស្ស

៣. ទ្រទ្រង់សង្គម ហើយការពារ និងស្មោះត្រង់ចំពោះរដ្ឋធម្មនុញ្ញ

## គោលការណ៍ទី១

- បម្រើសហគមន៍ និងការពារកុំឲ្យប្រជាជនប្រព្រឹត្តខុសច្បាប់ ។
- បំពេញភារកិច្ចរបស់ខ្លួនឲ្យបានត្រឹមត្រូវតាមច្បាប់គ្រប់ពេលវេលា ។
- ប្រកាន់ស្មារតីទទួលខុសត្រូវខ្ពស់បំផុត ។
- ជួយដល់សមាជិកសហគមន៍ទាំងឡាយណា ដែលត្រូវការជំនួយជាបន្ទាន់ ។

## គោលការណ៍ទី២

- គោរព និងការពារសេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិ ។
- លើកតម្កើងសិទ្ធិរបស់មនុស្សគ្រប់ៗគ្នា

## គោលការណ៍ទី៣

- អាចប្រើកម្លាំងបានតែនៅកាលៈទេសៈណាដែលចាំបាច់បំផុត ។
- ហាមផ្ដាច់មិនឲ្យប្រើកម្លាំងហួសកម្រិត ។

## គោលការណ៍ទី៤

រក្សាការសម្ងាត់ជានិច្ច ប្រសិនបើកាតព្វកិច្ចមិនបង្ខិតបង្ខំ ។

## គោលការណ៍ទី៥

- មិនត្រូវធ្វើទារុណកម្ម
- មិនត្រូវញុះញង់ឲ្យគេប្រព្រឹត្តទារុណកម្ម

- មិនត្រូវបណ្តោយឲ្យមានទារុណកម្ម ឬទណ្ឌកម្មដ៏សាហាវយង់ឃ្នង អមនុស្សធម៌ជាដាច់ខាត។

## គោលការណ៍ទី៦

ធានាកិច្ចការពារសុខភាពចំពោះបុគ្គលដែលជាប់ឃុំឃាំងនៅក្នុងបន្ទុករបស់ខ្លួន។

## គោលការណ៍ទី៧

- មិនប្រព្រឹត្តអំពើពុករលួយជាដាច់ខាត ។
- ត្រូវតែប្រឆាំង និងប្រយុទ្ធតតាំងនឹងអំពើពុករលួយទាំងអស់ឲ្យបានមោះមុតបំផុត ។

## គោលការណ៍ទី៨

- ការពារច្បាប់ដោយបង្ការ និងប្រឆាំងឲ្យពេញសមត្ថភាព និងយ៉ាងមោះមុតបំផុត ចំពោះអំពើទាំងឡាយណាដែលរំលោភច្បាប់ និងប៉ះពាល់ដល់បទវិន័យនេះ ។
- បើដឹងប្រាកដថាមានការរំលោភ ឬប្រុងនឹងមានការរំលោភលើបទវិន័យនេះ ត្រូវតែរាយការណ៍ទៅអាជ្ញាធរថ្នាក់លើ ។
- ត្រូវពង្រឹងវិន័យផ្ទៃក្នុងរបស់ក្រសួង ។
- ត្រូវដោះស្រាយបញ្ហារំលោភសិទ្ធិមនុស្សជាមូលដ្ឋាន ។
- នៅប្រទេសណាដែលមានច្បាប់ និងបទវិន័យតឹងរឹងជាងនេះ ភ្នាក់ងារប៉ូលីស ត្រូវគោរពតាមច្បាប់ និងបទវិន័យតឹងរឹងនោះវិញ ។

## សម្រាប់កងប្រដាប់អាវុធ

# គោលការណ៍ប្រតិបត្តិ ១០ប្រការ ក្នុងកិច្ចប្រតិបត្តិការសឹក

១. វាយប្រហារតែយុទ្ធជនរបស់ខ្មាំងសត្រូវប៉ុណ្ណោះ

២. កុំធ្វើបាបសត្រូវដែលចុះចូល

៣. កុំសម្លាប់ ឬធ្វើទារុណកម្មលើអ្នកទោសឲ្យសោះ

៤. ប្រមូលអ្នករបួសទាំងអស់ និងមើលថែទាំគេឲ្យបានសមស្រប

៥. កុំវាយប្រហារលើសម្ភារៈបរិក្ខារពេទ្យ ឬបុគ្គលិកពេទ្យ

៦. បំផ្លាញចោលកុំឲ្យហួសពីអ្វីដែលជាបេសកកម្មតម្រូវ

៧. យកចិត្តទុកដាក់ថែទាំប្រជាពលរដ្ឋទាំងអស់ដោយមេត្តាធម៌

៨. កុំលួច : គោរពទ្រព្យសម្បត្តិ និងកម្មសិទ្ធិឯកជន ។ ត្រូវខិតខំឲ្យអស់លទ្ធភាពដើម្បីទប់ស្កាត់ការរំលោភបំពានទៅលើច្បាប់សង្គ្រាម ។

៩. ត្រូវរាយការណ៍ទៅថ្នាក់លើអំពីការរំលោភបំពានទាំងអស់ទៅលើច្បាប់សង្គ្រាម ។

១០. ត្រូវការពារ និងស្មោះត្រង់ចំពោះរដ្ឋធម្មនុញ្ញជានិច្ច ។

FILENAME \p D:\CIHR-W6\LESS-GG\HR-Demo1.doc

# សប្បាយល្ងាចថ្ងៃសៅរ៍

==================

| | | | | |
|---|---|---|---|---|
| I | ប្រជុំគ្នារីករាយ | សប្បាយចិត្ត | ចូររាំឲ្យស្និទ្ធ | ចូលចិត្ត |
| | កុំឲ្យហ្មងសៅ | ចូររាំតាមភ្លេង | តាមភ្លេង | អធ្រាត្រយប់ជ្រៅ |
| | ពេលល្ងាចថ្ងៃសៅរ៍ | ជាថ្ងៃឈប់ | សំរាកកាយ ។ | ១.២. អារីបពីយ៉ា........ |
| II | យើងប្រជា | មានសិទ្ធិសេរីភាព | សិទ្ធិមានរបៀប | អភិវឌ្ឍន៍ |
| | គ្រប់កិច្ចករណី | សិទ្ធិជួបជុំគ្នា | កសាងស្មារគ្រប់វិស័យ | សិទ្ធិនិយាយស្ដី |
| | ជីវិតប្រពៃ | ជាពលរដ្ឋល្អ ។ | ១.២. អារីបពីយ៉ា ............ | |
| III | អ្នកកាសែត | មានសិទ្ធិសេរីភាព | ស្មារតីប្រុងប្រៀប | ផ្សព្វផ្សាយ |
| | ដោយចិត្តស្មោះស | ទទួលខុសត្រូវ | រៀបចំនិពន្ធបានល្អ | ប្រជាក្រីក្រ |
| | អានទស្សនា | ដោយមេត្រី ។ | ១.២. អារីបពីយ៉ា ................ | |
| IV | ទាំងអស់គ្នា | មានសិទ្ធិស្មើៗភាព | មិនគិតខ្ពស់ទាប | ស្មើភាព |
| | ទាំងប្រុសស្រី | គោរពស្រឡាញ់ | អាណិតចិត្តខន្តី | ចរិយាថ្លាថ្លៃ |
| | ពាក្យសំដី | ផ្អែមពីរោះ ។ | ១.២. អារីបពីយ៉ា ................ | |
| V | អង្គចៅក្រម | កាន់ក្រិត្យយុត្តិធម៌ | ប្រជាសាទរ | ត្រេកអរ |
| | ចិត្តស្ម័គ្រស្មោះ | គោរពតាមច្បាប់ | ធម្មនុញ្ញចែងឥតខ្ចោះ | មន្ត្រីថ្នាក់ខ្ពស់ |
| | ស្ងួយកិត្តិយស | ជាតិថ្កើងថ្កាន ។ | ១.២. អារីបពីយ៉ា .................... | |

លំនាំ : រីករាយល្ងាចថ្ងៃសៅរ៍

ទំនុកច្រៀង រៀបរៀងដោយ : នៅ ភាស៊ុំ

# ឧត្តមគតិកូលបុត្រខ្មែរ

==================

| | | | | |
|---|---|---|---|---|
| I | រួម | យើងស្រឡាញ់គ្នា | រួបរួមការពារ | ប្រយោជន៍សង្គម |
| | | បានខ្ពស់ឧត្តម | ព្រោះអ្នកដឹកនាំ | ចេះច្នៃប្រឌិត |
| | | ប្រាជ្ញាវាងវៃ | បញ្ជាក់ស្មារតី | ចេះស្គាល់ការពិត |
| | | ចេះច្នៃគំនិត | រកភាពសុក្រឹត | ជូនជាតិប្រជា ។ |
| II | ស្រី | និយាយបានល្អ | ស្តាប់ក៏បានល្អ | គ្រប់ពេលវេលា |
| | | តស៊ូពុះពារ | អង់អាចមោះមុត | គិតជាតិជាត្រួយ |
| | ប្រុស | កូនខ្មែរក្លាហាន | ផ្គុំគ្នាឲ្យបាន | វេញជាធ្លុងមួយ |
| | | នាំគ្នាលើកស្ទួយ | កិត្តិយសប្រទេស | ស្មើសកលលោក ។ |
| III | ស្រី | ទំនៀមទំលាប់ | ប្រពៃណីខ្ជាប់ | មិនអោយថយថោក |
| | | យើងត្រូវចាប់យក | នាទីប្រយោជន៍ | ជាអ្នកដឹកនាំ |
| | រួម | កសាងស្ថាបនា | សហគមន៍ថ្លៃថ្លា | ថ្កុំថ្កើងឧត្តម |
| | | ទឹកដីមនោរម្យ | កូនខ្មែរខិតខំ | សាងជាតិរុងរឿង ។ |

ផ្តួចផ្តើមគំនិតណែនាំដោយ : នៅ ភាស៊ី
និពន្ធដោយ : អ្នកគ្រូ គង់ ណារី

*"May all Cambodians have loving kindness and compassion!*
*And together protect the glorious interests of our nation*
*Under the wise guidance of intelligent leaders*
*And clear sighted policies with deft flexibility,*
*And who can provide their beloved people with justice and integrity,*

*Leaders with intelligence in speeches and clear thinking at all times*

*And determined bravely to overcome all hardships with constant devotion*
*Putting the interests of the nation above all*
*And able to bring our beloved nation unity and national reconciliation*
*And to promote the prestige of the country as high as those of other countries in the world.*

*Respecting our national custom and tradition by leaders*
*Don't let them wane,*
*And sticking firmly to the role as a leader*
*To establish glorious and advanced communities*
*And all Khmer children have to serve the country*
*To promote liberty and prosperity in our beloved motherland."*

# នឹកបង្គងចាស់

===========

នឹកវាលធ្លាប់ឃ្វាលគោ
នឹកព្រៃឫស្សីធ្លាប់ឆ្ការព្រៃយកឃុំ
នឹកសម្លេងហៅមិត្តភក្តិជុំៗ
នឹកស្រែនឹកភូមិនឹកស្ទឹងបឹងព្រែក ។

នឹកកីនឹករហាត់
នឹកយប់ខែភ្លឺទឹទុយយំស្រែក
នឹករាត្រីស្ងាត់សម្លេងខ្លែងឯក
នឹកងូតទឹកព្រែកពេលឡើងពីស្ទូង ។

នឹកកក្តិកអង្គុយលើភ្លឺស្រែ
នឹកស្ករឃ្មុំ ឃីកេ តាខេ ទ្រ ផង
នឹកផ្ការលាងស្លែសន្ទឹកក្តួងៗ
នឹកសន្ទូចមងនឹកគោនឹករទេះ ។

នឹកគ្រូបាអាចារ្យ
នឹកម៉ែនឹកឪមានគុណស្មើព្រះ
នឹកវត្តសាលាទីធ្លាប់ផ្តល់ចំណេះ
នឹកអ្នកយល់ច្បាស់អរិយធម៌ខ្មែរ ។

នឹកគុណបុព្វបុរស
ប្រាសាទរយពាន់ឱ្យនៅឋិតថេរ
យកសាច់ឈាមស្រស់រក្សាដីកើត
នឹកអង្គរកើតពីបង្គងចាស់ ។

# វប្បធម៌សន្តិភាព

=============

I ជយោ ! ទិវាវប្បធម៌សន្តិភាព ទន់ភ្លន់រៀងរាបប្រជាធិបតេយ្យ <u>ពីរដង</u>
គោរពសិទ្ធិមនុស្សគោរពតម្លៃ <u>ពីរដង</u> នៃអ្នកដទៃ និងខ្លួនឯងផង ។

II ប្រជាធិបតេយ្យក្រៅដំបូលច្បាប់ មិនយូរឬឆាប់អួរអាប់សៅហ្មង
កើតក្តីអនាធិបតេយ្យយង់ឃ្នង ច្បាប់គួរចម្បងលើអ្វីទាំងអស់ ។

**បន្ទរ** នីតិរដ្ឋមួយស្ទួយឱ្យសុក្រឹត ត្រិះរិះលំអិតលើច្បាប់ឥតខ្ចោះ
វឹចុងអារុំធពិតជាទំនាស់ របស់លទ្ធិប្រជាធិបតេយ្យ ។

III ជយោ ! ទិវាវប្បធម៌សន្តិភាព សម្រាប់ពលករកម្ពុជាប្រុសស្រី
ពង្រីកពង្រឹងប្រជាធិបតេយ្យ នៅលើវិស័យវប្បធម៌សន្តិភាព ។

<u>ច្រៀងពីរដង</u> ២

និពន្ធដោយ : សម្តេច ហ៊ុន សែន ~ នាយករដ្ឋមន្ត្រី
ច្រៀងដោយ : លោក ះធាម ប៊ុនយ៉ុង និងអ្នកនាង ឆោម និមល




# « អំពើពុករលួយ »

## បើយើងមិនកំចាត់វាទេ, វានឹងកំចាត់យើងវិញ

# សិទ្ធិមនុស្ស

(បកស្រាយសង្ខេប)

បើសរុបសេចក្ដីឲ្យស្រួលចាំពាក្យថា សិទ្ធិ គឺអ្វីៗដែលមនុស្សត្រូវតែមានជាចាំបាច់ដើម្បីរស់ឲ្យសមរម្យជាមនុស្ស ។ សិទ្ធិជាមូលដ្ឋាន ដែលមនុស្សមានជាស្រេច តាំងពីកំណើតមក គឺ **ជីវិត និង សេរីភាព** ។ ប៉ុន្តែ មនុស្សត្រូវការអ្វីមួយទៀតជាចាំបាច់ ពោលគឺការរស់នៅប្រចាំថ្ងៃប្រកបដោយ **សុភមង្គល** ។ ដូច្នេះ ដើម្បីរស់ឲ្យសមជាមនុស្ស យើងត្រូវការ ៖

១- **ជីវិត** (*សិទ្ធិរស់រានមានជីវិត*)

២- **សេរីភាព** (គឺជា *សេរីភាព*សព្វបែបសព្វយ៉ាងដែលយើងត្រូវការ)

៣- **សុភមង្គល** (ដែលក្នុងនោះមាន *សន្តិភាព* *បរិដ្ឋាន* និង*អភិវឌ្ឍន៍*)។

ដើម្បីគោរពសិទ្ធិសំខាន់ទាំងបីប្រការនេះឲ្យបានល្អប្រពៃ យើងគួរលើកយកសិទ្ធិមួយម្ដងៗមកពិនិត្យពិចារណាឲ្យបានល្អិតល្អន់ដូចខាងក្រោម :

## ១. ជីវិត

សូមលោកអ្នកអានសាកល្បងពិចារណាលើពាក្យ **ជីវិត** ។ ដើម្បីគោរពសិទ្ធិនេះពោលគឺដើម្បីទ្រទ្រង់**ជីវិតមនុស្ស**ឲ្យគង់វង្ស តើយើងត្រូវធ្វើអ្វីខ្លះ ? ចម្លើយគឺអ្វីៗដែលអាចប៉ះពាល់ដល់ជីវិតមនុស្សត្រូវតែហាមឃាត់ ទប់ស្កាត់ ចៀសវាង ឬកែលំអ ។ អ្វីៗទាំងនោះរួមមាន៖ សង្គ្រាម អាវុធ គ្រាប់មីន ចរាចរឥតសណ្ដាប់ធ្នាប់ ប្រើយានយន្តមិនសមស្របតាមច្បាប់, ការលក់និងប្រើថ្នាំខុស ឬគ្មានវេជ្ជបញ្ជា, ចោរកម្ម, ផ្លូវថ្នល់និងស្ពានគ្មានសុវត្ថិភាព, ម្ហូបអាហារ និងភេសជ្ជៈដែលមានជាតិពុល, កង្វះអនាម័យក្នុងភូមិស្រុក ព្រមទាំងកត្តាជាច្រើនទៀតដែលកំពុងតែយាយីជីវិតមនុស្សសព្វថ្ងៃ ។

## ២. សេរីភាព

**សេរីភាព** មានច្រើនប្រភេទ ។ ខ្លះជាសេរីភាពឥតព្រំដែន ដូចជា សេរីភាពក្នុងការគិត ឬប្រើគំនិត, សេរីភាពខាងជំនឿសាសនា និងសេរីភាពក្នុងការបញ្ចេញមតិជាដើម ។ រីឯសេរីភាពឯទៀត ដូចជាសេរីភាពនៃសារពត៌មាន សេរីភាពក្នុងការដើរហើរជាដើម គឺជាសេរីភាពមានព្រំដែន ។ សូមចងចាំថា *ការប្រើសេរីភាពទាំងនេះ ត្រូវតែមានការទទួលខុសត្រូវជានិច្ច* ។

### ៣. សុភមង្គល

សេចក្ដីសុខ ការមានជោគលាភល្អក្នុងផ្លូវចិត្ត ដើម្បីមានសុភមង្គលក្នុងប្រទេស ត្រូវឲ្យមានសុភមង្គលក្នុងសង្គមសិន ។ ហើយសុភមង្គលក្នុងសង្គម អាចសម្រេចបានអាស្រ័យដោយគ្រួសារមានសុភមង្គល ។ សុភមង្គលក្នុងគ្រួសារទាមទារឲ្យមនុស្សម្នាក់ៗដែលជាសមាជិកគ្រួសារមានសុភមង្គលផ្ទាល់ខ្លួន ។ ព្រះបរមគ្រូនៃយើងតែងតែទូន្មានយើងឲ្យប្រកាន់ខ្ជាប់នូវ សីលធម៌ ។ តើសីលធម៌ក្នុងអត្ថន័យប្រតិបត្តិគឺជាអ្វី? ដែលហៅថាមនុស្សមានសីលធម៌គឺជាមនុស្សដែលចៀសវាងនូវសេចក្ដីអាក្រក់ដាច់ខាតមិនប្រព្រឹត្តអំពើអាក្រក់គឺសីលៈ ហើយប្រព្រឹត្តតែអំពើល្អគឺធម្មៈ ។ កាលបើមនុស្សម្នាក់ៗមាន*សីលធម៌*ជានិច្ចហើយ *សន្តិភាព* *បរិដ្ឋាន* និង *អភិវឌ្ឍន៍* ក៏នឹងរីកចម្រើនជានិច្ចដែរ ។

## ប្រភេទចំបងបីយ៉ាងនៃសិទ្ធិមនុស្ស

### ក. សិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ

សិទ្ធិពីរប្រភេទនេះ បានចាប់កំណើតឡើងនៅចុងសតវត្សរ៍ទី១៨ នៅពេលដែលមានការវិវត្តន៍នយោបាយនៅក្នុងប្រទេសជឿនលឿនជាច្រើន ។ មូលហេតុគឺដោយចង់ការពារកុំឲ្យអ្នកមានអំណាចធ្វើទុក្ខបុកម្នេញពលរដ្ឋខ្លួន ។ គោលដៅចំបងនៃសិទ្ធិទាំងពីរនេះ គឺដើម្បីរកវិធីទប់ស្កាត់នូវអំពើរំលោភនានាជាយថាហេតុមកលើប្រជាពលរដ្ឋពីសំណាក់រដ្ឋអំណាច ។

### ខ. សិទ្ធិសង្គម សេដ្ឋកិច្ច និង វប្បធម៌

សិទ្ធិបីប្រភេទនេះ បានចាប់កំណើតនៅដើមសតវត្សរ៍ទី១៩ នៅក្នុងសម័យកាលនៃការលូតលាស់ខាងឧស្សាហកម្ម និងវិទ្យាសាស្ត្រ ។ វឌ្ឍនភាពខាងឧស្សាហកម្ម និងវិទ្យាសាស្ត្របានផ្ដល់ផលប្រយោជន៍ឲ្យមនុស្សជាច្រើន ជាពិសេសអ្នករស់នៅទីក្រុង ។ ប៉ុន្តែអ្នករស់នៅតាមជនបទភាគច្រើនត្រូវប្រឈមមុខនឹងការប្រែប្រួលរបៀបរស់នៅក្នុងសង្គម ការប្រែប្រួលស្ថានភាពសេដ្ឋកិច្ច ហើយនិងការដែលត្រូវទទួលយកនូវការរស់នៅលាយឡំគ្នាជាមួយវប្បធម៌ដទៃ ។ ក្នុងសុឆន្ទៈទប់ស្កាត់ ឬបន្ថយការប៉ះទង្គិចខ្លាំងទៅលើវិស័យសង្គម សេដ្ឋកិច្ច និងវប្បធម៌របស់មនុស្សក្រុមសិទ្ធិទាំងបីប្រភេទនេះ ទើបបានត្រូវចងក្រងឡើង ។

គ. សន្តិភាព អភិវឌ្ឍន៍ បរិដ្ឋាន

នៅមានកម្រងច្បាប់អន្តរជាតិជាច្រើនទៀត ដូចជា កតិកាសញ្ញា និងអនុសញ្ញានានា ដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់មនុស្សក្នុងការរក្សាសន្តិភាព ជម្រុញការអភិវឌ្ឍន៍ និងកែលំអបរិដ្ឋាន ។

## សិទ្ធិទាំងនោះចែកចេញជាអ្វីខ្លះ ?

ក. សិទ្ធិពលរដ្ឋ (ដោយសង្ខេប) មាន :

១- សិទ្ធិដើម្បីរស់រានមានជីវិត (*គឺមិនសម្លាប់ និងការពារជីវិតឲ្យគង់វង្ស* )

២- សិទ្ធិដើម្បីមានសេរីភាព (*បំបិទសេរីភាព គឺជាការរំលោភសិទ្ធិ* )

៣- សិទ្ធិរួចផុតពីការធ្វើទារុណកម្ម (*គឺមិនត្រូវមានទារុណកម្មជាដាច់ខាត* )

៤- សិទ្ធិស្មើគ្នានៅចំពោះមុខច្បាប់ ( *ច្បាប់ត្រូវការពារនិងផ្តន្ទាទោសមនុស្សស្មើៗគ្នា*)

៥- សិទ្ធិរួចផុតពីការរើសអើង (*គឺមិនត្រូវប្រកាន់បក្សពួក វណ្ណៈ ឋានៈ ។ល។* )

៦- សិទ្ធិឲ្យមានច្បាប់ការពារ (*គឺត្រូវមានច្បាប់ឲ្យគ្រប់គ្រាន់សម្រាប់ការពារមនុស្សលើគ្រប់វិស័យ* )

៧- សិទ្ធិដើម្បីមានសញ្ជាតិមួយ (*គឺឲ្យតែកើតមកជាមនុស្សត្រូវតែមានសញ្ជាតិមួយ* )

៨- សិទ្ធិមានឈ្មោះមួយ ( *គឺមនុស្សម្នាក់ត្រូវតែមានឈ្មោះមួយ* )

៩- សិទ្ធិប្រព្រឹត្តតាមដំណើរការច្បាប់ (*គឺត្រូវប្រតិបត្តិតាមលំនាំច្បាប់ជាធរមាន*)

១០- សិទ្ធិប្រើប្រាស់ប្រព័ន្ធតុលាការ (*គឺចេញចូលទាក់ទងតុលាការបានតាមត្រូវការ* )

១១- សិទ្ធិទទួលការជំនុំជំរះក្តី ដោយអាជ្ញាធរមានសមត្ថកិច្ច មិនលំអៀងនិងឯករាជ្យ (*គឺមានតែតុលាការទេ ដែលមានសមត្ថកិច្ចកាត់សេចក្តីហើយអង្គចៅក្រមត្រូវតែឥតលំអៀង និងមានឯករាជភាព*)

១២- សិទ្ធិក្នុងការជំនុំជំរះក្តីជាសាធារណៈ (*គឺតុលាការជំរះក្តីដោយមានសាធារណជនចូលស្តាប់ផង*)

១៣- សិទ្ធិទទួលពត៌មានស្តីពីការចោទប្រកាន់ (*គឺបើក្រសួងធ្វើការចោទប្រកាន់ជនណាម្នាក់ ត្រូវតែប្រាប់មូលហេតុនៃការចោទប្រកាន់នេះដល់ជនត្រូវចោទ* )

១៤- សិទ្ធិសន្មតទុកជាមុនថាជាមនុស្សគ្មានកំហុស (គឺបើតុលាការមិនទាន់រកភស្តុតាងឃើញថាជនណាបានប្រព្រឹត្តកំហុសទេ គេត្រូវចាត់ទុកជននោះថាជាជនគ្មានកំហុស)

១៥- សិទ្ធិមិនត្រូវគេបង្ខំឲ្យបង្ហាញភស្តុតាងដែលជាប់ជំពាក់ក្នុងបទឧក្រិដ្ឋដោយខ្លួនឯង (គឺមិនត្រូវបង្ខំឲ្យជនដែលជាប់សង្ស័យបង្ហាញភស្តុតាងដើម្បីទម្លាក់កំហុសលើខ្លួនឯងឡើយ)

១៦- សិទ្ធិអាចទារយកព័ត៌មានដែលជាប់ទាក់ទងនឹងខ្លួន

១៧- សិទ្ធិមានការឧបត្ថម្ភសេវាច្បាប់ដោយឥតគិតថ្លៃឈ្នួល (គឺបើជនជាប់ចោទមិនមានប្រាក់ជួលអ្នកការពារក្តីទេ ក្រសួង ឬស្ថាប័នឯទៀត ដែលទាក់ទិនត្រូវផ្តល់អ្នកការពារក្តីឲ្យជនជាប់ចោទ)

១៨- សិទ្ធិជ្រើសរើសសេវាច្បាប់ការពារខ្លួន (គឺជនជាប់ចោទអាចទទួលយកស្មាក្តីដែលរដ្ឋផ្តល់ឲ្យ ឬបើមានប្រាក់ គេអាចជួលស្មាក្តីដោយខ្លួនឯង)

១៩- សិទ្ធិមានពេលវេលា និងមានលទ្ធភាពរៀបចំកិច្ចការពារខ្លួនតាមផ្លូវច្បាប់ (គឺមុននឹងនាំជនជាប់ចោទទៅជំរះក្តីត្រូវទុកពេលឲ្យជននោះរកស្មាក្តីដើម្បីសិក្សាសំណុំរឿង និងរៀបចំការពារក្តីឲ្យគេ)

២០- សិទ្ធិការពារ និងសិទ្ធិឆ្លើយដោះសាដោយផ្ទាល់(គឺដាច់ខាតត្រូវផ្តល់លទ្ធភាពឲ្យជនជាប់ចោទឆ្លើយឆ្លងឲ្យបានគ្រប់គ្រាន់ដើម្បីការពារខ្លួន)

២១- សិទ្ធិមានការទាក់ទងជាមួយស្មាក្តី (គឺត្រូវអនុញ្ញាតឲ្យជនដែលនៅក្នុងមន្ទីរឃុំឃាំង ឬក្នុងគុក មានការទាក់ទងជាមួយអ្នកការពារក្តីតាមត្រូវការ)

២២- សិទ្ធិមានជំនួយពីអ្នកបកប្រែភាសាដោយឥតគិតឈ្នួល (គឺបើកាត់ទោសលើជនបរទេស ក្រសួង ឬស្ថាប័នពាក់ព័ន្ធត្រូវផ្តល់អ្នកបកប្រែភាសា)

២៣- សិទ្ធិមានលទ្ធភាពតក្តីស្មើគ្នា ចំពោះអំណាចច្បាប់

២៤- សិទ្ធិមានការពិនិត្យពិច័យលើសាក្សី (គឺអ្នកការពារក្តីអាចសួរដេញដោលសាក្សីដើមចោទ ឬចុងចោទ)

២៥- សិទ្ធិឲ្យតុលាការប្រតិបត្តិតាមនីតិវិធី គឺការកាត់ទោសដែលមិនស្របតាមនីតិវិធីនឹងទុកជាមោឃៈ)

២៦- សិទ្ធិទទួលការដោះស្រាយដោយប្រសិទ្ធភាព ( គឺនៅក្នុងដំណើរការកាត់ក្តីតុលា-ការត្រូវដោះស្រាយបញ្ហានានាដោយនីតិវិធីយ៉ាងឆាប់រហ័ស និងវាងវៃ )

២៧- សិទ្ធិមិនត្រូវមានទោសបញ្ញត្តិដែលមានប្រតិកម្មធាក់ថយ

២៨- សិទ្ធិសុំប្តឹងឧទ្ធរណ៍ (គឺបើមានភាគីណាមិនសុខចិត្តចំពោះសេចក្តីសម្រេចនៃតុលាការថ្នាក់ក្រោមទេ គេអាចប្តឹងតវ៉ាទៅតុលាការថ្នាក់លើទៀត )

២៩- សិទ្ធិមានការគ្រប់គ្រងដោយមនុស្សធម៌( គឺមិនត្រូវផ្តន្ទាទោសឬប្រព្រឹត្តអំពើឃោរឃៅអមនុស្សធម៌លើជនជាប់ចោទណាឡើយ )

៣០- សិទ្ធិមានការគ្រប់គ្រងសមរម្យជាអ្នកទោស (គឺត្រូវទុកដាក់អ្នកទោសឲ្យសមស្របតាមបទដ្ឋាននៃច្បាប់គ្រប់គ្រងអ្នកទោស )

៣១- សិទ្ធិការពារពីការរំលោភរបស់អាជ្ញាធរ (គឺត្រូវមានច្បាប់សម្រាប់ទប់ស្កាត់និងផ្តន្ទាទោសមន្ត្រីរាជការណាដែលប្រព្រឹត្តរំលោភលើរាស្ត្រស្លូតត្រង់)

៣២- សិទ្ធិទទួលយក ស្វែងរកនិងចែកចាយពត៌មាន(គឺមិនត្រូវហាមឃាត់មិនឲ្យយកពត៌មាននិងចែកចាយពត៌មានឡើយ )

៣៣- សិទ្ធិមានមនសិការ និងបញ្ចេញមតិដោយសេរី (រួមទាំងជំនឿសាសនា និងជំនឿនយោបាយផង )

៣៤- សិទ្ធិមានសន្តិសុខក្នុងលំនៅដ្ឋានឯកជនរបស់ខ្លួន (គឺមិនត្រូវយាយីលំនៅដ្ឋានគេឡើយ)

៣៥-សិទ្ធិមាននិរភ័យក្នុងទំនាក់ទំនងផ្ទាល់ខ្លួន(គឺមិនត្រូវជ្រៀតជ្រែកក្នុងកិច្ចការរបស់អ្នកដទៃ ជាអាទិ៍ការទាក់ទងផ្ទាល់ខ្លួន )

៣៦- សិទ្ធិមានកិច្ចការពារកិត្តិយស និងកិត្តិស័ព្ទ (គឺត្រូវមានច្បាប់ការពារកុំឲ្យមានការប៉ះពាល់ដល់កិត្តិស័ព្ទ និងកិត្តិយសរបស់បុគ្គល )

៣៧- សិទ្ធិធ្វើដំណើរដោយសេរី ( ប៉ុន្តែបើចូលទៅប្រទេសដទៃ ត្រូវមានការអនុញ្ញាតិពីអាជ្ញាធរនៃប្រទេសនោះ )

៣៨- សិទ្ធិតាំងលំនៅដ្ឋានដោយសេរី ( ប៉ុន្តែត្រូវឲ្យសមស្របតាមច្បាប់សំណង់ )

៣៩- សិទ្ធិមានសំណងជំងឺចិត្តក្នុងករណីមានការខុសឆ្លោយខាងយុត្តិធម៌(បើកាត់ទោសជនណាម្នាក់ខុស ត្រូវតែសងជំងឺចិត្តដល់ជននោះវិញ )

៤០- សិទ្ធិរួចផុតពីកិច្ចធ្វើការពិសោធន៍ខាងពេទ្យ ឬ ខាងវិទ្យាសាស្ត្រ ដោយគ្មានការព្រមព្រៀង ( *បើគ្មានការព្រមព្រៀងដោយសេរីពីសាម៉ីខ្លួនទេ គឺមិនអាចធ្វើការពិសោធន៍តាមបែបណាមួយលើជននោះឡើយ* )

៤១- សិទ្ធិរៀបអាពាហ៍ពិពាហ៍ ( *រួមមានសិទ្ធិបដិសេធមិនព្រមរៀបអាពាហ៍ពិពាហ៍ដោយគ្មានការសុខចិត្តដោយសេរី និងពេញលេញពីសាម៉ីខ្លួន* )

៤២- សិទ្ធិមិនឲ្យគេដកហូតទ្រព្យសម្បត្តិតាមអំពើចិត្ត ( *គឺដកហូតដោយគ្មានដីកាបញ្ជាពីតុលាការ* )

៤៣- សិទ្ធិរួចផុតពីការជាប់ពន្ធនាគារដោយសារការជំពាក់បំណុលគេ ( *គឺមិនត្រូវយកមនុស្សទៅដាក់គុកដោយសាររឿងជំពាក់បំណុលឡើយ* )

៤៤- សិទ្ធិមិនត្រូវគេនិរទេស ដោយគ្មានដីកាបញ្ជាពីតុលាការ ( *គឺមានតែស្ថាប័នតុលាការទេ ដែលមានអំណាចសម្រេចនិងចេញដីកានិរទេសមនុស្ស* )

៤៥- សិទ្ធិចាកចេញពីប្រទេសរបស់ខ្លួន និងសិទ្ធិត្រឡប់ចូលមកក្នុងប្រទេសខ្លួនវិញ

៤៦- សិទ្ធិមិនចូលបំរើកងទ័ព ដោយសំអាងទៅលើលទ្ធិ ឬជំនឿសាសនាអ្វីមួយ ។

ខ. សិទ្ធិនយោបាយ

១- សិទ្ធិបញ្ចេញមតិដោយសេរី ( *រួមទាំងសេរីភាពសារពត៌មានផងដរាបណាមិនប៉ះពាល់ដល់សិទ្ធិអ្នកដទៃ* )

២- សិទ្ធិរួមប្រជុំដោយសេរី ( *គឺមិនត្រូវហាមមនុស្សមិនឲ្យរួមប្រជុំគ្រប់បែបដោយសន្តិវិធីឡើយ* )

៣- សិទ្ធិបង្កើតសមាគមដោយសេរី ( *គឺមិនត្រូវហាមមិនឲ្យបង្កើតសមាគមគ្រប់បែប* )

៤- សិទ្ធិបោះឆ្នោត ( *សមស្របតាមច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់បោះឆ្នោត* )

៥- សិទ្ធិចូលរួមក្នុងឆាកនយោបាយ ( *សិទ្ធិធ្វើយុទ្ធនាការសម្រាប់គណបក្សនយោបាយ និងសិទ្ធិចូលរួមក្នុងបក្សនយោបាយ* )

៦- សិទ្ធិបោះឆ្នោតដោយសេរី និងទៀងទាត់ ( *គឺត្រូវមានការបោះឆ្នោតតាមកាលកំណត់ទៀងទាត់ ហើយមិនត្រូវឲ្យមានការបង្ខិតបង្ខំ ឬលួងលោមបញ្ឆោត* )

៧- សិទ្ធិមានលទ្ធភាពស្មើគ្នា ចំពោះសេវាកម្មសាធារណៈ
(រួមទាំងសិទ្ធិទទួលការជ្រើសរើស ឲ្យកាន់តំណែងការងារ)

គ. សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌

១- សិទ្ធិមានការងារធ្វើ (គឺសង្គម និងរដ្ឋមានភារកិច្ចបង្កើតការងារសម្រាប់ពលរដ្ឋធ្វើ ដើម្បីចិញ្ចឹមជីវិត បើពលរដ្ឋគ្មានការងារធ្វើ កំហុសត្រូវធ្លាក់លើសង្គម និងរដ្ឋ)

២- សិទ្ធិជ្រើសរើសការងារ(គឺមិនបង្ខំឲ្យធ្វើការងារដោយផ្ទុយនឹងឆន្ទៈឬផ្ទុយពីសមត្ថភាព នឹងមុខជំនាញឡើយ)

៣- សិទ្ធិមានទ្រព្យសម្បត្តិជាកម្មសិទ្ធិ (ការដាក់ជាសម្បត្តិរួមដូចសម័យខ្មែរក្រហម គឺជាការរំលោភមួយ)

៤- សិទ្ធិមានកំរិតជីវភាពរស់នៅសមរម្យ (ក្រៅពីបុគ្គលផ្ទាល់ សង្គមនិងរដ្ឋមានកាតព្វ-កិច្ចបង្កលក្ខណៈឲ្យមនុស្សគ្រប់គ្នាអាចរស់នៅបានក្នុងសេចក្ដីថ្លៃថ្នូរ)

៥- សិទ្ធិមានលទ្ធភាពក្នុងការសិក្សា (មនុស្សគ្រប់រូបត្រូវតែមានចំណេះដឹង ។ សង្គម និងរដ្ឋ មានកាតព្វកិច្ចចាំបាច់ធ្វើឲ្យពលរដ្ឋគ្រប់គ្នាបានរៀនសូត្រ)

៦-សិទ្ធិបង្កើតគ្រួសារ(ការរៀបចំគ្រួសារត្រូវមានការព្រមព្រៀងដោយសេរីពីភាគីទាំង សងខាង មិនត្រូវបង្ខិតបង្ខំឡើយ)

៧- សិទ្ធិគោរព និងការពារគ្រួសារទុកជាក្រុមដ៏សំខាន់របស់សង្គម (រដ្ឋត្រូវមានច្បាប់ ការពារខ្លឹមសារនេះ)

៨- សិទ្ធិមានសន្តិសុខសង្គម (សង្គមនិងរដ្ឋមានកាតព្វកិច្ចផ្ដល់សន្តិសុខនិងនិរភ័យដល់ មនុស្សក្នុងសង្គម ពោលគឺត្រូវជួយដោះទុក្ខដោយឧបត្ថម្ភនូវសេចក្ដីត្រូវការចាំបាច់ របស់មនុស្សក្នុងសង្គម)

៩- សិទ្ធិមានការធានារ៉ាប់រង (គួរឲ្យមានប្រព័ន្ធធានារ៉ាប់រងលើគ្រប់វិស័យ ជាពិសេសគឺ ការធានារ៉ាប់រងលើសុខភាព)

១០- សិទ្ធិមានកិច្ចឧបត្ថម្ភខាងសង្គមកិច្ចនិងពេទ្យ (គឺត្រូវមានប្រព័ន្ធឧបត្ថម្ភក្នុងវិស័យ កិច្ចការសង្គម និងសុខាភិបាល)

**១១- សិទ្ធិមានម្ហូបអាហារគ្រប់គ្រាន់** *(សង្គមនិងរដ្ឋ ត្រូវមានផែនការផលិតនិងណែនាំមនុស្សឲ្យផលិតស្បៀងឲ្យបានគ្រប់គ្រាន់តាមសេចក្ដីត្រូវការ)*

**១២- សិទ្ធិទទួលការការពារខាងសុខភាព** *(ដូចជាការចាក់ថ្នាំការពារនិងការពិនិត្យមើលពីភាវៈនៃរោគរាតត្បាត)*

**១៣- សិទ្ធិមានកិច្ចការពារសតិស្មារតី** *(គឺសង្គមនិងរដ្ឋ ត្រូវមានផែនការបង្ការនិងទប់ស្កាត់កុំឲ្យមនុស្សខូចអារម្មណ៍ ឬបាក់ស្មារតី)*

**១៤- សិទ្ធិមានការសម្រាក និងកំសាន្តកាយ** *(គឺជនណាក៏ដោយមានសិទ្ធិធ្វើការមានកំណត់ពេលម៉ោងត្រឹមត្រូវ និងមានពេលសំរាកកំសាន្ត)*

**១៥- សិទ្ធិចូលរួមដោយសេរីក្នុងជីវភាពវប្បធម៌** *(ផលនៃការបង្កើតបាន ឬការស្រាវជ្រាវវប្បធម៌ត្រូវមានច្បាប់ការពារ)*

## ភារកិច្ចរបស់ពលរដ្ឋ

ប្រជាពលរដ្ឋ មានភារកិច្ចនិងការទទួលខុសត្រូវក្នុងការរស់នៅរួមគ្នាក្នុងសង្គមដើម្បីធ្វើឲ្យមានសុខុមាលភាព និងសន្តិភាពនៃជីវិត ។

### ក/ ភារកិច្ច និងការទទួលខុសត្រូវចំពោះច្បាប់ចរាចរ

ប្រជាពលរដ្ឋម្នាក់ៗ ត្រូវគោរពច្បាប់ចរាចរ ដើម្បី ៖

- ការពារសុវត្ថិភាពដល់អ្នកធ្វើចរាចរ គឺភាពសុខសាន្តជាសាធារណៈនិងរបៀបរៀបរយក្នុងសង្គម ។
- ការពារអាយុជីវិតរបស់ខ្លួន និងគោរពសិទ្ធិរស់រានមានជីវិតរបស់អ្នកដទៃ
- ការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួន និងគោរពសិទ្ធិមានកម្មសិទ្ធិរបស់អ្នកដទៃ ។

### ខ/ ភារកិច្ច និងការទទួលខុសត្រូវចំពោះច្បាប់ក្នុងសង្គម

ច្បាប់គឺជាបញ្ញត្តិ មានភាពទៀងទាត់ត្រឹមត្រូវ កើតឡើងដោយឆន្ទៈប្រជាធិបតេយ្យរបស់ប្រជាពលរដ្ឋភាគច្រើន ដើម្បីការពារផលប្រយោជន៍ប្រជាពលរដ្ឋ ។

ប្រជាពលរដ្ឋ និងអាជ្ញាធរដែលជាបុត្រធីតារបស់ពលរដ្ឋ ត្រូវមានកាតព្វកិច្ចប្រតិបត្តិច្បាប់នោះ ដោយសេចក្ដីពេញចិត្ត ។ ជំពូកទី៣ នៃច្បាប់រដ្ឋធម្មនុញ្ញ បានចែងច្បាស់ពីសិទ្ធិនិងករណីយកិច្ចរបស់ប្រជាពលរដ្ឋ និងរដ្ឋាភិបាលដែលត្រូវបំពេញជាការចាំបាច់ ។

ដូច្នេះ ការគោរពច្បាប់រដ្ឋធម្មនុញ្ញឈ្មោះថាបាន ៖

- គោរពសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ
- ការពារបូរណភាពទឹកដី និងបរិដ្ឋាននៃប្រទេសជាតិ
- ជួយអភិវឌ្ឍ និងថែរក្សា វប្បធម៌សង្គមធម៌និងអរិយធម៌របស់ខ្លួន
- បំពេញកាតព្វកិច្ចផ្ទាល់ខ្លួន គឺបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួនដោយស្វ័យសំរេច។

គ/ <u>យន្តការនៃការលើកស្ទួយសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋ</u>

* សិទ្ធិឯកជន ឬ សិទ្ធិបុគ្គល
* សិទ្ធិសង្គម ឬ សិទ្ធិសហគមន៍
* សិទ្ធិសាធារណៈ ឬ សិទ្ធិជាមូលដ្ឋាននៃរបៀបរៀបរយសង្គម

ការការពារសិទ្ធិឯកជន ត្រូវមានកាតព្វកិច្ច និងការទទួលខុសត្រូវចំពោះសិទ្ធិសង្គម ។ ការ ការពារសិទ្ធិសង្គមត្រូវមានកាតព្វកិច្ច និងការទទួលខុសត្រូវចំពោះសិទ្ធិសាធារណៈ ។

រដ្ឋាភិបាល <u>មានកាតព្វកិច្ច</u>
<u>និងការទទួលខុសត្រូវ</u>ចំពោះប្រទេសជាតិនិងប្រជាពលរដ្ឋដែល
មានមូលដ្ឋានជាគោលដូចខាងក្រោមនេះ ៖

១. ការគោរព និងការទទួលខុសត្រូវចំពោះ<u>*សិទ្ធិមានជីវិត*</u>របស់ប្រជាពលរដ្ឋ

២. ការពារ និងទទួលខុសត្រូវ ចំពោះបូរណភាពដែនដី បរិដ្ឋាន និងសន្តិសុខក្នុងសង្គម

៣. អនុវត្តច្បាប់រដ្ឋធម្មនុញ្ញស្របតាមឆន្ទៈរបស់ប្រជាពលរដ្ឋ និងដឹកនាំស្ថាបនាផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ចនៃប្រទេសជាតិគ្រប់វិស័យ ដើម្បីបំពេញតាមសេចក្ដីត្រូវការរបស់រាស្ត្រ ក្នុងគោលដៅលើកស្ទួយរបបធម្មាធិបតេយ្យ ។

ឃ/ កាតព្វកិច្ចសម្រាប់នរណា ? ពេលណា ?

កាតព្វកិច្ចសម្រាប់ប្រជាពលរដ្ឋខ្មែរ និងអាជ្ញាធរខ្មែរ ។ បើខ្មែរទាំងអស់មិនគោរព មិនធ្វើ មិនគិត មិនការពារ បរិដ្ឋាននៃព្រលឹងជាតិរបស់ខ្លួនទេ តើនរណាអ្នកធ្វើ ? បើមិនចាប់ផ្តើមបំពេញ កាតព្វកិច្ចពីពេលឥឡូវនេះទៅទេ តើចាំដល់ពេលណាទើបអនុវត្ត ?

ដើម្បីដោះស្រាយបញ្ហាក្នុងសង្គមខ្មែរប្រជាពលរដ្ឋម្នាក់ៗត្រូវ :

១. ស្គាល់ខ្លួនឯង និងកាតព្វកិច្ចដែលត្រូវធ្វើចំពោះសង្គម

២. ឈ្វេងយល់ពីសកម្មភាពនយោបាយ និងកាតព្វកិច្ចរបស់រដ្ឋាភិបាលដែលត្រូវបំពេញចំពោះប្រជាពលរដ្ឋ

៣. ព្រះសង្ឃ ត្រូវរៀនសូត្រព្រះត្រៃបិដក យល់ដឹងច្បាស់លាស់ ហើយបំពេញកាតព្វកិច្ច រៀបចំផ្លូវប្រតិបត្តិមួយតាមពុទ្ធបញ្ញត្តិ និងពុទ្ធានុញ្ញាតដែលមាននៅក្នុង «សច្ចធម៌» និង «ពុទ្ធោវាទពិតៗ» ធម៌វិន័យរបស់ពុទ្ធសាសនា មានខ្លឹមសារថ្លៃវិសេសពុទ្ធបរិស័ទ ឬព្រះសង្ឃ ពុទ្ធសាសនិកត្រូវរៀនហើយប្រតិបត្តិផង ពុំមែនសូត្រតែធម៌ហើយនៅមានគំនិតលោភលន់ឡើយ ។

ឃ. សិទ្ធិស្ត្រី

១- សិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នានឹងបុរស (*គឺចំពោះកិច្ចការស្មើគ្នាត្រូវឲ្យទទួលកម្រៃស្មើគ្នា*)

២- សិទ្ធិមានសមភាពខាងផ្លូវភេទ (*គឺភេទណាក៏ដូចភេទណា អាចធ្វើអ្វីៗបានតាមសមត្ថភាពនិងលទ្ធភាព*)

៣- សិទ្ធិមានសមភាពរវាងប្តីប្រពន្ធ(*គឺភាពជាប្រពន្ធមានតម្លៃស្មើគ្នានឹងប្តីក្នុងរង្វង់គ្រួសារ*)

៤- សិទ្ធិទទួលកិច្ចការពារពីការកេងប្រវ័ញ្ច (*គឺសង្គមនិងរដ្ឋ មានកាតព្វកិច្ចការពារកុំឲ្យមានការកេងប្រវ័ញ្ចលើស្ត្រីភេទ តាមគ្រប់មធ្យោបាយ*)

៥- សិទ្ធិទទួលការឈប់សំរាកពេលសំរាលកូន (*គឺត្រូវមានច្បាប់អនុញ្ញាតឲ្យស្ត្រីឈប់សម្រាកពីការងារ ក្នុងពេល មុនពេល និងក្រោយពេលសម្រាលកូន*)

៦- សិទ្ធិរួចផុតពីទោសប្រហារជីវិតក្នុងពេលមានគភ៌ (*ប្រសិនបើមានទោសប្រហារ*

*ជីវិតមនុស្ស, ទោសនេះមិនត្រូវអនុវត្តលើស្ត្រីមានផ្ទៃពោះឡើយ)*

## ការតព្វកិច្ចយើងចំពោះស្ត្រី

ពាក្យស្លោកដែលពោលថា " **ស្ត្រីជាមាតានៃមនុស្សជាតិ** " នៅតែជាសច្ចភាព និងមានតម្លៃគ្រប់សម័យកាល ហើយជាពាក្យពោលដ៏ពិរោះ ងាយស្តាប់ ងាយយល់បំផុត ។

យើងលើកយកតែកាតព្វកិច្ចចំពោះស្ត្រីមកបង្ហាញ ដោយយល់ថា " **ជីវិត និងសុខទុក្ខរបស់ម៉ែគ្រប់រូប ត្រូវបានគេបំភ្លេចអស់រយៈកាលច្រើនជំនាន់មកហើយ** " ។

ក/ <u>ស្ថាប័នរដ្ឋ និងឯកជន</u>

គួរយល់ថា ថ្វីត្បិតតែស្ត្រីភេទមានលក្ខណៈទន់ខ្សោយខាងកម្លាំងកាយមែន ! ប៉ុន្តែកម្លាំងប្រាជ្ញា មិនទន់ខ្សោយឡើយ ។ ជាក់ស្តែងពាក្យថា " **ស៊ូស្លាប់បា កុំឲ្យស្លាប់មេ . . .**" ជាពាក្យបង្ហាញនូវភាពជាក់ស្តែងគ្រប់សម័យកាល ។ ស្ត្រីមេម៉ាយអាចចិញ្ចឹមកូន៨នាក់នៅក្នុងបន្ទុកបាន តែបុរសពោះម៉ាយ កម្រឃើញអាចចិញ្ចឹមកូន២នាក់នៅក្នុងបន្ទុកបានឡើយ ។

ស្ថាប័នរដ្ឋ និងឯកជន គួរជ្រើសរើសមុខការណាដែលប្រើប្រាស់កម្លាំងបញ្ញាច្រើនជាងកម្លាំងកាយសម្រាប់ស្ត្រីជាទូទៅ ។ ពិសេសការងារសំណង់ដែលគេធ្លាប់ជួបប្រទះឃើញស្ត្រីមានផ្ទៃពោះជិតគ្រប់ខែហើយ ត្រូវបង្ខំចិត្តនៅធ្វើការរហូតដល់ថ្ងៃសម្រាលកូននៅក្នុងការដ្ឋានសំណង់។ អំពើនេះពុំមែនចាត់ទុកថា ជាការតស៊ូរបស់មាតា(រូបនោះ)បានឡើយ គួរចាត់ទុកថាជាការធ្វេសប្រហែសរបស់ម្ចាស់ការដ្ឋានសំណង់ ដែលពុំបានយកចិត្តទុកដាក់គិតគូរដល់ស្ត្រីនោះ ។

ខ/ <u>សង្គមគ្រួសារ</u>

តាមធម្មតា សង្គមគ្រួសារខ្មែរភាគច្រើន តែងលើកតំកើង និងចាត់តាំងស្ត្រី (មាតា ឬភរិយា) ថាជា " <u>**មេផ្ទះ**</u> " ។ ពាក្យ " **មេផ្ទះ** " នេះ បានស្រូបយកអ្វីៗទាំងអស់នៅក្នុងផ្ទះឲ្យស្ត្រីជាភរិយា ឬជាមាតា ទទួលបន្ទុកគ្រប់គ្រងរក្សា ។ ដូចនេះ ភរិយា ឬម្តាយមានបន្ទុកយ៉ាងធ្ងន់ក្នុងការឃុំគ្រងផ្ទះ ។ បើនិយាយលំអិត គឺមានការងារយ៉ាងច្រើនអនេកសម្រាប់មេផ្ទះ ដូចជា ៖

- រៀបចំថែទាំទុកដាក់របស់របរផ្សេងៗ ឲ្យមានសណ្តាប់ធ្នាប់រៀបរយតាមផ្នែកតាមក្រុម ។ មួយផ្នែកទៀត ភរិយា ឬមាតា ត្រូវថែទាំសំលៀកបំពាក់ប្តី-កូន-ឪពុក-ម្តាយ និងខ្លួនឯង ដោយបោក-អ៊ុត-ទុកដាក់ទៅតាមក្រុម-តាមផ្នែក ។ល។ ភរិយា ឬមាតា ត្រូវលៃលកចំអិនម្ហូបអាហារតម្រូវតាមចំណង់ចំណូលចិត្តប្តី-កូន ឬឪពុក-ម្តាយ (បើម៉ែ-ឪនៅក្នុងបន្ទុក ) និងមើលថែទាំកូន

ផ្គូតទឹក-លាងលាមក-បញ្ចុកអាហារចំណី ព្រមទាំងការពារថែទាំជម្ងឺក្នុងគ្រួសារ (ដែលអាចកើតមានចៀសមិនផុត) ។ល។ និង ។ល។) ។

ក្នុងបន្ទុកដ៏ធ្ងន់ធ្ងរនេះ បុរសជាឪពុក ជាប្ដី ជាបងប្រុស ប្អូនប្រុស ត្រូវចេះជួយសម្រាលបន្ទុកស្ត្រី ដោយជួយរំលែកការងារណា នៅពេលណាដែលខ្លួនអាចជួយបាន និងត្រូវតែជួយរំលែកជាចាំបាច់ ។ បុរសដែលធ្វើយ៉ាងនេះគឺជាមនុស្សប្រកបដោយភាពថ្លៃថ្នូរ មានស្មារតីខ្ពស់ ។

គ/ ទាហាន - ប៉ូលីស

ទាហាន និងប៉ូលីស (នគរបាល) ក៏មានស្ត្រីភេទនៅក្នុងកងឯកភាពផងដែរ ។ ប៉ុន្តែទាំងអស់គ្នាត្រូវតែមានកាតព្វកិច្ចក្នុងការប្រតិបត្តិចំពោះស្ត្រីភេទជាទូទៅតាមការពាក់ព័ន្ធដល់មុខងារ ឬភារកិច្ចរបស់ខ្លួន (នៅនឹងកន្លែង ឬនៅក្នុងបេសកកម្ម) ផងដែរ ។

- មិនត្រូវប្រើពាក្យសំដីសំឡុត គម្រាមកំហែង ឬពាក្យទ្រគោះបោះបោកចំពោះស្ត្រីភេទឡើយ ។ ព្រោះអ្វីៗដែលយើងធ្វើចំពោះអ្នកដទៃ ក៏អាចជាការអប់រំចំពោះជននោះដែរ ។ យើងសំឡុតកំហែងគេ ក៏ហាក់ដូចជាបង្រៀនគេ ឲ្យចេះប្រើអំពើអាក្រក់អស់ទាំងនេះដែរ ។

- ត្រូវប្រើអាកប្បកិរិយាសុភាពរាបសា ថ្លៃថ្នូរ មានសីលធម៌ខ្ពង់ខ្ពស់សមតាមឯកសណ្ឋាននិងឋានៈរបស់ខ្លួន ពិសេសគោរពតាមប្រពៃណីដ៏ល្អរបស់ជាតិ និងសង្គមខ្មែរ ដែលទន់ភ្លន់ ថ្លៃថ្នូរនិងម៉ឺងម៉ាត់ ។

- ចំពោះសណ្ដាប់ធ្នាប់សង្គម (ប៉ូលីសចរាចរ ប៉ូលីសសេដ្ឋកិច្ច ប៉ូលីសយុត្តិធម៌ ប៉ូលីសសណ្ដាប់ធ្នាប់ ។ល។) ត្រូវមានទំនាក់ទំនងជាមួយស្ត្រីភេទឲ្យបានត្រឹមត្រូវតាមច្បាប់និងក្រិត្យក្រមដែលមានជាធរមាន ហើយដែលខ្លួនបានអប់រំរៀនសូត្រសម្រាប់យកទៅអនុវត្ត ។

- ត្រូវប្រកាន់ខ្ជាប់នូវវិន័យ និងបទបញ្ជា ហើយត្រូវតាំងខ្លួនថាខ្លួនមានឯកសណ្ឋានខុសពីពលរដ្ឋសាមញ្ញនេះ ដោយសារខ្លួនមានអ្វីលើសគេ។ នុ៎ះគឺការចេះដឹងខាងច្បាប់និងមានការគោរពច្បាប់ឥតល្អៀង និងជាអ្នកឲ្យគំរូល្អដល់ពលរដ្ឋជាទូទៅ ដើម្បីគេបានគោរពប្រតិបត្តិតាមគំរូល្អរបស់ខ្លួន ។

## ១. សិទ្ធិកុមារ និង យុវជន

### ១- សិទ្ធិមានឈ្មោះមួយ

២- កុមារកើតពីម្ដាយឥតខាន់ស្លាមានសិទ្ធិដូចគ្នានឹងកុមារដែលកើតពីឪពុកម្ដាយ ក្នុងភាពជាប្ដីប្រពន្ធពេញច្បាប់ដែរ

៣- សិទ្ធិទទួលការសិក្សា (រួមទាំងការសិក្សានៅកំរិតបឋមសិក្សាដោយចាំបាច់ និងឥតបង់ថ្លៃ )

៤- សិទ្ធិទទួលនូវការបណ្ដុះបណ្ដាលខាងវិជ្ជាជីវៈ កម្មសិក្សាដោយឥតគិតថ្លៃ

៥- សិទ្ធិ (នៃយុវជនដែលត្រូវបានចាប់ខ្លួន ) ត្រូវទទួលការអប់រំណែនាំអោយបានប្រសើរឡើងវិញ

៦- សិទ្ធិរួចផុតពីការកាត់ទោសប្រហារជីវិត (រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានដកទោសប្រហារជីវិតនេះចេញ)

៧- សិទ្ធិទទួលកិច្ចការពារមិនឲ្យគេបោះបង់ចោល មិនឲ្យមានអំពើឃោរឃៅ និងមិនឲ្យមានការកេងប្រវ័ញ្ចមកលើខ្លួនកុមារ

៨- សិទ្ធិទទួលកិច្ចគាំពារកុំឲ្យគេប្រើមុនអាយុអប្បបរមាសម្រាប់ការងារ(គឺត្រូវមានច្បាប់ការពារកុំឲ្យមានការជួលកុមារក្រោមអាយុធ្វើការធ្ងន់)

៩- សិទ្ធិមានឱកាសសម្រាប់ការសំរាកនិងកំសាន្ត(សង្គមនិងរដ្ឋត្រូវបង្កលក្ខណៈឲ្យក្មេងៗ មានឱកាសលេងកំសាន្តដើម្បីឲ្យរីកចម្រើនរាងកាយ និងប្រាជ្ញាស្មារតី)

១០ សិទ្ធិទទួលសេវាកម្មខាងសង្គមកិច្ច(គឺសង្គមនិងរដ្ឋត្រូវយកចិត្តទុកដាក់ជាពិសេសដល់កុមារ និងយុវជន ក្នុងការរស់នៅរបស់គេ ក្នុងសង្គម)

សិទ្ធិកុមារត្រង់ប្រការ ៣, ៤, ៥ សំដៅលើសិទ្ធិមានចំណេះដឹងរបស់កុមារ ។

សំណួរ : បុគ្គលណា ស្ថាប័នណា និងអង្គការណាខ្លះមានភារកិច្ចក្នុងការផ្ដល់ចំណេះដឹងដល់កុមារ ?

ចម្លើយ : ដើម្បីគោរពសិទ្ធិមានចំណេះដឹងរបស់កុមារ ពោលគឺដើម្បីឲ្យកុមារគ្រប់ៗគ្នាមានឱកាសបានរៀនសូត្រ កាតព្វកិច្ចត្រូវធ្លាក់មកលើយើងទាំងអស់គ្នា ៖

១- មាតា បិតា

មាតា បិតាត្រូវតែបញ្ជូនកូនប្រុសស្រីទាំងអស់ទៅសាលារៀន ហើយមិនត្រូវដកកូនឲ្យឈប់រៀនមុនពេលកូនរៀនចប់ថ្នាក់មធ្យមសិក្សាឡើយ ។ ការបញ្ឈប់កូនមិនឲ្យរៀនតទៅទៀតគឺជាការរំលោភសិទ្ធិរៀនសូត្ររបស់កុមារ ។

២- *សាលារៀន*

សាលារៀនត្រូវមានលក្ខណៈសមស្របទៅតាមនិយាមគរុកោសល្យ ដើម្បីជួយឲ្យក្មេងអាចទទួលវិជ្ជាបាន ដោយពុំមានការរអាក់រអួល និងដោយពុំប៉ះពាល់ដល់ការរីកលូតលាស់នៃសុខភាពកុមារ ។

៣- *រដ្ឋាភិបាល*

រួមមាន រដ្ឋអំណាចថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក ឃុំ និងភូមិ មានកាតព្វកិច្ចរៀបចំ និងផ្ដល់ទីកន្លែងសមស្របសម្រាប់ការសិក្សា ដូចជាការសាងសង់សាលារៀន ការផ្ដល់គ្រូបង្រៀន និងការឧបត្ថម្ភសម្ភារៈសិក្សាគ្រប់គ្រាន់ជាដើម ។ រីឯប្រាក់បៀវត្សរ៍សម្រាប់គ្រូបង្រៀនសាស្ត្រាចារ្យគ្រប់ជាន់ថ្នាក់ក៏គួរឲ្យមានការពិនិត្យសាជាថ្មីឲ្យបានទាន់ពេល ដោយឈរលើគោលការណ៍ច្បាប់ពលកម្មអន្តរជាតិ (ILO) ដែលចែងថា អ្នកធ្វើការត្រូវតែមានកម្រៃគ្រប់គ្រាន់ សម្រាប់រស់នៅសមរម្យ ។ ប៉ុន្តែក្នុងដំណាក់កាល ដែលប្រទេសនៅមានសេដ្ឋកិច្ចទន់ខ្សោយមិនអាចមានថវិកាសម្រាប់សាងសង់សាលាឲ្យគ្រប់គ្រាន់បាន រដ្ឋាភិបាលគួរឲ្យអាទិភាពទៅលើការអភិវឌ្ឍន៍ធនធានមនុស្ស ជាពិសេសគឺការបណ្ដុះបណ្ដាលគ្រូ - សាស្ត្រាចារ្យ ឲ្យមានចំណេះដឹងខ្ពស់ឡើងមួយកំរិតថែមទៀត ។ គួរបង្កើតឲ្យមានគ្រូចល័ត ឬគ្រូជាព្រះសង្ឃ សម្រាប់ជួយបង្រៀនក្មេងដែលរស់នៅតាមតំបន់ដែលគ្មានសាលារៀន ។

៤- *វត្តអារាម*

វត្តអារាមក៏មានកាតព្វកិច្ចរួមចំណែកក្នុងវិស័យអប់រំបណ្ដុះបណ្ដាលចំណេះដឹងដល់មនុស្សគ្រប់ជាន់ថ្នាក់ដែរ។ គួរបង្កលក្ខណៈឲ្យព្រះសង្ឃជួយក្នុងវិស័យនេះឲ្យបានច្រើន ដូចសម័យបុរាណ ។

៥- *សាលាឈ្នួល*

សាលាឈ្នួលមិនត្រូវគិតតែលុយទាំង ១០០ភាគរយពេកដែរ ។ សាលាឈ្នួលគួរសំចៃកន្លែងរៀនមួយចំនួនតូច ទុកសម្រាប់ផ្ដល់ជាអាហារូបករណ៍ដល់សិស្សក្រីក្រដែលរៀនពូកែហើយដែលមាតា បិតាពុំមានលទ្ធភាពអាចឲ្យសិស្សនេះបន្តវិជ្ជាទៅថ្នាក់ខ្ពស់ទៀតបាន ។

៦- *សមាគមមាតាបិតាសិស្ស*

សមាគមនេះក៏មានភារកិច្ចគិតគូរដល់ក្មេងៗដែលជាកូនអ្នកក្រីក្រផងដែរ ។ មាតាបិតា ទាំងឡាយមិនត្រឹមតែត្រូវគិតអំពីការសិក្សារបស់កូនខ្លួនប៉ុណ្ណោះទេ គេត្រូវរកវិធីជួយសម្រាល បន្ទុកអ្នកក្រីក្រដោយជួយជាវិភាគទានសម្រាប់ការសិក្សានៃកូនអ្នកទាំងនោះផង ។

៧- *អង្គការខ្មែរក្រៅរដ្ឋាភិបាល*

អង្គការខ្មែរក្រៅរដ្ឋាភិបាលទាំងនេះមានភារកិច្ចជួយរំលែកបន្ទុករដ្ឋាភិបាល ក្នុងការកសាង ប្រទេសជាតិមាតុភូមិ ។ វិស័យសិក្សាធិការ ក៏ជាវិស័យដែលអង្គការក្រៅរដ្ឋាភិបាលអាចជួយបាន ច្រើនណាស់ដែរ ។ កត្តាសំខាន់គឺការយោគយល់គ្នា ប្រកបដោយស្មារតីសហប្រតិបត្តិការយ៉ាង ជិតស្និទ្ធ ។

៨- *អង្គការអន្តរជាតិ* រួមមាន ៖

- មជ្ឈមណ្ឌលសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ (UNCHR) ដែលទទួលបន្ទុកខាង វិស័យសិទ្ធិមនុស្ស និងច្បាប់ ។
- អង្គការយូណេស្កូ (UNESCO) ដែលមាននាយកដ្ឋានមួយទទួលបន្ទុកខាងការអប់រំ ។
- អង្គការយូនីសេហ្វ (UNICEF)មាននាយកដ្ឋានមួយទទួលបន្ទុកខាងការអប់រំអំពីសិទ្ធិ កុមារ ។
- ស្នងការជាន់ខ្ពស់អង្គការសហប្រជាជាតិសម្រាប់ជនភៀសខ្លួន (UNHCR) ដែលទទួល បន្ទុកការអប់រំក្មេងៗ ដែលជាកូនជនភៀសខ្លួន ។

## កាតព្វកិច្ចយើងចំពោះកុមារ

ពាក្យថា កុមារជាទំពាំងស្នងឫស្សី ឬយុវជន-យុវតី ជាសសរទ្រូងនៃប្រទេសជាតិជាពាក្យ ដែលអ្នកប្រាជ្ញបុព្វបុរស បានសរុបអត្ថន័យប្រកបដោយខ្លឹមសារគ្រប់គ្រាន់រួចទៅហើយ ។ ដែល ហៅថា កុមារ គឺជនដែលមានអាយុតិចជាង១៨ឆ្នាំ លើកលែងតែច្បាប់នៃប្រទេសខ្លះ បានកំណត់ អាយុតិចជាងនេះ ។

កុមារទាំងពីរភេទ (ទោះកើតចេញពីមាតាប្រភេទណាក៏ដោយ)សុទ្ធតែជាអនាគតនៃពលរដ្ឋ របស់ប្រទេសជាតិមួយជាចាំបាច់ ។ **ការមិនយកចិត្តទុកដាក់គិតគូរចំពោះកុមារ គឺជាការលះបង់ កាតព្វកិច្ចខ្លួនជាពលរដ្ឋរួចទៅហើយ ។**

- គ្រប់ស្ថាប័ន គ្រប់ក្រសួង (ទាំងរដ្ឋទាំងឯកជន) គ្រប់គ្រួសារ ត្រូវតែមានកាតព្វកិច្ចចំពោះកុមារ គឺត្រូវថែទាំ និងការពារកុមារ ។ មិនត្រូវបោះបង់កុមារចោល មិនត្រូវវាយកុមារ និងមិនត្រូវព្រងើយកន្តើយចំពោះកុមារជាដាច់ខាត ។

- សង្គមណា មិនបានយកចិត្តទុកដាក់ថែទាំ និងការពារកុមារ សង្គមនោះនឹងធ្លាក់ចូលក្នុងជ្រោះនៃការវិនាសជាតិខ្លួនដោយខ្លួនឯង ។

- សិទ្ធិកុមារ : យើងគ្រប់គ្នាត្រូវតែចងចាំ និងយកចិត្តទុកដាក់បំពេញកាតព្វកិច្ចដល់គេ (កុមារ) ទាំងនោះ យ៉ាងហោចណាស់ក៏ត្រូវស្គាល់ថា ៖

- កុមារទាំងពីរភេទត្រូវបានទទួលការស្រឡាញ់ថ្នាក់ថ្នម និងបីបាច់រក្សាឲ្យបានដិតដល់ (ពីមាតាបិតា ឬអាណាព្យាបាល ឬពីសង្គម) ។
- ត្រូវតែបានរស់នៅដោយសន្តិភាពជាមួយគ្រួសារ ឬអាណាព្យាបាល
- ត្រូវមានអាហារបរិភោគគ្រប់គ្រាន់
- ត្រូវទទួលការថែរក្សាសុខភាពត្រឹមត្រូវ
- ត្រូវទទួលការអប់រំ និងអភិវឌ្ឍកាយសម្បទា និងបញ្ញាស្មារតី
- មតិកុមារ ត្រូវបានគេយកចិត្តទុកដាក់ស្តាប់ និងគិតគូជាចាំបាច់
- មិនត្រូវបានគេបំពារបំពានលើរាងកាយ លើចិត្តគំនិតនៃកុមារ
- មិនត្រូវបានគេរំលោភខាងផ្លូវភេទ ឬការគាបសង្កត់គ្រប់យ៉ាងលើកុមារ
- មិនត្រូវមានការកេងប្រវ័ញ្ចខាងផ្នែកសេដ្ឋកិច្ច ឬលើកម្លាំងពលកម្មរបស់កុមារ
- មិនត្រូវមានការបង្ខំកុមារឲ្យធ្វើពលកម្មហួសកម្លាំង
- មិនត្រូវមានការជួញដូរកុមារ
- កុមារជនជាតិភាគតិច ត្រូវមានសិទ្ធិប្រើប្រាស់ដោយពេញលេញនូវភាសា,វប្បធម៌អក្សរ សាស្ត្រ និងភាសារបស់ជាតិខ្លួន ។ល។

## ច. សិទ្ធិរបស់កម្មករ

**១- សិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នា** (*គឺទទួលប្រាក់ខែស្មើគ្នាចំពោះការងារដូចគ្នា*)

២- សិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីព (*ដើម្បីការពារប្រយោជន៍ខ្លួន*)

៣- សិទ្ធិ នៃសហជីព ដើម្បីបង្កើតជាសហព័ន្ធ (*គឺសហជីពជាច្រើនអាចរួមគ្នាដើម្បីជាកម្លាំង*)

៤- សិទ្ធិធ្វើកូដកម្ម (*គឺបើកម្មករមិនពេញចិត្តក្នុងប្រការណាមួយគេអាចនាំគ្នាធ្វើកូដកម្មអហិង្សាបាន*)

៥- សិទ្ធិទទួលប្រាក់បៀវត្ស (*នៅពេលមានការឈប់សំរាកស្របច្បាប់*)

៨- សិទ្ធិទទួលប្រាក់បំណាច់ត្រឹមត្រូវ (*តាមច្បាប់កំណត់*)

៩- សិទ្ធិធ្វើការតាមម៉ោងពេលកំណត់

១០- សិទ្ធិមានពេលឈប់សំរាកប្រចាំសប្តាហ៍

១១- សិទ្ធិទទួលនូវសេចក្តីជូនដំណឹងជាមុន (*ស្តីពីការបញ្ឈប់កម្មករពីការងារ*)

១២- សិទ្ធិមានឱកាសស្មើគ្នា (*សម្រាប់ការលើកស្ទួយ លក្ខខណ្ឌធ្វើការងារប្រកបដោយសុខភាព និងសុវត្ថិភាព*)

១៣- សិទ្ធិមានលក្ខខណ្ឌធ្វើការងារត្រឹមត្រូវ

១៤- សិទ្ធិមានការពិគ្រោះយោបល់រួមគ្នារវាងកម្មករ (និយោជិត)និងថៅកែ(និយោជក)

១៥- សិទ្ធិធ្វើការដោយមានជំរកស្នាក់អាស្រ័យ (*ក្នុងកាលៈទេសៈចាំបាច់*)

១៦- សិទ្ធិទទួលការណែនាំខាងវិជ្ជាជីវៈ

## ឆ. សិទ្ធិជនបរទេស

១- សិទ្ធិសុំការជ្រកកោនក្នុងប្រទេសដទៃ

២- សិទ្ធិរួចផុតពីការនិរទេស (*មិនត្រូវគេនិរទេសអោយទៅរស់នៅប្រទេសមួយដែលជីវិត ឬសេរីភាពផ្ទាល់ខ្លួនត្រូវទទួលគ្រោះថ្នាក់ដោយសារតែរឿងពូជសាសន៍ សញ្ជាតិ សាសនា ឋានៈសង្គម ឬការបញ្ចេញមតិខាងនយោបាយ*)

៣- សិទ្ធិដើម្បីជួបជុំគ្រួសារឡើងវិញ (*សិទ្ធិជួបជុំគ្រួសារដែលបែកខ្ញែកគ្នា*)

## ជ. សិទ្ធិរបស់អ្នកទោស

១- សិទ្ធិត្រូវបានចុះឈ្មោះក្នុងបញ្ជីរបស់អ្នកទោស

២- សិទ្ធិត្រូវឲ្យគេទុកដាក់អ្នកទោសតាមប្រភេទ *(អ្នកទោសជាបុរសត្រូវតែដាក់ឃុំឃាំងដោយឡែកពីអ្នកទោសស្ត្រី អ្នកទោសដែលមិនទាន់បានកាត់ទោសតាមច្បាប់ ត្រូវបំបែកពីអ្នកទោសដែលកាត់ទោសរួចហើយ, អ្នកជាប់ពន្ធនាគារដោយសាររឿងរដ្ឋប្បវេណី ត្រូវបំបែកពីឧក្រិដ្ឋជន, យុវជនត្រូវបំបែកពីមនុស្សពេញវ័យ )*

៣- សិទ្ធិមានកន្លែងស្នាក់នៅជាច់ៗពីគ្នា

៤- សិទ្ធិរស់នៅក្នុងបន្ទប់ដែលមានខ្យល់អាកាសចេញចូលគ្រប់គ្រាន់មានឧបករណ៍អនាម័យសម្រាប់ការពារកំដៅ ផ្តេកបន្ទោរ និងសំភារៈផ្សេងៗទៀតសម្រាប់សុខភាព និងអនាម័យ

៥- សិទ្ធិមានសំលៀកបំពាក់ និងមានកន្លែងដេកសមរម្យ

៦- សិទ្ធិមានទឹក និងម្ហូបអាហារគ្រប់គ្រាន់

៧- សិទ្ធិទទួលការហាត់ប្រាណសមស្រប និងសិទ្ធិលេងកីឡា

៨- សិទ្ធិទទួលសេវាកម្មពេទ្យ

៩- សិទ្ធិរួចផុតពីទារុណកម្មនិងរាល់ទណ្ឌកម្មឃោរឃៅដែលនាំឲ្យបាត់តំលៃជាមនុស្ស

១០- សិទ្ធិរួចផុតពីការដាក់ទណ្ឌកម្ម *(រួមមានទាំងវិធានការខាងវិន័យ លើកលែងតែអនុលោមទៅតាមច្បាប់ និងបទបញ្ជា)*

១១- សិទ្ធិធ្វើសំណូមពរ ឬ ដាក់ពាក្យប្តឹងតវ៉ាចំពោះអាជ្ញាធរ

១២- សិទ្ធិទាក់ទងជាមួយគ្រួសារ និងមិត្តភក្តិដែលមានកេរ្តិ៍ឈ្មោះល្អ ដោយការសរសេរឆ្លើយឆ្លង និងការសាកសួរសុខទុក្ខ

១៣- សិទ្ធិទទួលពត៌មានយ៉ាងជាក់លាក់ក្នុងពិភពលោកខាងក្រៅ

១៤- សិទ្ធិប្រើប្រាស់បណ្ណាល័យនៃពន្ធនាគារ

១៥- សិទ្ធិគោរពសាសនា

១៦- សិទ្ធិរក្សាទុកទ្រព្យសម្បត្តិផ្ទាល់ខ្លួន

១៧- **សិទ្ធិទទួលកិច្ចការពារពីសន្តិសុខសាធារណៈ**

១៨- **សិទ្ធិ** ( នៃអ្នកទោសជានារី ) ឲ្យមានតែភ្នាក់ងារនារីតែប៉ុណ្ណោះចូលត្រួតពិនិត្យ

១៩- **សិទ្ធិ** ( នៃអ្នកទោសវិកលចរិតនិងអ្នកទោសដែលមានភាពមិនធម្មតាខាងខួរក្បាល) ត្រូវបញ្ជូនគេទៅកាន់ស្ថាប័នទទួលខុសត្រូវខាងជំងឺសរសៃប្រសាទ ។

ឈ. សិទ្ធិរបស់មនុស្សចាស់

១- **សិទ្ធិរួចផុតពីទោសប្រហារជីវិត** គឺមានទោសធ្ងន់បំផុតត្រឹមជាប់គុកអស់មួយជីវិត

២- **សិទ្ធិដើម្បីមាននិរភ័យសង្គម** គឺរដ្ឋ និងសហគមន៍ត្រូវមានកម្មវិធីសមរម្យសម្រាប់ជួយមនុស្សចាស់

## តើអ្វីខ្លះដែលជាការរំលោភសិទ្ធិ ?

ការរំលោភសិទ្ធិមនុស្សមានពីរបែប :

១- គឺការរំលោភដោយអំពើ, ឧ. **ទារុណកម្ម** គឺជាបទរំលោភដោយប្រព្រឹត្ត, និង

២- គឺការមិនប្រតិបត្តិតាមបញ្ញត្តិច្បាប់និងកម្រងច្បាប់អន្តរជាតិ ឧ.ការ**ខ្វះច្បាប់ហាមប្រាម**ដើម្បីទប់ស្កាត់ទារុណកម្ម ក៏ជាការរំលោភដោយ**មិនប្រតិបត្តិ** ។

ជាសរុប អ្វីៗដែលធ្វើផ្ទុយនឹងខ្លឹមសារនៃកម្រងសិទ្ធិទាំងឡាយខាងលើចាត់ទុកជាការរំលោភសិទ្ធិ ។ ម្យ៉ាងទៀត បើប្រការនៃសិទ្ធិខ្លះទាមទារឲ្យរដ្ឋាភិបាលធ្វើជូនប្រជារាស្ត្រ ហើយរដ្ឋាភិបាលមិនបានបំពេញជូនទេនោះ ក៏ចាត់ទុកជាការរំលោភសិទ្ធិដែរ ។

ពេលណារដ្ឋាភិបាលប្រព្រឹត្តបទរំលោភលើសិទ្ធិរបស់ប្រជារាស្ត្រខ្លួន ក្នុងប្រការណាមួយខាងលើ ពេលនោះសហគមន៍អន្តរជាតិ ជាពិសេសអង្គការសហប្រជាជាតិ នឹងធ្វើរបាយការណ៍បន្ទោស ព្រមាន ឬដាក់ទណ្ឌកម្មរដ្ឋាភិបាល តាមវិធីផ្សេងៗដូចជាការផ្តាច់ជំនួយឬផ្តាច់ចំណងទូតជាដើម ។ រីឯការរំលោភពីសំណាក់បុគ្គលម្នាក់ ទៅលើបុគ្គលម្នាក់ទៀតវិញនោះ ត្រូវរកដំណោះស្រាយតាមរយៈតុលាការប្រចាំសាម៉ីប្រទេស ។

ប៉ុន្តែ តាមប្រពៃណីខ្មែរយើង ការវិវាទមួយចំនួនត្រូវដោះស្រាយបានដោយការសម្របសម្រួលផ្សះផ្សា និងយោគយល់គ្នា ។ នេះប្រហែលជាវិធីល្អជាងគេបំផុត ព្រោះពុំអស់សោហ៊ុយ

និងពេលវេលាច្រើន ហើយគូវិវាទទាំងសងខាងសុខចិត្តសុខកាយ ។ *នេះជា យុត្តិធម៌ដ៏ល្អបំផុត* ។

## ប្រទេសកម្ពុជាបានចុះហត្ថលេខាចូលជាភាគីលើកម្រងសិទ្ធិមនុស្សអ្វីខ្លះ ?

១- ការចូលជាសមាជិកនៃអង្គការសហប្រជាជាតិ បានន័យថា កម្ពុជាបានចុះហត្ថលេខាលើធម្មនុញ្ញអង្គការសហប្រជាជាតិរួចហើយ ។

២- កាលពីថ្ងៃទី ១៩ ខែសីហា ឆ្នាំ ១៩៥០ សម្តេច សឺន សាន តំណាងឲ្យរាជរដ្ឋាភិបាលខ្មែរ បានចុះហត្ថលេខាចូលជាភាគីនៃ*អនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសឧក្រិដ្ឋកម្ម ប្រល័យពូជសាសន៍* ។

៣- កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៨១ កម្ពុជាប្រជាធិបតេយ្យ បានចុះហត្ថលេខាចូលជាភាគីនៃអនុសញ្ញាអន្តរជាតិស្តីពីការបញ្ឈប់ និងផ្តន្ទាទោសឧក្រិដ្ឋកម្ម(ប្រកាន់ពណ៌សំបុរ) អាប៉ាថេត ។

៤- ថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ ១៩៨៣ លោក ខៀវ សំផន តំណាងកម្ពុជាប្រជាធិបតេយ្យ បាន ចុះហត្ថលេខាចូលជាភាគី*អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់ចោលសព្វបែបយ៉ាងនៃការ ប្រកាន់ពូជសាសន៍* ។

៥- ថ្ងៃទី ២០ ខែមេសា ឆ្នាំ ១៩៩២ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ក្រោមព្រះកិច្ចដឹកនាំនៃព្រះករុណា ព្រះបាទ នរោត្តម សីហនុ វរ្ម័ន បានចុះហត្ថលេខាចូលជាភាគីលើ*កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយហើយនិងកតិកាអន្តរជាតិស្តីពីសិទ្ធិសង្គម សេដ្ឋកិច្ច និងវប្បធម៌*។

៦- ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ក្រោមព្រះកិច្ចដឹកនាំនៃព្រះករុណា ព្រះបាទ**នរោត្តម សីហនុ វរ្ម័ន** បានចុះហត្ថលេខាចូលជាភាគីលើ *អនុសញ្ញាប្រឆាំងទារុណកម្ម និងការផ្តន្ទាទោសឬការប្រព្រឹត្តិទាំងឡាយណាដែលឃោរឃៅអមនុស្សធម៌ ឬដែលនាំឲ្យបាត់បង់តម្លៃជាមនុស្ស*, *អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើង ប្រឆាំងនឹងនារីភេទ*, *អនុសញ្ញាស្តីពីសិទ្ធិកុមារ*, *អនុសញ្ញាអន្តរជាតិស្តីពីជនភៀសខ្លួន* និង*ពិធីសារទាក់ទងនឹងស្ថានភាពរបស់ជនភៀសខ្លួន* ។

៧- ប្រទេសកម្ពុជាបានចុះហត្ថលេខាចូលជាភាគីនៃអនុសញ្ញាក្រុងហ្សឺណែវទាំងបួនស្តីអំពីការប្រព្រឹត្តិរបស់ទាហាន ក្នុងគ្រាមានសង្គ្រាម(ខែកក្កដា ឆ្នាំ១៩៥៨)។ អនុសញ្ញាក្រុងហ្សឺណែវទាំងបួនរបស់អង្គការសហប្រជាជាតិឆ្នាំ១៩៤៩
មានគោលការណ៍ធំៗ ៣គឺ ៖

- មនុស្សធម៌
- ស្មើភាពគ្នា
- ភាពមិនលំអៀង

+ អនុសញ្ញាទី១ : ស្តីពីយុទ្ធជនដែលត្រូវរបួស ឬឈឺថ្កាត់នៅលើសមរភូមិ ។

+ អនុសញ្ញាទី២ : ស្តីពីយុទ្ធជនដែលត្រូវរបួស ឈឺថ្កាត់ហើយនិងទូក ឬនាវាលិចលង់នៅកណ្តាលទន្លេ ឬសមុទ្រ ។

+ អនុសញ្ញាទី៣ : ស្តីពីការប្រព្រឹត្តិទៅលើឈ្លើយសង្គ្រាម ។

+ អនុសញ្ញាទី៤ : ស្តីពីកិច្ចការពារបុគ្គល និងជនស៊ីវិលក្នុងពេលសង្គ្រាម ។

## ការចូលជាភាគីនៃអនុសញ្ញាអន្តរជាតិបានប្រយោជន៍អ្វីខ្លះ ?

ការចុះហត្ថលេខាលើកម្រងសិទ្ធិមនុស្ស មានន័យថាចូលជាភាគីក្នុងកតិកាសញ្ញា និងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស ។ កន្លងមកប្រទេសកម្ពុជាបានចូលជាភាគីក្នុងកតិកាសញ្ញានិងអនុសញ្ញាអន្តរជាតិចំនួន១៤ រួចហើយ ។

ការចូលជាភាគីនៃកម្រងច្បាប់អន្តរជាតិ បានន័យថាប្រទេសខ្មែរបានចូលជាសមាជិកនៃសហគមន៍អន្តរជាតិ មិននៅដាច់តែលតោលតែឯងក្រៅសៃរៀនពិភពលោកឡើយ ។

ការចូលជាភាគីនៃបរិធានច្បាប់អន្តរជាតិ ក៏មានន័យថា ត្រូវប្រតិបត្តិតាមបញ្ញត្តិនានា ដែលមានចែងនៅក្នុងមាត្រាទាំងឡាយនៃច្បាប់អស់ទាំងនោះ ។ ច្បាប់ខ្មែរទាំងអស់ដែលសភាអនុម័តត្រូវតែស្របតាមខ្លឹមសារនៃបញ្ញត្តិទាំងនោះជាកំហិត ។ ការមិនប្រតិបត្តិតាមអាចបណ្តាលឲ្យមានការព្រមាន ឬទណ្ឌកម្មពីសំណាក់ភាគីអន្តរជាតិឯទៀតៗ ។ ការដាក់ទណ្ឌកម្ម ឬព្រមានទាំងនោះអាចប៉ះពាល់ដល់ទំនាក់ទំនងអន្តរជាតិ រវាងប្រទេសកម្ពុជា និងប្រទេសជាភាគីដទៃទៀត ក្នុងវិស័យនយោបាយ និងសេដ្ឋកិច្ច ។

ប៉ុន្តែបើប្រតិបត្តិបានល្អ កម្ពុជាយើងនឹងទទួលបាននូវការសរសើរ និងគាំទ្រប្រកបដោយ

កិត្តិយស ជាពិសេសពីសំណាក់ប្រទេសប្រជាធិបតេយ្យ ទាំងតូចធំលើសកលោក ។

## សិទ្ធិទាំងអស់នេះឈរលើមូលដ្ឋាននៃតម្លៃ ៨ យ៉ាង

១- **ជីវិត** ( *មិនត្រូវសម្លាប់, តែត្រូវទ្រទ្រង់ និងការពារជីវិតឥតធ្វេសប្រហែស* )

២- **សេរីភាព** ( *ត្រូវមានព្រំដែនពីរ គឺត្រូវប្រើតាមលទ្ធភាពផ្ទាល់ខ្លួន និងមិនត្រូវប្រើឲ្យប៉ះពាល់ដល់សេរីភាពអ្នកដទៃ* )

៣- **សមភាព និងមិនរើសអើង** ( *គឺទទួលស្គាល់និងគោរពតម្លៃមនុស្សគ្រប់ៗរូបស្មើៗគ្នា ព្រមទាំងមិនប្រកាន់ពូជសាសន៍ បក្សពួក វណ្ណៈ ឋានៈ ពណ៌សម្បុរ សាសនា* )

៤- **យុត្តិធម៌** ( *ត្រូវមានច្បាប់សម្រាប់រក្សាយុត្តិធម៌ក្នុងសង្គមឲ្យបានគ្រប់គ្រាន់* )

៥- **សាមគ្គីភាព** ( *ទាំងកាយ វាចា ចិត្ត ប្រព្រឹត្តស្មោះត្រង់គ្មានលាក់លៀម គឺតម្លាភាព* )

៦- **ការទទួលខុសត្រូវក្នុងសង្គម** ( *ម្នាក់ៗមានកាតព្វកិច្ចចំពោះខ្លួនឯងផង ចំពោះសង្គមផង* )

៧- **សន្តិភាព អហិង្សា** ( *ដើម្បីអ្វីៗខាងលើសម្រេចទៅកើត ត្រូវមានសន្តិភាពក្នុងចិត្ត និងអហិង្សាក្នុងអំពើគ្រប់យ៉ាង* )

៨- **ការគោរពមនុស្ស សត្វ និងធម្មជាតិ រុក្ខជាតិ** ( *ពិភពនៃមនុស្សជាតិអាចគង់វង្សស្ថិតស្ថេរទៅកើត អាស្រ័យដោយការគោរពចំពោះមនុស្ស សត្វ និងចំពោះធម្មជាតិ ដូចជាព្រៃព្រឹក្សា ទន្លេ ស្ទឹង បឹងបួរ ដែលជាសេចក្ដីត្រូវការចាំបាច់របស់មនុស្ស* ) ។

**ការបញ្ចូលវិជ្ជាសិទ្ធិមនុស្សក្នុងកម្មវិធីសិក្សានានា គឺជា សកម្មភាពមួយនៃការយកចិត្តទុកដាក់ចំពោះខ្លឹមសារសិទ្ធិមនុស្ស និងការអភិវឌ្ឍន៍ជាតិ ហើយក៏ជាមោទនភាពជាតិ ជួយទ្រទ្រង់ខ្មែរយើងឲ្យមានមុខមាត់ប្រកបដោយកិត្តិយស នៅលើឆាកអន្តរជាតិ**

# សិទ្ធិនយោបាយទាក់ទងនឹងការបោះឆ្នោត

(អត្ថបទដកស្រង់អំពីកម្រងឯកសារអន្តរជាតិមួយចំនួន)

សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ ១៩៤៨

មាត្រាទី២១

១. ជនគ្រប់រូបមានសិទ្ធិរួមចំណែកក្នុងកិច្ចការរដ្ឋាភិបាលនៃប្រទេសរបស់ខ្លួន ដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងដែលខ្លួនបានជ្រើសរើសដោយសេរី ។

២. ជនគ្រប់រូបមានសិទ្ធិទទួលយកដោយសមភាពនូវសេវាកម្មសាធារណៈ នៅក្នុងប្រទេសរបស់ខ្លួន ។

៣. ឆន្ទៈរបស់ប្រជាពលរដ្ឋ គឺជាមូលដ្ឋាននៃអំណាចរបស់រដ្ឋាភិបាល ។ ប្រការនេះនឹងត្រូវសំដែងឡើងនៅក្នុងការបោះឆ្នោតសេរី និងយុត្តិធម៌ ហើយការបោះឆ្នោតនេះត្រូវមានលក្ខណៈជាសាកល(នៅទូទាំងប្រទេស) និងមានសមភាព (គឺម្នាក់ៗបោះឆ្នោតក្នុងចំនួនសន្លឹកឆ្នោតស្មើគ្នា) ហើយត្រូវធ្វើឡើងដោយសន្លឹកឆ្នោតជាសម្ងាត់ ឬដោយទម្រង់ការបោះឆ្នោតដោយលក្ខណៈសេរី ប្រហាក់ប្រហែលគ្នាណាមួយនោះ ។

អនុសញ្ញាស្តីពីសិទ្ធិនយោបាយរបស់ស្ត្រី ឆ្នាំ១៩៥២

មាត្រាទី ១

ស្ត្រីមានសិទ្ធិបោះឆ្នោតនៅក្នុងការបោះឆ្នោតនានា ដោយលក្ខណៈស្មើភាពជាមួយបុរស ដោយមិនគិតពីការរើសអើងណាមួយឡើយ ។

អនុសញ្ញាស្តីពីការលុបបំបាត់នូវគ្រប់ទម្រង់ទាំងអស់នៃការប្រកាន់ពូជសាសន៍ ឆ្នាំ១៩៦៥

មាត្រាទី ៥

ដោយអនុលោមទៅនឹងកាតព្វកិច្ចជាសារវ័ន្ត ដែលមានចែងនៅក្នុងមាត្រាទី២ នៃអនុសញ្ញានេះ រាល់ប្រទេសជាហត្ថលេខីត្រូវអនុវត្តការហាមឃាត់ និងលុបបំបាត់ចោលការប្រកាន់ពូជសាសន៍គ្រប់ទម្រង់ទាំងអស់ ហើយនិងត្រូវធានានូវសិទ្ធិរបស់ជនគ្រប់រូបដោយមិនបែងចែកពីជាតិសាសន៍ ពណ៌សម្បុរឬដើមកំណើត ជាតិ ឬជាតិពន្ធុដោយស្មើភាពគ្នានៅចំពោះមុខច្បាប់ ជាពិសេសគឺការទទួលបាននូវសិទ្ធិផងទាំងឡាយដូចមានខាងក្រោមនេះ :

.......................................

.......................................

គ. សិទ្ធិនយោបាយ ជាពិសេសសិទ្ធិចូលរួមក្នុងការបោះឆ្នោតទៅបោះឆ្នោត ហើយនិងឈរឈ្មោះឲ្យគេបោះឆ្នោត - ដោយឈរលើមូលដ្ឋាននៃការបោះឆ្នោតជាសាកល និងស្មើភាព ដើម្បីរួមចំណែកក្នុងរដ្ឋាភិបាល ព្រមទាំងនៅក្នុងការ ប្រតិបត្តិកិច្ចការសាធារណៈនៅគ្រប់កម្រិតទាំងអស់ ហើយសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់សេវាកម្មសាធារណៈ ។

ឃ. សិទ្ធិពលរដ្ឋដទៃទៀត ជាពិសេស :

(VIII) សិទ្ធិក្នុងការនិយាយស្តី និងបញ្ចេញមតិដោយសេរី ។

(IX) សិទ្ធក្នុងការជួបប្រជុំដោយសន្តិវិធី និងការបង្កើតសមាគមដោយសេរី ។

កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦

មាត្រាទី២៥

ដោយមិនគិតពីការបែងចែកដូចដែលមានចែងក្នុងមាត្រាទី២ ហើយនិងដោយមិនគិតអំពីការកម្រិតមិនសមហេតុផលនានា ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិ និងមានឱកាសក្នុងការ :

ក. រួមចំណែកក្នុងការប្រតិបត្តិនៃកិច្ចការសាធារណៈដោយផ្ទាល់ ឬតាមរយៈតំណាងដែលខ្លួនបានជ្រើសរើសដោយសេរី ។

ខ. បោះឆ្នោត និងឈរឈ្មោះបោះឆ្នោតនៅក្នុងការបោះឆ្នោតជាសមាជិកដ៏ត្រឹមត្រូវដែលជាការបោះឆ្នោតមានលក្ខណៈសាកល និងសមភាព ហើយដែលធ្វើឡើងដោយសន្លឹកឆ្នោតសម្ងាត់ ដោយធានានូវការបញ្ចេញមតិដោយសេរីតាមឆន្ទៈរបស់អ្នកបោះឆ្នោត ។

គ. ទទួលបានដោយលក្ខណៈស្មើភាពជាទូទៅនូវសេវាកម្មសាធារណៈ នៅក្នុងប្រទេសរបស់ខ្លួន ។

អនុសញ្ញាស្តីពីការលុបចំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ ឆ្នាំ១៩៧៩

មាត្រាទី៧

ប្រទេសជាហត្ថលេខីទាំងអស់ត្រូវចាត់វិធានការដ៏ត្រឹមត្រូវទាំងឡាយ ដើម្បីលុបចំបាត់នូវរាល់ការរើសអើងប្រឆាំងស្ត្រី នៅក្នុងឆាកនយោបាយនិងជីវភាពសាធារណៈរបស់ប្រទេសខ្លួន

ហើយជាពិសេសត្រូវធានាដល់ស្ត្រី ដោយឈរលើលក្ខណៈស្មើគ្នាជាមួយនឹងបុរស នូវសិទ្ធិទាំងឡាយដូចខាងក្រោមនេះ :

ក. បោះឆ្នោតនៅក្នុងការបោះឆ្នោតនានា និងក្នុងការបោះឆ្នោតប្រជាមតិ ជាសាធារណៈ ហើយមានសិទ្ធិសម្រាប់ទទួលការជ្រើសរើសឲ្យទៅ បម្រើនៅក្នុងស្ថាប័ននៃមន្ត្រីដែលជាប់ឆ្នោតជាសាធារណៈ ។

ខ. ចូលរួមចំណែកនៅក្នុងការបង្កើតគោលនយោបាយរបស់រដ្ឋាភិបាល ហើយនិងការអនុវត្តន៍គោលនយោបាយនោះ ហើយនិងកាន់តំណែងក្នុងរាជការ ព្រមទាំងអនុវត្តនូវមុខងារសាធារណៈទាំងអស់នៅគ្រប់កម្រិតរបស់រដ្ឋាភិបាល ។

គ. ចូលរួមចំណែកនៅក្នុងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនានា ដែលយកចិត្តទុកដាក់នៅក្នុងជីវភាពនយោបាយ និងជីវភាព សាធារណៈរបស់ប្រទេសជាតិខ្លួន ។

សេចក្តីប្រកាសរបស់អាមេរិកាំង ស្តីពីសិទ្ធិនិងភារកិច្ចរបស់ប្រជាពលរដ្ឋ ឆ្នាំ១៩៤៨

មាត្រាទី២០

ពលរដ្ឋស្របច្បាប់គ្រប់រូប មានសិទ្ធិចូលរួមចំណែកនៅក្នុងរដ្ឋាភិបាលរបស់ប្រទេសខ្លួនដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងរបស់ខ្លួន ហើយនិងចូលរួមចំណែកក្នុងការបោះឆ្នោតជាសាធារណៈ ដែលត្រូវធ្វើឡើងដោយសន្លឹកឆ្នោតជាសម្ងាត់ ហើយដោយផ្ទាល់ តាមកាលកំណត់ជាក់លាក់ និងដោយសេរី ។

អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៥០ ពិធីសារទី ១

មាត្រាទី៣

ភាគីជាហត្ថលេខីជាន់ខ្ពស់នៃអនុសញ្ញានេះ ត្រូវតែរៀបចំការបោះឆ្នោតដោយសេរីតាមរយៈពេលដ៏សមរម្យណាមួយដោយសន្លឹកឆ្នោតសម្ងាត់ ហើយនៅក្រោមលក្ខខណ្ឌដែលនឹងធានាដល់ការបញ្ចេញមតិដោយសេរីរបស់ប្រជាពលរដ្ឋ ក្នុងការជ្រើសរើសក្រុមនីតិបញ្ញត្តិ ។

អនុសញ្ញាអាមេរិកាំងស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៦៩

មាត្រាទី២៣ : សិទ្ធិរួមចំណែកនៅក្នុងរដ្ឋាភិបាល

១. ប្រជាពលរដ្ឋគ្រប់រូបត្រូវមានសិទ្ធិ និងឱកាសដូចខាងក្រោមនេះ :

ក. ចូលរួមចំណែកនៅក្នុងការប្រតិបត្តិនូវកិច្ចការសាធារណៈ ដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងដែលជ្រើសរើសដោយសេរី ។

ខ. ទៅបោះឆ្នោត និងឈរឈ្មោះបោះឆ្នោត នៅក្នុងការបោះឆ្នោតជាក់ស្តែង តាមកាលកំណត់ត្រឹមត្រូវ ដែលជាការបោះឆ្នោតសាកល និងសមភាព ហើយធ្វើឡើងដោយសន្លឹកឆ្នោតសម្ងាត់ ដែលអាចធានានូវការបញ្ចេញឆន្ទៈដោយសេរីរបស់អ្នកបោះឆ្នោតទាំងពួង ។

គ. មានឱកាសទទួលសេវាកម្មសាធារណៈរបស់ប្រទេសខ្លួន ក្នុងលក្ខខណ្ឌស្មើភាពជាទូទៅ ។

២. ច្បាប់អាចដាក់កម្រិតលើការអនុវត្តន៍សិទ្ធិ និងកម្រិតឱកាសនានាដែលពាក់ព័ន្ធទៅនឹងកថាខណ្ឌខាងដើមបាន តែក្នុងករណីណាមានការពាក់ព័ន្ធដល់អាយុ ជាតិ លំនៅដ្ឋានភាសា ការអប់រំ ឋានៈជាពលរដ្ឋ និងផ្លូវចិត្ត ឬការកាត់ទោសដោយតុលាការមានសមត្ថកិច្ចក្នុងឱកាសនៃការធ្វើសវនាការបទឧក្រិដ្ឋនានានោះ ។

ធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាពលរដ្ឋ ឆ្នាំ១៩៨១

មាត្រាទី១៣

១. ពលរដ្ឋគ្រប់រូបមានសិទ្ធិចូលរួមដោយសេរី នៅក្នុងរដ្ឋាភិបាលនៃប្រទេសរបស់ខ្លួនដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងដែលត្រូវបានជ្រើសរើសដោយសេរី ដោយអនុលោមទៅតាមបទបញ្ញត្តិនានារបស់ច្បាប់ ។

២. ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិទទួលយកដោយសមភាព នូវសេវាកម្មសាធារណៈរបស់ប្រទេសខ្លួន ។

៣. បុគ្គលគ្រប់រូបមានសិទ្ធិទទួលយកឱកាសប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈ និងសេវាកម្មសាធារណៈ ក្នុងលក្ខណៈស្មើភាពត្រឹមត្រូវសម្រាប់ប្រជាពលរដ្ឋទាំងអស់នៅចំពោះមុខច្បាប់ ។

# ទិវាបុណ្យអន្តរជាតិសំរាប់សិទ្ធិមនុស្ស

(ថ្ងៃទី១០ ធ្នូ)

## តើយើងគួរធ្វើអ្វីខ្លះ ?

នៅលើពិភពលោកទាំងមូល មនុស្សម្នានាំគ្នាផ្ដោតចិត្តផ្ចិតអារម្មណ៍ទៅលើសិទ្ធិគ្រប់យ៉ាងរបស់ខ្លួន ហើយបានកំណត់យកថ្ងៃទី១០ធ្នូរៀងរាល់ឆ្នាំ ចារិកទុកជា " **ទិវាអន្តរជាតិ** " សម្រាប់ឲ្យមនុស្សទាំងអស់រំលឹកឡើងវិញនូវគុណសម្បត្តិ ដែលគេបានប្រតិបត្តិលើមនុស្សជាតិផងគ្នា ។

ដូចនេះ ថ្ងៃ១០ធ្នូ បានផ្ដល់ឲ្យយើងគ្រប់គ្នាពិចារណាឡើងវិញដើម្បីបង្កើននូវការគោរពសិទ្ធិមនុស្សឲ្យកាន់តែល្អប្រសើរថែមទៀត ។ យើងមានកាតព្វកិច្ចក្នុងការប្រតិបត្តិចំពោះថ្ងៃ១០ធ្នូ តាមមុខនាទីរៀងខ្លួន តាំងពីស្ថាប័នរដ្ឋ, ឯកជន, វត្តអារាម, សាលារៀន, សហគ្រាស, ឬហាងជំនួញធំៗ ។ល។ រហូតដល់គ្រួសារនីមួយៗផងដែរ ។

ក/ <u>នៅតាមស្ថាប័នរដ្ឋ</u> : តាំងពីមន្ទីរសភាជាតិ ទីស្ដីការគណៈរដ្ឋមន្ត្រីគ្រប់ក្រសួងនានា គួរតែចាត់តាំងឲ្យមានពិធីមិទ្ទិញរំលឹកខួបទិវា១០ធ្នូ នៅតាមស្ថាប័ននីមួយៗដោយផ្សព្វផ្សាយដល់បុគ្គលិករាជការ អំពីខ្លឹមសារនៃទិវានេះឲ្យបានជ្រួតជ្រាបគ្រប់ៗគ្នា ។ យ៉ាងហោចណាស់ ក៏ឲ្យបុគ្គលិកយល់ដឹងពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន និងសិទ្ធិរបស់អ្នកដទៃដែរ (ដោយចែកព្រំដែននៃការប្រើប្រាស់សិទ្ធិឲ្យបានត្រឹមត្រូវ) នៅក្នុងស្ថាប័នខ្លួន ។

- គួរបង្កើតឲ្យមានជាសិក្ខាសាលា (មួយពេល) ដើម្បីផ្លាស់ប្ដូរយោបល់គ្នាស្ដីពីទិវាសិទ្ធិមនុស្ស១០ធ្នូ ។

- តាមវិទ្យុ ទូរទស្សន៍ គួរមានកម្មវិធីពិសេស ដូចជានិមន្តធម្មកថិកសំដែងធម៌ទេសនា ល្បែងកំសាន្ត កំណាព្យ ឬឆាកល្ខោនឬគួរបង្កើតឲ្យមានល្បែងប្រជាប្រិយ ស្ដីពីការគោរពសិទ្ធិមនុស្សក្នុងថ្ងៃ១០ធ្នូ ។

- គួរធ្វើទេយ្យទានចំពោះព្រះសង្ឃ ឬមជ្ឈមណ្ឌលកុមារកំព្រា ជនពិការដោយសារសង្គ្រាម (តាមលទ្ធភាពដែលអាចធ្វើបាន) ។

- កងទ័ព នគរបាល ក៏គួរអនុញ្ញាតឲ្យប្រារព្ធពិធីបុណ្យនេះផងដែរព្រោះទាហាននិង

ប៉ូលីសមានតួនាទី និងកាតព្វកិច្ចដ៏ថ្លៃថ្លាបំផុតចំពោះសាធារណជន និងប្រទេសជាតិទាំងមូល ។

ខ/ នៅតាមវត្តអារាម : គណៈកម្មការ អាចារ្យវត្ត ( រួមទាំងព្រះចៅអធិការ ) គួរចាត់តាំងឲ្យមានពិធីចម្រើនព្រះបរិត្ត ឬជយន្តោ . . . រួចសំដែងធម៌ទេសនា ស្ដីពីសិទ្ធិមនុស្សតាមបែបព្រះពុទ្ធសាសនា (ពិសេសសំដែងអំពីនិច្ចសីល ព្រមទាំងអង្គនៃនិច្ចសីល) ជូនពុទ្ធបរិស័ទជាទូទៅ ( ១ពេលល្ងាចថ្ងៃ១០ធ្នូ )។

ពេលព្រឹក គណៈកម្មការគួរបង្កើតឲ្យមានទេយ្យទាន ឬចង្ហាន់ និងល្បែងប្រជាប្រិយ៍ ដូចជា៖ ចោលឈូង លោតអន្ទាក់ លាក់កន្សែង ចាប់កូនខ្លែង ។ល។ ក្នុងក្របខ័ណ្ឌគោរពសិទ្ធិមនុស្ស (ពោល គឺចាស់ព្រឹទ្ធាចារ្យចាំពន្យល់ពីខ្លឹមសារនៃល្បែងនីមួយៗ) នេះសម្ដែងឲ្យឃើញថា បុព្វបុរសខ្មែរយើង លោកចង់បង្រៀនយើងឲ្យមានការគោរពសិទ្ធិគ្នាទៅវិញទៅមកតាំងពីបុរាណកាលម្ល៉េះ ។ តែពុំគួរអនុញ្ញាតឲ្យមានលក់គ្រឿងស្រវឹង ឬល្បែងស៊ីសងជាដាច់ខាត (ក្នុងថ្ងៃនោះ) ។

គ/ នៅតាមសាលារៀន : ត្រូវឈប់សម្រាកពេញមួយថ្ងៃ(ថ្ងៃ១០ធ្នូ) ទាំងសាលារដ្ឋ និងឯកជន ។

## សំណូមពរ

* លោកគ្រូ-អ្នកគ្រូ ជាប្រភពផ្ទេរចំណេះដឹងឲ្យមនុស្សរាល់រូប មានពុទ្ធិសំខាន់ទី១ ព្រមទាំងជាប្រភពអប់រំទូទៅ សំខាន់ទី២ បន្ទាប់ពីការអប់រំផ្ទាល់របស់អាណាព្យាបាល ។

* ទិវា១០ធ្នូ ជាទិវាប្រកបដោយអភិលក្ខិតកាល របស់មនុស្សជាតិលើពិភពលោក ។ ការមិនរវល់ ឬមិនអើពើចំពោះទិវា១០ធ្នូ គឺជាការបដិសេធចោលនូវភាពនៃខ្លួនជាមនុស្សជាតិនិងបោះបង់ចោលនូវសេចក្ដីថ្លៃថ្នូររបស់ខ្លួនឯង ។

ដូច្នេះ សូមលោកគ្រូ-អ្នកគ្រូ ផ្ដោតការយកចិត្តទុកដាក់ចំពោះអរិយធម៌នៃសិទ្ធិមនុស្ស ៖

១. ប្រារព្ធពិធីរំឭកថ្ងៃបុណ្យសិទ្ធិមនុស្ស១០ធ្នូ នៅគ្រប់សាលារៀនរៀងរាល់ឆ្នាំ

២. ធ្វើបាឋកថាពន្យល់សិស្សអំពីខ្លឹមសារនៃថ្ងៃ១០ធ្នូ នៅពេលមុនថ្ងៃប្រារព្ធពិធីទិវាសិទ្ធិមនុស្សចំនួនមួយថ្ងៃ គឺថ្ងៃទី៩ធ្នូ ។

៣. ណែនាំឲ្យសិស្សពិភាក្សាគ្នាតាមក្រុម នៅថ្ងៃទី៩ធ្នូអំពីសិទ្ធិណាមួយដែលគេ

ចូលចិត្តប្រកបដោយបរិយាសកាសរីករាយរៀងរាល់ឆ្នាំ ។ ការធ្វើដូច្នេះ បង្កើតបានជាទម្លាប់មួយរបស់ជាតិយើង ក្នុងការលើកតម្កើងសេចក្តីថ្លៃថ្នូរ របស់មនុស្សជាតិ ដែលជាបច្ច័យនាំឲ្យមានការអភិវឌ្ឍន៍ធនធានមនុស្ស ហើយ នាំឲ្យកើតមានសន្តិភាពយូរអង្វែងផង ។

នាយកសាលា គួរចាត់លោកគ្រូ-អ្នកគ្រូ ឲ្យនាំសិស្សទៅចូលរួមទិវា១០ធ្នូនៅតាមទីកន្លែង ណាដែលនៅជិតជាងគេ ពិសេសក្នុងវត្តអារាមដែលនៅជិតសាលាជាងគេ (ប្រសិនបើមិនអាចធ្វើ ពិធីនៅតាមសាលានីមួយៗបាន) ។

ឃ/ នៅតាមសហគ្រាសនានា : សហគ្រិន (ម្ចាស់សហគ្រាស)នានា ត្រូវគោរពច្បាប់ការងារ តាមក្រសួងការងារសង្គមកិច្ច និងអតីតយុទ្ធជន ពោលគឺត្រូវឲ្យកម្មករបានឈប់សម្រាកពេញមួយ ថ្ងៃ ដោយមិនកាត់ប្រាក់ខែ ។ មិនតែប៉ុណ្ណោះ ត្រូវបង្កលក្ខណៈឲ្យកម្មករបានរៀបចំពិធី " រំលឹក ខួបទិវា១០ធ្នូ " ។

- គួរចាត់ឲ្យធ្វើបដាពាក្យស្លោកស្តីពីសិទ្ធិមនុស្ស
- គួរចាត់ឲ្យមានពិធីជួបជុំរវាងអ្នកដឹកនាំការងារ និងកម្មករ ដើម្បីសំណេះសំណាល គ្នាក្នុងក្របខ័ណ្ឌបង្កើនការគោរពសិទ្ធិគ្នាទៅវិញទៅមក ។

## ប្រជាធិបតេយ្យជាអ្វី ?

ខុសពីរបបកុម្មុយនិស្ត ឬរបបផ្តាច់ការ ប្រជាធិបតេយ្យនៅប្រទេសនានាក្នុងពិភពលោក នេះ មានចំណុចសំខាន់យ៉ាងតិច៨យ៉ាងខាងវិស័យសិទ្ធិនយោបាយ រួមមាន ៖

១. រដ្ឋាភិបាល និងសភាត្រូវកើតឡើងដោយការបោះឆ្នោតទៀងទាត់តាមកាលកំណត់ ។ ក្នុងការបោះឆ្នោតត្រូវមានបក្សនយោបាយច្រើន(ពហុបក្ស) ហើយជាការបោះឆ្នោត ដោយសេរី និងសមធម៌ ។
២. រាស្ត្រគ្រប់រូបមានសេរីភាពក្នុងការនិយាយស្តី ឬបង្កើតសមាគមនិងគោរពសាសនា ។
៣. មានការគ្រប់គ្រងតាមច្បាប់ដែលយកទៅអនុវត្តលើប្រជារាស្ត្រផង លើរដ្ឋាភិបាលផង និងលើស្ថាប័នរដ្ឋនានាផង ។
៤. ពលរដ្ឋទាំងអស់មានលក្ខណៈស្មើគ្នានៅចំពោះមុខច្បាប់ (ពោលគឺច្បាប់ការពារពលរដ្ឋ ទាំងអស់ស្មើៗគ្នា ហើយបើមានអ្នកប្រព្រឹត្តបទល្មើស ច្បាប់ផ្តន្ទាទោសស្មើៗគ្នាមិនថា

អ្នកមាន ឬអ្នកក្រ រាស្រ្ត ឬមន្ត្រីឡើយ) ។

៥. ពលរដ្ឋស្របច្បាប់មានសិទ្ធិស្មើគ្នាក្នុងការបោះឆ្នោត និងឈរឈ្មោះជាបេក្ខជនឲ្យគេបោះឆ្នោត ។

៦. ពលរដ្ឋមានសិទ្ធិប្រជុំគ្នា ឬធ្វើបាតុកម្មអហិង្សា ឬធ្វើញត្តិដោយសន្តិវិធី

៧. មានអង្គចៅក្រមឯករាជ្យ ពោលគឺជម្រះ ឬកាត់ក្តីដោយឥតលំអៀងនិងដោយគ្មានលុះក្រោមឥទ្ធិពលពីរដ្ឋអំណាចឡើយ ។

៨. សេរីភាពសារពត៌មាន ( *គឺការសំដែងយោបល់តាមឆន្ទៈរបស់ខ្លួន ហើយបើរិះគន់ក៏នៅក្នុងក្របខ័ណ្ឌស្ថាបនា* )

ក្រៅពីសិទ្ធិខាងវិស័យនយោបាយនៅមានសិទ្ធិសំខាន់ៗដទៃទៀតដែលពលរដ្ឋខ្មែរ ចាំបាច់ត្រូវតែមាន ដូចជា ៖

- សិទ្ធិមានការងារធ្វើ , សិទ្ធិមានការអប់រំ , សិទ្ធិមានសុខភាព និងមានផ្ទះសម្បែង ។ រីឯសង្គមមនុស្សក៏មានសិទ្ធិខ្លះដែរ សម្រាប់សង្គមទាំងមូល ដូចជា ៖

- សិទ្ធិមានអាកាស និងទឹកស្អាតព្រមទាំងមានបរិដ្ឋានធម្មជាតិដែលផ្តល់សុខភាព ។

ក្រៅពីការគ្រប់គ្រង និងចាត់ចែងកិច្ចការក្នុងសង្គមប្រជាធិបតេយ្យគឺជាការដែលបុគ្គលមួយរូបៗ ឬអង្គការ ស្ថាប័ននីមួយៗត្រូវចេះទំនាក់ទំនងគ្នានៅក្នុងជីវភាពនយោបាយប្រចាំថ្ងៃ ។ ប្រជាធិបតេយ្យទាមទារឲ្យមនុស្សក្នុងសង្គមមានអត្តចរិតល្អ ពោលគឺចេះអត់ឱនចំពោះអ្នកដែលមានមតិខុសពីខ្លួន ហើយចេះថ្លឹងថ្លែងចំពោះសេចក្តីត្រូវការនៃក្រុមនានាតាមរយៈការពិភាក្សា ឬទស្សនៈដេញដោល ឬការចរចារ ។

# គ្រឿងផ្សំសំខាន់៤យ៉ាង
# សម្រាប់ឲ្យលទ្ធិប្រជាធិបតេយ្យមានដំណើរបានល្អ

១- រដ្ឋធម្មនុញ្ញ ដែលប្រកាន់យកមាគ៌ាប្រជាធិបតេយ្យសេរីពហុបក្ស ។ រដ្ឋធម្មនុញ្ញបច្ចុប្បន្ន នៃរាជាណាចក្រកម្ពុជា មានការគោរព និងការពារសិទ្ធិគ្រប់យ៉ាងដូចបានពោលខាងលើ ជាពិសេស គឺក្នុងជំពូកបីទាំងមូល ពីមាត្រា ៣១ ដល់ មាត្រា៥០ ។ ប៉ុន្តែ បើគ្រាន់តែមានច្បាប់ តែការប្រតិបត្តិមិនបានល្អ ក៏មិនអាចឲ្យលទ្ធិប្រជាធិបតេយ្យមានដំណើរបានល្អដែរ ។

ដើម្បីឲ្យសម្រេចបានសមតាមប្រាថ្នា ត្រូវតែមានគ្រឿងផ្សំសំខាន់ៗឯទៀតៗ ដូចជា ៖

២- តុលាការ ដែលធានានូវ*ឯករាជ្យភាពនៃអង្គចៅក្រម* ដែលជំរះក្តីដោយសុចរិត យុត្តិធម៌ឥតលំអៀង និងហ៊ានធ្វើសេចក្តីសម្រេចដោយឯករាជ្យពិតៗ មិនលុះក្រោមឥទ្ធិពលជនណាឡើយ ។

៣- បណ្តាញផ្សព្វផ្សាយពត៌មានសេរី ប្រាកដនិយម និងឯករាជ្យ ។ កាសែត វិទ្យុ ទូរទស្សន៍ មិនត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលឡើយ ។ បើពុំនោះសោតទេគេនឹងបាត់បង់នូវឯករាជភាព ដែលគេត្រូវការជាចាំបាច់សម្រាប់ឲ្យគេបំពេញភារកិច្ចតាមគោលការណ៍ ។ ជាគោលការណ៍ កាសែត វិទ្យុ ទូរទស្សន៍ ត្រូវតែផ្សព្វផ្សាយជូនសាធារណជនជ្រាបនូវការពិតអំពីអ្វីៗដែល រដ្ឋាភិបាលធ្វើត្រូវ និងអំពីអ្វីៗដែលរដ្ឋាភិបាលធ្វើមិនត្រូវ ។ ហើយគេត្រូវទទួលខុសត្រូវជានិច្ច ចំពោះអ្វីៗដែលគេនិយាយ ឬផ្សាយ ។

៤- បក្សជំទាស់នៅក្នុងសភាជាតិ ។ បក្សជំទាស់នៅក្នុងសភាគឺជាក្រុមអ្នកតំណាងរាស្ត្រក្នុងគណៈបក្សភាគតិច ឬគណៈបក្សចាញ់ឆ្នោត ។ បក្សជំទាស់មានកាតព្វកិច្ចជួយរួមចំណែកកសាងជាតិក្នុងតួនាទី ដូច ឬស្រដៀងគ្នានឹងបណ្តាញផ្សាយពត៌មានដែរ ពោលគឺ ៖

ក- ជួយពិនិត្យលើកិច្ចការទាំងឡាយរបស់រដ្ឋាភិបាល ដើម្បីកុំឲ្យរដ្ឋាភិបាលធ្វើអ្វីដែលផ្ទុយនឹងឆន្ទៈប្រជារាស្ត្រ ឬផ្ទុយនឹងផលប្រយោជន៍ប្រជារាស្ត្រ ។

ខ- បក្សជំទាស់ មិនមែនចាំតែជំទាស់តែប៉ុណ្ណោះទេ ប៉ុន្តែក៏មាននាទីជាអ្នកជួយផ្តល់គំនិត ឬផ្តល់ដំណោះស្រាយមួយផ្សេងទៀត ជាជំនួសដំណោះស្រាយ ដែលខ្លួនបានជំទាស់ ។

គ- ជាអ្នកដែលតម្រូវឲ្យរដ្ឋាភិបាលទទួលខុសត្រូវចំពោះអំពើទាំងឡាយដែលរដ្ឋាភិបាល

បានធ្វើ ។

ឃ- តំណាងឲ្យសម្លេងប្រជារាស្ត្រទាំងឡាយណា ដែលមិនសប្បាយចិត្តចំពោះទង្វើរបស់រដ្ឋាភិបាល ។

កាលបើប្រជារាស្ត្រដឹងថាមានស្ថាប័នមួយនៅក្នុងសភាជាតិ កំពុងតែទាមទាររកយុត្តិធម៌ឲ្យ ហើយពួកគេក៏ពុំសូវមានទំនោរចង់បះបោររំជើបរំជួលឡើយ ។ នេះជាដំណោះស្រាយមួយ តាមបែបអហិង្សា ។ ហើយប្រសិនបើមានការប្រយុទ្ធ ក៏ជាការប្រយុទ្ធនៅក្នុងសាលប្រជុំ ឬសន្និសីទ ដែលគ្មានផ្សែង គ្មានគ្រាប់រំសេវ គ្មានការបង្ហូរឈាម និងគ្មានការបំផ្លិចបំផ្លាញជីវិតជនស្លូតត្រង់ គ្មានការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិជាតិ ។ គឺជាដំណោះស្រាយវិវាទ ដែលភាគីខ្មែរទាំងសងខាងជាអ្នកឈ្នះ ព្រមទាំងនាំមកនូវភាពចម្រុងចម្រើនដល់មាតុប្រទេសដ៏ជាទីស្រឡាញ់ នៃយើងទាំងអស់គ្នា ។ នេះជាការវិវត្តន៍ នៃដំណើរការលទ្ធិប្រជាធិបតេយ្យដ៏ល្អ ។

ប៉ុន្តែដើម្បីឲ្យលទ្ធិប្រជាធិបតេយ្យមានដំណើរល្អផងហើយមាននិរន្តរភាពផងត្រូវតែមានជាដាច់ខាតនូវការបោះឆ្នោតដោយសេរី និងយ៉ាងត្រឹមត្រូវ ។ កំណត់ពេលបោះឆ្នោតនេះ ជាការផ្តល់ឱកាសជូនប្រជាពលរដ្ឋធ្វើសេចក្តីជ្រើសរើសចំពោះអ្វីដែលគេចង់បាន ។ ការជ្រើសរើសតាមការបោះឆ្នោតនេះ ជាយន្តការមួយសម្រាប់បន្ធូរបន្ថយភាពតានតឹងខាងវិស័យនយោបាយ ហើយក៏អាចទប់ស្កាត់មិនឲ្យមានអំពើហិង្សាធំៗកើតឡើងបាន ដូចជារដ្ឋប្រហារ ឬសង្គ្រាមស៊ីវិលជាដើម ។

## ព្រះពុទ្ធសាសនា និងលទ្ធិប្រជាធិបតេយ្យ

*(ស្រាវជ្រាវ និងរៀបរៀងដោយ International Republican Institute (IRI))*

ហេតុអ្វីបានជាយើងត្រូវនិយាយអំពីព្រះពុទ្ធសាសនា និងលទ្ធិប្រជាធិបតេយ្យ ? ដោយ ហេតុថា ចំនួនភាគច្រើននៃប្រជារាស្ត្រ ដែលរស់នៅក្នុងប្រទេសកម្ពុជានាបច្ចុប្បន្ននេះ ជាអ្នកកាន់ព្រះពុទ្ធ-សាសនា ។ ហើយដូចគ្នាផងដែរក្នុងខែឧសភា ឆ្នាំ១៩៩៣ អ្នកដែលមានសិទ្ធិបោះឆ្នោតចំនួន៩០% បានចូលរួមក្នុងការបោះឆ្នោតថ្នាក់ជាតិនេះគឺជាគ្រឹះនៃលទ្ធិប្រជាធិបតេយ្យរបស់ប្រទេសកម្ពុជា ។ ចំនួនអ្នកបោះឆ្នោតអាចត្រូវបានអ្នកកាន់ព្រះពុទ្ធសាសនាបកស្រាយថា ជាឧត្តមប្រយោជន៍ ក្នុងលទ្ធិប្រជាធិបតេយ្យ ។

## លទ្ធិប្រជាធិបតេយ្យពិតប្រាកដមានន័យយ៉ាងដូចម្តេច ?

លទ្ធិប្រជាធិបតេយ្យជាប្រព័ន្ធមួយនៃរដ្ឋាភិបាល ដែលក្នុងនោះប្រជារាស្ត្រជាអ្នកគ្រប់គ្រងដោយខ្លួនឯង ។ លទ្ធិប្រជាធិបតេយ្យចែកចេញជាពីរប្រភេទគឺ : លទ្ធិប្រជាធិបតេយ្យ ផ្ទាល់ និងលទ្ធិប្រជាធិបតេយ្យ ប្រយោល (ឬតំណាង) ។ ក្នុងលទ្ធិប្រជាធិបតេយ្យផ្ទាល់ ប្រជារាស្ត្របោះឆ្នោត និងចូលរួមក្នុងដំណើរការធ្វើសេចក្តីសំរេចចិត្តដោយផ្ទាល់ ។ ក្នុងលទ្ធិប្រជាធិបតេយ្យប្រយោល (ឬ តំណាង) ប្រជារាស្ត្រជ្រើសរើសមេដឹកនាំទាំងឡាយក្នុងពេលបោះឆ្នោត ដើម្បីតំណាងនូវទស្សនៈរបស់គេ ។ ប្រទេសកម្ពុជាបានអនុវត្តប្រព័ន្ធលទ្ធិប្រជាធិបតេយ្យប្រយោល (ឬតំណាង) ជាច្រើនដងហើយ ។

គណបក្សនយោបាយមានសារសំខាន់ណាស់ក្នុងលទ្ធិប្រជាធិបតេយ្យ ។ តាមរយៈការពង្រីកគោលនយោបាយចំពោះបញ្ហាសំខាន់ៗនិងតាមរយៈការគាំទ្រមនោគមវិជ្ជាសំខាន់ៗ គណបក្សនយោបាយ ត្រូវផ្តល់ឲ្យដល់ប្រជារាស្ត្រនូវការបញ្ចេញសម្លេងការជ្រើសរើស និងនិរន្តរភាព ។ ប្រជារាស្ត្រ ដែលស្រឡាញ់កម្មវិធីនយោបាយរបស់គណបក្សមួយ គេនឹងបោះឆ្នោតឲ្យគណបក្សនោះ នេះគឺការបញ្ចេញសម្លេងក្នុងកិច្ចការជាតិ ហើយប្រសិនបើគេមិនស្រឡាញ់កម្មវិធីនយោបាយនោះទេ គេនឹងគាំទ្រគណបក្សផ្សេងទៀតវិញ នេះគឺការជ្រើសរើស ហើយគណបក្សនយោបាយកាន់លទ្ធិ ប្រជាធិបតេយ្យដ៏រឹងមាំ និងស្ថិតស្ថេរជានិច្ច ទោះបីជាមានការផ្លាស់ប្តូរថ្នាក់ដឹកនាំរបស់ខ្លួនក៏ដោយនេះគឺ និរន្តរភាព ។

លក្ខណៈគន្លឹះមួយនៃប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យគឺថា ប្រទេសនោះត្រូវធ្វើការបោះឆ្នោតតាមពេលកំណត់យ៉ាងទៀងទាត់ ដើម្បីនឹងឲ្យប្រជារាស្ត្រអាចធ្វើការសំរេចចិត្តថា តើគេចង់ធ្វើការផ្លាស់ប្តូររដ្ឋាភិបាល និងថ្នាក់ដឹកនាំរបស់គេឬទេ ។

### យើងនាំគ្នានិយាយអំពីព្រះពុទ្ធសាសនា

| | |
|---|---|
| ១. អត្តៈ | (អាត្មា) |
| ២. សទ្ធាៈ | (ការអត់ឱន) |
| ៣. ឧន្នាគារវៈ | (ការគោរព) |
| ៤. កម្មន្តៈ | (អំពើ) |
| ៥. បុច្ឆនៈ | (ចំណោទសួរ) |

អត្ថៈ (អាត្មា) ៖ ក្នុងព្រះពុទ្ធសាសនា អ្នកត្រូវស្វែងរកសច្ចធម៌សម្រាប់ខ្លួនរបស់អ្នកផ្ទាល់ ។ មិនដូចពួកអ្នកកាន់គ្រីស្តសាសនាទេ អ្នកកាន់ពុទ្ធសាសនាមិនត្រូវបានសង្គ្រោះ (ស្រោចស្រង់) ដោយ មនុស្សម្នាក់ទៀតឡើយ ប៉ុន្តែគេត្រូវតែយល់ដឹង និងចេះរកវិធីសង្គ្រោះខ្លួនដោយខ្លួនឯង ។

សង្គហៈ (ការអត់ឱន) ៖ ដោយហេតុថាការត្រាស់ដឹងជាការឈ្វេងយល់ផ្ទាល់ខ្លួន ហើយមនុស្សម្នាក់ៗធ្វើការសំរេចចិត្តផ្សេងៗពីគ្នាក្នុងការស្វែងរកសច្ចធម៌របស់ខ្លួននោះ ទើបព្រះពុទ្ធទ្រង់សម្តែង ថា យើង ត្រូវតែចេះអត់ឱនចំពោះការសំរេចចិត្តផ្សេងៗពីគ្នាទាំងនេះ ហើយជំនឿរបស់អ្នកដទៃ ទៀតក៏វាមានការខុសប្លែកពីជំនឿរបស់យើងដែរ ។

ខន្តាគារវៈ (សេចក្តីគោរព) ៖ ដោយយោលទៅតាមមគ្គសច្ចៈទាំង៨ ដូចជាការគោរពចំពោះអាយុជីវិត ធម្មៈ (ច្បាប់) និងវិន័យបព្វជិតដែលមានសិក្ខាបទ២២៧ គឺជាគន្លឹះសំខាន់ណាស់សម្រាប់ ធ្វើការឈ្វេងយល់ ឬត្រាស់ដឹង ។ បើគ្មានការគោរពទាំងនេះទេ គឺពិតជាមិនអាចធ្វើដំណើរឆ្ពោះ ទៅដល់និព្វានឡើយ ។

កម្មន្តៈ (អំពើ) ៖ ដោយយោងទៅតាមមគ្គសច្ចៈទាំង៨ ក្នុងចំណោមមាគ៌ា៨ រាល់អ្វីដែលអ្នកធ្វើត្រូវតែឆ្លុះបញ្ចាំងនូវ ៖ សម្មាទិដ្ឋិ គឺការយល់ដឹងដោយត្រឹមត្រូវ - សម្មាសង្កប្បៈ គឺការត្រិះរិះដោយត្រឹម ត្រូវ និងសម្មាវាចា គឺការនិយាយដោយត្រឹមត្រូវ ។

សម្មាសកម្មន្តៈ មនុស្សម្នាក់ៗ មិនអាចនិយាយ ថាខ្លួនជាអ្នកកាន់ពុទ្ធសាសនា រួចហើយបែរជាទៅសម្លាប់មនុស្សលោក ឬក៏សត្វពាហនៈសម្រាប់ ការសប្បាយនោះឡើយ ។

បុច្ឆនៈ (ចំណោទសួរ) ៖ ព្រះពុទ្ធទ្រង់សម្តែងថាចំពោះការចោទសួរអំពីសិក្ខាបទ (ការបង្រៀន) របស់ព្រះអង្គគឺ ដើម្បីឲ្យលោកអ្នកបានយល់ដឹងយ៉ាងច្បាស់លាស់អំពីអ្វីទៅជាសច្ចធម៌ ។ ការចោទ ជាសំណួរសួរខ្លួនឯងវាគឺជាវិធីឆ្ពោះទៅកាន់ការឈ្វេងយល់ (ត្រាស់ដឹង) ។

## យើងនាំគ្នានិយាយអំពីលទ្ធិប្រជាធិបតេយ្យ និងព្រះពុទ្ធសាសនា

អាត្មា ៖ ប្រជារាស្ត្រម្នាក់ៗត្រូវតែចូលរួមក្នុងការកសាងលទ្ធិប្រជាធិបតេយ្យដើម្បីឲ្យលទ្ធិប្រជាធិបតេយ្យមានដំណើរការ ។ លោកអ្នកជ្រើសរើសអ្នកដឹកនាំរបស់លោកអ្នកតាមរយៈការបោះឆ្នោត ហើយលោកអ្នកក៏ត្រូវតែដឹងផងដែរអំពីអ្វីដែលរដ្ឋាភិបាលកំពុងធ្វើ ។ ព្រោះថាចំនួន ៩០% នៃប្រជារាស្ត្រកម្ពុជា បានបោះឆ្នោតកាលពីខែឧសភា

ឆ្នាំ១៩៩៣ ហើយពេលនោះប្រទេស កម្ពុជាបានបង្ហាញរួចហើយថា ប្រជារាស្ត្ររបស់ខ្លួនមានឆន្ទៈចង់ចូលរួមក្នុងដំណើរការនយោបាយ ។

ការអត់ឱន : លទ្ធិប្រជាធិបតេយ្យលើកទឹកចិត្តប្រជារាស្ត្រឲ្យចេះគិតដោយខ្លួនឯង ហើយបញ្ចេញមតិ និងទស្សនៈរបស់ខ្លួន ។ ក្នុងលទ្ធិប្រជាធិបតេយ្យ ប្រជារាស្ត្រត្រូវចេះអត់ឱន និងអនុគ្រោះ ចំពោះមតិ និងទស្សនៈដែលផ្សេងគ្នាពីមតិ និងទស្សនៈរបស់ខ្លួន ។ រាល់បាតុភាពផ្សេងៗគ្នា ខាង នយោបាយ អាចដោះស្រាយបានដោយសន្តិវិធី (គឺដោយសន្លឹកឆ្នោត) មិនមែនដោយការប្រើកម្លាំង ឬអំពើហិង្សា (គ្រាប់កាំភ្លើង) ទេ ។

ការគោរព : ក្នុងលទ្ធិប្រជាធិបតេយ្យប្រជារាស្ត្រត្រូវគោរពនូវលក្ខខណ្ឌមួយចំនួនដូចគ្នា និងអ្នកកាន់ពុទ្ធសាសនាដែរ ដូចជាការគោរពចំពោះអាយុជីវិតជាដើម ។ ការគោរពច្បាប់ និងរដ្ឋធម្មនុញ្ញ របស់ប្រទេស ជាបញ្ហាដ៏សំខាន់បំផុតក្នុងលទ្ធិប្រជាធិបតេយ្យ ។ ជនគ្រប់រូបមានភាពស្មើគ្នាចំពោះមុខច្បាប់ ដោយមិនគិតអំពីអ្នកមាន ឬអ្នកក្រ ។

*ហេតុអ្វីបានជាការគោរពច្បាប់របស់ជនគ្រប់រូប មានសារសំខាន់ណាស់ក្នុងលទ្ធិប្រជាធិបតេយ្យ ?* ចូរគិតអំពីបញ្ហានេះក្នុងផ្នែកនៃការធ្វើដំណើរតាមផ្លូវឯកទិស ។ អ្នកបើកបររថយន្តសំរេច ថាខ្លួននឹងមិនស្តាប់បង្គាប់ច្បាប់ចរាចរ ហើយបើកបរបញ្ច្រាសទិសចរាចរនៅលើដងផ្លូវ គាត់អាច បណ្តាលឲ្យមានគ្រោះថ្នាក់ចរាចរ និងធ្វើឲ្យរបួសដល់អ្នកដទៃដោយការមិនគោរពច្បាប់ឬក៏គាត់អាច បណ្តាលឲ្យមានការស្ទះចរាចរ ឬក៏ការពពាក់ពពូនដោយសារតែសកម្មភាពរបស់គាត់ ។

អំពើ : អ្នកនយោបាយទាំងឡាយព្យាយាមជួយប្រទេសរបស់ខ្លួនជារឿយៗ ពួកគេធ្វើការសន្យាតាមវិធីផ្សេងៗជាច្រើន ។ ឧបមាដូចជាព្រះសង្ឃមួយអង្គដែលគេអាចមើលឃើញនូវអំពើល្អ ឬ អាក្រក់ គឺ អាស្រ័យដោយសកម្មភាពរបស់ព្រះសង្ឃអង្គនោះ ។ ដូច្នេះ ប្រសិនបើព្រះសង្ឃអង្គនោះ ឆាន់សុរា ជារៀងរាល់រាត្រីជាមួយស្រីពេស្យា យើងនឹងដឹងថា ព្រះសង្ឃអង្គនោះ មិនបានប្រតិបត្តិតាមមគ្គ (ផ្លូវ) ឆ្ពោះទៅកាន់ការត្រាស់ដឹងឡើយ -- តើអ្នក នយោបាយទាំងឡាយអាចធ្វើដូច្នេះ ដែរឬទេ? ។ ចូរលោកអ្នកប្រឹងស្តាប់នូវអ្វីដែលអ្នកនយោបាយ ទាំងនោះ និយាយ ប៉ុន្តែចូរកុំភ្លេចពិនិត្យអ្វីដែលពួកគេធ្វើផងដែរ ។ មានន័យថា *ធ្វើឲ្យបានច្រើនជាងនិយាយ* ។

ចំណោទសួរ : ក្នុងលទ្ធិប្រជាធិបតេយ្យមនុស្សម្នាក់តែងតែត្រូវការសួរសំណួរផ្សេងៗជានិច្ច : សំណួរទាំងនោះដូចជា ៖ តើរដ្ឋាភិបាលកំពុងធ្វើអ្វីខ្លះ ? - តើច្បាប់ដែលបាននឹងកំពុងអនុម័ត ដោយសភាជាតិនឹងប៉ះពាល់ដល់រូបខ្ញុំយ៉ាងដូចម្តេចខ្លះ ? - តើតំណាងរបស់ខ្ញុំធ្វើការងារបានល្អឬទេ ? គោលបំណងគឺមិនមែនជាការឈ្វេងយល់ ឬ(ត្រាស់ដឹង)

ដោយខ្លួនឯងដូចនៅក្នុងព្រះពុទ្ធសាសនាឡើយ ។ ផ្ទុយទៅវិញ គឺដើម្បីអប់រំលោកអ្នក អំពីគោលនយោបាយនិងសកម្មភាពផ្សេងៗ នៃអ្នកដឹកនាំដែលបានមកកាន់តំណែង ដោយសារឆ្នោតរបស់លោកអ្នកតែប៉ុណ្ណោះ ។

## ការអធិប្បាយប្រៀបធៀបអំពីរទេះមួយទៅនឹងលទ្ធិប្រជាធិបតេយ្យ

ព្រះពុទ្ធទ្រង់សំដែងអំពីរទេះមួយ និងវិធីដែលបុគ្គលរាល់រូបអាចសំគាល់បានថា រាងទាំងមូលនៃរទេះនេះ មានកង់ពីរត្រូវបានភ្ជាប់ទៅនឹងភ្លៅ ដែលជាអង្គសម្រាប់ទ្រតួរទេះ ។ ព្រះពុទ្ធបានមានពុទ្ធដីកាថា ប្រសិនបើរទេះនោះត្រូវបានគេរុះរើចេញជាផ្នែកៗ ហើយចំណែករបស់វាបានដាក់រាយប៉ាយនៅលើដីពេលនោះ គឺពិតជាគ្មាននរណាម្នាក់អាចសំគាល់វាបានថាជារទេះឡើយ ។

ប្រជាធិបតេយ្យ គឺដូចជារទេះនោះដែរ ។ប្រសិនបើយើងប្រើលក្ខណៈនៃប្រជាធិបតេយ្យប្រដូចទៅនឹងផ្នែករបស់រទេះតួយ៉ាងដូចជា : - សិទ្ធិមនុស្សគឺជាកង់ - ការគោរពច្បាប់គឺជាភ្លៅ និងសេរីភាពសារពត៌មានគឺជាតួរទេះ វានឹងអាចងាយស្រួលសំគាល់ នៅពេលរទេះនោះនៅមានរាងទាំងមូល ។ ដូច្នេះដើម្បីឲ្យរទេះអាចដំណើរការទៅបាន វាទាល់តែផ្នែកទាំងអស់នោះនៅជុំគ្នា ។ លទ្ធិប្រជាធិបតេយ្យ មិនអាចចម្រើនទៅមុខបានដែរ ប្រសិនបើភ្លៅ(គឺការគោរពច្បាប់) របស់វាស្ថិតនៅរាយប៉ាយលើដីនោះ ។

## មគ្គសច្ចៈទាំង៤ ក្នុងប្រាំបីដែលឆ្ពោះទៅកាន់ព្រះនិព្វាន

សូមលើកយកនូវសច្ចៈបួនក្នុងវគ្គដំបូងនៃមគ្គសច្ចៈទាំងប្រាំបី ដែលឆ្ពោះទៅកាន់និព្វាន ហើយជជែកវែកញែកបញ្ចូលទៅក្នុងក្របខ័ណ្ឌប្រជាធិបតេយ្យ ជំនួសឲ្យការត្រាស់ដឹង ដែលមានជាអាទិ ៖

១_ សម្មាទិដ្ឋិ ការយល់ឃើញត្រូវតាមសេចក្ដីពិត

២_ សម្មាសង្កប្បៈ ការគិតត្រិះរិះត្រូវតាមសេចក្ដីពិត

៣_ សម្មាវាចា ការនិយាយត្រូវតាមសេចក្ដីពិត

៤_ សម្មាកម្មន្តៈ ការធ្វើការត្រូវតាមសេចក្ដីពិត

សម្មាទិដ្ឋិ : យល់ឃើញត្រឹមត្រូវតាមសេចក្ដីពិត

IRI កំពុងព្យាយាមជួយដល់ពលរដ្ឋកម្ពុជាទាំងអស់ ឲ្យមានការយល់ឃើញត្រឹមត្រូវនូវលទ្ធិប្រជាធិបតេយ្យ ដើម្បីជាគ្រាប់ពូជដែលបានបណ្ដុះ កាលពីការបោះឆ្នោតនាខែឧសភា ឆ្នាំ១៩៩៣ កន្លងទៅនោះ បានរីកលូតលាស់ទៅជាស្ថាប័ន និងជាប្រពៃណីដ៏រឹងមាំទៅថ្ងៃអនាគត។ នៅពេលដែលពលរដ្ឋកម្ពុជាភាគច្រើនបានយល់ដឹងអំពីលទ្ធិប្រជាធិបតេយ្យ ពេលនោះលទ្ធិប្រជាធិបតេយ្យដ៏រឹងមាំមួយនឹងកើតមាននៅក្នុងប្រទេសនេះ ។

សម្មាសង្កប្ប : គិតត្រិះរិះត្រូវតាមសេចក្ដីពិត

អស់លោកត្រូវគិតអំពីរាល់រឿងរ៉ាវដែលយើងបានជជែកគ្នា -- សូមចោទនូវរឿងរ៉ាវនោះ -- ហើយគិតត្រិះរិះអំពីអ្វីដែលអស់លោកសង្ឃឹមថាដើម្បីធ្វើឲ្យបានសំរេចតាមរយៈប្រទេសកម្ពុជាដែល ប្រកាន់យកលទ្ធិប្រជាធិបតេយ្យ ( ឧទាហរណ៍ : ដូចជាធ្វើច្បាប់ឲ្យល្អប្រសើរឡើងនិងមានសម្លេងកាន់តែច្រើនឡើងនៅក្នុងរដ្ឋាភិបាល ) ។

សម្មាវាចា : និយាយត្រូវតាមសេចក្ដីពិត

ព្រះពុទ្ធទ្រង់មានពុទ្ធដីកាថា មិនត្រូវប្រើការនិយាយទៅក្នុងផ្លូវដែលនាំមកនូវទុក្ខទោសឡើយ ។ IRI សង្ឃឹមថាអស់លោក និងប្រើការនិយាយរបស់អស់លោកដើម្បីប្រាប់ទៅអ្នកដទៃអំពីការបណ្ដុះ បណ្ដាល និងខ្លឹមសារនេះ ហើយនិងផ្សព្វផ្សាយទៅអ្នកដទៃទៀត នូវអ្វីដែលអស់លោកបានរៀនសូត្រ។

សម្មាកម្មន្ត : ធ្វើការត្រូវតាមសេចក្ដីពិត

ទោះបីជាលោកអ្នកមានការយល់ឃើញត្រូវ (សម្មាទិដ្ឋិ) មានការគិតត្រិះរិះត្រូវ(សម្មាសង្កប្បៈ) មានការនិយាយត្រូវ(សម្មាវាចា)ក៏ដោយសម្រាប់លទ្ធិប្រជាធិបតេយ្យ វាមិនអាចមានលក្ខណៈគ្រប់គ្រាន់ដោយគ្មានការធ្វើត្រូវ (សម្មាកម្មន្តៈ) នោះបានឡើយ ។ ត្រូវអនុគ្រោះដល់អ្នកដទៃដែលមានទស្សនៈខុសប្លែកពីទស្សនៈផ្ទាល់របស់អ្នក ។ មិនត្រូវគម្រាមកំហែង ឬបំភិតបំភ័យដល់អ្នកដទៃជាដាច់ខាត ។ មិនត្រូវយករបស់អ្វីមួយ ដែលមិនមែនជាកម្មសិទ្ធិរបស់អ្នកជាដាច់ខាត ។

## បញ្ចប់

ប្រទេសអាមេរិកក៏ធ្លាប់មានសង្គ្រាមស៊ីវិលដូចប្រទេសខ្មែរអញ្ចឹងដែរ ។ ប្រទេសអាមេរិកមានសង្គ្រាមស៊ីវិលមួយ ដែលក្នុងនោះបងប្អូនបង្កើតសម្លាប់គ្នាឯងនិងក្រុមគ្រួសារត្រូវនិរាសព្រាត់ប្រាស អស់រយៈពេលយូរអង្វែង ។ ប្រធានាធិបតីអាមេរិកកាំង នៅពេលនោះគឺ លោកអេប្រាហាម លិនកិន (១៨៦០-១៨៦៥) ។ ក្នុងសុន្ទរកថាមួយយ៉ាងខ្លីបន្ទាប់ពីសង្គ្រាមបានចាប់ផ្តើម ប្រធានាធិបតី លិនកិន បានមានប្រសាសន៍ថា ៖ (លទ្ធិប្រជាធិបតេយ្យ) ជារឿយៗ ត្រូវបានគេឲ្យឈ្មោះថាជាការពិសោធន៍មួយ ។ «នៅក្នុងបទពិសោធន៍ខាងនយោបាយរបស់សហរដ្ឋអាមេរិក» គឺចំណុចពីរត្រូវបាន គេដោះស្រាយរួចអស់ហើយ ចំណុចទាំងពីរនោះ គឺ ៖ ១. ការបង្កើតឡើងដោយជោគជ័យ «នៃលទ្ធិប្រជាធិបតេយ្យ» និង ២. ការគ្រប់គ្រង ប្រកបដោយជោគជ័យ «នៃលទ្ធិប្រជាធិបតេយ្យ» ។ ចំណុចមួយដែលមិនទាន់បានទទួលជោគជ័យនៅឡើយ គឺការថែទាំប្រកបដោយជោគជ័យ«នៃលទ្ធិប្រជាធិបតេយ្យ» ។ លោកអ្នកត្រូវយល់ថា លទ្ធិប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជាមានឡើងពីខែឧសភា ១៩៩៣ បានបង្កើតឡើងនូវការបោះឆ្នោត ហើយរាជរដ្ឋាភិបាល គឺស្ថិតនៅក្នុងដំណើរការនៃការគ្រប់គ្រង ។ ប៉ុន្តែលោកអ្នកត្រូវតែចូលរួមនៅក្នុងការថែទាំលទ្ធិប្រជាធិបតេយ្យនេះ ។

## មាគ៌ាណែនាំនៃព្រះពុទ្ធព្រះបរមគ្រូ

យើងត្រូវប្រកាន់ខ្ជាប់នូវធម៌១០យ៉ាង ដើម្បីរក្សាសេចក្តីសុខចម្រើន និងសន្តិភាពសម្រាប់យើងទាំងអស់គ្នា ។

ធម៌ទាំង១០យ៉ាងនោះ គឺ ៖

១. ទានៈ (Charity)ចេះធ្វើអំណោយ (គឺចេះចែកគ្នារស់)

២. សីលៈ (Morality) ចេះធ្វើកាយ វាចា ចិត្ត ឲ្យសុចរិត ទៀតត្រង់ យុត្តិធម៌និងវៀរបង់អំពើអាក្រក់គ្រប់យ៉ាង (មិនធ្វើអាក្រក់)

៣. ចាគៈ (Sacrifice) ចេះលះបង់សេចក្តីកំណាញ់ ហើយបរិច្ចាគទ្រព្យសម្បត្តិកសាងប្រយោជន៍សង្គម ប្រយោជន៍សាធារណៈ (គឺមិនអាត្មានិយម)

៤. អាជ្ជវៈ (Honesty) មានចិត្តត្រង់ ប្រកាន់សច្ចធម៌(គឺនិយាយបែបណាធ្វើបែបនោះ)

៥. មទ្ទវៈ (Softness) ចេះបន្ទន់ឥរិយាបថ និងចិត្តគំនិត (គឺប្រើសំដីពីរោះផ្អែមល្ហែម)

៦. តបៈ (Austerity) ចេះព្យាយាមកំចាត់ចោលនូវសេចក្តីអាក្រក់ចេញពីខ្លួន(ទាំងកាយ

វាចាចិត្ត) ហើយតាំងខ្លួនឲ្យនៅក្នុងអំពើល្អជានិច្ច (គឺរាំងស្កាត់សេចក្ដីអាក្រក់)

៧. **អក្កោធនៈ** (Calmness) មិនសំដែងអាការៈច្រងេងច្រងាង ទទឹងទាស់ (គឺមិនធ្វើឲ្យគេខឹង)

៨. **អវិហឹសា** (Peacefulness) មិនសងសឹក មិនប្រព្រឹត្តបៀតបៀនអ្នកដទៃហ៊ានទទួល ឬឆាប់មើលឃើញទោសកំហុសខ្លួន មិនចាប់កំហុសអ្នកដទៃខុសបែបបទ

៩. **ខន្តី** (Patience) ចេះអត់ធ្មត់ / អត់ធន់

១០. **អវិរោធនៈ** (Respect of the Law) មិនធ្វើអ្វីឲ្យខុសឆ្គងពីគន្លងច្បាប់(គឺគោរពប្រតិបត្តិតាមច្បាប់ជានិច្ច)

ប្រសិនបើយើងមិនបានបំពេញធម៌ទាំង១០នេះឲ្យបានគ្រប់ចំនួនទេ យ៉ាងហោចណាស់ក៏ត្រូវតែមានធម៌៦យ៉ាងគឺ នាយកធម៌:

១. ខមា មានចិត្តលោះលាយ ត្រាប្រណីដល់អ្នកក្រោមបង្គាប់ (អនុគ្រោះទោស)

២. ជាគរិយៈ មានគំនិតផ្តើមមុន (ភ្ញាក់គំនិតមុន) អ្នកក្រោមបង្គាប់

៣. ឧដ្ឋានៈ ខំប្រឹងប្រែងជាងអ្នកដទៃ ស្រវាស្រទេញក្នុងការងារលើសអ្នកក្រោមបង្គាប់

៤. សំវិភាគៈ ចេះបែងចែកផល(លាភការ)តាមសមគួរដល់សមត្ថភាពនៃអ្នកក្រោមបង្គាប់

៥. ទយា មានក្ដីអាណិតដល់អ្នកក្រោមបង្គាប់ឥតរើសមុខ មានប្រាថ្នាតែម្យ៉ាងចង់ឲ្យអ្នកនៅក្រោមបង្គាប់បានសេចក្ដីសុខដូចខ្លួន

៦. ឥក្ខណា គិតសញ្ជឹង រំពៃ ពិនិត្យគ្រប់កិច្ចការរបស់អ្នកក្រោមបង្គាប់បានច្បាស់លាស់ (មិនស្រពិចស្រពិល)

## សំដីអ្នកដឹកនាំរដ្ឋាភិបាលអាមេរិកាំងក្នុងខ្លឹមសារសិទ្ធិមនុស្ស

" ក្រោមបារមីព្រះជាម្ចាស់ នេះជាជាតិដែលត្រូវឲ្យកំណើតថ្មីដល់សេរីភាព ហើយរដ្ឋាភិបាលរបស់ប្រជាជន ដែលបង្កើតឡើងដោយប្រជាជន និងសម្រាប់ប្រជាជន នឹងមិនត្រូវឲ្យលោយបាត់ពីផែនដីឡើយ ។ "

-- Abraham Lincoln

" យើងប្រកាន់ខ្ជាប់នូវសច្ចៈទាំងនេះ ដើម្បីធ្វើជាភស្តុតាងសម្រាប់ខ្លួនឯងថាមនុស្សទាំងអស់កើតមកមានភាពស្មើគ្នា ថាមនុស្សគ្រប់រូបត្រូវបានទទួលសិទ្ធិខ្លះដែលមិនអាចដកហូតបាន ដូចជាសិទ្ធិមានជីវិត មានសេរីភាព ហើយនិងសិទ្ធិមានសុភមង្គល ។ "

-- Thomas Jefferson

" ដូច្នេះ ជនជាតិអាមេរិកាំងទាំងឡាយ កុំសួរថាប្រទេសជាតិអាចធ្វើអ្វីខ្លះ សម្រាប់អ្នកត្រូវសួរថាតើអ្នកអាចធ្វើអ្វីខ្លះជូនប្រទេសជាតិ ។ "

-- John F. Kennedy

" រដ្ឋាភិបាលគឺជាសេចក្ដីទុកចិត្តរបស់យើង ហើយសមាជិកទាំងអស់នៃរដ្ឋាភិបាលជាអ្នកគ្រប់គ្រង ហើយទាំងពីរនេះបង្កើតឡើងសម្រាប់ជាផលប្រយោជន៍របស់ប្រជាពលរដ្ឋ ។ "

-- Henry Clay

" យើងជឿជាក់ថា នៅក្នុងភាពថ្លៃថ្នូរគ្មានទីបញ្ចប់របស់មនុស្សដែលដឹកនាំដោយសីលធម៌អមតៈ និងច្បាប់ធម្មជាតិ . . . រង្វាន់ទាំងឡាយនោះជាសិទ្ធិដែលមិនអាចដកហូតបាន (នៃមនុស្ស...) ។"

-- Dwight David Eisenhower

# សេចក្ដីថ្លែងការណ៍ជាសាកល

## ស្ដីអំពី

# សិទ្ធិមនុស្ស

## កថាដើម

១ - មនុស្សគ្រប់រូបត្រូវដឹងថា នៅក្នុងសង្គមមនុស្សអ្នកណាក៏ដូចអ្នកណាដែរ គឺមានសិទ្ធិស្មើៗគ្នា ។ បើយើងមិនយល់ច្បាស់អំពីរឿងនេះ ហើយមិនអនុវត្តតាមឲ្យបានត្រឹមត្រូវល្អទេ សេរីភាព យុត្តិធម៌ និងសន្តិភាព ប្រាកដជាមិនអាចគង់វង្សបានជាដាច់ខាត ។

២ - សិទ្ធិរបស់មនុស្សជាច្រើនបានត្រូវគេរំលោភ ។ សង្គ្រាមហើយ និងអំពើឃោរឃៅទៀត បានធ្វើទុក្ខបុកម្នេញមនុស្សក្នុងពិភពលោកជាច្រើនឆ្នាំមកហើយ ។ ពិភពលោកដ៏ល្អដែលយើងចង់បាន គឺពិភពលោកមួយដែលមនុស្ស មានសេរីភាពពេញទីក្នុងការនិយាយស្ដី ក្នុងជំជឿសាសនាអ្វីក៏បាន រស់នៅដោយសុខសាន្ត គ្មានភ័យគ្មានព្រួយ ហើយរស់នៅដោយសម្បូរសប្បាយ ។

៣ - ត្រូវតែឲ្យមានច្បាប់សម្រាប់ការពារសិទ្ធិមនុស្ស ។

៤ - គ្រប់ប្រទេសទាំងអស់ក្នុងពិភពលោកត្រូវតែចងមិត្តរវាងគ្នានឹងគ្នា ។

៥ - នៅក្នុងសេចក្ដីថ្លែងការណ៍នេះ ប្រទេសជាសមាជិកនៃអង្គការសហប្រជាជាតិមានជំនឿយ៉ាងមុតមាំទៅលើសិទ្ធិមនុស្ស ។ ព្រោះសិទ្ធិ គឺជាធម្មធាតុសំខាន់ និងមានតម្លៃមួយធ្វើឲ្យមនុស្សគ្រប់រូប ទាំងប្រុស ទាំងស្រី មានភាពស្មើគ្នា ។ ប្រទេសទាំងនោះបានព្រមព្រៀងគ្នា ដើម្បីធ្វើឲ្យរីកចម្រើនដល់សង្គមមនុស្ស និងធ្វើឲ្យការរស់នៅរបស់មនុស្សកាន់តែល្អប្រពៃឡើង ។

៦ - ប្រទេសទាំងឡាយ ដែលជាសមាជិកនៃអង្គការសហប្រជាជាតិបានសន្យាថា នឹងរួមដៃជាមួយអង្គការនេះគ្រប់ពេលវេលា ដើម្បីជួយការពារ និងជួយធ្វើឲ្យមានការគោរពដល់សិទ្ធិមនុស្សគ្រប់ៗគ្នា ។

៧ - ការយល់ច្បាស់អំពីសិទ្ធិ និងសេរីភាពទាំងនេះ មានសារសំខាន់បំផុតសំរាប់ឲ្យប្រទេសនានាគោរពតាមពាក្យសន្យារបស់ខ្លួន ។

## សេចក្តីប្រកាស

មហាសន្និបាតនៃអង្គការសហប្រជាជាតិប្រកាសជាឧឡារិកថា **សេចក្តីថ្លែងការណ៍ជាសាកលអំពីសិទ្ធិមនុស្ស** នេះ ជាការសម្រេចផលរួមមួយ សម្រាប់ជាប្រយោជន៍ដល់មនុស្សរាល់គ្នា និងប្រទេសទាំងអស់ក្នុងលោក ។ ក្នុងន័យនេះ មនុស្សគ្រប់រូបនៅក្នុងសង្គមត្រូវតែខំបំពេញភារកិច្ចឲ្យបានខ្ជាប់ខ្ជួន ដើម្បីឲ្យសម្រេចតាមសេចក្តីប្រាថ្នានេះ ដោយខិតខំបង្ហាត់បង្រៀនគ្នាអំពីការគោរពសិទ្ធិ និងសេរីភាពរបស់មនុស្ស ព្រមទាំងខំបង្កើនគុណភាពច្បាប់សម្រាប់ការពារសិទ្ធិ និងសេរីភាពឲ្យកាន់តែប្រសើរឡើង ។

**ចំណាំ** : សិទ្ធិមានពីរប្រភេទ : សិទ្ធិសម្រាប់មនុស្សម្នាក់ៗ គឺ**សិទ្ធិបុគ្គល**, និងសិទ្ធិសម្រាប់មនុស្សរួមគ្នា គឺ**សិទ្ធិសាធារណៈ** ឬ **សិទ្ធិសង្គម** ។

D CIHR-WOLESS-GG\HRDECLA

## មាត្រា១ មនុស្សរាល់រូបមានតម្លៃស្មើៗគ្នា

ទារកដែលកើតចេញពីផ្ទៃមាតាមក សុទ្ធតែមានរាងរៅខុសៗគ្នា ប៉ុន្តែ មានសេចក្តីថ្លៃថ្នូរ និងសិទ្ធិស្មើៗគ្នា ។ យើងត្រូវបីបាច់ថែរក្សាប្រៀនប្រដៅវាឲ្យបានល្អត្រឹមត្រូវ ដើម្បីឲ្យវាចេះគោរព និងស្រឡាញ់មនុស្សឯទៀតៗ ពេលដែលវាចំរើនវ័យធំឡើង ។

សេចក្តីណែនាំ : មនុស្សរាល់គ្នាពិតជាមិនមានរូបរាងដូចគ្នាបេះបិទ ឬប្រហាក់ប្រហែលគ្នាជានិច្ចនោះទេ ។ ប៉ុន្តែទោះបីមនុស្សមានភិនភាគខុសៗគ្នាទាំងភេទ ពណ៌សម្បុរ រាងរៅ កម្លាំងពលំ សុខភាព ប្រាជ្ញា ស្មារតី សមត្ថភាព គំនិត មារយាទ ព្រមទាំងអ្វីៗទៀតក៏ដោយ ក៏សារជាតិរបស់គេដែលជា មនុស្ស នៅតែ ដូចៗគ្នា ។ មនុស្សទាំងអស់ក្នុងលោកយើងនេះ សុទ្ធតែមានសិទ្ធិ និងសេរីភាពដូចៗគ្នា ។ ដើម្បីរក្សាសិទ្ធិឲ្យនៅមានតម្លៃល្អដូចគ្នាជាដរាបតទៅ យើងត្រូវតែគោរពរាប់អានគ្នាទៅវិញទៅមកឲ្យបានសមរម្យ និងស្មើៗគ្នា ។ នេះបានន័យថា បើយើងចង់ឲ្យគេគោរពយើង យើងត្រូវតែគោរពគេជាមុនសិន ។ ម្នាក់ៗក្នុងនាមជាមនុស្ស យើងសុទ្ធតែចង់ឮនូវពាក្យពីរោះពិសា ផ្អែមល្ហែម ក្នុងន័យគោរពស្រឡាញ់ និងរាប់អានជាមិត្តភក្តិនឹងគ្នា ។ ដូច្នេះ មុននឹងសម្លឹងមើលទៅអ្នកដទៃ គប្បីខិតខំពិនិត្យមើលមកលើខ្លួនឯងជាមុនសិន ។ ព្រោះអ្វីៗក៏ផ្តើមពីខ្លួនឯង ។ ប្រសិនបើខ្លួនឯងនៅមិនទាន់ស្អាតល្អត្រឹមត្រូវទេនោះ គួរកែលំអខ្លួនឯងសិន មុននឹងចាប់កំហុសអ្នកដទៃ ។ នេះគឺជាកាតព្វកិច្ចរបស់យើងទាំងអស់គ្នា ដើម្បីចៀសវាងកុំឲ្យមានការរំលោភសិទ្ធិគ្នាទៅវិញទៅមក ។

ចំណាំ : មុននឹងនិយាយពីភេទ ពណ៌សំបុរ ឋានៈ វណ្ណៈ សញ្ជាតិ សាសនា មតិ ឬជំហរនយោបាយ ទារកដែលកើតពីផ្ទៃមាតាមានសារជាតិដូចៗគ្នា គឺ មនុស្ស ។ ការវាយតម្លៃមនុស្សមិនស្មើគ្នា ជាការប្រាសចាកអំពីគោលការណ៍សិទ្ធិមនុស្ស ហើយគឺជាការរំលោភសិទ្ធិមនុស្សក្នុងមាត្រានេះ ។

## មាត្រា១



មនុស្សរាល់រូបមានតម្លៃស្មើៗគ្នា

## មាត្រា២ ត្រូវចាត់ទុកមនុស្សគ្រប់រូបឱ្យបានស្មើៗគ្នា

ទោះបីអ្នកមកពីស្រុកណាក៏ដោយ សម្បុរខ្មៅ ឬស ក៏ដោយ ស្រី ឬប្រុស ក៏ដោយ និយាយភាសាអ្វីក៏ដោយ កាន់សាសនាអ្វីក៏ដោយ មានទស្សនៈយ៉ាងដូចម្តេចក៏ដោយ មានទ្រព្យ ឬក្រីក្រក៏ដោយ រស់នៅក្នុងប្រទេសណាក៏ដោយ អ្នកត្រូវតែមានសិទ្ធិ និងសេរីភាពទាំងអស់ ដែលមានចែងក្នុងសេចក្តីថ្លែងការណ៍នេះ ។

<u>សេចក្តីណែនាំ</u> : មាត្រានេះរំលឹកដាស់តឿនយើងកុំឲ្យមានការរើសអើងដល់មនុស្សដទៃទៀត ដែលមានសម្បុរ ពូជសាសន៍ សាសនា ឬបក្សពួកខុសពីយើង ។ ច្បាប់ប្រចាំស្រុកនីមួយៗគួរតែគ្រប់គ្រងប្រជារាស្ត្រឲ្យបានស្មើៗគ្នា ទោះបីប្រុសឬស្រី ក្មេងឬចាស់ មានឬក្រ រាស្ត្រឬនាម៉ឺន មិត្តភក្តិឬអ្នកដទៃ មានជំនឿសាសនា ជំហរនយោបាយឬគោលគំនិតខុសគ្នាក៏ដោយ ។ ការបណ្តោយ ឬញុះញង់ឲ្យមានការប្រកែកប្រកាន់គ្នា គឺជាការរំលោភនឹងច្បាប់ ទាំងច្បាប់សង្គម ច្បាប់ស្រុក និងច្បាប់អន្តរជាតិ ។ មនុស្សគ្រប់គ្នាមានសិទ្ធិដើម្បីឲ្យច្បាប់ការពារកុំឲ្យមានការរើសអើង ។

គោលនយោបាយណា ដែលបំបិទសិទ្ធិសេរីភាពរបស់មនុស្ស គឺជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ។ ច្បាប់ដែលមានលក្ខណៈរើសអើង មិនត្រឹមត្រូវល្អសម្រាប់មនុស្សជាតិទេ ។ សិទ្ធិ និងសេរីភាព គឺជាសិទ្ធិចំបងបំផុត ហើយនិងជាខ្លឹមសារនៃការរស់នៅរបស់មនុស្សគ្រប់រូប ។ រស់នៅគ្មានសេរីភាព និងគ្មានសិទ្ធិជាមូលដ្ឋានទាំងពួង គឺជាការរស់នៅស្មើនឹងសត្វតិរច្ឆាន ។ របបគ្រប់គ្រងតែមួយគត់ដែលមនុស្សពាសពេញពិភពលោកកំពុងតែខំបណ្តុះបណ្តាលសព្វថ្ងៃនេះ គឺរបបដែលទ្រទ្រង់លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

<u>ចំណាំ</u> : ការចាត់ទុកមនុស្ស ដោយសំអាងលើភេទ ពណ៌សំបុរ ឋានៈ វណ្ណៈ សញ្ជាតិ សាសនា មតិ ឬជំហរនយោបាយ ឬបក្សពួក គឺជាអាកប្បកិរិយារើសអើងរំលោភទៅលើខ្លឹមសារនៃមាត្រានេះ ។

មាត្រា២



គ្មានចាត់ទុកមនុស្សគ្រប់រូបឲ្យបានស្មើៗគ្នា

D:\CIHR-W\LESS-GG\HRDECLA

## មាត្រា៣ សិទ្ធិមានជីវិតរស់នៅ

សិទ្ធិមានជីវិតរស់នៅ សិទ្ធិរស់នៅដោយសេរី និងសិទ្ធិប្រកបដោយសេចក្ដីសុខសាន្ត គឺជាសិទ្ធិរបស់យើងទាំងអស់គ្នា ។

សេចក្ដីណែនាំ : រដ្ឋាភិបាល ឬរដ្ឋត្រូវមានភារកិច្ចការពារជីវិតប្រជាពលរដ្ឋទាំងអស់ក្នុងប្រទេស ។ ត្រូវបង្ការកុំឲ្យមានការលួចសម្លាប់ ឬការប្រហារជីវិតខុសច្បាប់ ។ ការលុបចោលនូវទោសប្រហារជីវិត ដូចមានចែងនៅក្នុងកថាខ័ណ្ឌ២ មាត្រា៣២ នៃរដ្ឋធម្មនុញ្ញ គឺជាគោលនយោបាយត្រឹមត្រូវរបស់រាជរដ្ឋាភិបាលខ្មែរ ។

ផ្ទុយទៅវិញ ក្នុងរបបគ្រប់គ្រងណាដែលនៅតែមានមនុស្សស្លាប់ច្រើន រដ្ឋាភិបាល ឬរដ្ឋអំណាចមានកាតព្វកិច្ច កែលំអគោលនយោបាយគ្រប់គ្រង ដើម្បីបន្ថយអត្រានៃការបាត់បង់ជីវិតឲ្យនៅមានកំរិតទាបបំផុត ។ ការមិនខិតខំរិះរកវិធីសម្រាប់រក្សាជីវិតមនុស្សឲ្យបានគង់វង្ស គឺជាការរំលោភសិទ្ធិរស់រានមានជីវិតរបស់បុគ្គលម្នាក់ៗផង និងរំលោភសិទ្ធិសាធារណៈផង ។ សង្គមមនុស្ស និងមនុស្សគ្រប់រូប ក៏មានភារកិច្ច ថែរក្សាជីវិតមនុស្សដែរ ព្រោះជីវិតមនុស្សមានតម្លៃជាងអ្វីៗទាំងអស់ក្នុងលោក ។ ជាតិណាដែលមានមនុស្សស្លាប់ច្រើនឥតឈប់ឈរ ជាតិនោះនឹងត្រូវវិនាសផុតពូជ ។ ជាតិណាដែលរក្សាការពារជីវិតមនុស្សបានល្អ ជាតិនោះនឹងលូតលាស់ប្រទេសចំរើនរុងរឿង ។

ក្នុងប្រទេសកម្ពុជា បញ្ហាមនុស្សបាត់បង់ជីវិតជាច្រើន ដោយសារគ្រោះថ្នាក់ចរាចរ អសន្តិសុខ សង្គ្រាម គ្រាប់មីន ជំងឺ និងឃាតកម្ម ផ្សេងៗនៅមានច្រើន ។ នេះបានន័យថា ក្រសួងសាធារណការ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ចនិងការងារ ក្រសួងអប់រំជាតិ ព្រមទាំងសហគមន៍ទាំងមូល ពោលគឺយើងទាំងអស់គ្នាចាំបាច់ត្រូវសហការគ្នារកដំណោះស្រាយបញ្ហានេះជាបន្ទាន់បំផុត ។

ចំណាំ : មានច្បាប់សម្លាប់មនុស្ស គឺជាការរំលោភសិទ្ធិ ។ គ្មានច្បាប់ ឬគ្មានយន្តការសម្រាប់ទប់ស្កាត់កុំឲ្យមានការសម្លាប់មនុស្ស ក៏ជាការរំលោភសិទ្ធិ ។ មានច្បាប់ ឬមានយន្តការហើយ ប៉ុន្តែមិនអនុវត្តជាក់ស្តែងដើម្បីទ្រទ្រង់ជីវិតមនុស្សក៏ជាការរំលោភសិទ្ធិ ។

មាត្រា៣



សិទ្ធិមានជីវិតរស់នៅ

D CIHR-WHLESS-GG-HRDECLA

## មាត្រា៤ សិទ្ធិការពារមិនឱ្យគេយកទៅធ្វើជាខ្ញុំកញ្ជះ

គ្មានជនណាម្នាក់មានសិទ្ធិយកអ្នកធ្វើជាខ្ញុំកញ្ជះ ហើយអ្នកក៏មិនអាចយកអ្នកដទៃមកធ្វើជាខ្ញុំកញ្ជះដែរ ។

<u>សេចក្ដីណែនាំ</u> : ថ្វីត្បិតតែសព្វថ្ងៃនេះ នៅគ្រប់ប្រទេសមានច្បាប់ហាមប្រាមមិនឲ្យប្រើមនុស្សជាទាសៈ (*ខ្ញុំកញ្ជះដាច់ថ្លៃ*) ក៏នៅមានសង្គមខ្លះនៅតែអនុវត្តនៅឡើយ ។ សព្វថ្ងៃនេះនៅប្រទេសខ្លះមានមនុស្សយកក្មេងទៅលក់ឲ្យគេប្រើ ឬយកក្មេងស្រីទៅលក់ដើម្បីឲ្យធ្វើជាស្រីពេស្យា ឬជាខ្ញុំបំរើ ។ នេះជាការរំលោភសិទ្ធិមនុស្ស ។

នៅក្នុងពិភពលោកទាំងមូលនេះមានកុមារអាយុតិចជាង ១៤ឆ្នាំ ចំនួន ៥០លាននាក់ប្រកបការងារជារៀងរាល់ថ្ងៃ ហើយពុំបានទៅសាលារៀន ។ ការជួលក្មេងដែលមិនទាន់គ្រប់អាយុឲ្យធ្វើការ ទោះបីឲ្យប្រាក់ឈ្នួលគ្រប់គ្រាន់ក៏ដោយ ក៏ជាការរំលោភលើសិទ្ធិរួចទៅហើយ ព្រោះវានៅក្នុងវ័យត្រូវទៅសាលារៀន ។

<u>ចំណាំ</u> : ការជួលគេឲ្យធ្វើការដោយឲ្យប្រាក់ខែមិនគ្រប់គ្រាន់ ដើម្បីរស់ក្នុងសេចក្ដីថ្លៃថ្នូរជាមនុស្ស ក៏ជាការរំលោភសិទ្ធិ ។ ការប្រើមនុស្សឲ្យធ្វើជាខ្ញុំកញ្ជះដាច់ថ្លៃក៏ជាការរំលោភសិទ្ធិដែរ ។ ការពុំមានប្រាក់ខែគ្រប់គ្រាន់ជូនបុគ្គលិករាជការដែលបំរើការពេញលេញតាមពេលកំណត់ នោះក៏ជាការរំលោភសិទ្ធិផងដែរ ។

## មាត្រា៤



សិទ្ធិការពារមិនឲ្យគេយកទៅធ្វើជាខ្ញុំកញ្ជះ

## មាត្រា៥ សិទ្ធិមិនឱ្យមានទារុណកម្មមកលើខ្លួន

គ្មាននរណាមានសិទ្ធិវាយដំអ្នក ឬធ្វើទុក្ខបុកម្នេញយ៉ាងសាហាវ ឃោរឃៅមកលើរូបអ្នកឡើយ ។ ហើយអ្នកក៏គ្មានសិទ្ធិធ្វើបាប ឬវាយទាត់ធាក់អ្នកដទៃដែរ ។

<u>សេចក្តីណែនាំ</u> : ពាក្យទារុណកម្ម សំដៅទៅលើអំពើទាំងឡាយណាដែលបណ្តាលឲ្យមានការឈឺចាប់ខាងផ្លូវកាយ ឬផ្លូវចិត្ត ។ អំពើឯទៀតដែលមានសភាពឃោរឃៅ អមនុស្សធម៌ ឬធ្វើឲ្យខូចតម្លៃជាមនុស្ស ដោយរាប់បញ្ចូលទាំងការវាយដំនឹងរំពាត់ ឬវាយដំនឹងដំបង បញ្ច្រកទឹក ឬទឹកត្រី ដាក់ក្នុងគុកងងឹត ឃុំឃាំងក្នុងបន្ទប់តែម្នាក់ឯង ឃុំទុកដើម្បីសួរចម្លើយ ចាក់ថ្នាំឲ្យវង្វេងស្មារតី ចងដាក់ច្រវាក់ ឬខ្នោះឃ្នាង ទាំងអស់នេះគឺជាទារុណកម្ម ។ ទារុណកម្មបែបណាក៏ដោយ ក៏ចាត់ទុកជាការរំលោភសិទ្ធិមនុស្សដែរ ។

ការចាប់មនុស្សដោយគ្មានដីកាចាប់ខ្លួនពីតុលាការត្រឹមត្រូវ គឺជាការរំលោភសិទ្ធិ ។ ការយកមនុស្សទៅឃុំទុកចោលយូរហួសហេតុ មិនមានការកាត់ទោស ក៏ជាការរំលោភសិទ្ធិ ។ មន្ទីរឃុំឃាំងដែលគ្មានអនាម័យគ្រប់គ្រាន់សំរាប់អ្នកទោស ក៏ជាការរំលោភសិទ្ធិ ។ ការសួរចម្លើយតាមវិធីវាយដំបង្ខំឲ្យសារភាពក៏ជាការរំលោភសិទ្ធិ ។

នៅក្នុងប្រទេសជឿនលឿន ដែលមានលទ្ធិប្រជាធិបតេយ្យ មនុស្សនិយមយកការគោរពគ្នាជាធំ ក្រៅពីការរាប់អានគ្នា និងជួយបណ្តុះបណ្តាលគ្នាទៅវិញទៅមក ដើម្បីឲ្យចម្រើនជឿនលឿន ។ តម្រួត ឬប៉ូលីសណាដែលវាយដំអ្នកទោស ត្រូវទទួលទោសតាមច្បាប់ ។ ប្តីវាយប្រពន្ធ ឬឪពុកម្តាយវាយកូនក៏ត្រូវបានទោសដែរ ។ សង្គមប្រជាធិបតេយ្យមិនទទួលស្គាល់ទារុណកម្ម ឬការរំលោភជិះជាន់ឡើយ ។ ផ្ទុយទៅវិញ គេគោរពគ្នាទៅវិញទៅមកស្មើៗគ្នា ។

<u>**ចំណាំ**</u> : នគរបាលធ្វើទារុណកម្មអ្នកទោស ប្តីវាយប្រពន្ធ ឬឪពុកម្តាយវាយកូន គ្រូវាយសិស្ស ព្រមទាំងទារុណកម្មនានាដូចមានចែងខាងលើ គឺជាការរំលោភសិទ្ធិ ។ រីការគំរាមកំហែងបំភ័យ ការធ្វើឲ្យមនុស្សតក់ស្លុត ក៏ជាការរំលោភសិទ្ធិដែរ ។

D:\CIHR-W\LESS-GG\HRDECLA

## មាត្រា៥



សិទ្ធិមិនឲ្យមានធារុណកម្មមកលើខ្លួន

D:\CIHR-W\LESS-CG\HRDECLA

## មាត្រា៦ សិទ្ធិឱ្យគេទទួលស្គាល់ខ្លួនជាមនុស្ស

ទោះបីអ្នកនៅទីកន្លែងណាក៏ដោយ ច្បាប់ ត្រូវទទួលស្គាល់អ្នកថាជាមនុស្សពេញលេញ មិនមែនជាវត្ថុ ឬសត្វឡើយ ។

សេចក្ដីណែនាំ : មាត្រានេះចែងអំពីសិទ្ធិដែលមានទាក់ទិនដល់ច្បាប់ប្រចាំស្រុក ឬប្រទេស ។ នៅក្នុងសង្គមប្រជាធិបតេយ្យ មនុស្សគ្រប់រូបសុទ្ធតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់ច្បាប់ ទោះបីនៅទីណាក៏ដោយ ។ អ្នកណាម្នាក់ធ្វើអ្វីមួយ ក៏ត្រូវតែធ្វើឲ្យនៅក្នុងក្របខ័ណ្ឌច្បាប់ ។ នេះមិនមែនបានន័យថា មនុស្សគ្មានសេរីភាពទេ ។ ផ្ទុយទៅវិញ ច្បាប់គឺជាប្រភពនៃសេរីភាពដ៏ត្រឹមត្រូវសម្រាប់ជាប្រយោជន៍ដល់សង្គមទាំងមូល ។ សិទ្ធិមនុស្សបានបញ្ញត្តិថា យើងរាល់គ្នាមានសិទ្ធិសេរីភាពអាចធ្វើអ្វីៗបានទាំងអស់ ឲ្យតែត្រឹមត្រូវតាមច្បាប់ ។ នៅក្នុងសង្គមមនុស្ស យើងមិនអាចប្រើសិទ្ធិយើងបំពានទៅលើសិទ្ធិគេបានឡើយ ។ ផ្ទុយទៅវិញ ត្រូវប្រើសិទ្ធិដោយប្រុងប្រយ័ត្ន និងដោយមានការគោរពជានិច្ចដល់សិទ្ធិអ្នកដទៃ ។ បើមនុស្សគ្រប់ៗគ្នាក្នុងសង្គម ឬក្នុងប្រទេស គិតតែពីធ្វើតាមតែអំពើចិត្តរៀងៗខ្លួននោះ សង្គមមនុស្សប្រាកដជាគ្មានរបៀបរៀបរយ មានអនាធិបតេយ្យ ។ អនាធិបតេយ្យ អាចបណ្ដាលឲ្យសង្គមមនុស្សវិនាសហិនហោចដោយសារតែការលោភលន់ និងការបំពារបំពានពីសំណាក់អ្នកមានអំណាច ។ ព្រោះហេតុនេះហើយ បានជាត្រូវតែឲ្យមានច្បាប់សម្រាប់ស្រុកនីមួយៗ ហើយច្បាប់នេះត្រូវតែសមស្របទៅតាមការរស់នៅ និងសេចក្ដីត្រូវការរបស់មនុស្សក្នុងស្រុក ។

ចំណាំ : ការមិនមានច្បាប់គ្រប់គ្រាន់ជាការរំលោភសិទ្ធិ ។ មានច្បាប់គ្រប់គ្រាន់ ហើយមិនអនុវត្តឲ្យបានដិតដល់ ក៏ជាការរំលោភសិទ្ធិ ។ ត្រូវតែមានច្បាប់ឲ្យគ្រប់គ្រាន់ និងឲ្យត្រឹមត្រូវតាមកាលៈទេសៈ និងតាមស្ថានភាពរស់នៅដ៏ចាំបាច់របស់ប្រជាពលរដ្ឋ ។ សង្គម ឬប្រទេសដែលចំរុងចំរើន គឺសង្គម ឬប្រទេសដែលមានច្បាប់គ្រប់គ្រាន់ ។ ហើយទាំងរាស្ត្រ ទាំងនាម៉ឺនត្រូវតែគោរពច្បាប់ស្មើៗគ្នា ។

## មាត្រា៦



សិទ្ធិឲ្យគេទទួលស្គាល់ខ្លួនជាមនុស្ស

D\CIHR-W\LESS-GG\HRDECLA

# មាត្រា៧ សិទ្ធិស្មើគ្នានៅចំពោះមុខច្បាប់

មនុស្សរាល់គ្នាត្រូវគោរពច្បាប់ឲ្យបានដូចៗគ្នា មិនថាអ្នកនោះជា នាម៉ឺន ឬជារាស្ត្រឡើយ ។ ច្បាប់មិនត្រូវគ្រប់គ្រងមនុស្សខុសៗពីគ្នាទេ ទោះបីអ្នកនោះ សឬខ្មៅ មានឬក្រ ជារាស្ត្រឬជានាម៉ឺនក៏ដោយ ។

<u>សេចក្តីណែនាំ</u> : សេចក្តីប្រាថ្នាដ៏ល្អរបស់យើងគ្រប់ៗគ្នា គឺការលើកតម្លៃមនុស្សឲ្យខ្ពង់ខ្ពស់ ការពារមិនឲ្យមានការសង្កត់សង្កិនលើមនុស្ស និងរក្សាសង្គមមនុស្សឲ្យគង់វង្សនៅក្នុងពិភពលោកមួយ ដែលប្រកបដោយសុខសន្តិភាព ។ ដើម្បីឲ្យសម្រេចតាមសេចក្តីប្រាថ្នាដ៏ឧដុង្គឧត្តមនេះ ត្រូវតែមានច្បាប់ឲ្យបានគ្រប់គ្រាន់ និងឲ្យបានគ្រប់ផ្នែកផង ។ សម្រាប់ពិភពលោកទាំងមូលមានច្បាប់អន្តរជាតិជាគោលល័ក្ខឋាន ។ នៅក្នុងប្រទេស មានច្បាប់សម្រាប់រដ្ឋ ពោលគឺច្បាប់រដ្ឋធម្មនុញ្ញ ដែលនៅក្នុងនោះមានច្បាប់ផ្សេងៗគ្រប់វិស័យទាំងអស់ ដូចជាច្បាប់សេដ្ឋកិច្ច ច្បាប់ជំនួញ ច្បាប់ចរាចរ ច្បាប់ពន្ធដារ ច្បាប់ជាម្ចាស់កម្មសិទ្ធិ ច្បាប់សង្គម ព្រមទាំងច្បាប់ជាច្រើនប្រការទៀត ។ មានច្បាប់គ្រប់គ្រាន់ហើយ ប៉ុន្តែ មនុស្សមិនគោរព ឬគោរពមិនបានជិតដល់ក៏អាចបណ្តាលឲ្យកើតជាគ្រោះថ្នាក់ដល់សង្គមមនុស្សដែរ ។ មនុស្សទាំងអស់ក្នុងលោកមានភាពស្មើគ្នា ទាំងក្មេងទាំងចាស់ ទាំងប្រុសទាំងស្រី ទាំងអ្នកមានទាំងអ្នកក្រីក្រ ទាំងនាម៉ឺនទាំងរាស្ត្រ ត្រូវគោរពច្បាប់ស្មើៗគ្នា ។ ច្បាប់ គឺជាឆន្ទៈរួមគ្នារបស់មនុស្សនៅក្នុងសង្គម ឬនៅក្នុងប្រទេស ។ កាលណាសង្គមមនុស្សប្រែប្រួល របៀបរស់នៅត្រូវកែសំរួលច្បាប់ឲ្យស្របទៅតាមការប្រែប្រួលនោះ ។

<u>ចំណាំ</u> : ច្បាប់ត្រូវការពារផលប្រយោជន៍មនុស្សឲ្យបានគ្រប់ៗគ្នា និងឲ្យបានស្មើៗគ្នា ។ អ្នកណាក៏ដោយឲ្យតែធ្វើខុសត្រូវទទួលទោសតាមច្បាប់ មិនថានាម៉ឺន ឬរាស្ត្រឡើយ។ អនុវត្តច្បាប់មិនស្មើគ្នា គឺជាការរំលោភសិទ្ធិ ។

# មាត្រា៧



សិទ្ធិស្មើគ្នានៅចំពោះមុខច្បាប់

## មាត្រា៨ សិទ្ធិសុំឱ្យច្បាប់ការពារខ្លួន

បើមានអ្នកណាប្រព្រឹត្តបំពានច្បាប់រដ្ឋ ហើយរំលោភមកលើសិទ្ធិអ្នក ដោយធ្វើឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិ ឬកិត្តិយសអ្នក អ្នកអាចទៅប្ដឹងសុំឲ្យតុលាការរកយុត្តិធម៌ឲ្យអ្នក ដោយរួមទាំងប្ដឹងទារឲ្យសងជំងឺចិត្តចំពោះការរំលោភនេះផង ។

<u>សេចក្ដីណែនាំ</u> : តុលាការ ឬចៅក្រម ភ្នាក់ងារតម្រួត ឬនាម៉ឺនសព្វមុខមន្ត្រីត្រូវតែគោរពច្បាប់ជាដាច់ខាត ។ ការនិយមបក្សពួក គឺជាការរំលោភច្បាប់ ។ អ្នករំលោភច្បាប់ត្រូវមានទោស។ រដ្ឋអំណាចដែលប្រព្រឹត្តបំពានច្បាប់ទៅលើអ្នកណាម្នាក់ ត្រូវតែសងជំងឺចិត្តដល់អ្នករងគ្រោះនោះ ។ តុលាការដែលកាត់ទោសដាក់ទណ្ឌកម្មជនណាម្នាក់ផ្ទុយនឹងច្បាប់រដ្ឋតុលាការនោះ ត្រូវតែមានកំហុស ហើយត្រូវតែសងជំងឺចិត្តដល់ជនរងគ្រោះ ។

នៅក្នុងលទ្ធិប្រជាធិបតេយ្យ មនុស្សយកច្បាប់ជាធំ ។ រដ្ឋាភិបាលមិនមែនជាច្បាប់ទេ ហើយរដ្ឋាភិបាលក៏មិនមែនជាម្ចាស់ច្បាប់ដែរ ។ ផ្ទុយទៅវិញ រដ្ឋាភិបាលគឺគ្រាន់តែជាភ្នាក់ងាររបស់សង្គម ហើយត្រូវតែបំពេញភារកិច្ចក្នុងឋានៈជាអ្នកបំរើសង្គម នៅក្នុងក្របខ័ណ្ឌនៃច្បាប់ដែលតំណាងឲ្យឆន្ទៈប្រជារាស្ត្រទូទៅ ។ នៅក្នុងប្រទេសដែលមានច្បាប់ត្រឹមត្រូវ រាស្ត្រដែលទទួលរងគ្រោះដោយសារកំហុសរបស់រដ្ឋាភិបាល ឬភ្នាក់ងាររដ្ឋការមានសិទ្ធិប្ដឹងទាមទារឲ្យរដ្ឋាភិបាលសងជំងឺចិត្ត ។ ភារកិច្ចរបស់រដ្ឋាភិបាល គឺការពារផលប្រយោជន៍រាស្ត្រ មិនមែនសង្កត់សង្កិនរាស្ត្រទេ ។ ដើម្បីឲ្យមានយុត្តិធម៌ក្នុងសង្គម អ្នកណាធ្វើឲ្យខូចខាតទ្រព្យសម្បត្តិ ឬកិត្តិយសគេ ត្រូវតែសងជម្ងឺចិត្ត ទោះបីជាអ្នកប្រព្រឹត្តិកំហុសនោះជាភ្នាក់ងាររដ្ឋាភិបាល ជានាម៉ឺនធំ ឬមានតួនាទី ឋានៈជាអ្វីក៏ដោយ ។

ដើម្បីឲ្យសម្រេចដូចបំណងនេះ ទី១ : ម្នាក់ៗត្រូវខំរៀនឲ្យចេះដឹងអំពីច្បាប់ ហើយទី២ : ប្រជាពលរដ្ឋត្រូវរួមកម្លាំងគ្នាការពារយុត្តិធម៌ក្នុងសង្គម កុំបណ្ដោយឲ្យមានការរំលោភជាដាច់ខាត។

D:\CIHR-W6\LESS-GG\HRDECLA

## មាត្រា៨





សិទ្ធិសុំឲ្យច្បាប់ការពារខ្លួន

D:\CIHR-W\LESS-GG\HRDECLA

## មាត្រា៩ សិទ្ធិមានសេរីភាព

គ្មានជនណាមានសិទ្ធិចាប់អ្នកយកទៅឃុំឃាំង ឬដាក់គុកដោយរំលោភឡើយ ។ ហើយគ្មានជនណាមានសិទ្ធិបណ្តេញអ្នកចេញពីប្រទេសរបស់អ្នកដោយពុំសមហេតុផល ឬដោយគ្មានមូលហេតុត្រឹមត្រូវឡើយ ។

សេចក្តីណែនាំ : មាត្រានេះចែងអំពីលទ្ធភាពការពារខ្លួនតាមប្រព័ន្ធច្បាប់ ។ ការចាប់មនុស្សដោយរំលោភ មានន័យថា ការចាប់មនុស្សតាមតែអំពើចិត្ត ឬតាមតែបញ្ជារបស់អ្នកកាន់អំណាច ដោយគ្មានគិតពីទោសកំហុស ឬដោយគ្មានដីកាចាប់ខ្លួនត្រឹមត្រូវតាមផ្លូវច្បាប់ ។ ការចាប់មនុស្សដោយគ្មានដីកាចាប់ខ្លួន គឺជាការរំលោភសិទ្ធិ ។ ការដាក់គុកមនុស្សដោយគ្មានកាត់ទោសត្រឹមត្រូវ គឺជាការរំលោភសិទ្ធិ ។

ចំណាំ : កាលណាមានភ្នាក់ងារតម្រួត ឬទាហានមកចាប់ខ្លួនអ្នក អ្នកមានសិទ្ធិការពារខ្លួនដោយធ្វើដូចតទៅនេះ : **ទី១** : ត្រូវសួររកដីកាចាប់ខ្លួនពីតុលាការ ហើយត្រូវពិនិត្យមើលតើមានឈ្មោះរបស់អ្នកមែនឬទេ ព្រោះបើគ្មានដីកាទេ ការចាប់ខ្លួននេះជាការរំលោភ ។ **ទី២** : អ្នកមានសិទ្ធិសួរតម្រួតអំពីហេតុផលនៃការចាប់នេះ ។ **ទី៣** : តម្រួតត្រូវបង្ហាញអ្នកនូវគ្រឿងសំគាល់ខ្លួនរបស់គេ ដូចជាឈ្មោះ អត្តលេខ ឈ្មោះ ឬលេខកងឯកភាព ព្រមទាំងសំបុត្របេសកកម្ម ។ **ទី៤** : ត្រូវរក្សាភាពស្ងាត់ស្ងៀម ពោលគឺកុំនិយាយស្តីអំពីបញ្ហាអ្វីទាំងអស់ក្នុងពេលនេះ ចាំពិគ្រោះជាមួយស្មាក្តី (មេធាវី) ឲ្យច្បាស់លាស់សិន ព្រោះស្មាក្តីជាអ្នកចេះដឹង អំពីច្បាប់ក្នុងរឿងច្បាប់ចាប់ចងនេះ ។ **ទី៥** : ត្រូវទាក់ទងជាមួយបងប្អូន មិត្តភក្តិ ឲ្យរកជួលស្មាក្តីភ្លាម ។ បើគ្មានប្រាក់ទេ អ្នកមានសិទ្ធិស្នើសុំឲ្យរដ្ឋផ្តល់ស្មាក្តីម្នាក់ដោយឥតចាំបាច់បង់ថ្លៃឈ្នួល ។ **ទី៦** : មិនត្រូវចុះហត្ថលេខាលើអ្វីទាំងអស់ ចាំសួរស្មាក្តីជាមុនសិន ។ **ទី៧** : បើសិនជាមានការកៀបសង្កត់ទារប្រាក់កាស ការសំឡុតកំហែង ឬការប្រើកម្លាំងបាយ ត្រូវរាយការណ៍ទៅឲ្យស្មាក្តីភ្លាម ។ **ទី៨** : បើមានការដកហូតឥវ៉ាន់ អ្នកមានសិទ្ធិសុំឲ្យប៉ូលីសចេញលិខិតកត់ត្រាអំពីវត្ថុទាំងអស់ដែលត្រូវគេដកហូត ។ ការមិនប្រតិបត្តិតាមបែបបទខាងលើ គឺជាការរំលោភសិទ្ធិ ។

D:\CIHR-W6\LESS-GG\HRDECLA

## មាត្រា៩



សិទ្ធិមានសេរីភាព

D:\CIHR-W\LESS-GG\HRDECLA

# មាត្រា១០ សិទ្ធិឱ្យមានការកាត់ក្ដីត្រឹមត្រូវ

បើអ្នកត្រូវទៅតុលាការដើម្បីកាត់ក្ដី តុលាការត្រូវតែធ្វើការកាត់សេចក្ដីជាសាធារណៈ និងយ៉ាងត្រឹមត្រូវ ។ ពួកអ្នកធ្វើការក្នុងក្រសួងតុលាការ មិនត្រូវប្រកាន់បក្សពួកឡើយ ។

<u>សេចក្ដីណែនាំ</u> : ការកាត់សេចក្ដីជាសាធារណៈ និងត្រឹមត្រូវ មានន័យថាអ្នកជាប់ចោទមានសិទ្ធិរាយការណ៍ឲ្យបានសព្វគ្រប់អំពីអ្វីៗដែលខ្លួនមាន ។ បើអ្នកពេញចិត្ត អ្នកមានសិទ្ធិជួលឬស្នើសុំឲ្យមានស្មាក្ដីការពារអ្នក ។ តុលាការកាត់ក្ដីត្រូវមានឯករាជភាព ពោលគឺមិននៅក្រោមឥទ្ធិពលអាជ្ញាធរណាឡើយ ហើយមិនត្រូវប្រកាន់វណ្ណៈ ឬបក្សពួកទៀតផង ។ អ្នកដែលគេចាប់ខ្លួនហើយ មានសិទ្ធិត្រូវឲ្យគេនាំខ្លួនទៅកាត់ទោសតាមការកំណត់ពេលវេលាយ៉ាងច្បាស់លាស់ និងតាមនីតិវិធីត្រឹមត្រូវ ។

សព្វថ្ងៃនេះ គេមានការចាប់អារម្មណ៍ទៅលើអាជ្ញាធរក្នុងប្រទេសជាច្រើន ដែលចាប់មនុស្សយកទៅឃុំឃាំង ដាក់គុក និងធ្វើទារុណកម្ម ។ អំពើបែបនេះ គឺជាការរំលោភលើសិទ្ធិមនុស្ស ។ ការឃុំឃាំងមនុស្សមិនត្រូវឲ្យយូរពេកទេ ។ បើមិនអាចកាត់ទោសភ្លាមៗ ឬក្នុងកំឡុងពេលដ៏ខ្លីខាងមុខទេ ត្រូវអនុញ្ញាតឲ្យមានការធានាដោះយកជនជាប់ចោទចេញទៅរស់នៅក្រៅឃុំទម្រាំដល់ថ្ងៃកាត់ទោសសឹមត្រឡប់មកវិញ ។

ចំពោះការប្រើសិទ្ធិ សូមប្រើឲ្យត្រឹមត្រូវតាមក្របខ័ណ្ឌច្បាប់ ។ អង្គការសហប្រជាជាតិបានខំបញ្ញត្តិសិទ្ធិអស់ទាំងនេះឡើង គឺដើម្បីណែនាំមនុស្សឲ្យចេះរស់ជាមួយគ្នាដោយសុខសន្តិភាព ។ ដូច្នេះ ការយកសិទ្ធិទៅប្រើដើម្បីចោទប្រកាន់គ្នា ឬឈ្លោះប្រកែកគ្នា គឺជាការឆ្គាំឆ្គងមួយគួរឲ្យខ្មាសអៀន ។ ការចចេសរឹងរូស មិនស្ដាប់បង្គាប់អាជ្ញាធរដែលបំពេញភារកិច្ចដែលត្រឹមត្រូវតាមគន្លងច្បាប់ គឺជាកំហុសដ៏ធំមួយ ។ ប៉ុន្តែ អាជ្ញាធរដែលជាអ្នកយកច្បាប់ទៅប្រតិបត្តិក៏ត្រូវតែគោរពតាមច្បាប់ឲ្យបានខ្ជាប់ខ្ជួនណាស់ដែរ ។ អាជ្ញាធរមិនមែនជាច្បាប់ទេ ផ្ទុយទៅវិញ អាជ្ញាធរគឺជាអ្នកបំរើប្រជារាស្ត្រដោយយកច្បាប់ជាគោល ។

**<u>ចំណាំ</u>** : ការកាត់ក្ដីដែលមិនបានប្រព្រឹត្តតាមល័ក្ខខ័ណ្ឌដូចមានចែងខាងលើ គឺជាការរំលោភសិទ្ធិ ។

# មាត្រា១០




សិទ្ធិឲ្យមានការកាត់ក្តីត្រឹមត្រូវ

## មាត្រា១១ សិទ្ធិទទួលការកាត់ទោសសមស្របតាមច្បាប់

បើមិនទាន់រកកំហុសអ្នកឃើញទេ អ្នកនៅជាមនុស្សគ្មានទោសដូចមនុស្សធម្មតា ។ ហើយអ្នកអាចរកច្បាប់ឲ្យជួយការពារខ្លួនអ្នកនៅក្នុងការកាត់ក្ដីជាសាធារណៈ ។ បើអ្នកបានប្រព្រឹត្តិកំហុសអ្វីមួយមុនពេលមានច្បាប់ហាមប្រាម អ្នកមិនត្រូវមានទោសទណ្ឌចំពោះកំហុសនោះទ្បើយ ព្រោះច្បាប់ហាមប្រាមនេះទើបតែបញ្ញត្តិក្រោយការប្រព្រឹត្តិកំហុស ។ នេះហៅថា *"ច្បាប់គ្មានប្រតិកម្មថាក់ថយ"* ទ្បើយ ។

<u>**សេចក្ដីណែនាំ**</u> : មាត្រានេះរៀបរាប់អំពីការកាត់ទោសត្រឹមត្រូវ ។ មានគោលការណ៍សំខាន់បួនដែលត្រូវអនុវត្តឲ្យខ្ជាប់ខ្ជួន ។ **ទីមួយ** គឺការសន្និដ្ឋានថា ជនជាប់ចោទជាមនុស្សគ្មានកំហុស ។ ជនដែលជាប់ចោទទាំងអស់មិនមែនសុទ្ធតែមានកំហុសទេ ។ ដូច្នេះ មុននឹងរកភស្តុតាងឃើញថាអ្នកណាមានកំហុសឬគ្មាន ត្រូវសន្មតជាបណ្ដោះអាសន្នថា ជនជាប់ចោទទាំងនោះគ្មានទោស ហើយត្រូវតែគ្រប់គ្រងថែរក្សាឲ្យត្រឹមត្រូវ និងប្រកបដោយការគោរពសិទ្ធិយ៉ាងពេញលេញផង ។ នៅប្រទេសជឿនលឿនខ្លះមានច្បាប់អនុញ្ញាតឲ្យមានការធានាដោះយកជនជាប់ចោទទៅរស់នៅក្រៅឃុំដោយសេរី ទម្រាំដល់ថ្ងៃកាត់ទោស ។ ប៉ុន្តែចំពោះជនជាប់ចោទណាដែលគេយល់ថាអាចបណ្ដាលឲ្យមានគ្រោះថ្នាក់ដល់មនុស្សគេមិនអនុញ្ញាតឲ្យចេញជាដាច់ខាត ។ **ទីពីរ** ជនជាប់ចោទមានសិទ្ធិការពារខ្លួនតាមរយៈមេធាវី ឬសាក្សី ។ **ទីបី** ដើម្បីឲ្យសាធារណជនមានជំនឿទៅលើប្រព័ន្ធតុលាការ ការកាត់ក្ដីត្រូវតែប្រព្រឹត្តិនៅចំពោះមុខសាធារណជន ពោលគឺអនុញ្ញាតឲ្យសាធារណជនចូលស្ដាប់ការកាត់ក្ដី ។ ជនជាប់ចោទត្រូវមានឱកាសធ្វើសេចក្ដីវាយការណ៍នៅចំពោះមុខតុលាការផង នៅចំពោះមុខសាធារណជនផង ។ ធ្វើយ៉ាងនេះទើបមានយុត្តិធម៌ ។ **ទីបួន** បើមានចែងច្បាប់ថ្មី ច្បាប់នោះមិនត្រូវមានប្រតិកម្មថាក់ថយទ្បើយ ពោលគឺមិនអាចយកទៅអនុវត្តលើអំពើដែលបានប្រព្រឹត្តរួចហើយក្នុងអតីតកាលទេ ។

D:\CIHR-W\LESS-GG\HRDECLA

## មាត្រា១១



សិទ្ធិទទួលការកាត់ទោសសមស្របតាមច្បាប់

## មាត្រា១២ សិទ្ធិការពារជីវភាពឯកជនរបស់ខ្លួន

បើមានជនណាមកបង្ខិតបង្ខំអ្នក ឬគ្រួសារអ្នកឲ្យផ្លាស់ប្តូរគំនិត ឬឲ្យផ្លាស់ប្តូររបៀបរស់នៅ អ្នកមានសិទ្ធិទៅរកច្បាប់ឲ្យជួយការពារ ។ គ្មានជនណាអាចចូលផ្ទះអ្នកដោយគ្មានមូលហេតុត្រឹមត្រូវឡើយ ។ គ្មានជនណាមានសិទ្ធិនិយាយបង្កាច់បង្ខូចប្រាសចាកការពិត ដែលនឹងបណ្តាលឲ្យប៉ះពាល់ដល់កិត្តិយសអ្នក និងគ្រួសារអ្នកឡើយ ។ ច្បាប់ហាមមិនឲ្យមានការរំលោភដល់រឿងផ្ទៃក្នុងរបស់អ្នកដទៃជាដាច់ខាត ។

សេចក្តីណែនាំ : ពាក្យថាកិច្ចការផ្ទាល់ខ្លួន ឬជីវភាពឯកជន ផ្ទះសម្បែង កិត្តិយស និងកិត្តិនាមមានអត្ថន័យខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយ យោលទៅតាមពូជសាសន៍ ប្រពៃណី វប្បធម៌ និងទំនៀមទំលាប់ ។ មាត្រា ១២ នេះ ណែនាំឲ្យអនុវត្តតាមច្បាប់របស់ប្រទេសនីមួយៗ ។ មនុស្សគ្រប់ៗគ្នាសុទ្ធតែមានជីវិតឯកជនរៀងៗខ្លួន ពោលគឺម្នាក់ៗមានអាថ៌កំបាំងប្រចាំខ្លួនជានិច្ច ។ ដើម្បីជៀសវាងការប៉ះទង្គិចគ្នាក្នុងគ្រួសារ ឬក្នុងសង្គម ការទាក់ទងរវាងគ្នានឹងគ្នាត្រូវឲ្យមានកម្រិតព្រំដែន ។ មិនត្រូវលួចបើកសំបុត្រអ្នកដទៃមើលទេ ទោះសំបុត្រនោះជារបស់ប្រពន្ធ ឬកូនយើងក៏ដោយ ។ បើត្រូវការធ្វើអ្វីដែលមានទាក់ទងដល់អ្នកណាម្នាក់ ត្រូវតែឲ្យមានការយល់ព្រមអំពីអ្នកនោះ ។

ការនិយាយបង្កាច់បង្ខូចគេប្រាសចាកការពិត គឺការរំលោភសិទ្ធិ ។ សារពត៌មានអាចរាយការណ៍ដោយសេរី ។ ប៉ុន្តែ ត្រូវប្រកាន់សច្ចៈធម៌ ពោលគឺនិយាយតែការពិត ។ អ្នករងគ្រោះដោយសារការធ្វើឲ្យខូចកិត្តិយស ឬកិត្តិនាម មានសិទ្ធិប្តឹងទាមទារឲ្យក្រុមហ៊ុនសារពត៌មានសងជំងឺចិត្តយ៉ាងដំណំ ប្រសិនបើមានសេចក្តីរាយការណ៍មិនពិត ។

ចំណាំ : ដើម្បីការពារខ្លួនតទល់នឹងការនិយាយបង្ខូចបែបនេះ មនុស្សគ្រប់ៗគ្នាមានសិទ្ធិប្តឹងទៅតុលាការឲ្យច្បាប់រកខុសត្រូវ ប៉ុន្តែ មិនមានសិទ្ធិប្រើហិង្សាវាយការិយាល័យកាសែត ឬវាយអ្នកកាសែតឡើយ ។

## មាត្រា១២





សិទ្ធិការពារជីវភាពឯកជនរបស់ខ្លួន

## មាត្រា១៣ សិទ្ធិធ្វើដំណើរទៅមកដោយសេរី

នៅក្នុងប្រទេសរបស់អ្នក អ្នកមានសិទ្ធិពេញទីក្នុងការធ្វើដំណើរចុះឡើង ។ ហើយអ្នកក៏មានសិទ្ធិចាកចេញពីប្រទេសអ្នក និងត្រឡប់ចូល មកកាន់ប្រទេសអ្នកវិញបានតាមចិត្តប្រាថ្នា ។

សេចក្តីណែនាំ : សិទ្ធិក្នុងមាត្រា ១៣ នេះមានកម្រិតព្រំដែន ។ គេអាចដាក់បំរាមគោចរ (ហាមមិនឲ្យធ្វើដំណើរ) ក្នុងកាលៈទេសៈណាដែលមានភាពអាសន្ន ។ អ្នកមានសិទ្ធិពេញទីតែក្នុងគ្រាណាដែលមានសេចក្តីសុខសាន្តត្រាណ ។ ផ្ទុយទៅវិញ នៅក្នុងគ្រាណាដែលគេត្រូវការរក្សាសន្តិសុខជាតិ ការពារសីលធម៌ និងសុខុមាលភាពសាធារណៈ គេអាចឃាត់ឃាំងមិនឲ្យធ្វើដំណើរបានតាមរយៈដាក់បំរាមគោចរ ។ ពេលស្រុកមានអាសន្នដោយសារជំងឺឆ្លងផ្សេងៗ ដូចជាជំងឺអាសន្នរោគជាដើម គេត្រូវហាមឃាត់មិនឲ្យមនុស្សធ្វើដំណើរចុះឡើងដែរ ។

សិទ្ធិចាកចេញពីប្រទេសក៏មានកម្រិតព្រំដែន ។ ជនឧក្រិដ្ឋ ឬជនជាប់ចោទអំពីប្រការផ្សេងៗ ដែលចង់រត់ចេញពីប្រទេសដើម្បីគេចវេះអំពីច្បាប់តុលាការ មិនមានសិទ្ធិសេរីភាពចាកចេញពីប្រទេសឡើយ ។

ទោះបីយើងមានសិទ្ធិសេរីភាពដើម្បីនឹងទៅតាំងទីលំនៅក្នុងបរិវេណនៃប្រទេសណាមួយដូចមានចែងនៅក្នុងមាត្រា ១៣ នេះក៏ដោយ ក៏ត្រូវអាស្រ័យទៅលើការព្រមព្រៀងពីសំណាក់ប្រទេសនោះផងដែរ ។ បើប្រទេសនោះមិនព្រមអនុញ្ញាតឲ្យយើងចូល យើងពុំមានសិទ្ធិចូលប្រទេសគេបានឡើយ ។

សិទ្ធិចាកចេញពីប្រទេស ខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត ។ ប្រទេសខ្លះដោយមូលហេតុផ្សេងៗបានហាមប្រាមពលរដ្ឋមិនអោយចាកចេញពីប្រទេស ។ ប្រទេសណាដាក់ល័ក្ខខ័ណ្ឌបែបនេះបានត្រូវមជ្ឈដ្ឋានអន្តរជាតិ ជាពិសេសប្រទេសសេរី ខ្តើមរអើម និងទិតៀនយ៉ាងខ្លាំងជាទីបំផុត ។

# មាត្រា១៣



សិទ្ធិធ្វើដំណើរទៅមកដោយសេរី

# មាត្រា១៤ សិទ្ធិទៅសុំការជ្រកកោននៅប្រទេសក្រៅ

បើមានគេធ្វើទុកបុកម្នេញ ឬជិះជាន់សង្កត់សង្កិនអ្នកដោយរំលោភ ឬបំពានលើរូបអ្នកដែលពុំបានប្រព្រឹត្តបទល្មើសអ្វីសោះនោះ អ្នកមានសិទ្ធិទៅសុំជ្រកកោននៅប្រទេសក្រៅមួយរយៈ ដើម្បីការពារសន្តិសុខផ្ទាល់ខ្លួន ។ ប៉ុន្តែ បើអ្នកបានប្រព្រឹត្តបទល្មើសណាមួយ ឬបានរំលោភលើចំណុចណាមួយដែលមានចែងនៅក្នុងសេចក្តីថ្លែងការណ៍នេះ អ្នកជាជនមានកំហុស អ្នកគ្មានសិទ្ធិចាកចេញពីប្រទេសអ្នកទេ ព្រោះអ្នកត្រូវទទួលទោសកម្មតាមច្បាប់ជាធរមានរបស់ប្រទេសអ្នកសិន ។

<u>សេចក្តីណែនាំ</u> : ការសុំជ្រកកោននៅប្រទេសក្រៅអាចធ្វើទៅបានតែចំពោះករណីណាដែលមានការរំលោភយាយីមកលើសេរីភាព ឬជីវិតខ្លួន ឬដោយខ្លាចអំពើទាំងអស់ទាំងនេះកើតមានឡើងលើខ្លួន ដោយសារខ្លួនមានមតិនយោបាយឬជំនឿសាសនាខុសពីគេ ។ អង្គការសហប្រជាជាតិបានបញ្ញត្តិថា មនុស្សជំពូកនេះមានសិទ្ធិដើម្បីអោយសហគមន៍អន្តរជាតិការពារសន្តិសុខដោយទទួលអោយជ្រកកោននៅប្រទេសណាមួយ ។ ធម្មនុញ្ញនៃអង្គការសហប្រជាជាតិចែងថា មនុស្សជំពូកនេះអាចសុំសិទ្ធិជ្រកកោននៅប្រទេសណាមួយ ។ ប៉ុន្តែ ប្រទេសនោះក៏មានសិទ្ធិសម្រេចថា ទទួលឬមិនទទួល ដោយយោលទៅតាមស្ថានភាពនយោបាយរបស់ប្រទេស និងសន្តិសុខជាតិ ។ ប៉ុន្តែ បើមានមនុស្សជំពូកនេះទៅដល់ប្រទេសណាមួយហើយប្រទេសនោះពុំគួរបញ្ជូនអ្នកនោះត្រឡប់ទៅប្រទេសដើមវិញឡើយ ប្រសិនបើមនុស្សនោះត្រូវប្រឈមមុខនឹងគ្រោះថ្នាក់ ។

សព្វថ្ងៃនេះ អគ្គស្នងការជាន់ខ្ពស់ផ្នែកជនភៀសខ្លួននៃអង្គការសហប្រជាជាតិ កំពុងតែមានភារកិច្ចគ្រប់គ្រងជនភៀសខ្លួនជាច្រើនលាននាក់ ដែលជាបញ្ហាបណ្តាលមកពីការរំលោភសិទ្ធិ ។

<u>ចំណាំ</u> : ជនដែលមានបញ្ហាដោយសាររឿងឯទៀត ដែលមិនមែនជារឿងនយោបាយ មិនអាចប្រើសិទ្ធិនេះបានទេ ។ ជនល្មើសច្បាប់មិនអាចប្រើសិទ្ធិនេះទេ ។

## មាត្រា១៤



សិទ្ធិទៅសុំការជ្រកកោននៅប្រទេសក្រៅ

D:\CIHR\W\LESS-GG\HRDECLA

# មាត្រា១៥ សិទ្ធិមានសញ្ជាតិមួយ

អ្នកមានសិទ្ធិសុំចូលសញ្ជាតិមួយណាក៏បាន ហើយទៅរស់នៅប្រទេសមួយណាក៏បាន អោយតែសមស្របតាមច្បាប់នៃប្រទេសនោះ ។ គ្មានជនណាអាចខាឃាំងអ្នកដោយគ្មានមូលហេតុត្រឹមត្រូវឡើយ ។ គ្មានជនណាអាចដកសញ្ជាតិពីអ្នកបានឡើយ ។ ហើយអ្នកក៏មានសិទ្ធិផ្លាស់ប្តូរសញ្ជាតិដែរ ។

សេចក្តីណែនាំ : ពាក្យជាតិ ឬស្នេហាជាតិ មានន័យចេញពីជំរៅចិត្តមនុស្ស ។ ប៉ុន្តែពាក្យនេះត្រូវបានគេយកទៅប្រើសំរាប់ជាផលប្រយោជន៍ផ្សេងៗពីគ្នា នៅក្នុងកាលៈទេសៈ និងស្ថានភាពផ្សេងៗពីគ្នា ។ ប៉ុន្តែ នៅក្នុងមាត្រានេះគេនិយាយអំពីសញ្ជាតិដែលមានន័យថាជាកំណើតធម្មជាតិរបស់មនុស្សគ្រប់រូបដែលត្រូវតែទទួលនូវការគាំពារ ។

អាណិកជននៃប្រទេសនីមួយៗមានសិទ្ធិសុំចូលសញ្ជាតិ ។ ប៉ុន្តែ អាណិកជននេះត្រូវគោរពតាមល័ក្ខខ័ណ្ឌទាំងឡាយដែលរដ្ឋាភិបាលតម្រូវឲ្យ ។ ឧទាហរណ៍ដូចជានៅសហរដ្ឋអាមេរិក អាណិកជនគ្រប់ៗគ្នាត្រូវរស់នៅក្នុងប្រទេសយ៉ាងតិចប្រាំឆ្នាំ ទើបមានសិទ្ធិសុំចូលសញ្ជាតិ ។ ហើយក្នុងរយៈពេលប្រាំឆ្នាំនេះ សាមីខ្លួនត្រូវមានគំនិតមារយាទល្អត្រឹមត្រូវ ទើបគេអោយចូលសញ្ជាតិ ។ ប្រទេសទាំងឡាយមាន សិទ្ធិបដិសេធមិនអោយអាណិកជនណាមួយចូលសញ្ជាតិ បានកាលណាគេយល់ថាអាណិកជននេះអាចបណ្តាលឲ្យមានគ្រោះថ្នាក់ដល់សង្គមជាតិគេ ។ ប្រទេសនីមួយៗ តែងតែមានច្បាប់អន្តោប្រវេសន៍ខុសៗពីគ្នា ដោយអាស្រ័យទៅតាមស្ថានភាពភូមិសាស្ត្រ ស្ថានភាពសេដ្ឋកិច្ច និងស្ថានភាពនយោបាយ ។

ចំណាំ : មនុស្សគ្រប់គ្នាមានសិទ្ធិលាពីសញ្ជាតិមួយដើម្បីចូលសញ្ជាតិមួយទៀតបាន ។ ការបង្ខំឲ្យមនុស្សចូល ឬលាសញ្ជាតិគឺជាការរំលោភសិទ្ធិ ។

D:\CIHR-W\LESS-GG\HRDECLA

## មាត្រា១៥



សិទ្ធិមានសញ្ញាតិមួយ

D\CIHR-W\LESS-GG\HRDECLA

# មាត្រា១៦ សិទ្ធិរៀបចំគូស្រករ និងមានគ្រួសារ

ពេលអ្នកពេញវ័យ អ្នកមានសិទ្ធិពេញទីក្នុងការរើសគូស្រករ ដើម្បីរៀបការជាប្តីប្រពន្ធ ។ ទោះបីគូស្រករនោះមានជាតិខុសគ្នា ឬសាសនាខុសគ្នា ឬរស់នៅប្រទេសខុសគ្នាក៏ដោយ ឲ្យតែមានការព្រមព្រៀងគ្នាទាំងសងខាង គ្មាននរណាមានសិទ្ធិមកខាយាំងមិនអោយអ្នករៀបការជាមួយអ្នកនោះឡើយ ។ ប្រុសនិងស្រីមានសិទ្ធិស្មើគ្នាក្នុងការជ្រើសរើសគូស្រករ ។ អ្នកមិនត្រូវបានគេបង្ខំឲ្យទៅរៀបការជាមួយបុគ្គលណាដែលអ្នកមិនពេញចិត្តឡើយ ។ រដ្ឋាភិបាលនៃប្រទេសរបស់អ្នកត្រូវការពារគ្រួសារអ្នក ។

<u>សេចក្តីណែនាំ</u> : បញ្ហារៀបការយកគ្នាជាគូស្រករ ការរស់នៅជាមួយគ្នាជាគូប្រចាំជីវិត តែងតែមានភាពខុសៗគ្នាពីជាតិមួយទៅជាតិមួយ ពីសង្គមមួយទៅសង្គមមួយ យោងទៅតាមទំនៀមទំលាប់ និងប្រពៃណី ។ តាមប្រពៃណីស្រុកខ្លះ ប្រុសៗមានសិទ្ធិរើសគូស្រករ រីឯស្រីៗវិញគ្មានសិទ្ធិធ្វើយ៉ាងនេះទេ ។ ហើយនៅក្នុងសង្គមបុរាណខ្លះទៀត គេអនុញ្ញាតអោយប្រុសៗមានគូស្រករលើសពីម្នាក់ ។ ការនិយមបែបនេះ ច្រើនមាននៅក្នុងប្រទេសជាច្រើននៃទិបខាងកើត ។ តើភាពស្មើគ្នាជាមនុស្សជាតិនៅត្រង់ណា ?

យោងទៅតាមបញ្ញត្តិសិទ្ធិមនុស្ស ម្នាក់ៗមានតម្លៃស្មើៗគ្នា ។ ដូច្នេះការជ្រើសរើសគូប្រចាំជីវិត ការរួមរស់ជាមួយគ្នា ការលែងលះគ្នា គឺជាការសម្រេចចិត្តរបស់មនុស្សទាំងប្រុសទាំងស្រី ។ អ្នកដទៃពុំគួរជ្រៀតជ្រែកឲ្យហួសពីព្រំដែនពេកទេ ។ ឪពុកម្តាយ បងប្អូន មិត្តភក្តិមានសិទ្ធិត្រឹមតែជួយណែនាំ និងអប់រំ ។

<u>ចំណាំ</u> : នៅក្នុងគ្រួសារ ប្តីប្រពន្ធ មានសិទ្ធិស្មើគ្នា មានការទទួលខុសត្រូវស្មើៗគ្នា ហើយត្រូវគោរពគ្នាទៅវិញទៅមកឲ្យបានស្មើៗគ្នា ។

# មាត្រា១៦



សិទ្ធិរៀបចំគូស្រករ និងមានគ្រួសារ

D CIHR-WoLESS-GG HRDECLA

## មាត្រា១៧ សិទ្ធិមានសម្បត្តិកម្មសិទ្ធិ

អ្នកមានសិទ្ធិមានសម្បត្តិកម្មសិទ្ធិជាឯកជនក៏បាន រួមជាមួយអ្នកដទៃក៏បាន ។ គ្មាននរណាអាចដកហូតទ្រព្យសម្បត្តិអ្នកដោយគ្មានហេតុផលសមស្របតាមច្បាប់ឡើយ ។

សេចក្តីណែនាំ : ក្នុងសង្គមប្រជាធិបតេយ្យមនុស្សគ្រប់រូបមានសិទ្ធិធ្វើជាម្ចាស់ទ្រព្យ ។ អ្នកខ្លះជាម្ចាស់តែម្នាក់ឯង អ្នកខ្លះទៀតមានសម្បត្តិរួមជាមួយអ្នកដទៃ។ ខ្លះមានច្រើន ខ្លះមានតិច យោលទៅតាមការខិតខំ ការប៉ិនប្រសប់ និងតម្រិះវិជ្ជារបស់គេ ។ អ្នកអាចមានសម្បត្តិច្រើនប៉ុនណាក៏បាន ឲ្យតែសម្បត្តិនោះជាសម្បត្តិដែលរកបានដោយសុចរិតយុត្តិធម៌ ។ ហើយអ្នកដទៃទាំងអស់ ទាំងរដ្ឋអំណាច ទាំងរដ្ឋាភិបាល ពុំអាចដកហូតទ្រព្យសម្បត្តិអ្នកដោយខុសច្បាប់បានឡើយ។ ប៉ុន្តែ បើរដ្ឋត្រូវការប្រើប្រាស់ ឬដកហូតសម្បត្តិដីធ្លីអ្នកដើម្បីផលប្រយោជន៍សាធារណៈ អ្នកពុំអាចបដិសេធបានឡើយ ។ ក្នុងករណីបែបនេះ រដ្ឋត្រូវចេញប្រាក់សងថ្លៃសម្បត្តិអ្នកតាមតម្លៃត្រឹមត្រូវ ។ បើរដ្ឋមិនសងប្រាក់ថ្លៃសម្បត្តិដែលរឹបអូសទាំងនោះទេ បានន័យថារដ្ឋរំលោភលើកម្មសិទ្ធិរបស់ប្រជារាស្ត្រ ។ ផ្ទុយទៅវិញ បើមានភស្តុតាងច្បាស់លាស់ថា សម្បត្តិទាំងនេះកើតមកពីអំពើពុករលួយ តុលាការអាចចេញបញ្ញត្តិឲ្យរឹបអូសសម្បត្តិទាំងនេះយកទៅដាក់ជាសម្បត្តិរដ្ឋបាន ។

ក្នុងការកសាងប្រទេស ដូចជាការសង់ទីក្រុងថ្មី សង់ផ្លូវថ្នល់ថ្មី ឬបង្កើតជាគម្រោងការថ្មីៗសំរាប់ជាប្រយោជន៍សាធារណៈ ដែលត្រូវតែមានការប៉ះពាល់ដល់ដីធ្លី ផ្ទះសម្បែង ឬសម្បត្តិអ្វីផ្សេងៗទៀតរបស់អ្នក រដ្ឋត្រូវទិញពីអ្នកដែលជាម្ចាស់ទ្រព្យ ។ ម្ចាស់ទ្រព្យត្រូវតែលក់ជូនរដ្ឋតាមតម្លៃត្រឹមត្រូវ គឺតាមតម្លៃជាផ្លូវការ ។

ចំណាំ : អ្នករឹបអូសសម្បត្តិទ្រព្យ គេធ្វើជាសម្បត្តិខ្លួនដោយសារខ្លួនមានអំណាច គឺជាការរំលោភពេញទី ។ តាមច្បាប់ សម្បត្តិទាំងនេះនៅតែជាសម្បត្តិរបស់ម្ចាស់ដើមគេជានិច្ច ទោះនៅក្នុងស្ថានការណ៍ ឬកាលៈទេសៈបែបណាក៏ដោយ ។

## មាត្រា១៧





សិទ្ធិមានសម្បត្តិកម្មសិទ្ធិ

## មាត្រា១៨ សិទ្ធិមានជំនឿដោយសេរី

អ្នកអាចសំរេចចិត្តដោយសេរី អាចធ្វើតាមសម្បជញ្ញៈអ្នកដោយសេរី អាចជ្រើសរើសសាសនាដោយសេរី អាចប្តូរសាសនាដោយសេរី អាចបង្រៀនអំពីសាសនាដល់អ្នកដទៃក៏បាន អាចប្រារព្ធបុណ្យទានខាងសាសនាតាមប្រាថ្នា ទោះបីធ្វើតែម្នាក់ឯងក្តី ឬជាមួយគេឯទៀតក្តី ។

សេចក្តីណែនាំ : សិទ្ធិដើម្បីគិត និងសិទ្ធិក្នុងការប្តូរគំនិត អាចបណ្តាលឲ្យមានសកម្មភាពខាងសម្បជញ្ញៈ ការស្គាល់តម្លៃវប្បធម៌ ព្រមទាំងជំនឿសាសនា ។ ប៉ុន្តែ ការសំដែងមតិ ហើយនិងសកម្មភាពនានាដែលយោងទៅតាមសម្បជញ្ញៈ និងជំនឿសាសនា អាចបណ្តាលឲ្យមានបញ្ហាប្រសិនបើមិនស្របនឹងស្ថានការណ៍សង្គម និងស្ថានការណ៍នយោបាយរបស់បរទេស ជាពិសេសគឺការសំដែងមតិជាក្រុមធំៗ ។ តាមពិត មនុស្សមានសិទ្ធិពេញទីក្នុងការបញ្ចេញមតិ ឲ្យតែការនោះធ្វើដោយសន្តិវិធី ។ ប៉ុន្តែ មនុស្សពុំអាចយកសិទ្ធិនេះទៅប្រើដើម្បីបំផ្លិចបំផ្លាញទ្រព្យ-សម្បត្តិអ្នកដទៃឡើយ ។

ការសង់វត្តអារាម ការប្រារព្ធពិធីបុណ្យតាមសាសនានានា គឺជាសិទ្ធិរបស់មនុស្សទាំងអស់គ្នា ដរាបណាមិនរំខានដល់អ្នកដទៃ ។ ការប្រើសិទ្ធិក្នុងសង្គមត្រូវតែប្រយ័ត្នជានិច្ចកុំឲ្យប៉ះទង្គិចដល់សិទ្ធិអ្នកឯទៀត ។ ធម្មតា ស្រុកនីមួយៗ តែងតែមានច្បាប់វិន័យដែលពលរដ្ឋត្រូវតែប្រតិ-បត្តិតាម ។ មុននឹងធ្វើបុណ្យអ្វីមួយត្រូវតែសុំច្បាប់ ។ ការសុំច្បាប់មិនមែនជាការបំបិទសិទ្ធិទេ ។ ផ្ទុយទៅវិញ គឺជាការរក្សាសណ្តាប់ធ្នាប់សង្គម និងការរក្សាសន្តិសុខជូនពលរដ្ឋ ។

ចំណាំ : សង្គមខ្លះលើកស្ទួយសាសនាមួយ ហើយសង្កត់សង្កិនសាសនាដទៃទៀត ។ ការបង្ខិតបង្ខំឲ្យមនុស្សប្តូរគំនិត ឬប្តូរជំនឿសាសនា គឺជាការរំលោភ ។ ការបង្ខំមនុស្សឲ្យធ្វើអ្វីមួយដែលផ្ទុយនឹងឆន្ទៈផ្ទាល់របស់គេ គឺជាការរំលោភ ។ ការប្រារព្ធធ្វើបុណ្យតាមសាសនាខ្លួនដោយរំខានដល់អ្នកដទៃគឺជាការរំលោភសិទ្ធិគេ ។

# មាត្រា១៨



សិទ្ធិមានជំនឿដោយសេរី

## មាត្រា១៩ សិទ្ធិនិយាយស្តី ឬសំដែងមតិដោយសេរី

អ្នកមានសេរីភាពពេញទីក្នុងការគិតគូរ សំដែងមតិ និងនិយាយស្តី ។ គ្មានជនណាអាចឃាត់ឃាំងអ្នកមិនឲ្យនិយាយស្តី បញ្ចេញយោបល់ យកពត៌មាន ឬផ្តល់ពត៌មាន ទោះបីតាមរយៈសៀវភៅ កាសែត វិទ្យុ ទូរទស្សន៍ ឬតាមមធ្យោបាយផ្សេងៗទៀតក៏ដោយ ។

<u>សេចក្តីណែនាំ</u> : សេរីភាពខាងការបញ្ចេញមតិ និងខាងការនិយាយស្តីតែងតែជួបប្រទះនឹងការគាបសង្កត់ពីសំណាក់រដ្ឋអំណាចនៅប្រទេសជាច្រើន ។ អ្នកនិពន្ធ និងអ្នកកាសែតនានាបានត្រូវគេធ្វើបាប ។ សៀវភៅ កាសែត និងទស្សនាវដ្តីផ្សេងៗបានត្រូវគេហាមឃាត់ ឬបំបិទចោល ។ ជួនកាលរដ្ឋជាម្ចាស់វិទ្យុ ទូរទស្សន៍ សារពត៌មាន ហើយនិងប្រព័ន្ធផ្សាយពត៌មានព្រមទាំងប្រព័ន្ធត្រួតពិនិត្យគ្រប់ប្រភេទ ។ ពេលណារដ្ឋអំណាចចង់ធ្វើការគាបសង្កត់លើការនិយាយស្តី និងការបញ្ចេញមតិដោយសេរី ដែលជាសិទ្ធិដ៏ត្រឹមត្រូវរបស់មនុស្ស គេតែងតែយកលេសថា មានអំពើវិទ្ធង្សនា ឬដើម្បីរក្សាសន្តិសុខជាតិ ។ អំពើគាបសង្កត់បែបហ្នឹងមិនអាចស្ថិតស្ថេរជាអចិន្ត្រៃយ៍បានឡើយ ។ ប៉ុន្តែកាលណាមានការហាមឃាត់មិនឲ្យមានការផ្សព្វផ្សាយពត៌-មានដោយសេរី គំនិត និងមតិរបស់មនុស្សជាទូទៅក្លាយទៅជាចង្អៀតចង្អល់ ប្រាសចាកភាពប្រាកដនិយម ហើយធ្វើការមិនសូវបានល្អទៀតផង ។

ម្យ៉ាងវិញទៀត មានបញ្ហាមួយដែលអាចកើតឡើងទៅអនាគត ដោយសារការប្រើប្រដាប់ផ្សាយមិនត្រឹមត្រូវ ។ ឧទាហរណ៍ ដូចជាភាពយន្ត ឬវីដេអូជាដើម ដែលអាចនាំមកជូនសង្គមនូវរឿងអាស្រូវពុំគប្បី ដែលជាកត្តាបណ្តាលឲ្យកើតការហិនហោចខ្លោចផ្សាដល់មនុស្សជាតិ ។

<u>ចំណាំ</u> : ការប្រើសិទ្ធិសេរីភាពក្នុងមាត្រានេះ ត្រូវតែមានការប្រយ័ត្នជាទីបំផុត ដើម្បីចៀសវាងកុំឲ្យប៉ះទង្គិចដល់សិទ្ធិដទៃៗទៀត ដែលមានសារសំខាន់ដូចគ្នាដែរនោះ ។

D:\CIHR-W\LESS-GG\HRDECLA

## មាត្រា១៩



សិទ្ធិនិយាយស្តី ឬសម្តែងមតិដោយសេរី

D\CIHR-WALESS-GGHRDECLA

## មាត្រា២០ សិទ្ធិរួមប្រជុំដោយសេរី

អ្នកមានសិទ្ធិប្រជុំគ្នា ឬរៀបចំធ្វើបាតុកម្មផ្សេងៗបាន ឲ្យតែប្រកបដោយសន្តិវិធី ។ អ្នកអាចចូលរួមជាមួយក្រុមណាក៏បានឲ្យតែក្រុមនោះយល់ព្រម ។ គ្មានជនណាអាចមកបង្ខំអ្នកឲ្យចូលរួមជាមួយក្រុម ឬពួកណាដែលអ្នកមិនពេញចិត្តឡើយ ។

<u>សេចក្តីណែនាំ</u> : ការរួមប្រជុំគ្នា និងធ្វើបាតុកម្ម គឺជាសិទ្ធិពេញទីរបស់អ្នក ។ ប៉ុន្តែ បើមានប្រើហិង្សា ឬធ្វើឲ្យខូចខាតដល់សម្បត្តិអ្នកដទៃ គឺជាការរំលោភដល់សិទ្ធិអ្នកដទៃ ឬរំខានដល់របៀបរៀបរយសង្គម ឬប៉ះពាល់ដល់សន្តិសុខសាធារណៈ ។ បាតុករមានសិទ្ធិត្រឹមតែធ្វើការរួមប្រជុំ និងធ្វើបាតុកម្មប៉ុណ្ណោះ ។ ត្រូវចៀសវាងជាដាច់ខាតនូវអំពើឃោរឃៅ ឬហិង្សា ។ បើត្រូវធ្វើបាតុកម្មដោយមានដង្ហែជាក្បួនតាមផ្លូវសាធារណៈ ត្រូវតែសុំច្បាប់អនុញ្ញាតពីក្រសួងមានសមត្ថកិច្ច ព្រោះមានប៉ះពាល់ដល់សិទ្ធិសាធារណៈ ។ ហើយបើមានប៉ះពាល់ដល់សន្តិសុខសាធារណៈ រដ្ឋអំណាចតែងតែយកជាលេសដើម្បីធ្វើការគាបសង្កត់មកលើក្រុមបាតុករ ។ យ៉ាងណាមិញ ការរួមប្រជុំគ្នាដោយស្ងាត់ស្ងៀម និងដោយមិនមានប៉ះពាល់ដល់សិទ្ធិអ្នកដទៃ គឺជាសិទ្ធិពេញទីរបស់មនុស្សគ្រប់ៗគ្នា ។ ការហាមមិនឲ្យមនុស្សធ្វើបាតុកម្មអហិង្សា ឬមិនឲ្យរួមប្រជុំបែបនេះ គឺជាការរំលោភសិទ្ធិ ។ ការប្រើកងកម្លាំងប្រដាប់អាវុធទៅបំបាក់បាតុករដែលជាពាស្ត្រស្លូតត្រង់ ឬដែលជាសិស្សគ្មានអាវុធ គឺជាការរំលោភដ៏គួរឲ្យខ្ពើមរអើម ។

ម្យ៉ាងវិញទៀត ការចូលជាសមាជិកនៃសមាគម ឬសហជីពនានា គឺជាសិទ្ធិជ្រើសរើសនិងជាឆន្ទៈរបស់មនុស្សម្នាក់ៗ ។ ក្នុងករណីនេះ មិនត្រូវប្រើការបង្ខិតបង្ខំឡើយ ព្រោះជាការរំលោភលើសិទ្ធិក្នុងមាត្រា ២០ នេះ ។

អង្គការសហប្រជាជាតិបានណែនាំឲ្យយើងប្រើសេរីភាពយើងដោយប្រុងប្រយ័ត្ននិងដោយមានភាពថ្លៃថ្នូរជានិច្ច ។

## មាត្រា២០



សិទ្ធិរួមប្រជុំដោយសេរី

## មាត្រា២១ សិទ្ធិរួមចំណែកក្នុងសកម្មភាពនយោបាយ

អ្នកមានសិទ្ធិចូលរួមក្នុងកិច្ចការរបស់ប្រទេសអ្នក ដោយធ្វើជាភ្នាក់ងាររាជការបំរើក្នុងក្រសួងនានា ឬចូលរួមបោះឆ្នោតជ្រើសរើសអ្នកធ្វើការជូនជាតិតាមឆន្ទៈរបស់អ្នកផ្ទាល់ ។

សេចក្តីណែនាំ ៖ មាត្រា២១ នេះជាឆន្ទៈដ៏មហាប្រសើររបស់អង្គការសហប្រជាជាតិ ដើម្បីឲ្យមនុស្សអាចរួមចំណែកក្នុងសកម្មភាពផ្សេងៗនៃរដ្ឋាភិបាលខ្លួន ដូចជា ធ្វើជាអ្នករាជការ ធ្វើទាហាន ឬនគរបាល ឬអាចឈរឈ្មោះជាតំណាងរាស្ត្រ ។ បើពុំនោះសោតទេ ធ្វើជាពលរដ្ឋធម្មតាដែលមានសិទ្ធិបោះឆ្នោតរើសតំណាងខ្លួនដោយសេរី ព្រមទាំងអាចទទួលការគ្រប់គ្រងពីរដ្ឋាភិបាលស្មើៗគ្នា ។ ប៉ុន្តែ គេអនុវត្តបានយ៉ាងណាៗ អាស្រ័យទៅលើច្បាប់រដ្ឋធម្មនុញ្ញរបស់ប្រទេស ហើយនិងប្រពៃណីរបស់ជាតិនីមួយៗ ។ ប៉ុន្តែ បើកាលណាមានការត្រួតត្រាពីបរទេស ឬមានរបបផ្តាច់ការ សិទ្ធិអស់ទាំងនេះត្រូវគេជាន់ឈ្លីចោលអស់ ។ សូម្បីតែក្នុងកាលៈទេសៈធម្មតាក៏ដោយ ក៏នៅតែមានប្រទេសជាច្រើនពុំអាចធានាឲ្យមានការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ពោលគឺក្នុងឱកាសបោះឆ្នោតរើសតំណាងរាស្ត្រម្តងៗ គេតែងតែព្យួរនូវការបង្ខិតបង្ខំការគាបសង្កត់ ឬការស្រូកប៉ាន់ទិញសន្លឹកឆ្នោត ដែលបណ្តាលឲ្យមានការរអាក់រអួលដល់សិទ្ធិជ្រើសរើសដោយសេរីរបស់ពលរដ្ឋ ។ លទ្ធផលដែលលេចចេញអំពីការបោះឆ្នោតបែបនេះ មិនអាចចាត់ថាធ្វើជាតំណាងឆន្ទៈរាស្ត្របានទេ ។

ប្រទេសរុងរឿងដោយសារមានរដ្ឋាភិបាលល្អ និងមានច្បាប់រដ្ឋធម្មនុញ្ញល្អ ។ ច្បាប់រដ្ឋធម្មនុញ្ញល្អ គឺដោយសារអ្នកតំណាងរាស្ត្រដែលជាអ្នកតែងច្បាប់ ជាអ្នកដែលរាស្ត្រជ្រើសរើសដោយសេរី និងដោយត្រឹមត្រូវ ។ រដ្ឋាភិបាលល្អ គឺជារដ្ឋាភិបាលដែលប្រតិបត្តិតាមច្បាប់យ៉ាងខ្ជាប់ខ្ជួន បំរើប្រយោជន៍ប្រជាពលរដ្ឋជានិច្ច និងប្រកបដោយសេចក្តីស្មោះត្រង់ផង ។

ចំណាំ ៖ បើពលរដ្ឋមិនពេញចិត្តនឹងសមាជិករដ្ឋាភិបាលណាមួយ គេមានសិទ្ធិសុំឲ្យតំណាងរាស្ត្រដកចេញ ។ ហើយបើរាស្ត្រមិនពេញចិត្តនឹងរដ្ឋាភិបាល ពលរដ្ឋត្រូវរង់ចាំដល់ផុតអាណត្តិ ហើយបោះឆ្នោតរើសរដ្ឋាភិបាលថ្មី ។ ក្នុងលទ្ធិប្រជាធិបតេយ្យ ការផ្លាស់ប្តូរអំណាចត្រូវធ្វើដោយការបោះឆ្នោត មិនមែនដោយចុងអាវុធទេ ។

## មាត្រា២១




សិទ្ធិរួមចំណែកក្នុងសកម្មភាពនយោបាយ

## មាត្រា២២ សិទ្ធិមានគិរភ័យសង្គម

អ្នកមានសិទ្ធិប្រកបដោយនីរភ័យសង្គម ។ ( មាននីរភ័យសង្គម គឺមានកន្លែងជ្រកនៅ មានលុយកាក់គ្រប់គ្រាន់ដើម្បីរស់ មានពេទ្យមើលថែពីពេលអ្នកឈឺ ) ហើយអ្នកមានសិទ្ធិចូលរួមក្នុងសកម្មភាពនានាខាងវិស័យសេដ្ឋកិច វិស័យសង្គម និងវិស័យវប្បធម៌ ដូចជាដន្ត្រី សិល្បៈ សិប្បកម្ម អាជីវកម្ម កីឡា ព្រមទាំងសកម្មភាពផ្សេងៗទៀតដែលអាចជួយឲ្យរីកចំរើនដល់បុគ្គលិកលក្ខណៈរបស់អ្នក ។

សេចក្តីណែនាំ : មាត្រានេះជាតំណាងសេចក្តីប្រាថ្នាដ៏ឧដុង្គឧត្តមរបស់អង្គការសហប្រជាជាតិ ដើម្បីឲ្យមនុស្សគ្រប់ៗគ្នាមានលទ្ធភាពរស់នៅក្នុងភាពដ៏ល្អប្រសើរខាងវិស័យសេដ្ឋកិច្ចសង្គម និងវប្បធម៌ ដែលចាំបាច់ដើម្បីឲ្យមានការរីកចំរើនដល់សង្គម ។

តាមការពិត ទាំងក្នុងប្រទេសជឿនលឿន ទាំងក្នុងប្រទេសកំពុងលូតលាស់ មានមនុស្សច្រើនណាស់ដែលរស់យ៉ាងក្រីក្រតោកយ៉ាក ដោយមកពីហេតុច្រើនប្រការ ។ ជួនកាលពួកអ្នកមានទ្រព្យរំលោភសិទ្ធិពួកអ្នកក្រីក្រ ។ ជួនកាលពួកអ្នកមានអំណាចបំបិទសិទ្ធិរាស្ត្រតូចតាច មិនឲ្យរីកចំរើនតាមសេចក្តីប្រាថ្នានេះបាន ។

ការប្រតិបត្តិតាមសេចក្តីប្រាថ្នានេះ គឺជាការសំខាន់បំផុត ។ រីឯពួកអ្នកមានសម្បត្តិ និងពួកអ្នកមានអំណាច ជាចាំបាច់ត្រូវយកចិត្តទុកដាក់ដល់សុខុមាលភាពនៃពួកអ្នកក្រីក្រ ។ បើពុំនោះសោតទេ ការរស់នៅក្នុងសង្គមជាមួយគ្នាប្រាកដជាមានភាពរង្គោះរង្គើដោយសារអសន្តិសុខ ឬដោយសារកត្តាផ្សេងៗទៀតដែលបណ្តាលមកពីភាពមិនគ្រប់គ្រាន់ក្នុងការរស់នៅ ។

ចំណាំ : ការរស់នៅរបស់មនុស្សម្នាក់ៗនៅក្នុងសង្គម សុទ្ធតែមានទំនាក់ទំនងជាមួយអ្នកឯទៀត ។ ត្រូវតែធ្វើឲ្យមានយុត្តិធម៌ក្នុងសង្គមជានិច្ច ដើម្បីជាប្រយោជន៍ដល់មនុស្សគ្រប់ៗគ្នា ។ ការបណ្តោយឲ្យខ្វះយុត្តិធម៌ក្នុងសង្គម គឺជាការរំលោភសិទ្ធិ ។

## មាត្រា២២



សិទ្ធិមាននិរភ័យសង្គម

D:\CIHR-W\\LESS-CG\HRDECLA

# មាត្រា២៣ សិទ្ធិមានការងារធ្វើ

អ្នកមានសិទ្ធិធ្វើការងារដើម្បីបានលុយកាក់សំរាប់រស់នៅ ។ អ្នកមានសិទ្ធិជ្រើសរើសការងារធ្វើដោយសេរី ។ ចំពោះការងារដែលអ្នកធ្វើ ត្រូវតែមានប្រាក់កម្រៃគ្រប់គ្រាន់សំរាប់អ្នក និងគ្រួសារអ្នករស់បានដោយសមរម្យ ។ ប្រុស និងស្រីដែលធ្វើការដូចគ្នា ត្រូវតែបានប្រាក់ខែ ឬប្រាក់កម្រៃស្មើគ្នា ។ បើមានការចាំបាច់ អ្នកមានសិទ្ធិសុំប្រាក់សំរាប់ឧបត្ថម្ភពេលណាអ្នកគ្មានការងារធ្វើ ។ ដើម្បីការពារផលប្រយោជន៍អ្នក អ្នកមានសិទ្ធិចូលរួមក្នុងសហជីព ។

<u>សេចក្តីណែនាំ</u> : ការងារគឺជាជីវិត និងការចំរុងចំរើនរបស់មនុស្ស ។ កាលណាមនុស្សបានចំរុងចំរើន សង្គមក៏ចំរើន ។ សង្គមចំរើន ធ្វើឲ្យប្រទេសទាំងមូលរីកចំរើន ។ ដូច្នេះ រដ្ឋាភិបាលនៃប្រទេសនីមួយៗ ត្រូវរកមធ្យោបាយដើម្បីបង្កើតការងារឲ្យបានគ្រប់គ្រាន់ជូនប្រជាពលរដ្ឋក្នុងប្រទេស ។

ការមានការងារធ្វើដើម្បីរស់ ការជ្រើសរើសការងារដោយសេរី គឺជាសិទ្ធិរបស់មនុស្សគ្រប់ៗគ្នា ។ ប៉ុន្តែ នៅមានមនុស្សជាច្រើនណាស់ក្នុងលោកនេះ ដែលពុំមានការងារធ្វើ ឬដែលធ្វើការងារដែលខ្លួនមិនពេញចិត្ត ។ មានអ្នកខ្លះទៀតបានត្រូវគេធ្វើបាបដោយមិនឲ្យការងារធ្វើ ឬដោយបង្ខំឲ្យធ្វើការច្រើនហួសប្រមាណ ហើយឲ្យប្រាក់កម្រៃមិនគ្រប់គ្រាន់ ។
អំពើទាំងនេះជាការរំលោភសិទ្ធិ ។

ដោយមានជំនួយពីអង្គការអន្តរជាតិផ្នែកការងារ (I L O) ជារៀងរាល់ឆ្នាំ អង្គការសហប្រជាជាតិបានតាមដានពិនិត្យមើលល័ក្ខខ័ណ្ឌការងារ និងសិទ្ធិអ្នកធ្វើការ ដែលប្រទេសនានាបានផ្តល់ជូនពលរដ្ឋខ្លួន ដើម្បីឲ្យដឹងថា តើមានប្រទេសណា ខ្លះដែលគោរព ឬមិនគោរពសេចក្តីណែនាំរបស់អង្គការសហប្រជាជាតិ ។

D:\CIHR-W6\LESS-GG\HRDECLA

## មាត្រា២៣



សិទ្ធិមានការងារធ្វើ

## មាត្រា២៤ សិទ្ធិមានការសម្រាក និងកំសាន្តកាយ

ក្នុងក្របខ័ណ្ឌការងារ អ្នកមានសិទ្ធិឈប់សម្រាក មានសិទ្ធិទៅកំសាន្តកាយ ។ អ្នកមិនត្រូវបានគេបង្ខំឲ្យធ្វើការហួសពីកំរិតពេលម៉ោងដ៏សមរម្យឡើយ ។ ហើយអ្នកក៏ត្រូវមានសិទ្ធិទទួលប្រាក់កម្រៃក្នុងពេលឈប់សម្រាក ឲ្យតែការសម្រាកនោះត្រឹមត្រូវ ។

សេចក្តីណែនាំ : អង្គការសហប្រជាជាតិបានបញ្ញត្តិល័ក្ខខ័ណ្ឌម៉ោងពេល សម្រាប់ធ្វើការព្រមទាំងទទូចឲ្យមានការសម្រាកពីការងារដោយមានប្រាក់កម្រៃ ។

នៅប្រទេសណាដែលមានច្បាប់រដ្ឋធម្មនុញ្ញល្អ គេបានកំរិតពេលធ្វើការត្រឹម ៨ ម៉ោងក្នុងមួយថ្ងៃ សម្រាប់ប្រាំថ្ងៃក្នុងមួយអាទិត្យ ។ ត្រូវមានពេលសម្រាកដែលមានប្រាក់ខែពីរអាទិត្យក្នុងមួយឆ្នាំ និងមានពេលសម្រាប់ឈឺខានមកធ្វើការចំនួនមួយអាទិត្យ ។ ពេលឈប់នៅថ្ងៃបុណ្យជាតិផ្សេងៗ ក៏ត្រូវមានប្រាក់កម្រៃដែរ ។ ប៉ុន្តែ បើឈប់លើសពីពេលដែលគេកំរិតទាំងអស់នេះ គេត្រូវកាត់ប្រាក់កម្រៃតាមចំនួនពេលម៉ោងដែលខកខាន ។ ហើយអ្នកដែលឈប់ច្រើនហួសហេតុពេក ដោយរំលោភលើកិច្ចសន្យា នឹងត្រូវគេបណ្តេញឲ្យឈប់ធ្វើការ ព្រោះមុននឹងគេទទួលឲ្យចូលធ្វើការ ម្នាក់ៗត្រូវចុះកិច្ចសន្យាយ៉ាងត្រឹមត្រូវ ។

នៅប្រទេសជឿនលឿនមនុស្សធ្វើការទាំងអស់គ្នា ទាំងប្រុសទាំងស្រី ។ សិស្សភាគច្រើនដែលមានអាយុពី១៨ឆ្នាំឡើងទៅ ច្រើនតែទៅរៀនផង និងធ្វើការផង ។ ម្នាក់ៗគិតតែខិតខំធ្វើការ មិនថាការងារណាជាការងារណាឡើយ ឲ្យតែបានប្រាក់កម្រៃ ។ មនុស្សដេកស៊ីខ្ជិលធ្វើការត្រូវសង្គមស្អប់ខ្ពើម ។

ចំណាំ : អ្នកធ្វើការទាំងអស់ត្រូវមានពេលសម្រាកដោយមានប្រាក់ខែ ។ ស្ថាប័នណាមិនអនុវត្តដូចនេះ ស្ថាប័ននោះរំលោភសិទ្ធិលើបុគ្គលិកខ្លួន ។

## មាត្រា២៤



សិទ្ធិមានការសំរាក និងកំសាន្តកាយ

D CIHR W LESS-GG HRDECLA

# មាត្រា២៥ សិទ្ធិមានជីវភាពរស់នៅសមរម្យ

អ្នកត្រូវតែមានជីវភាពរស់នៅសមរម្យ គឺជាសិទ្ធិរបស់អ្នក ។ ប្រសិនបើអ្នកពុំអាចធ្វើការបានដោយសារគ្មានការងារធ្វើ ឬដោយសារអ្នកមានជម្ងឺ ឬដោយសារអ្នកមានវ័យចាស់ ឬដោយសារប្តី ឬប្រពន្ធអ្នកស្លាប់ ឬដោយសារមូលហេតុផ្សេងទៀតដែលហួសពីសមត្ថភាពខ្លួនអ្នក អ្នកមានសិទ្ធិសុំឲ្យគេជួយឧបត្ថម្ភ ។

ត្រូវយកចិត្តទុកដាក់រក្សាមាតា និងកូនក្មេងឲ្យបានដិតដល់បំផុត ។ ក្មេងៗទាំងអស់មានសិទ្ធិស្មើៗគ្នា ទោះបីឪពុកម្តាយមានខាន់ស្លា ឬគ្មានក៏ដោយ ។

<u>សេចក្តីណែនាំ</u> : អង្គការសហប្រជាជាតិមានឆន្ទៈចង់ឲ្យមនុស្សគ្រប់ៗគ្នាមានឋានៈ ជីវភាពល្អប្រពៃ ថ្លៃថ្នូរសមជាមនុស្ស ។ ទោះនៅពេលមានការងារធ្វើក្តី ពេលគ្មានការងារធ្វើក្តី មនុស្សត្រូវមានជីវភាពយ៉ាងហោចណាស់ក៏ល្មមរស់កើត ។ រដ្ឋនីមួយៗមានកាតព្វកិច្ចបង្កលក្ខណៈឲ្យប្រជាពលរដ្ឋរស់នៅបានដោយសន្តិសុខ ព្រមទាំងមានវត្ថុសំរាប់ការរស់នៅដូចជា : អាហារ ទីជម្រក និងសម្លៀកបំពាក់ ព្រមទាំងឧបករណ៍ចាំបាច់ខ្លះៗទៀត ដូចជាទឹកប្រើប្រាស់ និងប្រដាប់អនាម័យជាដើម ។ សុខភាព និងការអប់រំ ក៏ជាការចាំបាច់សំរាប់សង្គមដែរ ។ ប្រាក់ខែដែលទាបបំផុត ត្រូវមានចំនួនល្មមគ្រប់គ្រាន់សម្រាប់មនុស្សម្នាក់រស់នៅបានសមរម្យ ។

ម្យ៉ាងវិញទៀត អង្គការសហប្រជាជាតិបានខិតខំណែនាំឲ្យមនុស្សទាំងអស់ក្នុងលោកយកចិត្តទុកដាក់ជាពិសេសលើស្ត្រី និងកុមារ ។ ត្រូវជួយថែទាំស្ត្រី និងកុមារ ឲ្យបានដិតដល់ជាទីបំផុត ។ ស្ត្រីគឺជាមាតានៃមនុស្សជាតិផង រីឯពួកកុមារវិញ គឺជាពពួកមនុស្សដែលនឹងបន្តតំណែងបំរើសង្គមមនុស្សតទៅអនាគត ។ ដូច្នេះ កុមារជាអនាគតនៃសង្គមប្រទេស និងពិភពលោកទាំងមូល ។ ដូចនោះយើងត្រូវតែផ្តល់ឲ្យកុមារនូវការអប់រំ ត្រឹមត្រូវសម្រាប់ជាប្រយោជន៍ដល់ការទ្រទ្រង់មនុស្សជាតិ ។

## មាត្រា២៥



សិទ្ធិមានជីវភាពរស់នៅសមរម្យ

## មាត្រា២៦ សិទ្ធិទទួលការអប់រំ

អ្នកមានសិទ្ធិរៀនសូត្រឲ្យបានចេះដឹង ។ សាលាបឋមសិក្សាត្រូវតែឲ្យមានជាចាំបាច់ និងដោយឥតគិតថ្លៃឈ្នួលទៀតផង ។ បើអ្នករៀនពូកែ អ្នកមានសិទ្ធិបន្តការសិក្សាឡើងទៅថ្នាក់លើ ឬចូលទៅរៀនខាងវិជ្ជាជីវៈក៏បាន ។ សាលារៀនត្រូវបង្រៀនអំពីអ្វីៗដែលជួយឲ្យអ្នកអាចយកទៅប្រើបានដើម្បីរស់នៅ ។ សាលារៀនត្រូវអប់រំឲ្យអ្នកចេះរស់ជាមួយអ្នកឯទៀតដោយមិនប្រកាន់ភេទ ពូជសាសន៍ ពណ៌សម្បុរ ភាសា សាសនា ឬជាតិកំណើតឡើយ ។ ការសិក្សាអប់រំត្រូវសំដៅយកគំនិតជួយគាំទ្រអង្គការសហប្រជាជាតិ ក្នុងការខិតខំរក្សាសន្តិភាពជូនពិភពលោកយើងនេះ ។ ឪពុកម្តាយអ្នកមានសិទ្ធិជ្រើសរើសសាលារៀនឲ្យអ្នក ។

<u>សេចក្តីណែនាំ</u> : វិជ្ជាគឺជាសម្បត្តិដែលមិនអាចទិញដូរបាន និងមិនចេះបាត់បង់ដូចសម្បត្តិធម្មតាឡើយ ។ ចំណេះវិជ្ជាគឺជាស្ពានសម្រាប់ឲ្យមនុស្សឆ្លងពីភាពក្រីក្រទៅកាន់ភាពរុងរឿង ។ ប្រទេសចម្រើនគឺជាប្រទេសដែលមានមនុស្សចេះដឹងច្រើន ។ ភាពល្ងង់ខ្លៅជាសត្រូវយ៉ាងសាហាវដែលអាចបំផ្លាញមនុស្សជាតិបាន ។

នៅក្នុងមាត្រានេះ អង្គការសហប្រជាជាតិមានគោលដៅល្អពីរ : **ទីមួយ** គឺចង់ឲ្យមនុស្សគ្រប់ៗគ្នានៅក្នុងលោកនេះចេះអក្សរ ដោយសូមឲ្យប្រទេសទាំងអស់មានសាលារៀនគ្រប់គ្រាន់ជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ ។ **ទីពីរ** គឺត្រូវផ្តល់វិជ្ជាឲ្យមនុស្សយកទៅប្រើដើម្បីជាប្រយោជន៍ដល់មនុស្សជាតិ ។ មនុស្សណាប្រើចំណេះដោយគ្មានសីលធម៌ និងខ្វះគតិយុត្តិធម៌ មនុស្សនោះអាចជាគ្រោះថ្នាក់ដល់សង្គម និងដល់ប្រទេស ឬដល់ពិភពលោកទាំងមូលផង ។ ចំណេះវិជ្ជាត្រូវតែយកទៅប្រើក្នុងក្របខ័ណ្ឌនៃការគោរពសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់មនុស្ស ព្រមទាំងដើម្បីទ្រទ្រង់សន្តិភាពពិភពលោកផង ។

<u>ចំណាំ</u> : ការបណ្តោយឲ្យកុមារចម្រើនវ័យដោយគ្មានការអប់រំ គឺជាការរំលោភសិទ្ធិកុមារផង រំលោភសិទ្ធិសាធារណៈផង ។

# មាត្រា២៦



សិទ្ធិទទួលការអប់រំ

## មាត្រា២៧ សិទ្ធិទទួលផលក្នុងជីវភាពវប្បធម៌ និងរក្សាសិទ្ធិ

អ្នកមានសិទ្ធិរួមចំណែកក្នុងសកម្មភាពផ្សេងៗផ្នែកវប្បធម៌ និងមានភាគផលអំពីការរីកចំ-រើននៃវិទ្យាសាស្ត្រ ។ បើអ្នកមានបង្កើត ឬសរសេរ ឬផលិតអ្វីមួយ អ្នកមានសិទ្ធិហាមប្រាម មិនឲ្យអ្នកដទៃយកទៅប្រើដោយគ្មានការអនុញ្ញាតអំពីអ្នក ។ ភាគផលដែលកើតចេញអំពីកិច្ចការរបស់អ្នក គឺជាកម្មសិទ្ធិរបស់អ្នក ។

<u>សេចក្តីណែនាំ</u> : ការរីកចម្រើនខាងវិស័យវិទ្យាសាស្ត្រ គឺជាការរីកចម្រើនរបស់មនុស្សជាតិទាំងមូល ។ ប៉ុន្តែ ការយកវិទ្យាសាស្ត្រទៅប្រើខុសរបៀប អាចក្លាយទៅជាការបំផ្លិចបំផ្លាញមនុស្សជាតិទៅវិញ ។ ការរីកចម្រើនផ្នែកសិល្បៈ និងវប្បធម៌ក្នុងសង្គម ក៏ជាការរីកចម្រើនរបស់មនុស្ស ។ ម្នាក់ៗមានសេរីភាពដើម្បីរួមចំណែកនៅក្នុងការវិវឌ្ឍន៍នេះ ប៉ុន្តែត្រូវចៀសវាងកុំឲ្យមានការប៉ះទង្គិចដល់ផលប្រយោជន៍អ្នកដទៃ ។ ការធ្វើឲ្យខូចគុណភាពខ្យល់អាកាស និងគុណភាពទឹក ដែលបណ្តាលមកពីការពិសោធន៍ខាងវិស័យវិទ្យាសាស្ត្រ គឺជាការរំលោភដល់មនុស្សជាតិទាំងមូល ព្រោះផលវិបាកនៃការពិសោធន៍ទាំងនេះ អាចបំផ្លាញមនុស្សជាតិទៅអនាគត។ រោងចក្រនានាដែលខំផលិតគ្រឿងទំនើបៗសំរាប់សេចក្តីត្រូវការរបស់មនុស្ស ក៏អាចជាគ្រោះថ្នាក់ដល់មនុស្សដែរ ព្រោះកាកសំណល់ដែលបង្ហូរតាមទឹកទន្លេ អាចធ្វើឲ្យមនុស្សមួយក្រុមទៀតទទួលគ្រោះថ្នាក់យ៉ាងធ្ងន់ ។ ផ្សែងដែលបង្ហុយចោលទៅលើអាកាសអាចធ្វើឲ្យមានជាតិក្រខ្វក់ក្នុងទឹកភ្លៀង ។ ដូច្នេះការរីកចំរើនផ្នែកវិទ្យាសាស្ត្រ អាចផ្តល់ផលអាក្រក់ជូន មនុស្សជាតិផងដែរ ។

អត្ថបទដែលអ្នកបាននិពន្ធ ឬវិទ្យាសាស្ត្រដែលអ្នកបានរកឃើញ គឺជាកម្មសិទ្ធិរបស់អ្នក ។ បើចង់ហាមមិនឲ្យគេយកទៅប្រើដោយគ្មានការអនុញ្ញាត អ្នកត្រូវសរសេរថា : <u>រក្សាសិទ្ធិ</u> ។ បើមានពាក្យថា : <u>រក្សាសិទ្ធិ</u> នេះ អ្នកដទៃមិនមានសិទ្ធិប៉ះពាល់ឡើយ ដរាបណាមិនមានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ ។

## មាត្រា២៧



សិទ្ធិទទួលផលក្នុងជីវភាពវប្បធម៌ និងរក្សាសិទ្ធិ

D:CIHR-W\LESS-GG\HRDECLA

## មាត្រា២៨ សិទ្ធិឱ្យមានច្បាប់ការពារសិទ្ធិរបស់ខ្លួន

ដើម្បីកុំឲ្យមានការរំលោភមកលើសិទ្ធិ និងសេរីភាពរបស់មនុស្សទាំងនៅក្នុងប្រទេសអ្នក ទាំងនៅក្នុងពិភពលោកទាំងមូល ត្រូវតែមានច្បាប់បញ្ញត្តិយ៉ាងម៉ឺងម៉ាត់ ដើម្បីការពារសិទ្ធិ និង សេរីភាពទាំងនេះឲ្យបានជិតដល់ ។

<u>សេចក្តីណែនាំ</u> : មនុស្សទាំងអស់ ទោះនៅទីណាក៏ដោយ មានសេចក្តីប្រាថ្នា ដូចៗគ្នា គឺការរស់ដោយសុខសន្តិភាព និងដោយមានការគោរពដល់សិទ្ធិទាំងឡាយ ដែលមានចែងនៅ ក្នុងសេចក្តីថ្លែងការណ៍នេះ ។ ប៉ុន្តែ ពីដើមរៀងមកមានការរំលោភលើសិទ្ធិជាមូលដ្ឋានរបស់ មនុស្សដោយឥតឈប់ឈរ ដូចមានការលេបទឹកដីនៃប្រទេសតូចតាចជាច្រើន បញ្ចូលទៅក្នុង ប្រទេសធំណាមួយ ការសម្លាប់ និងការធ្វើឲ្យមនុស្សស្លាប់រាប់លាននាក់ ដោយសារសង្គ្រាមពិភព លោកទាំងពីរលើក និងសង្គ្រាមផ្សេងៗទៀតជាច្រើនឥតឈប់ឈរ ។ ហេតុអ្វីបានជាចេះតែមាន សង្គ្រាម បើមនុស្សប្រាថ្នាចង់រស់នៅដោយសន្តិភាព ? នេះគឺមកអំពីសណ្តាប់ធ្នាប់សង្គមនៅក្នុង ប្រទេសជាច្រើនមិនមានលំនឹង ។ របៀបរៀបរយអន្តរជាតិ ក៏ពុំមានលំនឹងដែរ ។ ការរំលោភសិទ្ធិ ជាមូលដ្ឋានសំខាន់បំផុតរបស់មនុស្សនៅតែមាន គឺការរំលោភសិទ្ធិមានជីវិតរស់នៅរបស់មនុស្ស ។ មនុស្សក្នុងលោកនេះបានចំណាយធនធានយ៉ាងច្រើនដើម្បីកសាងឧបករណ៍សំរាប់សម្លាប់មនុស្ស។ ការគិតតែប្រយោជន៍ផ្ទាល់ខ្លួននៃប្រទេសនីមួយៗ បានបង្កើតឲ្យមានគោលនយោបាយព្រមទាំង ស្ថាប័នសេដ្ឋកិច្ចដែលបណ្តាលឲ្យប្រទេសក្រីក្រកាន់តែក្រទៅ ហើយប្រទេសមានទ្រព្យកាន់តែមាន ទៅ ។

វិធីដោះស្រាយមានតែមួយ គឺដើម្បីឲ្យមនុស្សរស់ជាមួយគ្នាបានដោយសន្តិភាព មនុស្ស ទាំងអស់នៅគ្រប់ទិសទីមានឆន្ទៈយ៉ាងមុតមាំថា ត្រូវតែគោរពតាមសេចក្តីណែនាំរបស់សេចក្តី ថ្លែងការណ៍នេះ ។ មាត្រា២៨ នេះ ស្នើសុំឲ្យបង្កើតប្រព័ន្ធអន្តរជាតិមួយសំរាប់សេដ្ឋកិច្ចថ្មី ដើម្បី ការពារសិទ្ធិនេះ ។

<u>ចំណាំ</u> : គ្មានច្បាប់ការពារសិទ្ធិមនុស្ស គឺជាការរំលោភសិទ្ធិ ។

## មាត្រា២៨




សិទ្ធិឱ្យមានច្បាប់ការពារសិទ្ធិរបស់ខ្លួន

## មាត្រា២៩ កាតព្វកិច្ចចំពោះសហគមន៍ និងគោរពសិទ្ធិអ្នកដទៃ

គ្រប់ៗគ្នាសុទ្ធតែមានកាតព្វកិច្ចចំពោះសហគមន៍ និងគោរពសិទ្ធិអ្នកដទៃ ។ ការប្រើសិទ្ធិត្រូវឲ្យមានព្រំដែនច្បាស់លាស់ ។ នៅក្នុងសង្គមប្រជាធិបតេយ្យ មនុស្សប្រើសិទ្ធិយ៉ាងប្រុងប្រយ័ត្ន ដើម្បីកុំឲ្យមានការរំលោភ ឬប៉ះពាល់ដល់សិទ្ធិនិងសេរីភាពអ្នកដទៃទៀត ។

<u>សេចក្ដីណែនាំ</u> : នេះជាចំណុចសំខាន់បំផុតក្នុងការប្រើប្រាស់សិទ្ធិរៀងៗខ្លួន ។ មនុស្សទាំងអស់ចង់ប្រើប្រាស់សិទ្ធិរបស់ខ្លួន ហើយមនុស្សទាំងអស់ក៏ត្រូវការការពារសិទ្ធិរបស់ខ្លួនផងដែរ ។ មានសិទ្ធិជំពូកខ្លះ មនុស្សត្រូវប្រើដោយប្រយ័ត្នបំផុត ព្រោះវាអាចប៉ះទង្គិចដល់សិទ្ធិអ្នកដទៃ ។ ឧទាហរណ៍ អ្នកមានសិទ្ធិប្រារព្ធពិធីបុណ្យដែលមានដន្ត្រី ច្រៀងរាំកំសាន្តយ៉ាងគគ្រឹកគគ្រេង ប៉ុន្តែអ្នកមិនត្រូវភ្លេចថា សម្លេងភ្លេងដ៏គគ្រឹកគគ្រេង នេះអាចរំខានដល់មនុស្សឯទៀតដែលគេត្រូវសំរាកឲ្យស្ងាត់ស្ងៀម ។ យ៉ាងហ្នឹងហើយបានជាត្រូវឲ្យមានច្បាប់យ៉ាងច្បាស់លាស់ដើម្បីចៀសវាងកុំឲ្យមានការប៉ះពាល់ដល់សិទ្ធិគ្នានឹងគ្នានៅក្នុងសង្គម ព្រោះវាអាចបណ្ដាលឲ្យខូចរបៀបរៀបរយសង្គមដែលជាកត្តានាំឲ្យប៉ះពាល់ដល់សន្តិសុខជាតិ ។

ការតាក់តែងច្បាប់ដើម្បីការពារផលប្រយោជន៍ពួកអ្នកមានទ្រព្យ ឬពួកអ្នកមានអំណាចអាចមានការប៉ះពាល់ដល់សិទ្ធិរបស់រាស្ត្រតូចតាច ។ នៅក្នុងលទ្ធិប្រជាធិបតេយ្យ ច្បាប់តម្រូវឲ្យបុគ្គលិករាជការបំរើ និងគោរពតាមឆន្ទៈប្រជារាស្ត្រ ព្រោះរាស្ត្រជាសមាសភាព ឬកោសិកាសង្គម ហើយរដ្ឋាភិបាលត្រូវជាភ្នាក់ងាររបស់សង្គម ។ គោលនយោបាយ ឬស្ថាប័ននានា ត្រូវឈានទៅរកផលប្រយោជន៍រួមរបស់មនុស្សជាទូទៅក្នុងសង្គម ។

<u>ចំណាំ</u> : គោលដៅនៃមាត្រានេះ គឺការគោរពសិទ្ធិអ្នកដទៃឲ្យខ្ជាប់ខ្ជួន ដូចការដែលយើងចង់ឲ្យគេគោរពសិទ្ធិរបស់យើង ។ មនុស្សម្នាក់ៗមានកាតព្វកិច្ចទ្រទ្រង់សុខុមាលភាពមនុស្សជាតិទូទៅ ។

## មាត្រា២៩




ភារកិច្ចចំពោះសហគមន៍ និងគោរពសិទ្ធិអ្នកដទៃ

## មាត្រា៣០ កាតព្វកិច្ចការពារខ្លឹមសារនៃសេចក្តីថ្លែងការណ៍នេះ

មិនត្រូវបំផ្លិចបំផ្លាញច្បាប់បញ្ញត្តិនៃសិទ្ធិ និងសេរីភាព ដែលមានចែងនៅក្នុងសេចក្តីថ្លែងការណ៍នេះឡើយ ទោះបីជារដ្ឋាភិបាល អង្គការ ឬមនុស្សជំពូកណាក៏ដោយ ។

សេចក្តីណែនាំ : មាត្រានេះចង់និយាយថា មនុស្ស មិនត្រូវដកយកបញ្ញត្តិណាមួយនៃសេចក្តីថ្លែងការណ៍ទាំងមូលនេះ ទៅប្រើឲ្យប៉ះពាល់ដល់សិទ្ធិជនណាម្នាក់ឡើយ ។

សេចក្តីសង្ខេប : មាត្រាទាំង៣០ នេះ ចែកចេញជាបីក្រុម : **ក្រុមទីមួយ** : មាត្រា ១ ដល់មាត្រា ២១ ចែងអំពីការគ្រប់គ្រងត្រឹមត្រូវ និងការធានាឲ្យមានការគោរពសិទ្ធិ និងសេរីភាពទាំងឡាយរបស់មនុស្សគ្រប់គ្នា ។ **ក្រុមទីពីរ** : មាត្រា ២២ ដល់មាត្រា ២៧ និយាយអំពីសិទ្ធិមានការអប់រំ មានការងារធ្វើ មានម្ហូបអាហារ និងការថែរក្សា ព្រមទាំងមានសន្តិសុខនៅក្នុងសហគមន៍ ។ **ក្រុមទីបី** : មាត្រា ២៨ ដល់មាត្រា ៣០ បញ្ជាក់ពីកាតព្វកិច្ចរបស់មនុស្សគ្រប់ៗគ្នាក្នុងការប្រតិបត្តិតាមបញ្ញត្តិនៃសិទ្ធិទាំងឡាយនេះ ហើយខំធ្វើឲ្យកូនចៅយើងជំនាន់ក្រោយៗបានក្រេបជញ្ជក់រសជាតិនៃសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្សនេះ ។

សេចក្តីរំឭក : ការពុំបានដឹងអំពីសិទ្ធិមនុស្ស បណ្តាលឲ្យមានការរំលោភលើសិទ្ធិមនុស្ស ។ចេះដឹងហើយ ប៉ុន្តែមិនបានជួយឈឺឆ្អាលដើម្បីការពារ ឬគោរពសិទ្ធិមនុស្សក៏អាចបណ្តាលឲ្យមានការរំលោភលើសិទ្ធិមនុស្សដែរ ។ ដោយសារការរំលោភសិទ្ធិមនុស្ស ប្រជាជាតិ និងប្រជារាស្ត្រខ្មែរបានរងទុក្ខវេទនា និងទទួលការហិនហោចខ្ទេចខ្ទាំឥតគណនា ដែលយើងទាំងអស់គ្នាត្រូវតែចងចាំទុកជាមេរៀន ហើយនឹងខិតខំសិក្សាវិជ្ជាសិទ្ធិមនុស្សនេះឲ្យបានច្បាស់លាស់ ។

## មាត្រា៣០



ភាគពួកកិច្ចការពារខ្លឹមសារនៃសេចក្តីថ្លែងការណ៍នេះ

# ការបោះឆ្នោត

តាមឯកសាររបស់ **វិទ្យាស្ថានខ្មែរសម្រាប់លទ្ធិប្រជាធិបតេយ្យ**

## I វិធីសំរាប់សង្គមមនុស្សធ្វើសេចក្តីសំរេច

គេបានសង្កេតឃើញថា មានវិធីធំៗប្រាំមួយបែបសំរាប់សង្គមមនុស្សធ្វើសេចក្តីសំរេច :

+ ទីមួយ គឺការប្រកួតប្រជែងគ្នា : គេប្រើវិធីនេះ ដើម្បីជ្រើសរើសមនុស្សដែលមានលក្ខណៈសម្បត្តិ គុណសម្បត្តិ និងសមត្ថភាពចាំបាច់ ដើម្បីធ្វើការងារ ឬបំពេញបេសកកម្មអោយបានជោគជ័យ ។

+ ទីពីរ គឺការផ្សងសំណាង : គេប្រើប្រាស់វិធីនេះ នៅពេលណាគេមិនច្បាស់ថា ការសំរេចបានល្អ ឬអាក្រក់ ឬក៏បេក្ខជន ឬក៏របស់ដែលត្រូវជ្រើសរើសមានច្រើនពេកមិនដឹងយកមួយណា ហើយការសំរេចដោយវិធីណាមួយទៀត អាចនាំអោយខូចទំនាក់ទំនងសមាជិកក្នុងក្រុម ឬ ក៏ក្នុងអង្គភាព ។ ការចាប់ឆ្នោតជ្រើសរើសជាបច្ចេកទេសមួយក្នុងវិធីធ្វើសេចក្តីសំរេចតាមការផ្សងសំណាងនេះ ។

+ ទីបី គឺការប្រគល់អំណាចអោយបុគ្គលម្នាក់ ១ ឬក៏ក្រុមតូចមួយធ្វើសេចក្តីសំរេច : គេច្រើនប្រើវិធីនេះ នៅពេលដែលគេត្រូវការជំនាញការ ដែលមានតែមនុស្សចំនួនតូចទេ ដែលមានជំនាញការបែបនោះ ដើម្បីធ្វើសេចក្តីសំរេចភ្លាម ១ ។

+ ទីបួន គឺការសំរេចអត់មានក្បួនខ្នាត : គឺដោយអនាធិបតេយ្យគ្មាននរណាស្តាប់បង្គាប់នរណាឡើយ ។ វិធីអនាធិប-តេយ្យនាំអោយមនុស្សធ្វើសេចក្តីសំរេចទៅមិនប៉ះទង្គិចគ្នាដែរ ដូចជាមនុស្សច្រើនដើរតែពីសតែពាសនៅពេលបុណ្យទាន ឬនៅទីនានា ហើយចេះតែជៀសគ្នាបានទៅ ។

+ ទីប្រាំ គឺយន្តការទីផ្សារ : ក្រុមមនុស្សចូលរួមក្នុងការធ្វើសេចក្តីសំរេចដោយតថ្លៃគ្នាទៅវិញទៅមក ។ ការសំរេចទិញលក់ផលិត នៅក្នុងសេដ្ឋកិច្ចច្រើនតែធ្វើនៅក្នុងយន្តការទីផ្សារនេះ ។

+ ទីប្រាំមួយ គឺតាមយន្តការលទ្ធិប្រជាធិបតេយ្យ : យន្តការនេះត្រូវមានលក្ខណៈបួនយ៉ាង ។ មួយគឺអ្នកទាំងឡាយដែលបានចូលរួមត្រូវផ្តល់សិទ្ធិអោយទៅម្នាក់ៗ បង្ហាញផែនការ និងបញ្ចេញមតិអោយអ្នកទាំងនោះស្តាប់ ។ ពីរ គឺអ្នកទាំងអស់អាចជជែកពិភាក្សាគ្នាអំពីបញ្ហាទាំងឡាយដែលត្រូវមានសេចក្តីសំរេច ។ បី គឺអ្នកទាំងឡាយត្រូវមានសិទ្ធិស្មើគ្នាក្នុងការចូលរួមក្នុងកិច្ចការនៃក្រុមរបស់ខ្លួន ។ ហើយបួនគឺយន្តការធ្វើ សេចក្តីសំរេចជាចុងក្រោយ ។ យន្តការ

គឺការព្រមព្រៀងទាំងអស់គ្នា ពេញចិត្ត ពេញថ្លើម (Consencus) ក្រោយពីការបង្ហាញហេតុផល ឬតាមរយៈការបោះឆ្នោតរបស់សមាជិកទាំងអស់ដែលចូលរួម ។

ក៏ប៉ុន្តែការបោះឆ្នោតផ្ទាល់ដែលគេហៅថា លទ្ធិប្រជាធិបតេយ្យដោយផ្ទាល់ ( direct democracy) នឹងអាចប្រព្រឹត្តទៅបានសំរាប់តែក្រុមតូចដែលមានសមាជិកតិច ហើយអាចមកជួបជុំគ្នាបាន ។ សំរាប់ក្រុមធំមានសមាជិកច្រើន ឬសំរាប់ប្រទេសទាំងមូល គេមានយន្តការបោះឆ្នោតជ្រើសតាំងតំណាងដើម្បីទៅធ្វើសេចក្តីសំរេចជូនគេ ។ នេះគេហៅថាលទ្ធិប្រជាធិបតេយ្យដោយមិនផ្ទាល់ ( indirect democracy ) ។ ក្នុងសម័យបច្ចុប្បន្នមានតែប្រជាមតិពោលគឺការសំរេចដោយផ្ទាល់ពីប្រជាពលរដ្ឋនៅក្នុងភូមិ ឃុំ ស្រុក ឬខេត្ត នៅប្រទេសខ្លះ ជាអាទិ៍នៅប្រទេសស្វីសដែលលទ្ធិប្រជាធិបតេយ្យនៅមានជាលក្ខណៈលទ្ធិប្រជាធិបតេយ្យ ដោយផ្ទាល់ ។ ការសំរេចរបស់សមាគមធំៗ និងផ្នែកទាំងឡាយនៅក្នុងប្រទេសប្រជាធិបតេយ្យច្រើនតែធ្វើឡើងតាមរយៈតំណាងរាស្ត្រ ។ ហេតុដូច្នេះហើយទើបគេច្រើននិយាយថា លទ្ធិប្រជាធិបតេយ្យនៅប្រទេសទាំងឡាយនោះជាលទ្ធិប្រជាធិបតេយ្យដោយតំណាង ( representative democracy )។ នៅក្នុងប្រទេសទាំងឡាយនេះ ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រសំរាប់សភាជាតិ ឬសភាខេត្ត ស្រុក ឃុំ ភូមិ ជាលក្ខណៈមួយ ដ៏សំខាន់នៃលទ្ធិប្រជាធិបតេយ្យ ។ គោលបំណងនៃការបោះឆ្នោតនេះ គឺការជ្រើសរើសតំណាងរាស្ត្រ ដែលនឹងទៅធ្វើសេចក្តីសម្រេចជូនរាស្ត្រ ។

## II ប្រវត្តិនៃការបោះឆ្នោតនៅប្រទេសខ្មែរ

ការបោះឆ្នោតដើម្បីសំរេចពីបញ្ហា ឬដើម្បីជ្រើសតាំងមេដឹកនាំ ឬក៏តំណាង មិនមែនជាវិធីថ្មីស្រឡាងនៅក្នុងវប្បធម៌ខ្មែរទេ ។ វិធីនេះត្រូវបានប្រើប្រាស់នៅក្នុងព្រះពុទ្ធសាសនា ជាពិសេសនៅក្នុងគណៈសង្ឃ ។

ក្រោយពីសង្គ្រាមលោកលើកទី ២មក នៅប្រទេសខ្មែរមានការរៀបចំការបោះឆ្នោត និងប្រជាមតិ មានចំនួនទាំងអស់ប្រមាណ១៨ដង ។ ចំនួនប្រជាពលរដ្ឋដែលមានឈ្មោះបោះឆ្នោត ហើយដែលបានចូលរួមបោះឆ្នោតផ្ទាល់កាន់តែមានចំនួនច្រើន ប្រសិនបើមានការប្រណាំងប្រជែងគ្នារវាងគណបក្ស ឬបេក្ខជន ។ តាមស្ថិតិដែលមាននៅពេលបោះឆ្នោតលើកដំបូងឆ្នាំ១៩៤៦ មានអ្នកបោះឆ្នោតជាង ៦០ភាគរយ ដែលធ្វើ អោយអាណានិគមបារាំងភ្ញាក់ផ្អើលយ៉ាងខ្លាំង ព្រោះថានៅប្រទេសឯទៀតដែលមានស្ថានភាព និងកំរិតលូតលាស់ដូចខ្មែរនោះ ភាគរយនៅត្រឹមតែខ្ទង់ ២០ភាគរយតែប៉ុណ្ណោះ ។ នៅឆ្នាំ ១៩៥១ ភាគរយនេះបានចុះមក ជាង ៥០ភាគរយ ដោយមកពីអសន្តិសុខ ។ នៅឆ្នាំ ១៩៦៦ ភាគរយនេះឡើងទៅដល់ជាង ៦៥ ភាគរយ ។ ការបោះឆ្នោតនៅពេលនោះ ធ្វើឡើងតែក្នុងពេលមួយថ្ងៃទេ។ ដល់មកការបោះឆ្នោតឆ្នាំ ១៩៩៣ ដែលរៀបចំដោយអ៊ុនតាក់ ចំនួន ៦ថ្ងៃ ភាគរយក៏ឡើងទៅដល់ក្បែរ ៩០ភាគរយ ។

## III ការបោះឆ្នោត សិទ្ធិបោះឆ្នោត និង សិទ្ធិឈរឈ្មោះបោះឆ្នោត

ខ្មែរបេះប្រើសិទ្ធិបោះឆ្នោត និងឈរឈ្មោះអោយគេបោះឆ្នោត ទាំងនៅក្នុងការបោះឆ្នោតដែលខ្មែរខ្លួនឯងរៀបចំទាំងការបោះឆ្នោតដែលគេរៀបចំអោយខ្មែរ ។ ការបោះឆ្នោត និងសិទ្ធិបោះឆ្នោត និងឈរឈ្មោះអោយគេបោះឆ្នោត នៅប្រទេសខ្មែរមានចែងច្បាស់លាស់នៅក្នុងកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយ នយោបាយរួមមួយនៃជំលោះកម្ពុជា នៅទីក្រុងប៉ារីស នៅថ្ងៃទី ២៣ ខែតុលា ឆ្នាំ១៩៩១ នៅក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ហើយនិងនៅក្នុងសេចក្តីថ្លែងការណ៍ អនុសញ្ញា និងកតិកាសញ្ញា អន្តរជាតិស្តីពីសិទ្ធិមនុស្ស ដែលខ្មែរយើងបានចុះហត្ថលេខា ។ ដើម្បីគូសបញ្ជាក់នូវសារៈសំខាន់នៃការបោះឆ្នោត និងសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋខ្មែរក្នុងការបោះឆ្នោត សូមធ្វើសេចក្តីយោងទៅលើឯកសារមួយចំនួន ដូចខាងក្រោមនេះ :

ឧបសម្ព័ន្ធទី ៥ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសបានកំណត់គោលការណ៍មួយចំនួនសំរាប់រដ្ឋធម្មនុញ្ញថ្មីមួយរបស់កម្ពុជា ។ គោលការណ៍មួយបានចែងថា : រដ្ឋធម្មនុញ្ញត្រូវប្រកាសថា កម្ពុជានឹងអនុវត្តប្រព័ន្ធប្រជាធិបតេយ្យសេរីដោយឈរលើមូលដ្ឋានពហុបក្ស ។ រដ្ឋធម្មនុញ្ញត្រូវកំណត់អោយមានការបោះឆ្នោតដោយសំងាត់ ដោយតំរូវអោយទំរង់នៃការបោះឆ្នោតត្រូវផ្តល់ឱកាសគ្រប់គ្រាន់ និងសមរម្យ ដើម្បីរៀបចំ និងចូលរួមក្នុងដំណើរការបោះឆ្នោត ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងអំពីសិទ្ធិបោះឆ្នោតនិងសិទ្ធិឈរឈ្មោះបោះឆ្នោតក្នុងមាត្រា ៣៤ និង ៧៦ ដូចតទៅ :

<u>មាត្រា៣៤ :</u> " ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះអោយគេបោះឆ្នោត ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ឆ្នាំ អាចឈរឈ្មោះអោយគេបោះឆ្នោត ។ បទបញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះអោយគេបោះឆ្នោតត្រូវចែងក្នុងច្បាប់បោះឆ្នោត " ។

<u>មាត្រា៧៦ :</u> " អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ ឆ្នាំ មានសញ្ជាតិជាខ្មែរតាំងពីកំណើតមក " ។

## IV លក្ខណៈនៃការបោះឆ្នោត

រដ្ឋធម្មនុញ្ញដែលបានចែងនូវលក្ខណៈវិនិច្ឆ័យមូលដ្ឋាននៃការបោះឆ្នោតជ្រើសតំណាងរាស្ត្រនៅក្នុងមាត្រា ៧៦ ដូចតទៅ :

" តំណាងរាស្ត្រជ្រើសតាំងដោយការបោះឆ្នោតសកលដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសំងាត់ " ។

តទៅនេះ គឺជាអត្ថបទបកស្រាយរបស់អ្នកជំនាញការខាងការបោះឆ្នោត សញ្ជាតិអាល្លឺម៉ង់ម្នាក់ឈ្មោះ វល់ទ័រ ហ្គិញស៊ីយរ[1] (Walter Gensior ) :

## ការបោះឆ្នោតជាសកល

ការបោះឆ្នោតជាសកលមានន័យថា ពលរដ្ឋគ្រប់ៗរូបមានសិទ្ធិចូលរួមក្នុងការបោះឆ្នោតដោយមិនគិតពីសាសនា ពូជសាសន៍ ការអប់រំ ភេទ ទ្រព្យសម្បត្តិ ស្ថានភាពសង្គមទេ ។ តាមប្រវត្តិសាស្ត្រ ការចូលរួមបោះឆ្នោតពីសំណាក់ស្ត្រីមិនសូវជាមានមូលដ្ឋានប្រាកដទេ សូម្បីក្នុងពេលថ្មីៗនេះក៏ដោយ ប៉ុន្តែសព្វថ្ងៃនេះការចូលរួមពីសំណាក់ស្ត្រីបានត្រូវទទួលស្គាល់ថា ជាចំណែកខានមិនបាននៃការបោះឆ្នោតសកល ។

## ការបោះឆ្នោតដោយសេរី

ការបោះឆ្នោតដោយសេរីមានន័យថា អ្នកបោះឆ្នោតអាចជ្រើសរើសបេក្ខជន ឬបញ្ជីគណបក្សដោយគ្មានការបង្ខំ ឬការគៀបសង្កត់ពីប្រភពឯកជនក្តី ឬពីរដ្ឋអំណាចក្តី ។ សេរីភាពក្នុងការបោះឆ្នោតគឺជាគោលការណ៍មិនមែនសំរាប់តែបោះឆ្នោតប៉ុណ្ណោះទេ គឺសម្រាប់នីតិវិធីបោះឆ្នោតទាំងមូលផងដែរ ជាពិសេសការចាត់តាំងបេក្ខជន និងការរៀបចំដទៃទៀតមានរួមទាំងការឃោសនាបោះឆ្នោត និងការយកសន្លឹកឆ្នោតទៅបោះទៀតផង ។ ឧទាហរណ៍ នគរបាល មិនត្រូវមានវត្តមាននៅក្នុង និងជុំវិញស្ថានីយបោះឆ្នោតដូចក្នុងប្រទេសមួយចំនួននោះទេ លើកលែងតែសន្តិសុខនៅស្ថានីយ៍បោះឆ្នោតជួបប្រទះនឹងគ្រោះថ្នាក់ ។

សេរីភាពក្នុងការបោះឆ្នោតមិនមែនមានន័យថា សេរីភាពមិនចូលបោះឆ្នោតនោះទេ ។ ហេតុនេះ ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងប្រទេសខ្លះ បានត្រូវច្បាប់បង្ខំឱ្យទៅបោះឆ្នោត ។

គោលការណ៍ " សេរីភាពក្នុងការបោះឆ្នោត " គឺវាមានលក្ខណៈចំបងខ្លាំងណាស់ចំពោះមុខងារ និងលក្ខណៈនៃការបោះឆ្នោត ពោលគឺ គេមិនហៅថាការបោះឆ្នោតឡើយ បើគ្មានសេរីភាពក្នុងការបោះឆ្នោតទេ ។ ព្រោះហេតុនេះទើបរដ្ឋធម្មនុញ្ញខ្លះ និងច្បាប់បោះឆ្នោតខ្លះ មិនបានបញ្ជាក់ជាពិសេសអំពីសេរីភាពក្នុងការបោះឆ្នោតនោះទេ ។ គេចាត់ទុកថាវាជាបំណែកជាក់ច្បាស់បង្កប់នៅក្នុងរាល់ការបោះឆ្នោតនោះទៅហើយ ។

---

[1] ប្រភព : អត្ថន័យនៃពាក្យបោះឆ្នោតសេរី និងយុត្តិធម៌
គោលការណ៍ជាមូលដ្ឋាន ដោយបណ្ឌិត វល់ទ័រ ហ្គិញស៊ីយរ

## ការបោះឆ្នោតដោយស្មើភាព

ការបោះឆ្នោតនឹងប្រកបដោយសមភាព លុះត្រាតែសន្លឹកឆ្នោតរបស់អ្នកបោះមានតំលៃស្មើៗគ្នា នៅពេលគេរាប់ ។ នេះមានន័យថា ការធ្វើអោយទម្ងន់នៃសន្លឹកឆ្នោតឱ្យខុសគ្នាដោយឈរនៅលើមូលដ្ឋាន ភេទ ជាតិសាសន៍ ចំណេះដឹង ទ្រព្យសម្បត្តិ ស្ថានភាពសង្គម ឬក៏លក្ខណៈដទៃទៀត គឺមិនស្របតាមច្បាប់ទាំងអស់ ។ លើសពីនេះទៅទៀតគោលការណ៍នៃការបោះឆ្នោតដោយស្មើភាព មានន័យថា សន្លឹកឆ្នោតរបស់អ្នកបោះឆ្នោតណាម្នាក់ ត្រូវបានគេរាប់ជាវិភាគទានស្មើៗគ្នា សំរាប់លទ្ធផលនៃការបោះឆ្នោត ។ គោលការណ៍គ្មានប្រែប្រួលទេ សូម្បីតែនៅក្នុងប្រព័ន្ធឯកត្តនាមក៏ដោយ ទោះជាក្នុងប្រព័ន្ធនេះមានតែសន្លឹកឆ្នោតបោះឱ្យបេក្ខជនឈ្នះឆ្នោតនោះទេ ដែលមានតម្លៃ ។ ផ្ទុយទៅវិញក្នុងប្រព័ន្ធបោះឆ្នោតសមាមាត្រសុទ្ធសាធ ភាពខុសគ្នាណាមួយ រវាងតម្លៃក្នុងការរាប់ និងតម្លៃក្នុងជ័យជំនះត្រូវចាត់ទុកជាការប្រាសចាកពីការបោះឆ្នោតដោយសមភាព ដែលគេមិនអាចទទួលយកបានឡើយ ។

នៅទីបញ្ចប់ គោលការណ៍សមភាពទាមទារអោយមានការរៀបចំផ្នែកបច្ចេកទេសជាក់ច្បាស់ក្នុងនីតិវិធីទាំងឡាយនៃការបោះឆ្នោតដែលមិនធ្វើអោយខូចដល់សមភាពនៃសិទ្ធិរបស់អ្នកចូលរួមទាំងអស់ ។ នីតិវិធីនេះមានរាប់បញ្ចូលទាំងការកំណត់ព្រំដែននៃមណ្ឌលបោះឆ្នោត ក៏ដូចជាលក្ខខណ្ឌនៃការប្រើសិទ្ធិបោះឆ្នោត នីតិវិធីតែងតាំងឈ្មោះបេក្ខជនរចនាសម្ព័ន្ធនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងអង្គការដទៃ ទៀតដែលទាក់ទងនឹងការរៀបចំនេះ ព្រមទាំងការផ្តល់ទីកន្លែងសំរាប់រៀបចំការបោះឆ្នោត និងការចូលរួមនៃមន្ត្រីរាជការ ក្នុងការឃោសនាបោះឆ្នោតនេះផងដែរ ។

ព្រោះហេតុនេះហើយនៅពេលបច្ចុប្បន្ននេះគោលការណ៍នៃសមភាពត្រូវបានគេយល់ថាជាគោលការណ៍ទូទៅធំបំផុតសំរាប់ការរៀបចំនីតិវិធីនានាសំរាប់ការបោះឆ្នោត ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏គោលការណ៍នេះ អាចអោយមានការលើកលែងខ្លះៗដូចក្នុងករណីប្រទេសអាល្លឺម៉ង់ តុលាការធម្មនុញ្ញនេះ បានយល់ព្រមឱ្យដាក់ " ឃ្លាកំរិតគណបក្សតូចៗ " នៅក្នុងច្បាប់បោះឆ្នោតអាល្លឺម៉ង់ ដើម្បីជៀសវាងនូវការបង្កើតឱ្យមានគណបក្សនយោបាយតូចៗច្រើនពេក ដែលអាចបង្កឱ្យមានអស្ថេរភាពនយោបាយជាយថាហេតុ ។

## ការបោះឆ្នោតដោយចំពោះ (ឬដោយផ្ទាល់)

ការបោះឆ្នោតដោយផ្ទាល់មានន័យថា អ្នកបោះឆ្នោតនីមួយៗអាចសំរេចជ្រើសរើសបេក្ខជន ឬឈ្មោះបេក្ខជនក្នុងបញ្ជីដោយខ្លួនឯងផ្ទាល់ ដោយមិនមានមេអណ្តើក ឬអ្នកណាឯទៀតចូលរួមជាមួយទេ។ អ្នកបោះឆ្នោតត្រូវតែសំរេចដោយខ្លួនឯងតែម្តង ពុំមាននរណាម្នាក់អាចប្តូរ ឬក៏អាចប្រែប្រួលសេចក្តីសំរេចរបស់គាត់ ក្រោយពេលបោះឆ្នោតបានឡើយ ។

គោលការណ៍នៃការបោះឆ្នោតដោយខ្លួនឯងផ្ទាល់នេះ ហាក់ដូចជាពុំសូវតឹងតែងដូចគោលការណ៍ដទៃៗទៀតទេ ។ មានរដ្ឋធម្មនុញ្ញឬច្បាប់បោះឆ្នោតមួយចំនួនតូចបានបញ្ជាក់គោលការណ៍នេះអោយបានច្បាស់ ដូចប្រទេសអាល្លឺម៉ង់ ។ គ្មាននរណាអាចនិយាយថា ការបោះឆ្នោតមិនផ្ទាល់ អាចជាការបោះឆ្នោតមិនប្រជាធិបតេយ្យ ឬក៏ថាមានប្រជាធិបតេយ្យតិចនោះឡើយ ។ យើងទាំងអស់គ្នាដឹងអំពីការបោះឆ្នោតមិនផ្ទាល់ដើម្បីជ្រើសរើសប្រធានាធិបតីនៅសហរដ្ឋអាមេរិក ។ យើងក៏ដឹងទៀតថា ប្រជាពលរដ្ឋអាល្លឺម៉ង់ ក៏មិនបោះឆ្នោតជ្រើសរើសប្រធានាធិបតីខ្លួនដោយផ្ទាល់ដែរ ។ Bundesversammlung ដែលជាគណៈកម្មការមួយមាន ( Bundestabgeordnete) សមាជិករបស់រដ្ឋសភាសហព័ន្ធ (Laenderparlament) និងសមាជិកចំនួនស្មើគ្នារបស់រដ្ឋសភា ដែលបោះឆ្នោតជ្រើសតាំងប្រធានាធិបតីអាឡឺម៉ង់ ។

## ការបោះឆ្នោតដោយសំងាត់

ពាក្យថាការបោះឆ្នោតដោយសំងាត់មានន័យថា អ្នកបោះឆ្នោតអាចបោះសន្លឹកឆ្នោតរបស់ខ្លួនដោយមិនមានអ្នកណាម្នាក់ដឹងអំពីសេចក្តីសំរេចរបស់គាត់ឡើយ ។ គោលការណ៍នៃការបោះឆ្នោតសំងាត់នេះ ជាការការពារការបោះឆ្នោតសេរី ។ តាមប្រវត្តិសាស្ត្រ គោលការណ៍អោយមានការសំងាត់នេះ លែងអោយមានការបោះឆ្នោតតាមការលើកដៃ ឬក៏ការបោះឆ្នោតតាមការចុះហត្ថលេខាតាមសន្លឹកឆ្នោតដូចដែលគេធ្លាប់ធ្វើក្នុងអតីតកាល។ គោលការណ៍នេះមិនគ្រាន់តែការពារការបោះសន្លឹកឆ្នោតនេះឯងប៉ុណ្ណោះទេ គឺវាជួយដល់ជំហររបស់អ្នកបោះឆ្នោតថែមទៀតផង ។ បុរស ឬស្ត្រីដែលទៅបោះឆ្នោត មិនគ្រាន់តែអាចបោះសន្លឹកឆ្នោត របស់ខ្លួនទៅក្នុងហិបឆ្នោតដោយសំងាត់ប៉ុណ្ណោះទេ តែត្រូវ តែបោះសន្លឹកឆ្នោតខ្លួននោះដោយសំងាត់ ដើម្បីធ្វើឱ្យមានការបោះឆ្នោតដោយសំងាត់ ។ លើសពីនេះទៅទៀត គោលការណ៍នៃការបោះឆ្នោតដោយសំងាត់នេះ នៅជាធរមានសំរាប់នីតិវិធីបោះឆ្នោតទាំងមូល មានន័យថា សេចក្តីសំរេចជាសំងាត់របស់ម្ចាស់ឆ្នោតត្រូវតែបានទទួលការការពារគ្រប់ទីកន្លែងដែលអាចធ្វើទៅបាន ។ ឧទាហរណ៍ បញ្ជីហត្ថលេខាដែលដាក់ជូនមកជាជំនួយក្នុងការជ្រើសរើសបេក្ខជនអោយឈរឈ្មោះ ត្រូវទុកជាការសំងាត់ ។

លក្ខណៈទាំងប៉ុន្មានខាងលើនេះ ចែងតែអំពីសិទ្ធិអ្នកបោះឆ្នោត ។ នៅមានលក្ខណៈវិនិច្ឆ័យមួយចំនួនទៀតដែលចែងអំពីសិទ្ធិឈរឈ្មោះជាបេក្ខជនអោយគេបោះឆ្នោត ។

ទីមួយ គឺពលរដ្ឋគ្រប់រូបត្រូវមានសិទ្ធិចូលរួមចំណែកក្នុងការគ្រប់គ្រងរដ្ឋ និងមានសិទ្ធិស្មើគ្នាក្នុងការឈរឈ្មោះជាបេក្ខជនអោយគេបោះឆ្នោត ។ រដ្ឋធម្មនុញ្ញខ្មែរបានចែងអំពីសិទ្ធិនេះហើយ ។ មាត្រា ៣៥ នៃរដ្ឋធម្មនុញ្ញបានចែងជាអាទិ៍ថា " ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច

និងវប្បធម៌របស់ប្រទេសជាតិ ” ។ រីឯសិទ្ធិឈរឈ្មោះជាបេក្ខជនក៏មានចែងដែរ ដូចដែលបានចែងនៅខាងលើនេះស្រាប់ ។

ទីពីរ គឺពលរដ្ឋគ្រប់រូបត្រូវមានសិទ្ធិអាចបង្កើតគណបក្សនយោបាយ ឬក៏ចូលជាសមាជិកនៃគណបក្សនយោបាយ ។ រដ្ឋធម្មនុញ្ញខ្មែរបានចែងអំពីសិទ្ធិនេះដែរ ដូចបានចែងនៅខាងលើ ។

ទីបី គឺពលរដ្ឋគ្រប់រូបត្រូវមានសិទ្ធិបញ្ចេញមតិនយោបាយដោយគ្មានអន្តរាគមន៍ សិទ្ធិទទួល និងផ្សាយ ពត៌មាន សិទ្ធិដើរហើរដោយសេរី ដើម្បីធ្វើយុទ្ធនាការឃោសនា ហើយនិងធ្វើការឃោសនាដោយស្មើភាពគ្នា រួមទាំងស្មើភាពគ្នានិងគណបក្សដែលកំពុងតែគ្រប់គ្រងរដ្ឋទៀតផង ។

ទីបួន គឺបេក្ខជនឈរឈ្មោះបោះឆ្នោតគ្រប់រូបនិងគណបក្សទាំងអស់ត្រូវមានលទ្ធភាពស្មើគ្នាក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ដើម្បីបង្ហាញទស្សនៈនយោបាយរបស់ខ្លួន ។

ទីប្រាំមួយ គឺបេក្ខជន និងគណបក្សនយោបាយ មានសិទ្ធិអោយច្បាប់ការពារសិទ្ធិនយោបាយ និងសិទ្ធិ ផ្នែកបោះឆ្នោត ហើយនិងមានសិទ្ធិទាមទារអោយការដោះស្រាយកែតំរូវវិញ នៅពេលដែលសិទ្ធិរបស់ខ្លួនទាំងនេះ ត្រូវបានគេរំលោភ ។

សិទ្ធិទាំងឡាយរបស់បេក្ខជន និងគណបក្សនយោបាយអាចត្រូវគេកាត់បន្ថយបានតែក្នុងលក្ខណៈពិសេសដែលមានចែងក្នុងច្បាប់ ។ ការកាត់បន្ថយក៏ត្រូវតែអោយសមរម្យក្នុងសង្គមប្រជាធិបតេយ្យ ព្រោះវាចាំបាច់ក្នុងការការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ សីលធម៌ ឬក៏ការការពារសិទ្ធិសេរីភាពរបស់អ្នកដទៃ ។ ការកាត់បន្ថយនេះទៀត ក៏អោយសម និងស្របទៅនឹងកាតព្វកិច្ចអន្តរជាតិរបស់រដ្ឋដែរ ហើយមិនត្រូវមានការរើសអើងដោយសារពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិអ្វីណាមួយទៀត ជាតិកំណើត ឬសង្គមដើម ទ្រព្យសម្បត្តិ ឬកំណើតរបស់បុគ្គលឡើយ ។

បេក្ខជន ឬគណបក្សនយោបាយ ដែលត្រូវបានគេបន្ថយសិទ្ធិទាំងឡាយខាងលើ មានសិទ្ធិប្តឹងតវ៉ាទៅឧទ្ធរណ៍បាន ។

## ប្រព័ន្ធបោះឆ្នោត [1]

ជាបឋម តើអ្វីដែលហៅថា ប្រព័ន្ធបោះឆ្នោត ? គឺជាយន្តការដែលធ្វើសំលេងឆ្នោតរបស់ប្រជាពលរដ្ឋឱ្យក្លាយជាអាសនៈ ក្នុងអង្គការដែលជាប់ឆ្នោតដូចជាអង្គការនីតិបញ្ញត្តិ ឬសភា ឬក្រុមប្រឹក្សា ។

---

[1] ប្រភព : ទស្សនៈទូទៅលើប្រព័ន្ធបោះឆ្នោតផ្សេងៗ
ដោយលោក រ៉េន ហ្វូល

ប្រទេសទាំងឡាយនៅលើសកលលោកប្រើប្រព័ន្ធបោះឆ្នោតមូលដ្ឋានពីរប្រព័ន្ធនោះគឺ :

- ប្រព័ន្ធភាគច្រើនដោយប្រៀប (ឯកត្តនាម)
- ប្រព័ន្ធសមាមាត្រ

ថែមពីលើនេះ នៅមានប្រព័ន្ធចំរុះដែលបញ្ចូលប្រព័ន្ធទាំងពីរខាងលើដើម្បីប្រមូលយកចំណុចខ្លាំង ៗ របស់ប្រព័ន្ធនីមួយៗ ហើយបង្រួញចំណុចខ្សោយទាំងឡាយឱ្យនៅតិចជាអប្បបរមា ។

## ប្រព័ន្ធភាគច្រើនដោយប្រៀប (ឯកត្តនាម)

ក្នុងប្រព័ន្ធភាគច្រើនដោយប្រៀប (ឯកត្តនាម) បេក្ខជនឈ្នះឆ្នោតដែលបានទទួលសំលេងឆ្នោតច្រើនជាងបេក្ខជនឯទៀតនៅក្នុងមណ្ឌលមួយ ។

មណ្ឌលបោះឆ្នោតនីមួយៗអាចជ្រើសរើសយកបេក្ខជនតែម្នាក់ ឬច្រើននាក់ ។ ក្នុងករណីជ្រើសរើសច្រើននាក់ បេក្ខជនទាំងឡាយណា ដែលទទួលបានសំលេងឆ្នោតច្រើនជាងគេ ត្រូវបានជាប់ឆ្នោត ។ គេហៅថា " នរណាដល់ទីមុនឈ្នះ " ( first past the post ): ឬមតិភាគច្រើនធម្មតា" ។ គេអាចនិយាយម្យ៉ាងទៀតថា បេក្ខជនម្នាក់ ឬច្រើនគ្នា អាចទទួលសំលេងឆ្នោតបានតែ ៣៥ ឬ ៤០ភាគរយនៃចំនួនសរុប ប៉ុន្តែដោយសារបានទទួលសំលេងច្រើនជាងគេហើយ បេក្ខជនទាំងនោះក៏ឈ្នះ ទោះបីជាខ្លួនមិនបានទទួលសំលេងភាគច្រើនរបស់ប្រជាពលរដ្ឋក្នុងមណ្ឌលមួយក៏ដោយ ។ ដើម្បីដោះស្រាយបញ្ហានេះ ប្រទេសមួយចំនួនរៀបចំអោយមានការបោះឆ្នោតលើកទីពីរទៀត សំរាប់តែបេក្ខជនពីររូបដែលបានសំលេងច្រើនជាងគេបង្អស់ប៉ុណ្ណោះ ក្នុងមណ្ឌលណាដែលគ្មានបេក្ខជនណាមួយបានទទួលសំលេងភាគច្រើនដាច់ខាតគឺយ៉ាងតិច ៥០% បូក១ នៃចំនួនសន្លឹកឆ្នោតទាំងអស់ក្នុងមណ្ឌល ។ ទង្វើនេះ ធានាបាននូវតំណាងមតិភាគច្រើន ប៉ុន្តែវាអស់លុយច្រើនដោយសារគេត្រូវរៀបចំការបោះឆ្នោតពីរដងនៅច្រើនកន្លែង ។ រូបមន្តមួយទៀត ដើម្បីធានាអោយបេក្ខជនឈ្នះឆ្នោតទទួលបានសំលេងភាគច្រើនដាច់ខាតលើសពី ៥០% គឺការប្រើឆ្នោតជំរើស (Alternative Vote) ដែលអនុញ្ញាតអោយអ្នកបោះត្រូវជ្រើសរើសបេក្ខជន ដែលខ្លួនពេញចិត្តតាមលំដាប់លេខរៀង (ឧទាហរណ៍ ១.២...) ។ ប្រសិនបើគ្មានបេក្ខជនណាម្នាក់បានទទួលសំលេងលើសពី ៥០ % នៃឆ្នោតជ្រើសរើសលំដាប់ លេខ១ ទេ ពេលនោះបេក្ខជនដែលមានសំលេងតិចជាងគេបំផុតត្រូវបានដកចោល ហើយគេក៏យកឆ្នោតជ្រើសរើសលំដាប់លេខទី២ របស់បេក្ខជននោះ ទៅចែកតាមឈ្មោះ ។ គេចេះតែបន្តធ្វើបែបនេះរហូតទាល់តែជ្រើសបានបេក្ខជនដែលមានសំលេងគាំទ្រលើសពី ៥០%។

## ប្រព័ន្ធសមាមាត្រ

គោលបំណងនៃប្រព័ន្ធសមាមាត្រ គឺដើម្បីបែងចែកចំនួនកៅអីបានត្រឹមត្រូវតាមការចូលចិត្តរបស់អ្នកបោះឆ្នោត ក្នុងការជ្រើសរើសតំណាងរបស់ខ្លួន ក្នុងអង្គការនីតិបញ្ញត្តិ ។

ក្រោមប្រព័ន្ធសមាមាត្រ គេច្រើនតែផ្តោតអារម្មណ៍ទៅលើគណបក្សដែលនឹងទទួលចំណែកកៅអីនៅក្នុងអង្គការនីតិបញ្ញត្តិប្រហាក់ប្រហែលស្មើនឹងភាគរយនៃសំលេងឆ្នោត ដែលខ្លួនបានទទួលពីមណ្ឌលបោះឆ្នោតណាមួយ ។

ប្រព័ន្ធនេះមានន័យថា មណ្ឌលបោះឆ្នោតនីមួយៗ មានតំណាងច្រើនផ្ទុយពីប្រព័ន្ធឯកត្តនាម ដែលមណ្ឌលនីមួយៗច្រើនតែមានតំណាងតែម្នាក់ប៉ុណ្ណោះ ។

ប្រភេទនៃប្រព័ន្ធសមាមាត្រដែលគេឃើញច្រើនជាងគេនេះ គឺប្រភេទដែលកំណត់អោយគណបក្សដាក់បញ្ជីឈ្មោះបេក្ខជនរបស់ខ្លួនទៅមណ្ឌលបោះឆ្នោតនីមួយៗ ហើយជាធម្មតាគណបក្សជាអ្នកសំរេចពីបេក្ខជន និងលេខរៀងរបស់បេក្ខជនទាំងឡាយក្នុងបញ្ជីឈ្មោះនោះ ។ យោងទៅតាមចំនួនកៅអីដែលឈ្នះគណបក្ស ក៏ជ្រើសរើសឈ្មោះបេក្ខជនជាប់ឆ្នោតចាប់ផ្តើមពីលេខរៀងលើគេចុះមក ។

ក៏ប៉ុន្តែនៅមានវិធីផ្សេងៗគ្នាមួយចំនួនទៀតដូចជា "ឆ្នោតតែមួយដែលអាចផ្ទេរបាន" (the Single Transferable Vote) ដែលអនុញ្ញាតអោយអ្នកបោះឆ្នោតមានសិទ្ធិជ្រើសរើសទូលំទូលាយលើបេក្ខជនក្នុងបញ្ជីគណបក្ស ។ ក្នុងវិធីផ្សេងៗនេះ អ្នកបោះឆ្នោតអាចជ្រើសរើសចំនួនបេក្ខជនចំៗតែម្តងក្នុងបញ្ជីគណបក្ស ឬមួយក្នុងបញ្ជីគណបក្សតែមួយ ឬមួយក៏ក្នុងបញ្ជីគណបក្សផ្សេងៗ អាស្រ័យនឹងវិធីដែលគេជ្រើសយក ។ វិធីទាំងនេះមានលក្ខណៈស្មុគស្មាញច្រើនដោយមានការជ្រើសរើសច្រើនរបស់អ្នកបោះឆ្នោត ។

ខ្ញុំបានបញ្ជាក់ខាងដើមហើយថា ប្រព័ន្ធចំរុះមានមណ្ឌលបោះឆ្នោតមានតំណាងតែម្នាក់ ហើយមានបញ្ជីឈ្មោះរបស់គណបក្សជាមួយគ្នាតែម្តង ។ អ្នកបោះឆ្នោតមានការជ្រើសរើសលើសន្លឹកឆ្នោតរបស់ខ្លួន គឺរើសយកបេក្ខជនមួយ និងគណបក្សមួយ ។

## ចំណុចខ្លាំង និងចំណុចខ្សោយ

ប្រព័ន្ធភាគច្រើនដោយប្រៀប ( ឯកត្តនាម )

- ប្រព័ន្ធនេះ ច្រើនតែបង្កើតរដ្ឋាភិបាលរបស់គណបក្សតែមួយ ដែលជាប់ឆ្នោតច្រើនញឹកញយផង ជាងប្រព័ន្ធសមាមាត្រ ។
- ប្រព័ន្ធនេះឃើញថា មានលក្ខណៈសាមញ្ញងាយស្រួលទាំងទ្រឹស្តីទាំងការអនុវត្តន៍សំរាប់អ្នកបោះឆ្នោត ។

- ប្រព័ន្ធនេះ ច្រើនតែជួយដល់គណបក្សដែលខ្លាំងហើយធំ ហើយមិនជួយដល់គណបក្សតូចៗ ឬ ថ្មីៗ ទេ ។
- ជាទូទៅ ការតំណាងនៅក្នុងរដ្ឋសភាមិនបានឆ្លុះបញ្ចាំងនូវឆន្ទៈរបស់អ្នកបោះឆ្នោតភាគច្រើនទេ។
- គណបក្សដែលមានការគាំទ្រច្រើន តែរាយប៉ាយទូទាំងប្រទេសច្រើនតែចាញ់ប្រៀបគណបក្ស ដែលមានការគាំទ្រក្នុងកំរិតប្រហាក់ប្រហែលគ្នាតែនៅផ្តុំតែក្នុងមណ្ឌលខ្លះ ឬតំបន់ខ្លះ ។ នេះអាចមានផលវិបាកបំបែកមតិជាតិ ឬប្រទេសជាតំបន់ៗដាច់ៗគ្នា ។
- នៅក្នុងមណ្ឌលដែលមានតំណាងតែម្នាក់ អ្នកបោះឆ្នោតយល់ថា បេក្ខជនជាប់ឆ្នោតជាតំណាងជិតស្និទ្ធរបស់ខ្លួនផ្ទាល់ នៅរដ្ឋសភា ។ នេះអាចមានផលវិបាកវិជ្ជមាន និងអវិជ្ជមាន ព្រោះបេក្ខជនត្រូវបែងចែកភក្តីភាពខ្លួនអោយទៅគណបក្សផង និងជូនមណ្ឌលខ្លួនផង ។

## ប្រព័ន្ធសមាមាត្រ :

- ប្រព័ន្ធសមាមាត្រឆ្លុះបញ្ចាំងពី " ឆន្ទៈរបស់ប្រជាពលរដ្ឋ" ត្រឹមត្រូវបានច្រើនជាង ។ ឆន្ទៈលេចចេញជាចំនួនអាសនៈនៅរដ្ឋសភា ។
- អ្នកបោះឆ្នោតច្រើនតែចង់គាំទ្រគណបក្សតូចៗ ក្រោមប្រព័ន្ធនេះ ព្រោះគេដឹងថាសំលេងឆ្នោតរបស់គេមិនឥតប្រយោជន៍ឡើយ ។
- ប្រព័ន្ធសមាមាត្រអាចផ្តល់លទ្ធភាពច្រើនដល់ក្រុមភាគតិច និងស្ត្រីអោយមានតំណាងរបស់ខ្លួន ។
- ដំណើរការបោះឆ្នោតនឹងផ្ទៀងផ្ទាត់សំលេងឆ្នោតមានលក្ខណៈស្មុគស្មាញជាទូទៅ ហើយនៅប្រទេសខ្លះសន្លឹកឆ្នោតដែលមិនបានការមានកំរិតខ្ពស់ ពេលណាគេអោយមានសិទ្ធិជ្រើសរើសច្រើន។
- ប្រព័ន្ធសមាមាត្រ ច្រើនតែបង្កើតរដ្ឋាភិបាលចំរុះញឹកញយផង ជាងប្រព័ន្ធភាគច្រើនដោយប្រៀប (ឯកត្តនាម)។ ដូច្នេះរដ្ឋាភិបាលនេះ មិនមែនកើតឡើងពីលទ្ធផលផ្ទាល់នៃការបោះឆ្នោតទេ ប៉ុន្តែតាមការតថ្លៃគ្នាក្រោយពេលបោះឆ្នោត ។ វាគ្មានប្រព័ន្ធណាមួយល្អឥតខ្ចោះឬវាក៏គ្មានគំរូណាមួយឧត្តុងឧត្តមទេ ។ ប្រព័ន្ធដែលល្អ គឺប្រព័ន្ធដែលអាចឆ្លើយតបនឹងតំណាងនយោបាយដែលប្រទេសខ្មែរសព្វថ្ងៃត្រូវការ ។
- ប្រព័ន្ធណាដែលអាចឱ្យអ្នកបោះយល់បាន និងគណបក្សនយោបាយមានជំនឿជឿជាក់បាន ហើយដែលមានភាពប្រាកដនិយមខាងផ្នែកហិរញ្ញវត្ថុ និងខាងផ្នែកការរៀបចំចាត់ចែង ។

## VI ភារកិច្ចនានាក្នុងការរៀបចំការបោះឆ្នោត[1]

ខាងក្រោមនេះ ជាផ្នែកធំៗនៃការងារ ដែលត្រូវធ្វើដើម្បីរៀបចំការបោះឆ្នោតអោយបានសំរេច ។ សូមគូសបញ្ជាក់ថា ប្រទេសនីមួយៗតែងតែជួបនឹងស្ថានភាពផ្សេងៗគ្នា ហើយកិច្ចការខ្លះត្រូវបានចាត់ទុកថាសំខាន់សំរាប់ប្រទេសខ្លះ ប៉ុន្តែសំរាប់ប្រទេសខ្លះទៀត វាគ្រាន់តែជាការងារបន្ទាប់បន្សំតែប៉ុណ្ណោះ ។

ប្រភេទការងារនីមួយៗត្រូវបានរៀបចំតាមលំដាប់នៃការអនុវត្តន៍ ប៉ុន្តែក៏មិនមានន័យថា ការងារក្នុងលំដាប់មួយ ត្រូវតែបញ្ចប់ឱ្យហើយទើបចាប់ធ្វើការងារប្រភេទមួយទៀតនោះទេ ។ ប្រភេទការងារខ្លះ ត្រូវធ្វើត្រួតលើគ្នាមិនចាំមួយចប់ ហើយសឹមធ្វើមួយទៀតទេ ។ ជាឧទាហរណ៍ :

- ការរៀបចំការបោះឆ្នោតអាចចាប់ផ្តើមធ្វើមុនការចុះឈ្មោះត្រូវបានបញ្ចប់ ។ តាមពិត គេត្រូវតែរៀបចំស្ថានីយ៍នេះមុន ។
- ការតាក់តែង និងការកែប្រែគំរោងផែនការឱ្យបានទាន់ពេលវេលា គឺភារកិច្ចដែលត្រូវធ្វើជាប្រចាំ ហើយវាជាការងារបន្តរហូតដល់ពេលបោះឆ្នោតចប់សព្វគ្រប់ ។

ក្នុងករណីខ្លះ ប្រភេទការងារមួយជំពូកអាចត្រូវធ្វើមុនឬក្រោយពេលគ្នា នោះគឺអាស្រ័យលើសេចក្តីសំរេចផ្នែកនយោបាយ ។ ឧទាហរណ៍ការកំណត់ព្រំដែនមណ្ឌលបោះឆ្នោតអាចធ្វើបានអាស្រ័យនឹងស្ថិតិចំនួនប្រជាពលរដ្ឋ (ក្នុងករណីនេះ ត្រូវកំណត់ព្រំដែននេះមុនការចុះឈ្មោះ) ឬក៏ត្រូវធ្វើដោយពឹងផ្អែកលើស្ថិតិចំនួនអ្នកបោះឆ្នោតដែលបានចុះឈ្មោះនៅក្នុងតំបន់នានា (ក្នុងករណីនេះ គេនឹងអាចកំណត់ព្រំដែនបានទាល់តែការចុះឈ្មោះនេះបានចប់សព្វគ្រប់សិន) ។

### ភារកិច្ចទី១ ~ ការធ្វើគំរោងផែនការ

មានភារកិច្ចពិសេសៗ ធំៗ និងភារកិច្ចបន្ទាប់បន្សំដែលត្រូវបំពេញដល់ទៅរាប់រយ ។ វិធីល្អបំផុតដើម្បីតាមដាន ការងារទាំងនេះ នៅពេលចាប់ផ្តើមដំណើរការរៀបចំការបោះឆ្នោត គេត្រូវតាក់តែង និងរក្សាជារហូតនូវគម្រោង ផែនការមួយដែលបង្ហាញបញ្ជាក់ថា :

- តើភារកិច្ចអ្វីខ្លះត្រូវសំរេចឱ្យហើយ ?
- តើនរណាទទួលខុសត្រូវលើភារកិច្ចនីមួយៗ ?

---

[1] ប្រភព : ទស្សនៈទៅលើការរៀបចំការបោះឆ្នោត

តើគេត្រូវធ្វើអ្វីខ្លះ តើស្ថាប័ន និងក្រុមណាខ្លះត្រូវចូលរួម ដើម្បីរៀបចំការបោះឆ្នោតសេរី និង យុត្តិធម៌ ?

ដោយលោក ម៉ៃខុល ម៉េលី (Michael Maley)

- តើភារកិច្ចនោះត្រូវការពេលប៉ុន្មាន ? និង
- តើភារកិច្ចប្រភេទខុសៗគ្នាទាំងនោះមានទំនាក់ទំនងនឹងគ្នាអ្វីខ្លះ ? (ឧទាហរណ៍ ៖ តើភារកិច្ចណាត្រូវបញ្ចប់ជាមុនសិន ដើម្បីឱ្យភារកិច្ចណាទៀតអាចដំណើរការបាន ) ។

គំរោងផែនការដែលល្អ ត្រូវមានផែនការជួយនៅពេលមានអាសន្ន និងយុទ្ធវិធីស្តារ នៅពេលផែនការណាមួយត្រូវដួលរលំ ។ ត្រូវមានគំរោងផែនការជាឧទាហរណ៍ចាំបាច់សំរាប់រៀបចំការបោះឆ្នោត ។ ការតាក់តែងគំរោងផែនការនេះត្រូវចាត់ទុកជាអាទិភាពទីមួយ ។

**ភារកិច្ចទី២ ‑ ដំណោះស្រាយបញ្ហានយោបាយធំៗ**

មុនពេលចាប់ផ្តើមធ្វើផែនការជាដុំកំភួនគេត្រូវដោះស្រាយបញ្ហា ជាមូលដ្ឋានមួយចំនួនដែលទាក់ទងនឹងលក្ខណៈសំខាន់ៗទាំងឡាយនៃដំណើរការបោះឆ្នោត ។ បញ្ហាទាំងនេះរួមមាន ៖

- តើគេរៀបចំបោះឆ្នោតតាមមណ្ឌលនីមួយៗឬយ៉ាងណា? ប្រសិនបើរៀបចំតាមមណ្ឌល តើមណ្ឌលនីមួយៗជ្រើសយកតំណាងម្នាក់ឬច្រើននាក់ ?
- ប្រសិនបើបោះតាមមណ្ឌល តើព្រំដែននៃមណ្ឌលទាំងនោះអាចឆ្លងចូលខេត្តនានាបានទេ ?
- តើនរណាខ្លះមានសិទ្ធិបោះឆ្នោត ?
- តើមានការចុះឈ្មោះអ្នកបោះឆ្នោតឬទេ ? ប្រសិនបើមានចុះ តើយើងចេញកាតឱ្យគេឬទេ ឬតើបញ្ជីឈ្មោះអ្នកបោះឆ្នោតត្រូវប្រើនៅស្ថានីយបោះឆ្នោតដែរឬទេ ?
- តើបញ្ជីឈ្មោះអ្នកបោះឆ្នោតពេលបង្កើតហើយ ត្រូវទុកសំរាប់ប្រើពេលបោះឆ្នោតក្រោយៗទៀតដែរឬទេ? ឬក៏ពេលបោះឆ្នោតណាក៏ត្រូវតែចុះឈ្មោះសាជាថ្មី ?
- តើការចុះឈ្មោះ និងការបោះឆ្នោតធ្វើបានតែក្នុងប្រទេស ឬក៏គេនឹងបង្កើតបទបញ្ញត្តិដើម្បីអោយមានការចុះឈ្មោះ និងបោះឆ្នោតនៅក្រៅប្រទេស ?
- តើសន្លឹកឆ្នោតបែបណាដែលគេនឹងយកមកប្រើ ( ជាសន្លឹកឆ្នោតឬម៉ាស៊ីនបោះឆ្នោត ។ល។ ) ?
- តើគេត្រូវបោះឱ្យគណបក្ស ឬបោះអោយបេក្ខជនមួយរូបៗ ?
- តើអ្នកបោះឆ្នោតអាចបោះបានតែនៅស្ថានីយបោះឆ្នោតមួយតាមការកំណត់ឱ្យឬអាចទៅបោះនៅស្ថានីយ៍បោះឆ្នោតតាមតែការចូលចិត្ត ?
- តើមានរៀបចំកន្លែងបោះឆ្នោតពិសេសនៅមន្ទីរពេទ្យ ពន្ធនាគារ ឬនៅតាមផ្ទះជនពិការដែលមិនអាចទៅបោះឆ្នោតបានដែរឬទេ ?

- តើការបោះឆ្នោតធ្វើឡើងតែមួយថ្ងៃឬច្រើនថ្ងៃ ?
- តើគេជៀសវាងការចុះឈ្មោះច្រើនដង និងបោះច្រើនដងដោយវិធីណា?
- តើចាំបាច់មានសន្លឹកឆ្នោតអនុគ្រោះដែរឬទេ ?

បញ្ហាទាំងអស់នេះមានសារៈសំខាន់ណាស់ សំរាប់សម្រេចអំពីទិដ្ឋភាពឯទៀតនៃការរៀបចំបោះឆ្នោតជាក់ស្តែង ។ ហេតុដូច្នេះហើយបានជាគេមិនអាចផ្លាស់ប្តូរការសម្រេចទាំងឡាយ ដែលគេបានសម្រេចហើយ ដើម្បីកុំឱ្យប៉ះពាល់ដល់ពេលវេលានៃដំណើរការបោះឆ្នោត ។

## ភារកិច្ចទី៣ ~ ការបង្កើតរដ្ឋបាលរៀបចំការបោះឆ្នោត

សំខាន់បំផុត គេត្រូវចាត់តាំងច្បាស់លាស់ឱ្យហើយនូវអង្គការ ឬស្ថាប័ន ដែលទទួលខុសត្រូវរៀបចំនិងធ្វើការបោះឆ្នោត ។ គេអាចបង្កើតគណៈកម្មការឯករាជ្យរៀបចំបោះឆ្នោត ឬចាត់តាំងក្រសួងណាមួយឱ្យទទួលបន្ទុករៀបចំ ។ ទោះជាគេជ្រើសយកអង្គការណាមួយក៏ដោយអង្គការដែលទទួលខុសត្រូវនេះត្រូវបំពេញភារកិច្ចរបស់ខ្លួនដោយប្រកាន់ជំហរអព្យាក្រិត្យឱ្យបានហ្មត់ចត់ ហើយត្រូវឱ្យគេឃើញថាអព្យាក្រិត្យមែន ។ ដោយសារការរៀបចំបោះឆ្នោតជាប្រតិបត្តិការ ត្រូវពង្រាយតាមមូលដ្ឋានតាមស្ថានីយបោះឆ្នោតរាប់រយគេត្រូវមានរចនាសម្ព័ន្ធរដ្ឋបាលបោះឆ្នោតប្រចាំទីនោះ តាមលំដាប់ខេត្ត ឬក៏ស្រុក ។ ភារកិច្ចរបស់មន្ត្រីបោះឆ្នោត នៅថ្នាក់មជ្ឈិម ថ្នាក់ខេត្ត និងស្រុក ត្រូវតែកំណត់ឱ្យបានច្បាស់លាស់ ហើយត្រូវឱ្យបុគ្គលិកម្នាក់ៗយល់ឱ្យបានច្បាស់ពីការទទួលខុសត្រូវនិងភារកិច្ចរបស់ខ្លួននៅគ្រប់ជាន់ថ្នាក់ ។ គេត្រូវកំណត់ថវិកាសំរាប់ផ្នែកនីមួយៗ និង ចែងបទបញ្ជាអំពីការចំណាយថវិកាឱ្យបានច្បាស់លាស់ ។ គេត្រូវមាន បទបញ្ញត្តិចែងពីថវិកាបន្ទាន់សំរាប់ចំណាយដែលលើសពីការគ្រោងទុក ។

ប្រសិនមានគណៈកម្មការរៀបចំបោះឆ្នោតគណៈកម្មការនេះ ត្រូវកំណត់ឱ្យច្បាស់ថា បញ្ហាណាខ្លះ ដែលសមាជិកគណៈកម្មការមើលផ្ទាល់ហើយបញ្ហាណា ដែលទុកឱ្យលេខាធិការដ្ឋានដោះស្រាយ ។

បើមានអង្គការថ្មីរៀបចំការបោះឆ្នោត អង្គការត្រូវរៀបចំបទបញ្ញត្តិរដ្ឋបាលរបស់ខ្លួនជាក្បួនខ្នាតរួមបញ្ចូលទាំងបទបញ្ញត្តិអំពីបុគ្គលិក និងហិរញ្ញវត្ថុទៀតផង ។ គេត្រូវតាក់តែងបទបញ្ញត្តិយ៉ាងណាដើម្បីឱ្យមាន ការងាយស្រួលក្នុងការប្រើប្រាស់បុគ្គលិករៀបចំការបោះឆ្នោតរាប់ពាន់នាក់ ដែលចាំបាច់ឱ្យបានប្រសិទ្ធភាពនៅពេលបោះឆ្នោតម្តងៗ ។

## ភារកិច្ចទី៤ ៖ ការតាក់តែងច្បាប់បោះឆ្នោត

ភារកិច្ចនេះវាហាក់ដូចជាគ្មានអ្វីលំបាកទេ តែវាក៏មានសារៈសំខាន់ដែរ ។ ការបញ្ចូលសេចក្តីសំរេចអំពីបញ្ហានយោបាយធំៗនានាក្នុងទម្រង់ច្បាប់មួយ មានន័យច្បាស់លាស់នឹងធ្វើឱ្យគេគោរពធ្វើតាមផ្តល់នូវ គំនិតនៃភាពទៀងទាត់ដែលគេត្រូវការដើម្បីបំពេញការងារនៅដំណាក់កាលក្រោយៗ ទៀតនៃដំណើរការ បោះឆ្នោត ។

ច្បាប់បោះឆ្នោតមិនមែនមានតែមាត្រាកំណត់ភារកិច្ចនោះទេ ប៉ុន្តែត្រូវមានចែងអំពីទោសបញ្ញត្តិសំរាប់ទប់ទល់នឹងបទល្មើស ដូចជាការចុះឈ្មោះបន្លំ ការបន្លំសន្លឹកឆ្នោត ការបន្លំធ្វើជាអ្នកបោះឆ្នោត អំពើពុករលួយ និងការទិញសន្លឹកឆ្នោត ការគំរាមកំហែងមកលើបេក្ខជន និងអ្នកបោះឆ្នោត ។ល។ ច្បាប់ត្រូវប្រគល់អំណាច និងមធ្យោបាយជូនរដ្ឋបាលរៀបចំបោះឆ្នោតដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងកាលៈទេសៈដែលមិននឹកស្មានដល់ ដូចជាមានយន្តការមួយពិសេសអនុញ្ញាតអោយបន្តការបោះឆ្នោតដើម្បីដោះស្រាយបញ្ហាភស្តុភារ ។

## ភារកិច្ចទី៥៖ការកំណត់ព្រំដែនរបស់មណ្ឌល ការធ្វើផែនទី និងការបែងចែកកៅអីសំរាប់មណ្ឌល

ប្រសិនបើគេប្រើប្រព័ន្ធបោះឆ្នោតតាមមណ្ឌលការកំណត់ព្រំដែននៃមណ្ឌលទាំងនោះ គឺភារកិច្ចធំមួយ ។ ដើម្បីរៀបចំបង្កើតមណ្ឌលទាំងឡាយឱ្យមានចំនួនប្រជាពលរដ្ឋប្រហាក់ប្រហែលគ្នាតាមការចាំបាច់នោះ គេត្រូវមានពត៌មានឱ្យបានលំអិតអំពីភូមិសាស្ត្រនៃលំនៅស្ថានរបស់ប្រជាពលរដ្ឋ ។

ប្រសិនបើគេកំណត់ព្រំដែនមុនពេលចុះឈ្មោះ គេអាចប្រាប់ទៅអ្នកបោះឆ្នោតនៅពេលចុះឈ្មោះក្នុងមណ្ឌលមួយដែលអ្នកចុះឈ្មោះនឹងទៅបោះឆ្នោត ។ ប្រសិនបើកំណត់ព្រំដែនក្រោយវិញ គេត្រូវមានយន្តការមួយ ដើម្បីប្រាប់ទីកន្លែងដល់អ្នកបោះឆ្នោតឱ្យបានដឹងគ្រប់គ្នា ។

ប្រព័ន្ធបោះឆ្នោតតាមមណ្ឌលទាមទារឱ្យមានការងារធ្វើផែនទីច្រើន ។ មន្ត្រីរៀបចំបោះឆ្នោតត្រូវតែកំណត់តំបន់ដែលគេអោយអ្នកបោះឆ្នោតទៅចុះឈ្មោះ ហើយនិងបង្កើតស្ថានីយ៍បោះឆ្នោត ។

ប្រសិនបើគេយកខេត្តធ្វើជាមណ្ឌលដែលជ្រើសយកតំណាងច្រើននាក់ (ដូចមានចែងក្នុងកិច្ចព្រមព្រៀងក្រុងប៉ារីស) គេត្រូវមានវិធីកំណត់ចំនួនអ្នកតំណាងសំរាប់ខេត្តនីមួយៗនោះ ។ រូបមន្តសំរាប់វិធីនេះ ត្រូវបានចែងក្នុងច្បាប់អ៊ុនតាក់ ១៩៩២ ដោយយកចំនួនអ្នកចុះឈ្មោះក្នុងខេត្តជាមូលដ្ឋាន។

## ភារកិច្ចទី៦ ៖ ការតាក់តែងប្រព័ន្ធកុំព្យូទ័រ

ប្រព័ន្ធកុំព្យូទ័រមិនចាំបាច់សំរាប់ការបោះឆ្នោតនេះទេ ក៏ប៉ុន្តែប្រព័ន្ធនេះអស់ថ្លៃច្រើនណាស់ហើយ ក៏នៅមានភារកិច្ចជាច្រើនដែលត្រូវធ្វើដោយដៃបាន ។ ប៉ុន្តែផ្នែកនៃកិច្ចការរដ្ឋបាលខ្លះត្រូវការបច្ចេកទេសកុំព្យូទ័រណាស់ ដូចជា :

- រក្សាឯកសាររបស់អ្នកចុះឈ្មោះ និងការបោះពុម្ពបញ្ជីឈ្មោះអ្នកបោះឆ្នោត។
- ធ្វើផែនការភស្តុភាររៀបចំបង្កើតស្ថានីយបោះឆ្នោតការចែកចាយឧបករណ៍និងសំភារៈសំរាប់បោះឆ្នោត។
- រក្សាឯកសាររបស់បុគ្គលិក រៀបចំបោះឆ្នោត និងកិច្ចការរដ្ឋបាលផ្នែកប្រាក់ខែរបស់ពួកគេ។
- ការចាត់ចែងហិរញ្ញវត្ថុទូទៅ ។
- ការត្រួតពិនិត្យសំភារៈ ។
- ការគូរផែនទីបោះឆ្នោត ។
- ប្រមូលលទ្ធផលឆ្នោត និងការបង្កើតស្ថិតិបោះឆ្នោតផ្លូវការ ។
- ការងារការិយាល័យទូទៅ ។

បើគេប្រើប្រាស់កុំព្យូទ័រ គេត្រូវការពេលវេលាយូរដើម្បីទិញឧបករណ៍ទាំងនោះគាត់តែងប្រព័ន្ធ និងសាកល្បង ហើយនិងហ្វឹកហ្វឺនបុគ្គលិកឱ្យចេះប្រើប្រាស់ ។ ហេតុនេះហើយបានជាគេត្រូវធ្វើសេចក្តីសំរេចថា ត្រូវប្រើប្រាស់កុំព្យូទ័រ ហើយប្រើកុំព្យូទ័រប្រភេទណាឱ្យបានឆាប់រហ័សពីដំបូងនៃដំណើរការរៀបចំការបោះឆ្នោត។

## ភារកិច្ចទី៧ ៈ ការអប់រំអ្នកបោះឆ្នោត

អ្នកបោះឆ្នោត ត្រូវការពត៌មានគ្រប់គ្រាន់ដើម្បីទៅចុះឈ្មោះបោះឆ្នោត និងទៅបោះឆ្នោតឱ្យបានត្រឹមត្រូវតាមច្បាប់ទំលាប់ហើយយល់ដឹងពីអ្វី ដែលខ្លួនធ្វើអោយច្បាស់លាស់ ។ ធនធានដែលត្រូវចំណាយលើការអប់រំបោះឆ្នោត អាស្រ័យនឹងទំហំនៃចំណេះដឹងដែលអ្នកបោះឆ្នោតមានស្រាប់ហើយអំពីដំណើរការបោះឆ្នោត ។ ការអនុវត្តន៍នូវនីតិវិធីបោះឆ្នោតដែលអ្នកបោះឆ្នោតធ្លាប់យល់ដឹងនឹងកាត់បន្ថយនូវការអប់រំចាំបាច់នោះបាន ។ គេត្រូវយកចិត្តទុកដាក់ជាពិសេសដល់ការអប់រំរបៀបបោះឆ្នោតដល់ស្ត្រី យុវជន និងអ្នកទាំងឡាយណាដែលទើបមកបោះឆ្នោតលើកទីមួយ ។

## ភារកិច្ចទី៨ៈ ការចុះឈ្មោះគណបក្សនយោបាយ និងបេក្ខជនតំណាក់តំណែង និងការហ្វឹកហ្វឺនភ្នាក់ងារបេក្ខជន និងមន្ត្រីគណបក្ស

ប្រសិនបើគេជ្រើសរើសយកការបោះឆ្នោត អោយគណបក្សពេលនោះគេត្រូវមានគំរោងចុះឈ្មោះគណបក្ស។ តាមធម្មតារដ្ឋបាលរៀបចំការបោះឆ្នោតជាអ្នកត្រូវបំពេញភារកិច្ចនេះ ។ លទ្ធផលនៃការចុះឈ្មោះគណបក្សធម្មតា មានដូចតទៅនេះ :

- បញ្ជីរាយពីឈ្មោះគណបក្សដែលមានសិទ្ធិចូលរួមក្នុងការបោះឆ្នោតហើយដែលមានឈ្មោះ និងរូបសញ្ញាសំគាល់កំណត់ឡើងច្បាស់លាស់មិនច្រលំ និង

- បញ្ជីបេក្ខជនដែលគណបក្សពេញសិទ្ធិស្នើឡើង។

កំរិតនៃការទទួលភាពត្រឹមត្រូវនៃដំណើរការបោះឆ្នោតពីសំណាក់គណបក្សទាំងឡាយវាអាស្រ័យនឹងការយល់ដឹងរបស់គេទាំងនោះអំពីដំណើរការនេះ ហើយនិងលទ្ធភាពឱ្យដល់គណបក្សទាំងនោះ ដើម្បីពិនិត្យមើលភាពត្រឹមត្រូវនៃវិធីដែលគេអនុវត្ត ។ ហេតុនេះគេត្រូវយកចិត្តទុកដាក់ផ្តល់អោយភ្នាក់ងារគណបក្សនូវលទ្ធភាពអង្កេតតាមដានសកម្មភាពរៀបចំបោះឆ្នោតរបស់រដ្ឋបាលរៀបចំការបោះឆ្នោត ។ វិធីផ្សេងៗដើម្បី សំរេចគោលដៅនេះរួមមាន :

- កិច្ចប្រជុំឱ្យបានញឹកញាប់រវាងរដ្ឋបាលរៀបចំការបោះឆ្នោត ជាមួយនិង គណបក្សនយោបាយដើម្បីឱ្យមានទំនាក់ទំនងល្អ ។
- ការហ្វឹកហ្វឺន និងការផ្តល់ពត៌មាន អំពីនីតិវិធីបោះឆ្នោតជូនភ្នាក់ងារគណបក្សបេក្ខជននិងមន្ត្រីឯទៀតៗរបស់គណបក្ស ។

យន្តការទាំងនេះមិនគ្រាន់តែជំរុញឱ្យគណបក្សប្រើសិទ្ធិរបស់ខ្លួនអោយបានពេញលេញត្រឹមត្រូវនោះទេ ថែមទាំងជួយទប់ស្កាត់ទំនាស់កុំអោយកើតឡើងដោយសារតែការយល់ច្រលំរវាងគណបក្ស និងរដ្ឋបាល រៀបចំការបោះឆ្នោតទៀតផង ។

## ភារកិច្ចទី៩ ‸ ការជ្រើសរើសនិងហ្វឹកហ្វឺនបុគ្គលិកបោះឆ្នោត

ចំណុចនេះដូចជាមិនចាំបាច់ពន្យល់ច្រើនទេ ។ ការបោះឆ្នោតយូរៗធ្វើម្តង ។ អ្នកចុះឈ្មោះបុគ្គលិកប្រចាំការស្ថានីយ៍បោះឆ្នោត និងបុគ្គលិករាប់សន្លឹកឆ្នោតអាចបំរើការមានប្រសិទ្ធភាពបាន លុះត្រាតែពួកគេបានទទួលការហ្វឹកហ្វឺនត្រឹមត្រូវ ។ ការងារពិសេសនេះមិនស្រួលប៉ុន្មានទេ ត្រូវមានប្រាក់ច្រើននិងមានអ្នកជំនាញក៏ច្រើន ពីព្រោះគេត្រូវជ្រើសរើសនិងហ្វឹកហ្វឺនចំនួនមនុស្សដ៏ច្រើនសន្ធឹកសន្ធាប់ ។ ការបោះឆ្នោតរបស់អ៊ុនតាក់ ឆ្នាំ ១៩៩៣ មានមន្ត្រីចុះឈ្មោះ ៤.០០០នាក់ និងមន្ត្រីបោះឆ្នោត ៤៨.០០០នាក់ត្រូវបានហ្វឹកហ្វឺន ។

## ភារកិច្ចទី១០ ‸ ការចុះឈ្មោះអ្នកបោះឆ្នោត

ដំណាក់កាលនេះមិនជាចាំបាច់គ្រប់ពេលនោះទេ ‸ នៅពេលបោះឆ្នោតខ្លះ ពុំចាំបាច់មានការចុះឈ្មោះដោយឡែកទេ ។ អ្នកបោះឆ្នោតគ្រាន់តែយកឯកសារមួយចំនួនទៅកាន់ស្ថានីយបោះឆ្នោតដើម្បីបង្ហាញថាខ្លួនមានសិទ្ធិបោះឆ្នោតតែប៉ុណ្ណឹង ។ វិធីនេះត្រូវបានគេអនុម័តយកដោយពេលវេលាខ្លីដូចជាការបោះឆ្នោត នៅរ៉ូដេស៊ីយ៉ា Rhodesia ឆ្នាំ១៩៨០ និងនៅអាហ្វ្រិកខាងត្បូង ឆ្នាំ១៩៩៤ ។

ក៏ប៉ុន្តែដំណើរការចុះឈ្មោះបោះឆ្នោត មានអត្ថប្រយោជន៍ពីរសំខាន់ ។ អត្ថប្រយោជន៍ទីមួយសំខាន់បំផុតគឺវាអាចដោះស្រាយបញ្ហាសិទ្ធិបោះឆ្នោតរបស់បុគ្គលបានមុនពេលការបោះឆ្នោត មិនទុកឱ្យមានការទាស់ទែងគ្នាវិខាន

នៅស្ថានីយ៍បោះឆ្នោតទេ ។ នេះរារិតតែសំខាន់ទៅទៀតចំពោះប្រទេសមួយចំនួនដូចជាកម្ពុជា ដែលមានបញ្ហាអ្នកគ្មានសិទ្ធិបោះឆ្នោតចូលមកបោះឆ្នោតនៅក្នុងអតីតកាល ។

សារៈប្រយោជន៍ទីពីរ គឺការចុះឈ្មោះផ្តល់នូវពត៌មានលំអិតអំពីទីកន្លែងរស់នៅនឹងការផ្តុំរបស់អ្នកបោះឆ្នោតកន្លែងណាមានមនុស្សច្រើន កន្លែងមានមនុស្សតិច ដែលជាការងាយស្រួលដើម្បីធ្វើគំរោងផែនការបោះឆ្នោត ជាពិសេសគឺដើម្បីបែងចែក និងចែកចាយធនធាន ។ ការខ្វះពត៌មានទាំងនេះ អាចបង្កការលំបាកដូចជាការបោះឆ្នោតនៅអាហ្វ្រិកខាងត្បូងឆ្នាំ ១៩៩៤ ។

តំរូវការចាំបាច់មួយនៃដំណើរការចុះឈ្មោះ គឺអ្នកដែលមានសិទ្ធិចុះឈ្មោះត្រូវមានលទ្ធភាពសមរម្យដើម្បីទៅចុះឈ្មោះបោះឆ្នោត ។ ក្នុងន័យនេះ ការចុះឈ្មោះបោះឆ្នោតក្លាយជាការងារចាត់ចែងភស្តុភារមួយយ៉ាងសំខាន់ទាមទារឱ្យមានផែនការពិស្តារនិងសព្វមុខ ។ បញ្ហាដែលគេត្រូវដោះស្រាយមាន :

- ការទិញសំភារៈ
- ការបោះទីតាំងចុះឈ្មោះ
- ការជ្រើសរើស និងហ្វឹកហ្វឺនបុគ្គលិក
- ការចែកចាយសំភារៈ
- មធ្យោបាយធ្វើដំណើរសំរាប់ក្រុមចុះឈ្មោះចល័ត
- ទំនាក់ទំនងគមនាគមន៍
- សន្តិសុខ រួមទាំងមានការដឹកជញ្ជូនឯកសារចុះឈ្មោះ ដែលប្រើហើយ និងមិនបានប្រើ
- ដំណោះស្រាយជម្លោះ រួមទាំងយន្តការឧទ្ធរណ៍សំរាប់ការតវ៉ា និងការចុះឈ្មោះមិនបាន ហើយនិងយន្តការសំរាប់អ្នកតវ៉ាប្រឆាំងនឹងសិទ្ធិចុះឈ្មោះរបស់អ្នកដទៃ។

## ភារកិច្ចទី១១ ៖ ការរៀបចំឱ្យប្រជាពលរដ្ឋបោះឆ្នោតបាន

គេត្រូវរៀបចំមុនឱ្យបានវែងឆ្ងាយ និងដោយលំអិតទុកមុនអោយយូរ ដើម្បីអោយប្រជាពលរដ្ឋបោះឆ្នោតរបស់គេបាន ។ បញ្ហាទាំងឡាយដែលគេត្រូវដោះស្រាយជាគោល១ មានដូចគ្នានឹងបញ្ហាទាំងឡាយទាក់ទងនឹងការចុះឈ្មោះអ្នកបោះឆ្នោតដូចចែងខាងលើដែរ ។ គេត្រូវចាប់អារម្មណ៍ជាពិសេសទៅលើសម្ភារៈអ្វីខ្លះ ដែលគេត្រូវការឃ្លាំងផ្ទុកសំភារៈ ការដឹកជញ្ជូន និងការចែកចាយ ។ គេត្រូវរៀបចំបណ្តាញទំនាក់ទំនងទូរគមនាគមន៍ពីស្ថានីយ៍បោះឆ្នោតរហូតដល់ទៅរដ្ឋបាលកណ្តាលរៀបចំការបោះឆ្នោត បើគេចង់ដោះស្រាយវិវាទទាំងឡាយដែលកើតឡើងនៅពេលបោះឆ្នោតនោះអោយបានឆាប់រហ័សទាន់ចិត្តភ្លាម១ ។ គេត្រូវរៀបចំប្រព័ន្ធទូរគមនាគមន៍នេះឱ្យបានលំអិតមែនទែន ។

## ភារកិច្ចទី១២ ~ ការចាត់ចែងយុទ្ធនាការឃោសនាបោះឆ្នោត

រយៈពេលយុទ្ធនាការឃោសនាបោះឆ្នោត ជារយៈពេលប្រកបដោយសកម្មភាពនយោបាយខ្លាំងក្លា ហើយច្រើនតែនាំមកនូវគ្រោះថ្នាក់ ទំនាស់វិវាទ ដោយអ្នកនយោបាយពេលនោះឆ្លៀតប្រើប្រាស់យ៉ាងពេញទំហឹងនូវសិទ្ធិនយោបាយនិងសិទ្ធិដែលរដ្ឋធម្មនុញ្ញផ្ដល់អោយ។ ផលវិបាកចំពោះមុខរបស់រដ្ឋបាលរៀបចំការបោះឆ្នោត គឺសំរបសំរួលសកម្មភាពរបស់គណបក្សទាំងឡាយដើម្បីចៀសវាងទំនាស់ក្នុងពេលដែលរដ្ឋបាលនេះផ្ដល់លទ្ធភាពទាំងអស់ផ្សព្វផ្សាយគំនិតរបស់ខ្លួនដល់អ្នកបោះឆ្នោត ។

មាគ៌ាវិសេសវិសាលដើម្បីអោយបានដល់គោលដៅនេះគឺមានតែគណបក្សទាំងអស់ខំទប់ខ្លួនឯងកុំអោយមានការជ្រុលជ្រួស ។ វិធីមួយដែលប្រទេសខ្លះបានប្រើប្រាស់គឺការអនុវត្តនូវក្រមសីលធម៌មួយ ដែលហាមឃាត់មិនអោយធ្វើសកម្មភាពឃោសនាដោយប្រើការញុះញង់ ឬប្រកបដោយគ្រោះថ្នាក់ ។

ជាទូទៅ ក្រមសីលធម៌ផ្ដល់តួនាទីពិសេសមួយដល់រដ្ឋបាលរៀបចំបោះឆ្នោតក្នុងការជួយសំរបសំរួលសកម្មភាពរបស់គណបក្ស ដើម្បីចៀសវាងទំនាស់វិវាទ ។ ប៉ុន្តែតួនាទីបែបនេះអាចត្រូវបានគាំទ្រដោយបទបញ្ញត្តិច្បាប់មួយចំនួនដើម្បីឱ្យរដ្ឋបាលរៀបចំការបោះឆ្នោតមានអំណាចដោះស្រាយទំនាស់វិវាទរវាងគណបក្ស ។ ការពិតចំណុចសំខាន់គឺនៅត្រង់ដែលរដ្ឋបាលរៀបចំការបោះឆ្នោតប្រើប្រាស់អំណាចនេះក្នុងភាព ឯករាជ្យហើយឥតលំអៀង។

## ភារកិច្ចទី១៣ ~ ការរៀបចំសន្តិសុខ

ការរៀបចំសន្តិសុខ ជាផ្នែកចំបងមួយក្នុងការរៀបចំ និងធ្វើការបោះឆ្នោត ។ ហើយទោះជារដ្ឋបាលរៀបចំការបោះឆ្នោតមិនមែនជាអង្គការដែលត្រូវការពារភាគីណាទាំងអស់ក្នុងដំណើរការបោះឆ្នោត ក៏រដ្ឋបាលត្រូវមានទំនាក់ទំនងដ៏ជិតស្និទ្ធបំផុតជាមួយផ្នែកសន្តិសុខ ។ ប្រភេទបញ្ហាសន្តិសុខដែលគេត្រូវដោះស្រាយមានដូចតទៅនេះ :

- តើអ្នកណាត្រូវការពារកន្លែងចុះឈ្មោះបោះឆ្នោត និងស្ថានីយបោះឆ្នោត?
- តើត្រូវធានាសុវត្ថិភាពដល់ការទុកដាក់សំភារៈ ការចែកចាយ និងការដឹកជញ្ជូនយ៉ាងដូចម្ដេច ?
- ប្រសិនបើការបោះឆ្នោតត្រូវធ្វើច្រើនថ្ងៃ តើត្រូវការពារសំភារៈនិងឯកសារទាំងអស់យ៉ាងដូចម្ដេច?
- តើសន្តិសុខក្នុងពេលមានអាសន្ន ដូចជាការបះបោរ ការវាយប្រហារទៅលើអ្នកបោះឆ្នោតនៅស្ថានីយបោះឆ្នោតជាដើម ត្រូវដោះស្រាយយ៉ាងដូចម្ដេច ?

## ភារកិច្ចទី១៤ ៖ ការបោះឆ្នោតជាក់ស្តែង

ការបោះឆ្នោតជាក់ស្តែងជាដំណាក់កាលមួយពិបាកជាងគេ ព្រោះវាចេះតែប្រព្រឹត្តទៅក្នុងរយៈពេលខ្លី ហើយពុំមានលទ្ធភាពគ្រប់គ្រាន់សំរាប់ដោះស្រាយបញ្ហាដែលអាចកើតឡើង ។ ផ្ទុយនិងដំណាក់កាលចុះឈ្មោះដែលគេធ្វើក្នុងរយៈពេលរាប់អាទិត្យឬរាប់ខែ ។

ក្នុងពេលចងក្រងនីតិវិធីបោះឆ្នោត គឺគោលដៅដ៏សំខាន់ធ្វើឱ្យអ្នកបោះឆ្នោតអាចទៅបោះឆ្នោតក្នុងស្ថានភាពមួយដោយគ្មានការគំរាមកំហែង និងក្នុងលក្ខខណ្ឌដែលគេអាចចូលទៅបោះបានដោយសេរី គ្មានការលំបាក ហើយធានាភាពសំងាត់ដល់សន្លឹកឆ្នោតដែលគេបោះ ។

បើមានគំរោងត្រឹមត្រូវជាមុន ការបោះឆ្នោតនេះនឹងមានដំណើរការបានដោយគ្មានរអាក់រអួល ។ តែបើគ្មានគំរោងល្អវិញនោះ មហន្តរាយនឹងកើតឡើងជាមិនខាន ។

## ភារកិច្ចទី ១៥ ៖ ការកំណត់លទ្ធផលនៃការបោះឆ្នោត

គោលដៅនៃដំណាក់កាលរាប់សន្លឹកឆ្នោតគឺត្រូវកំណត់លទ្ធផលនៃការបោះឆ្នោតឱ្យបានត្រឹមត្រូវ ដោយចំហ និងអោយបានឆាប់រហ័សដែលអាចធ្វើទៅបាន ។

តាមការសង្កេតជាទូទៅ ការរាប់សំលេងឆ្នោតនៅស្ថានីយបោះឆ្នោតតែម្តងមានលក្ខណៈប្រសើរជាង ។ ការធ្វើរបៀបនេះផ្តល់អត្ថប្រយោជន៍ដូចតទៅ :

- ភ្នាក់ងារគណបក្សអាចអង្កេតតាមដានភ្លាមនៅពេលនោះ
- បញ្ហាដែលកើតចេញពីការដឹកជញ្ជូនហិបឆ្នោតពីកន្លែងបោះទៅកន្លែងរាប់ពិតជាគ្មានទេ
- ការរាប់នេះអាចបំបែកជាផ្នែកតូចៗ ។ ការរាប់សន្លឹកឆ្នោត១០០,០០០

សន្លឹកនៅតាមស្ថានីយបោះឆ្នោត ១០០កន្លែងវាប្រសើរជាងរាប់តែនៅតែមួយកន្លែង ។ ពេលខ្លះស្ថានីយបោះឆ្នោតស្ថិតនៅតំបន់ដែលមិនសូវមានសន្តិសុខ ដូច្នេះគួរតែដឹកជញ្ជូនសន្លឹកឆ្នោតយកទៅរាប់នៅមជ្ឈមណ្ឌលរាប់សន្លឹកឆ្នោតដែលមានការការពារគ្រប់គ្រាន់ ។

## ភារកិច្ចទី ១៦ ៖ ការដោះស្រាយទំនាស់វិវាទ

ត្រូវមានយន្តការមួយ ដើម្បីផ្តល់លទ្ធភាពឱ្យអ្នកដែលមានការតវ៉ាទាក់ទងនឹងដំណើរការបោះឆ្នោតណាមួយទៅតវ៉ាឱ្យគេដោះស្រាយ ។ យន្តការគំរូមួយចំនួនមានហើយ ។

នៅប្រទេសខ្លះ គេចែងច្បាប់ប្រគល់យុត្តាធិការជូនតុលាការជំនុំជម្រះរឿងទំនាស់វិវាទដែលទាក់ទងនឹងការបោះឆ្នោត ។ ការជំនុំជម្រះបែបនេះជាការដោះស្រាយទំនាស់វិវាទក្រៅពីអាជ្ញាធររៀបចំការបោះឆ្នោត ហើយសេចក្តីសំរេចរបស់តុលាការអាចធ្វើឱ្យទុកចិត្តគោរពតាមយ៉ាងប្រសើរដោយសារវាចេញមកពីស្ថាប័នក្រៅពីអាជ្ញាធររៀបចំការបោះឆ្នោត ។

ប្រទេសខ្លះទៀតដូចជាប្រទេសអេស្ប៉ាញ សមាជិកនៃសាលាជំរះក្តីមួយផ្នែកស្ថិតក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលរៀបចំការបោះឆ្នោត ហើយមាននាទីដោះស្រាយពាក្យបណ្តឹង ។ ទោះជាជ្រើសយកគំរូណាមួយក៏ដោយការសំខាន់គឺច្បាប់បោះឆ្នោតត្រូវចែងអោយបានច្បាស់ពីប្រភេទនៃភស្តុតាងដែលត្រូវយកមកសំអាង ឬទាត់ចោលពាក្យបណ្តឹងទាក់ទងនឹងការបោះឆ្នោត ហើយនរណាទទួលបន្ទុកសំរេចថា ដំណើរប្រព្រឹត្តទៅនៃការបោះឆ្នោតត្រឹមត្រូវ ឬមិនត្រឹមត្រូវ។

# សេចក្ដីព្រាងខ្លឹមសារមេរៀនសម្រាប់អ្នកបោះឆ្នោត

ដោយបណ្ឌិត ឡៅ ម៉ុងហៃ

## សេចក្ដីផ្ដើម

ការបោះឆ្នោតដើម្បីសម្រេចពីបញ្ហា ឬដើម្បីជ្រើសតាំងមេដឹកនាំ ឬតំណាង ហាក់ដូចជាមិនមែនជាវិធីថ្មីស្រឡាងនៅក្នុងប្រវត្តិសាស្ត្រខ្មែរទេ ។

ក្រោយពីសង្គ្រាមលោកលើកទី២មក នៅប្រទេសខ្មែរមានការរៀបចំការបោះឆ្នោត និងប្រជាមតិមានចំនួនទាំងអស់ប្រមាណ១៨ដង ។ ហើយចំនួនប្រជាពលរដ្ឋដែលមានឈ្មោះបោះឆ្នោត ហើយដែលបានចូលរួមបោះឆ្នោតផ្ទាល់កាន់តែមានចំនួនច្រើន ប្រសិនបើមានការប្រណាំងប្រជែងគ្នារវាងគណបក្ស ឬបេក្ខជន ។

ខ្មែរចេះប្រើសិទ្ធិបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោតដែលខ្លួនឯងរៀបចំ ទាំងការបោះឆ្នោតដែលគេរៀបចំឱ្យខ្មែរ ។ ការបោះឆ្នោត និងសិទ្ធិបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោតនៅប្រទេសខ្មែរ មានចែងយ៉ាងច្បាស់លាស់នៅក្នុងកិច្ចព្រមព្រៀង ស្ដីពីដំណោះស្រាយនយោបាយរួមមួយនៅកម្ពុជា នៅទីក្រុងប៉ារីស នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ហើយនិងនៅក្នុងសេចក្ដីថ្លែងការណ៍ជាសកល អនុសញ្ញា និងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិមនុស្សដែលខ្មែរយើងបានចុះហត្ថលេខា។

## គោលការណ៍ច្បាប់

តាមគំរូច្បាប់អន្តរជាតិស្ដីពីការបោះឆ្នោតតម្រូវឱ្យមានសិទ្ធិជាមូលដ្ឋានបី គឺ :

១_ សិទ្ធិចូលរួមក្នុងកិច្ចការរដ្ឋាភិបាល

២_ សិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត

៣_ សិទ្ធិស្មើភាពគ្នាក្នុងកិច្ចការសាធារណៈ

សេចក្ដីថ្លែងការណ៍ជាសកលស្ដីពីសិទ្ធិមនុស្សបញ្ជាក់យ៉ាងច្បាស់ថា ឆន្ទៈរបស់ប្រជាពលរដ្ឋ គឺជាមូលដ្ឋាននៃអំណាចរបស់រដ្ឋាភិបាល ហើយឆន្ទៈនេះនឹងត្រូវបានបង្ហាញយ៉ាងច្បាស់នៅពេលបោះឆ្នោត និងការបោះឆ្នោតដោយឥតក្លែងបន្លំ ដែលនឹងត្រូវធ្វើឡើងការបោះឆ្នោតដោយសេរី ត្រឹមត្រូវ សកល សន្លឹកឆ្នោតសំងាត់ និងសមភាព ។

ការបោះឆ្នោត និងសិទ្ធិបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត នៅប្រទេសខ្មែរមានចែងយ៉ាងច្បាស់លាស់នៅក្នុងកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៅកម្ពុជា នៅទីក្រុងប៉ារីស នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ហើយនិងនៅក្នុងសេចក្តីថ្លែងការណ៍ជាសកលអនុសញ្ញា និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស ដែលខ្មែរយើងបានចុះហត្ថលេខា ។

## លក្ខណៈសំខាន់នៃលទ្ធិប្រជាធិបតេយ្យ

### តើអ្នកណាមានសិទ្ធិបោះឆ្នោត?

- ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច១៨ឆ្នាំ ឡើងទៅគិតដល់ថ្ងៃបោះឆ្នោត
- មានទីលំនៅយ៉ាងតិចប្រាំមួយខែ (៦ខែ) ក្នុងខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជា
- មិនត្រូវស្ថិតនៅក្នុងស្ថានភាពជាទណ្ឌិត
- ត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោត
- ប្រជាពលរដ្ឋត្រូវតែមានអត្តសញ្ញាណប័ណ្ណប្រជាជន និងប័ណ្ណបោះឆ្នោត
- មិនត្រូវបានគេដកសិទ្ធិបោះឆ្នោត ដោយតុលាការ ឬផ្អាកសិទ្ធិបោះឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬដោយក្រុមប្រឹក្សាធម្មនុញ្ញ
- ពុំមែនជាជនវិកលចរិត

### តើហេតុអ្វីចាំបាច់ឱ្យមានការបោះឆ្នោត?

- ការប្រើប្រាស់សិទ្ធិជាពលរដ្ឋខ្មែរ " តើប្រើប្រាស់វា ឬត្រូវឱ្យវាបាត់បង់? "
- ជ្រើសរើសបេក្ខជន ឬគណបក្សមួយសម្រាប់ឱ្យកាន់ការ ឬមុខតំណែងផ្សេងៗ ដោយឆន្ទៈរបស់ប្រជាពលរដ្ឋ និងធ្វើតាមបំណងប្រាថ្នារបស់ពលរដ្ឋដែលជាម្ចាស់ឆ្នោត
- ដើម្បីអំណាច និងអ្នកកាន់អំណាច
- ជាលទ្ធភាពនៃការជ្រើសរើសនូវអ្វីដែលប្រជាពលរដ្ឋ ឬអ្នកបោះឆ្នោតចង់បាន
  " បើមិនហ៊ានធ្វើ គឺគ្មានបានការអ្វីទាំងអស់ " :
  - ដើម្បីខ្លួនឯងផ្ទាល់ ក្នុងពេលបច្ចុប្បន្ន និងអនាគត
  - ដើម្បីជាតិក្នុងពេលបច្ចុប្បន្ន និងអនាគត
  - ដើម្បីកូនចៅរបស់យើងទាំងអស់គ្នា
- អ្នកប្រាកដជាអាចប្រើប្រាស់សិទ្ធិរបស់អ្នក ពីព្រោះអ្នកធ្លាប់ប្រើប្រាស់វារួចមកហើយ

- ដោយមានការគោរព និងសោមនស្សយ៉ាងក្រៃលែងពីសហគមន៍អន្តរជាតិ
- ការបោះឆ្នោតគឺជាការធម្មតាហើយដែលធ្លាប់ទទួលបាននូវលទ្ធផលដ៏ល្អប្រសើរបំផុត

● សូមកុំអស់សង្ឃឹម បើសិនជាអ្នកបោះឆ្នោតឱ្យតំណាងរាស្ត្រណាដែលមិនបានធ្វើតាមដូចសេចក្តីប្រាថ្នារបស់អ្នក តែត្រូវចងចាំបុរាណសុភាសិតខ្មែរមួយឃ្លា ដែលនិយាយពីការដាំពុះស្រូវថា " បើខុសមួយឆ្នាំ ក៏នៅមួយឆ្នាំទៀតដែរ "

● ការបោះឆ្នោតគឺជាមធ្យោបាយដែលត្រូវតែធានាឱ្យមានបរិយាកាសសេរី និងទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ
  - ត្រួតពិនិត្យលើអ្នកដឹកនាំ
  - ការពារសិទ្ធិសេរីភាព

● ដើម្បីគោរពស្មារតីរដ្ឋធម្មនុញ្ញ គោរពតាមច្បាប់បោះឆ្នោត និងគោលការណ៍លទ្ធិប្រជាធិបតេយ្យ

- តើអ្នកត្រូវបោះឆ្នោតឱ្យអ្នកណា?

យើងជាប្រជាពលរដ្ឋខ្មែរដែលតែងតែទាមទារ និងចង់បានជានិច្ចនូវសន្តិភាព ការរីកចំរើនជឿនលឿន មានវប្បធម៌ និងអារិយធម៌ថ្កុំថ្កើង ដូចនេះយើងត្រូវតែនាំគ្នាចូលរួមបោះឆ្នោតតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ ។ យើងត្រូវប្រើប្រាស់សិទ្ធិរបស់យើងក្នុងការជ្រើសរើសអ្នកដឹកនាំម្នាក់ដែលមានលក្ខណៈដូចតទៅ :

● បេក្ខជន ឬគណបក្សដែលបានចុះឈ្មោះផ្លូវការហើយ
● ជាបុគ្គលដែលប្រកបដោយមេត្តាករុណា និងស្មោះត្រង់
● ជាអ្នកដឹកនាំដែលអាចពឹងពាក់បានទាំងផ្លូវការ និងក្រៅផ្លូវការ
● ជាមនុស្សដែលជឿជាក់ និងអនុវត្តតាមក្រឹតក្រមសីលធម៌ គឺជាមនុស្សដែលមានសីលធម៌ជាប់ខ្លួន
● ជាមនុស្សដែលមានអាកប្បកិរិយាទន់ភ្លន់សុភាពរាបសា ចេះជួយទុក្ខធុរៈអ្នកដទៃ
● ជាមនុស្សដែលគិតផលប្រយោជន៍ជាតិធំជាងផលប្រយោជន៍បុគ្គល ឬបក្ស
● ជាមនុស្សដែលមិនផ្លាស់ប្តូរមនសិការក្នុងការជួយចៅហ្វាយនាយខ្លួនឯង ឬសាធារណជន
● ជាមនុស្សដែលមិនឱ្យ ឬទទួលនូវសំណូកពីអ្នកណាម្នាក់តាមគ្រប់មធ្យោបាយ
● ជាមនុស្សដែលគោរពតាមពាក្យសន្យា
● ជាមនុស្សដែលគោរពអនុវត្តច្បាប់ ជួយការពារស្ថាប័ន និងទ្រព្យសម្បត្តិសាធារណៈ
● ជាមនុស្សចូលចិត្តក្នុងការជជែកវែកញែក ការយល់ព្រមគ្នា និងគោរពមតិអ្នកដទៃ
● ជាមនុស្សដែលត្រៀមខ្លួន និងមានបំណងដើម្បីប្រកាសឱ្យគេដឹងនូវទ្រព្យសម្បត្តិធនធានដែលខ្លួនមាន
● ជាអ្នកដែលជួយបង្កើនធនធានជាតិ និងមិនមែនជាមនុស្សចិត្តកំណាញ់

- ជាអ្នកដឹកនាំដែលមិនប្រើអំពើហិង្សា អមនុស្សធម៌ និងមានតែភាពជូរចត់ ទុក្ខវេទនា

- តើអ្នកត្រូវបោះឆ្នោតដោយវិធីណា?

- ជ្រើសរើសតាមប្រព័ន្ធសមាមាត្រ : អ្នកបោះឆ្នោតត្រូវបោះឱ្យគណបក្ស ចំនួនសន្លឹកឆ្នោតដែលគណបក្សទទួលបាន គឺបញ្ជាក់បង្ហាញពីចំនួនអាសនៈ (កៅអី) ដែលគណបក្សនីមួយៗមាននៅក្នុងរដ្ឋាភិបាល
- ការបោះឆ្នោតដោយសេរី : អ្នកបោះឆ្នោតអាចជ្រើសរើសបេក្ខជន ឬបញ្ជីគណបក្ស " ធ្វើឡើងដោយឆន្ទៈរបស់ប្រជាពលរដ្ឋ " រួចចាកពីការបង្ខំ ឬកៀបសង្កត់ពីប្រភពឯកជនក្តី ឬពីរដ្ឋអំណាចក្តី " ។
- ការបោះឆ្នោតដោយសំងាត់ : អ្នកបោះឆ្នោតអាចបោះសន្លឹកឆ្នោតរបស់ខ្លួនដោយមិនមានអ្នកណាម្នាក់ដឹងអំពីសេចក្តីសម្រេចរបស់អ្នកឡើយ ។ ការបោះឆ្នោតដោយសំងាត់គឺធានាសិទ្ធិរបស់អ្នកដើម្បីបោះឆ្នោតដោយសេរី និងយុត្តិធម៌ :
  - សិទ្ធិដើម្បីរក្សាការសំងាត់របស់អ្នក គឺត្រូវធានា និងត្រូវបានការពារដោយច្បាប់បោះឆ្នោត
  - អ្នកមិនត្រូវសរសេរឈ្មោះរបស់អ្នកនៅលើសន្លឹកឆ្នោតឡើយ
  - អ្នកអាចចូលទៅគូសសន្លឹកឆ្នោតតែម្នាក់ឯង ដោយមិនមានសាក្សី ឬអ្នកឯទៀតចូលទៅជាមួយអ្នកឡើយ
  - អ្នកត្រូវបត់សន្លឹកឆ្នោតមុនពេលដាក់ទៅក្នុងហិបឆ្នោត កុំឱ្យនរណាមើលឃើញ
- ការបោះឆ្នោតដោយចំពោះ : អ្នកបោះឆ្នោតនីមួយៗអាចសម្រេចជើសរើសបេក្ខជន ឬឈ្មោះបេក្ខជនក្នុងបញ្ជីដោយខ្លួនឯងផ្ទាល់ ដោយមិនចាំបាច់មានអ្នកមកបង្គាប់បញ្ជាឡើយ ។ អ្នកបោះឆ្នោតត្រូវតែសម្រេចចិត្តដោយខ្លួនឯងតែម្តង ពុំមាននរណាម្នាក់អាចប្តូរ ឬអាចប្រែប្រួលការសម្រេចចិត្តរបស់អ្នក ក្រោយពេលបោះឆ្នោតបានឡើយ ។
- ការបោះឆ្នោតជាសកល : ប្រជាពលរដ្ឋគ្រប់ៗរូបមានសិទ្ធិចូលរួមក្នុងការបោះឆ្នោត ដោយមិនគិតពី សាសនា ពូជសាសន៍ ការចេះដឹង ភេទ ទ្រព្យសម្បត្តិ ស្ថានភាពសង្គម ឬប្រាក់បង់ពន្ធនោះទេ ។
- ដំណើរការបោះឆ្នោត :
  - ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវធ្វើឡើងប្រាំ (៥) ឆ្នាំម្តង
  - ការបោះឆ្នោតនឹងប្រព្រឹត្តទៅចាប់ពីម៉ោងប្រាំពីរព្រឹក រហូតដល់ម៉ោងបួនរសៀល
  - នៅក្នុងមណ្ឌលបោះឆ្នោតនីមួយៗមាន :
    - មន្ត្រីគណៈអធិបតី
    - មន្ត្រីអត្តសញ្ញាណកម្ម
    - អ្នកលាបទឹកខ្មៅ

- អ្នកចេញក្រដាសសន្លឹកឆ្នោត
- អ្នកពិនិត្យមើលប្រអប់ឆ្នោត
- មន្ត្រី ឬភ្នាក់ងារតំណាងគណបក្សម្នាក់ មកពីគ្រប់គណបក្សដើម្បីតាមដានមើលការបោះឆ្នោត
- កងកម្លាំងរក្សាសន្តិសុខអព្យាក្រឹត្យ
- អ្នកសង្កេតការណ៍មកពីអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រទេសនានា
- មន្ត្រីត្រួតពិនិត្យការរៀបចំការបោះឆ្នោតអង្គុយនៅនឹងតុ នៅក្នុងការិយាល័យបោះឆ្នោត

- <u>វិធីប្រើប្រាស់សិទ្ធិបោះឆ្នោត</u> : នៅតាមស្ថានីយបោះឆ្នោតត្រូវធ្វើតាមបែបបទដូចតទៅ :

☞ អ្នកបោះឆ្នោតត្រូវឈរជាជួរនៅក្នុងមណ្ឌលបោះឆ្នោត

☞ អ្នកបោះឆ្នោតបង្ហាញប័ណ្ណរបស់ខ្លួនទៅមន្ត្រីត្រួតពិនិត្យមើលដំណើរការបោះឆ្នោត ។ មន្ត្រីត្រួតមើលដំណើរការបោះឆ្នោតនេះ ត្រូវពិនិត្យមើលប័ណ្ណអ្នកបោះឆ្នោតក្នុងបំណងធ្វើឱ្យប្រាកដប្រជាថាមិនមែនជាប័ណ្ណក្លែងក្លាយ

☞ គណៈកម្មាការត្រួតសន្លឹកឆ្នោត ត្រួតពិនិត្យឈ្មោះដែលមាននៅក្នុងបញ្ជីរាយនាមអ្នកដែលមានសិទ្ធិបោះឆ្នោត

☞ នៅពេលដែលគណៈកម្មាការត្រួតសន្លឹកឆ្នោត បានត្រួតពិនិត្យត្រឹមត្រូវរួចហើយនោះ ត្រូវអានឈ្មោះ និងអាសយដ្ឋានរបស់អ្នកដែលចូលទៅបោះឆ្នោតនោះខ្លាំងៗ

☞ មុននឹងសន្លឹកឆ្នោតត្រូវបានចេញឱ្យទៅអ្នកបោះឆ្នោត អ្នកបោះឆ្នោតត្រូវបានលាបដៅទឹកខ្មៅ ឬសារជាតិម្យ៉ាងនៅលើម្រាមដៃរបស់ខ្លួន ដែលនឹងចង្អុលឱ្យឃើញថាខ្លួនបានបោះរួចហើយ

☞ ម្រាមដៃអ្នកបោះឆ្នោតត្រូវបានត្រួតពិនិត្យ ដើម្បីកំណត់ឱ្យឃើញថា មាន ឬគ្មានស្នាម ដែលបង្ហាញឱ្យឃើញថាសាម៉ីខ្លួនបានបោះឆ្នោតពីមុនរួចហើយ ។ បើឃើញមានស្នាម អ្នកនោះមិនត្រូវបានអនុញ្ញាតឱ្យបោះទៀតទេ

☞ កាលណាគេបានកំណត់ថា ជនណាម្នាក់មានសិទ្ធិបោះឆ្នោតហើយ គេនឹងចេញសន្លឹកឆ្នោតមួយសន្លឹកឱ្យ ។ រួចហើយអ្នកត្រូវដើរតែម្នាក់ឯងទៅក្នុងបន្ទប់មួយដែលមានរនាំង ឬវាំងននបាំងនៅក្នុងការិយាល័យបោះឆ្នោត ដើម្បីគូសសញ្ញាមួយគឺ ☒ នៅចំពីមុខឈ្មោះបេក្ខជន ឬគណបក្សណាដែលអ្នកចង់បោះឱ្យ ។

☞ ក្រោយពីគូសសញ្ញា ☒ រួចហើយ អ្នកត្រូវបត់ក្រដាសសន្លឹកឆ្នោតនោះឱ្យបានរៀបរយល្អ បន្ទាប់មកត្រូវយកទៅញាត់ចូលទៅក្នុងប្រអប់ (ហិប) ឆ្នោត ។

☞ អ្នកបោះឆ្នោតម្នាក់អាចបោះឆ្នោតបានម្តង ហើយអាចជ្រើសរើសយកបេក្ខជន ឬគណបក្សតែមួយប៉ុណ្ណោះ ។ សន្លឹកឆ្នោតដែលអ្នកបានបោះ គឺពិតជាមានតម្លៃដូចគ្នា ។ ដូច្នេះមុននឹងសម្រេចចិត្តបោះ អ្នកត្រូវតែគិតពិចារណាឱ្យល្អិតល្អន់ ។

## សេចក្តីសន្និដ្ឋាន

" ការចូលរួមក្នុងការបោះឆ្នោត គឺជាការចូលរួមចំណែកដ៏សំខាន់ក្នុងការសម្រេច និងទទួលខុសត្រូវខ្ពស់ចំពោះវាសនាអនាគតជាតិ "

- ការបោះឆ្នោតគឺជាឱកាស និងជាយន្តការមួយសម្រាប់អ្នកមានសិទ្ធិបោះឆ្នោតប្រើប្រាស់សិទ្ធិជ្រើសរើសអ្នកដឹកនាំរបស់ពួកគេ ។ ប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតទាំងឡាយអាចប្រើ ឬក៏មិនប្រើប្រាស់សិទ្ធិបាន ។
- ការបោះឆ្នោតគឺជាជំហានទីមួយដើម្បីឆ្ពោះទៅរកការកសាងជាតិ និងការផ្លាស់ប្តូរនូវជីវភាពរស់នៅរបស់យើងឱ្យបានប្រសើរឡើង ក៏ប៉ុន្តែនៅមានមធ្យោបាយផ្សេងៗច្រើនទៀត ក្នុងការផ្លាស់ប្តូរនេះ ។
- ការបោះឆ្នោត គឺដើម្បី :
  - " អនាគតដ៏ប្រសើរសម្រាប់ប្រទេសជាតិខ្លួនឯងផ្ទាល់ និងកូនចៅរបស់យើង
  - រកសន្តិភាព និងបញ្ចប់ការរំលោភ និងអំពើហិង្សាទាំងឡាយ
  - បញ្ចប់ការបំបាក់បំបែកពូជសាសន៍
  - លទ្ធិប្រជាធិបតេយ្យនៅក្នុងព្រះរាជាណាចក្រកម្ពុជា
  - គាំទ្រគណបក្សដែលយើងស្រឡាញ់ពេញចិត្ត "
- ដើម្បីការពារសិទ្ធិបោះឆ្នោត :
  - បើសិនអ្នកជាពាណិជ្ជករ អ្នកត្រូវផ្អាកការលក់ដូររបស់អ្នក ដើម្បីទៅបោះឆ្នោត
  - បើសិនអ្នកជាកសិករ អ្នកត្រូវផ្អាកការដាំដុះ ដើម្បីទៅបោះឆ្នោត
  - បើសិនអ្នកជាមេផ្ទះ អ្នកត្រូវចំអិនអាហាររួចជាស្រេច ដើម្បីទៅបោះឆ្នោត
  - បើសិនអ្នកជាសិស្សនិស្សិត អ្នកត្រូវទុកសៀវភៅនៅដោយឡែក ដើម្បីទៅបោះឆ្នោត

" បើអ្នកមានបំណងចូលរួមសកម្មក្នុងភាពជាពលរដ្ឋខ្មែរ អ្នកត្រូវតែប្រើប្រាស់សិទ្ធិបោះឆ្នោតរបស់អ្នក "

" បើការបោះឆ្នោតប្រព្រឹត្តទៅបានល្អត្រឹមត្រូវពិតប្រាកដ ជាការបោះឆ្នោតសេរី សមស្រប និងយុត្តិធម៌មែន នោះប្រាកដជាមានការគាំទ្រពីសំណាក់សាធារណៈមតិ ទាំងជាតិ ទាំងអន្តរជាតិ ។ កាលបើមានការទទួលស្គាល់ពីសំណាក់អន្តរជាតិហើយ ការគាំទ្រ និងជំនួយផ្សេងៗប្រាកដជានឹងមានជាលំដាប់

សម្រាប់ការស្តារ និងកសាងប្រទេសកម្ពុជាយើងឡើងវិញ ។ ផ្ទុយទៅវិញ បើអន្តរជាតិមិនទទួលស្គាល់នូវលទ្ធផលនៃការបោះឆ្នោតនេះទេ ដោយសារប្រការឆ្គាំឆ្គងណាមួយនោះ នោះគេនឹងមិនទទួលស្គាល់រដ្ឋាភិបាលដែលកើតចេញពីការបោះឆ្នោតនេះទេ ហើយជំនួយ និងចំណងមេត្រីភាពផ្លូវទូត និងផ្លូវសេដ្ឋកិច្ចនានា មុខជានឹងត្រូវដាច់ជាបន្តបន្ទាប់ ។ យើងទាំងអស់គ្នាមិនត្រូវបណ្តោយឱ្យស្រុកយើងធ្លាក់ចូលទៅក្នុងសភាពឯកោរអនាថា ដូចលើកមុនទៀតជាដាច់ខាត ” ។

# ក្រមសីលធម៌នៃការបោះឆ្នោតសេរីនិងយុត្តិធម៌

(ឧទាហរណ៍ជម្រើស)

## ប្រទេសកម្ពុជា (សម័យអ៊ុនតាក់)

ក្រមសីលធម៌

១. ប្រជាពលរដ្ឋទាំងអស់ គណបក្សនយោបាយ មេដឹកនាំ សមាជិក និងអ្នកគាំទ្រគណបក្សនយោបាយទាំងអស់ គណបក្សនយោបាយដែលបានចុះឈ្មោះជាបណ្ដោះអាសន្ន និងចុះឈ្មោះជាផ្លូវការ មេដឹកនាំ សមាជិក អ្នកគាំទ្រ និងបេក្ខជនរបស់គណបក្សទាំងអស់ត្រូវអនុវត្តតាមក្រមសីលធម៌នេះ ។

២. គណបក្សនយោបាយទាំងអស់មានសិទ្ធិទទួលយកនូវសិទ្ធិជាមូលដ្ឋាននៃការបោះឆ្នោតដោយសេរី និងយុត្តិធម៌ រួមទាំងសេរីភាពក្នុងការធ្វើយុទ្ធនាការឃោសនាបោះឆ្នោតផងដែរ ។

៣. គណបក្សនយោបាយទាំងអស់ត្រូវគោរពសិទ្ធិ និងសេរីភាពរបស់គណបក្សដទៃទៀតក្នុងការធ្វើយុទ្ធនាការឃោសនាបោះឆ្នោត និងការផ្សព្វផ្សាយនូវគោលការណ៍ និងគំនិតនយោបាយរបស់គេ ដោយគ្មានការភ័យបារម្ភ ។

៤. ជាពិសេសទៅទៀត គណបក្សនយោបាយទាំងអស់ ទាំងគណបក្សនយោបាយដែលបានចុះឈ្មោះជាបណ្ដោះអាសន្ន និងជាផ្លូវការ មេដឹកនាំ សមាជិក អ្នកគាំទ្រ និងបេក្ខជនទាំងអស់ត្រូវគោរពតាមវិធានដូចខាងក្រោមនេះ :

   ១. ការបំភិតបំភ័យ ទោះជាក្នុងទម្រង់ណាក៏ដោយ ត្រូវហាមឃាត់ ហើយឯកសារការផ្សព្វផ្សាយ និងបទបញ្ជានានារបស់គណបក្សនយោបាយ និងគណបក្សនយោបាយដែលបានចុះឈ្មោះជាបណ្ដោះអាសន្ន និងផ្លូវការទាំងពួង ត្រូវដាក់ឲ្យប្រតិបត្តិ និងសង្កត់ធ្ងន់ទៅលើការហាមឃាត់នេះ ។

   ២. ការកាន់កាប់ និងការប្រើប្រាស់នូវអាវុធគ្រប់ប្រភេទ ឬឧបករណ៍ដែលអាចប្រើប្រាស់បានជាអាវុធនៅក្នុងការប្រជុំនយោបាយ ការប្រជុំ ការដើរជាក្បួន

ឬការធ្វើបាតុកម្ម ត្រូវហាមឃាត់ ។ ឯកសារការផ្សព្វផ្សាយ និងបទបញ្ជាវិន័យទាំងពួងរបស់គណបក្សនានា ត្រូវប្រតិបត្តិនូវការហាមឃាត់នេះ ។

៣. គណបក្ស និងបេក្ខជនត្រូវជម្រាបជូនដំណឹងដល់មន្ត្រីអ៊ុនតាក់ (UNTAC) ប្រចាំមូលដ្ឋាន នូវការប្រជុំជាសាធារណៈ ឬការប្រជុំនយោបាយដែលខ្លួនបានគ្រោងទុក ហើយនិងត្រូវប្រើគ្រប់វិធានការចាំបាច់ក្នុងស្មារតីស្មោះស ដើម្បីបញ្ចៀសនូវជម្លោះ ឬការប្រឈមមុខដោយហិង្សា រវាងអ្នកគាំទ្ររបស់ខ្លួន ហើយត្រូវអនុវត្តតាមរាល់ការណែនាំ អនុទ្ទេស ឬបទបញ្ជា ដែលចេញដោយអ៊ុនតាក់ (UNTAC) ពាក់ព័ន្ធទៅនឹងកិច្ចប្រជុំបែបនោះ ។

៤. គណបក្សទាំងអស់ត្រូវជៀសវាងកុំឲ្យមានការស្ទួនគ្នាជាមួយគណបក្សដទៃទៀត ខាងពេលវេលា ឬទីកន្លែងសម្រាប់ការប្រជុំ អង្គមីទ្ទីញ ការដើរក្បួន ឬបាតុកម្មរបស់ខ្លួន ហើយដើម្បីកុំឲ្យមានរឿងបែបនេះ គណបក្សទាំងអស់ត្រូវទំនាក់ទំនង និងធ្វើសហប្រតិបត្តិការជាមួយអ៊ុនតាក់ (UNTAC) ហើយនិងជាមួយគណបក្សដទៃទៀត ។

៥. គណបក្សទាំងអស់ សមាជិក និងអ្នកគាំទ្ររបស់ខ្លួន ត្រូវជៀសវាងកុំធ្វើអ្វីដែលរំខានដល់កិច្ចប្រជុំ ការដើរជាក្បួន ឬការធ្វើបាតុកម្ម របស់គណបក្សដទៃទៀត ។

៦. គ្រប់ពេលវេលាទាំងអស់ នៅក្នុងសុន្ទរកថា ការប្រកាសផ្សាយចម្លងលិខិត ព្រឹត្តប័ត្រ ពត៌មាន សេចក្ដីថ្លែងការណ៍ សារពត៌មាន ប័ណ្ណប្រកាសអំពីគោល-នយោបាយគណបក្សរបស់ខ្លួន ការផ្សព្វផ្សាយយុទ្ធនាការបោះឆ្នោត ឬបញ្ហាផ្សេងទៀត គណបក្សនយោបាយ និងសមាជិកទាំងអស់ត្រូវជៀសវាងកុំប្រើប្រាស់នូវភាសាអសុរោះ អុជអាល ឬភាសាដទៃទៀតនានា ដែលគំរាមកំហែង ឬញុះញង់ឲ្យកើតអំពើហិង្សាគ្រប់រូបភាពទាំងអស់ ប្រឆាំងនឹងអ្នកដទៃទៀត ។

៧. គណបក្សនយោបាយទាំងអស់ត្រូវជៀសវាងកុំរារាំងជនទាំងឡាយណា ដែលទៅចូលរួមនៅក្នុងការប្រជុំ ការដើរជាក្បួន ឬអង្គមីទ្ទីញរបស់គណបក្សដទៃទៀត ។

៨. គណបក្សទាំងអស់ត្រូវជៀសវាងកុំធ្វើឲ្យខូចខាតផ្លាកសញ្ញារបស់គណបក្សដទៃទៀត ហើយមិនត្រូវលួចបំផ្លាញឬធ្វើឲ្យខូចទ្រង់ទ្រាយនូវប័ណ្ណប្រកាសនយោបាយ ឬសម្ភារៈធ្វើយុទ្ធនាការបោះឆ្នោតរបស់គណបក្សដទៃទៀត ឬសម្ភារៈពត៌មានបោះឆ្នោតរបស់អ៊ុនតាក់ (UNTAC) ។

៩. គណបក្សនយោបាយទាំងអស់ ជាពិសេសមេដឹកនាំគណបក្ស ត្រូវធានានូវសេរីភាពរបស់គណបក្សដទៃទៀត ដើម្បីឲ្យគេមានឱកាសជួបប្រជុំជាមួយអ្នកបោះឆ្នោតដោយប្រើប្រាស់សម្បត្តិសាធារណៈ ឬឯកជន នៅក្នុងជំរុំ ឬមណ្ឌលទទួលភៀស ឬក៏ទីកន្លែងដទៃផ្សេងទៀត ។ គណបក្សនានាត្រូវធានាថាអ្នកបោះឆ្នោតដែលមានបំណងចូលរួមក្នុងសកម្មភាពនយោបាយ ត្រូវមានសេរីភាពគ្រប់គ្រាន់ក្នុងការសម្រេចចិត្តធ្វើបែបនេះ ។

១០. គណបក្សទាំងអស់ត្រូវប្រតិបត្តិ និងសង្កត់ធ្ងន់ជានិច្ចចំពោះអ្នកគាំទ្ររបស់ខ្លួន និងចំពោះអ្នកបោះឆ្នោតទាំងអស់ថា ការបោះឆ្នោតគឺធ្វើឡើងដោយសម្ងាត់ ហើយគ្មានជនណាម្នាក់នឹងដឹងថាតើគេបោះឆ្នោតយ៉ាងណាឡើយ ។

១១. គណបក្សទាំងអស់ត្រូវបង្កើតប្រព័ន្ធគមនាគមន៍មានប្រសិទ្ធភាព ដើម្បីទំនាក់ទំនងជាមួយបក្សឯទៀតៗនៅថ្នាក់មជ្ឈិម ខេត្ត និងស្រុក ហើយត្រូវតែងតាំងបុគ្គលិកទំនាក់ទំនងដើម្បីធ្វើការនេះនៅគ្រប់ពេលវេលា ក្នុងការដោះស្រាយបញ្ហាណាមួយដែលអាចកើតឡើងក្នុងអំឡុងពេលចុះឈ្មោះបោះឆ្នោត ពេលធ្វើយុទ្ធនាការបោះឆ្នោត ឬក៏ពេលកំពុងបោះឆ្នោត ។

១២. គណបក្សទាំងអស់ត្រូវចូលរួមប្រជុំយ៉ាងតិចមួយដងរៀងរាល់ពីរសប្តាហ៍ ក្រោមអធិបតីភាពរបស់មន្ត្រីប្រធានរៀបចំការបោះឆ្នោត ដើម្បីពិភាក្សានូវបញ្ហានានាដែលពាក់ព័ន្ធទៅនឹងយុទ្ធនាការនៃការបោះឆ្នោត ។ លើសពីនេះទៀត ត្រូវមានគណៈកម្មការអចិន្ត្រៃយ៍មួយ ដែលមេបក្សបានចុះឈ្មោះជាសមាជិកតាមផ្លូវការ ហើយសមាជិកនេះត្រូវជួបប្រជុំយ៉ាងតិចពីរអាទិត្យម្តង ក្រោមអធិបតីភាពនៃលោកតំណាងពិសេស ឬឧបការីរបស់គាត់ ដើម្បីពិភាក្សាលើបញ្ហានានាទាក់ទិនដល់ការធ្វើយុទ្ធនាការឃោសនាបោះឆ្នោត ។ កិច្ចប្រជុំដែលបានពិពណ៌នាដូចខាងលើត្រូវចាប់ផ្តើមពីកាលបរិច្ឆេទមួយដែលត្រូវកំណត់ដោយអ្នកតំណាងពិសេស ។

១៣. គណបក្សទាំងអស់ត្រូវនាំពត៌មាន ឬពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងការបំភិតបំភ័យ ឬក៏ចោទប្រកាន់ដទៃទៀត ចំពោះការប្រតិបត្តិមិនស្របច្បាប់ ទៅដាក់ជូនអាជ្ញាធរអ៊ុនតាក់ (UNTAC) ជាបន្ទាន់ ។

១៤. គណបក្សនានាមិនត្រូវប្រើសិទ្ធិខ្លួនដោយរំលោភក្នុងការតវ៉ា ឬធ្វើការប្តឹងតវ៉ាបែបមិនត្រឹមត្រូវ បែបមិនប្រាកដប្រជា ឬបែបសន្សំរឿងឡើយ ។

១៥. គណបក្សទាំងអស់ត្រូវសហការដោយពេញលេញជាមួយគណៈកម្មាធិការក្រុមប្រឹក្សាបោះឆ្នោត របស់អ្នកតំណាងពិសេស ។

១៦. គណបក្សទាំងអស់ត្រូវដាក់ចេញនូវការណែនាំ និងបទបញ្ជាដល់សមាជិក និងអ្នកគាំទ្ររបស់ខ្លួនឲ្យប្រតិបត្តិច្បាប់បោះឆ្នោត ក្រមសីលធម៌នេះ សេចក្តីណែនាំរបស់មន្ត្រីអ៊ិនតាក់ ហើយនិងប្រតិបត្តិតាមបញ្ជា និងសេចក្តីបង្គាប់របស់អ្នកតំណាងពិសេសនៃ(អ.ប.ស) ហើយត្រូវចាត់នូវវិធានការជាចាំបាច់នានាដោយស្មោះស្ម័គ្រ ដើម្បីធានាឲ្យបាននូវការអនុលោមតាមច្បាប់បោះឆ្នោត ហើយនិងក្រមសីលធម៌នេះ ។

១៧. អ្នកតំណាងពិសេស(អ.ប.ស) និងគណបក្សទាំងអស់ត្រូវផ្សព្វផ្សាយនូវក្រមសីលធម៌នេះ ហើយនិងច្បាប់បោះឆ្នោតឲ្យបានទូទាំងប្រទេស ដោយប្រើគ្រប់មធ្យោបាយតាមឆន្ទៈរបស់ខ្លួន ។

=====================================

# សេយឆែលលេស

(SEYCHELLES)

ក្រមសីលធម៌/ក្រមប្រតិបត្តិដែលត្រូវតែប្រកាន់យកដោយខ្ជាប់ខ្ជួន ដោយគណបក្សនយោបាយសមាជិក និងអ្នកគាំទ្ររបស់ខ្លួនចំពោះការបោះឆ្នោត ឬការធ្វើប្រជាមតិ ។

ក្រមសីលធម៌នេះត្រូវគេអនុវត្តសំដៅថែរក្សានូវបរិយាកាសស្ងប់ស្ងាត់ ក្នុងអំឡុងពេលនៃការធ្វើយុទ្ធនាការបោះឆ្នោត ឬការធ្វើប្រជាមតិ ហើយនិងក្នុងថ្ងៃបោះឆ្នោត ។

ក្រមសីលធម៌

១. បទបញ្ជា និងច្បាប់បោះឆ្នោតដែលកំពុងតែមានអត្ថិភាព ត្រូវតែអនុវត្តដោយខ្ជាប់ខ្ជួន ។

២. គណបក្សនយោបាយ និងគូបដិបក្ខប្រកួតប្រជែងទាំងអស់ ត្រូវតែផ្តល់នូវកិច្ចសហប្រតិបត្តិការគ្រប់យ៉ាង និងការជួយដ៏ចាំបាច់ ចំពោះអាជ្ញាធរប្រតិបត្តិច្បាប់ ។

៣. ជនគ្រប់រូបគួរតែដឹង មិនត្រឹមតែពីសិទ្ធិរបស់ខ្លួនផ្ទាល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគួរត្រូវគោរពនូវសិទ្ធិរបស់អ្នកដទៃទៀតផងដែរ ។

៤. គណបក្សនយោបាយ និងបេក្ខជនទាំងអស់ដែលចូលរួមក្នុងការបោះឆ្នោត ត្រូវផ្តល់នូវកិច្ចសហប្រតិបត្តិការដ៏ពេញលេញចំពោះមន្ត្រីរៀបចំការបោះឆ្នោត ហើយត្រូវធានាសុវត្ថិភាពរបស់មន្ត្រីទាំងអស់នេះ រហូតដល់ចប់ការបោះឆ្នោត ។

៥. យុទ្ធនាការបោះឆ្នោត គួររៀបចំនៅក្នុងបរិយាកាសស្ងប់ស្ងាត់ និងត្រូវវ៉ូវគ្នា ដើម្បីឲ្យបរិយាកាសបែបនេះស្ថិតនៅរហូតដល់អំឡុងពេលមានការបោះឆ្នោត ។

៦. ពាក្យទិតៀនរបស់គូបដិបក្ខ តែងតែកើតមានឡើងក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។ គណបក្សទាំងអស់ត្រូវអត់ធ្មត់ទាំងពាក្យសំដី លក្ខណៈឫកពា ហើយនិងការប្រតិបត្តិ ហើយត្រូវគោរពមតិអ្នកដទៃ ដើម្បីធ្វើឲ្យការឃោសនារកសម្លេងឆ្នោតមិនក្លាយទៅជាសង្គ្រាមពាក្យសំដី និងការប្រឈមមុខដាក់គ្នា ។

៧. ពាក្យទិតៀនតែងតែកើតមាននៅក្នុងអំឡុងពេលឃោសនា ។ ប៉ុន្តែ សុន្ទរកថា សេចក្តីថ្លែងការណ៍ ប័ណ្ណប្រកាស ដែលញុះញង់ ហើយនិងពាក្យសំដីជេរប្រមាថ បញ្ជិតបញ្ជៀងត្រូវតែជៀសវាង ។ គណបក្សនានាត្រូវប្រយ័ត្នប្រយែង ដើម្បីកុំឲ្យអាកប្បកិរិយា សេចក្តីថ្លែងការណ៍ ឬការពន្យល់នានា បង្កឲ្យមានភាពតានតឹង ។

៨. គណបក្សនយោបាយទាំងអស់មានកាតព្វកិច្ច ត្រូវទប់ទល់ប្រឆាំងនឹងអំពើហិង្សាដោយឥតសំចៃ ។ រាល់គណបក្ស មិនត្រូវបណ្តោយខ្លួនឲ្យធ្លាក់ទៅក្នុងទម្រង់ណាមួយនៃសកម្មភាពហិង្សា ហើយមិនត្រូវប្រើអំពើហិង្សាដើម្បីបង្ហាញនូវអំណាចរបស់គណបក្ស ឬដើម្បីបង្ហាញនូវបរមានុភាពនោះឡើយ ។ គណបក្សនយោបាយទាំងអស់ ត្រូវផ្តល់នូវកិច្ចសហប្រតិបត្តិការចំពោះភ្នាក់ងារប្រតិបត្តិច្បាប់ ក្នុងការប្រមូលយកនូវអាវុធខុសច្បាប់ ។ រាល់គណបក្សមិនត្រូវផ្តួចផ្តើមឲ្យមានការដោះលែងជនដែលត្រូវបានឃាត់ខ្លួនដោយនគរបាល ពីបទមានអាវុធខុសច្បាប់ក្នុងពេលយុទ្ធនាការបោះឆ្នោត ឬធ្វើប្រជាមតិ ឬនៅក្បែរស្ថានីយ៍បោះឆ្នោតក្នុងអំឡុងពេលបោះឆ្នោត ឬនៅក្បែរស្ថានីយ៍បោះឆ្នោតពេលកំពុងមានការបោះឆ្នោត ។

៩. បេក្ខជន និងគណបក្សទាំងអស់ ត្រូវមានឱកាសស្មើភាពគ្នាក្នុងការផ្សាយជាសាធារណៈ ។ ការប្រជុំ ការដើរជាក្បួនហើយនិងសកម្មភាពយុទ្ធនាការបោះឆ្នោតដទៃទៀតរបស់គូបដិបក្ខមិនអាចត្រូវគេធ្វើការឆាឆៅបានឡើយ ។ ប័ណ្ណប្រកាស និងខិតប័ណ្ណត្រូវដាក់បិទតាំងដោយអនុលោមទៅនឹងក្រមសីលធម៌ ដែលមាននៅក្នុងតារាងកាលវិភាគនៃក្រមនេះ ។

១០. ទីភ្នាក់ងារប្រតិបត្តិច្បាប់នឹងត្រូវផ្តល់កិច្ចឧបត្ថម្ភ ដើម្បីទប់ទល់ និងអង្កេតពិនិត្យនូវការបំពានដល់ការបោះឆ្នោតដោយប្រការណាមួយ ។

១១. ការប៉ុនប៉ងទាំងពួងដើម្បីជះឥទ្ធិពលដល់ការបោះឆ្នោត ដោយប្រើលុយកាក់ ឬការលួងចិត្ត គឺជាការបំពានដល់ការបោះឆ្នោត ។ ជនគ្រប់រូបគួរតែយល់ដឹងពីការបំពានទាំងអស់នេះ ។

១២. មិនត្រូវយកយាន្តជំនិះរបស់រដ្ឋាភិបាលទៅប្រើដើម្បីដឹកនាំអ្នកបោះឆ្នោត ទៅកាន់ស្ថានីយ៍បោះឆ្នោតឡើយ ។ យាន្តទាំងនេះ គឺសម្រាប់បុគ្គលដែលធ្វើការឲ្យក្រសួង ស្ថាប័នរដ្ឋាភិបាល ដែលកំពុងបំពេញភារកិច្ចឬសម្រាប់បុគ្គលដែលរស់នៅក្នុងស្ថាប័នរដ្ឋាភិបាល ។ បទបញ្ជានេះ មិនអនុវត្តចំពោះជនដែលមានសិទ្ធិប្រើប្រាស់យាន្តជំនិះរដ្ឋាភិបាល ហើយនិងយាន្តជំនិះដែលគេទុកប្រើប្រាស់សម្រាប់ខ្លួនឯង និងគ្រួសារឡើយ ។

១៣. មិនត្រូវយករថយន្តកងទ័ពទៅប្រើដើម្បីដឹកនាំអ្នកបោះឆ្នោត រួមទាំងបុគ្គលិកយោធាផ្ទោះទៅកាន់ស្ថានីយ៍បោះឆ្នោតឡើយ ។

១៤. បុគ្គលិកយោធា មិនត្រូវទៅបោះឆ្នោតដោយមានសម្លៀកបំពាក់ជាឯកសណ្ឋានយោធាឡើយ ។

១៥. គណបក្សនយោបាយមិនត្រូវទាក់ទាញសន្លឹកឆ្នោតដោយសារឥទ្ធិពលការងាររបស់ខ្លួនធ្វើការក្នុងស្ថានីយ៍បោះឆ្នោត ឬក៏ដោយសារតែតាមរយៈសកម្មភាពខុសច្បាប់ នៅក្នុងស្ថានីយ៍បោះឆ្នោត ។

១៦. គ្មានបេក្ខជន ឬគណបក្សណាអាចផ្តល់វិភាគទានប្រភេទណាមួយដោយលក្ខការណ៍ ឬដោយចំហ ផ្តល់មូលនិធិ ឬការឧបត្ថម្ភដល់បុគ្គលណាមួយ ដល់ស្ថាប័នណាមួយ ដល់អង្គការណាមួយ រហូតដល់កាលបរិច្ឆេទការបោះឆ្នោត ឬការធ្វើប្រជាមតិក្នុងគោលបំណងសម្រាប់ការធ្វើយុទ្ធនាការបោះឆ្នោត ហើយនិងទទួលសន្លឹកឆ្នោត ។

១៧. បរិយាកាសដោយសន្តិភាព និងភាតរភាពសម្រាប់ការបោះឆ្នោត ឬការធ្វើប្រជាមតិ មិនអាចត្រូវរំខានដោយពាក្យចចាមអារ៉ាម ដែលសាយភាយមិនពិត ឬបណ្តាលឲ្យមានឧបាស្រ័យឆ្ពោះទៅរកការរួមគំនិតធ្វើអំពើទុច្ចរិតទេ ។

១៨. គ្មានជំរុំបោះឆ្នោត កន្លែងត្រួតពិនិត្យ និងហាងភេសជ្ជៈ ត្រូវរៀបចំឡើងដោយគណបក្សនយោបាយ អ្នកគាំទ្រ និងសមាជិករបស់ខ្លួនទេ ។ មិនត្រូវមានយុទ្ធនាការបោះឆ្នោតដោយប្រភេទណាមួយធ្វើឡើងនៅថ្ងៃបោះឆ្នោត ទោះជាក្នុងលក្ខណៈជាបុគ្គល ឬជា

សម្ងាត់សមូហភាពក៏ដោយ ។ ការិយាល័យក្រុមប្រឹក្សាស្រុកត្រូវឈប់ធ្វើការនៅថ្ងៃបោះឆ្នោត ឬថ្ងៃធ្វើប្រជាមតិ ។ អ្នកបោះឆ្នោតត្រូវចាកចេញពីជួរម្នាក់ម្តង ចូលទៅក្នុងបន្ទប់បោះឆ្នោត ។ ធ្វើដូច្នេះ ដើម្បីជៀសវាងឥទ្ធិពលដែលកើតឡើងដោយប្រការណាមួយ ។

១៩. ប្រសិនបើអ្នកបោះឆ្នោតគ្មានលទ្ធភាពដោយសារពិការភ្នែក ឬបុព្វហេតុសរីរាង្គផ្សេងទៀតនោះ គាត់អាចស្នើសុំឲ្យមន្ត្រីរៀបចំការបោះឆ្នោតជួយគូសសន្លឹកឆ្នោតរបស់គាត់ នៅចំពោះមុខវត្តមាននៃជនម្នាក់ដែលជ្រើសរើសដោយគាត់ផ្ទាល់ ។ នៅក្នុងកាលៈទេសៈទាំងអស់នោះ មន្ត្រីរៀបចំការបោះឆ្នោតត្រូវធានាចំពោះខ្លួនឯងថា : ក. អ្នកបោះឆ្នោតពិតជាពិការមានភាពដូចដែលគាត់បានអះអាងពិតមែន ។ ខ. ជនដែលជាសាក្សីក្នុងការបោះឆ្នោតត្រូវជ្រើសរើសដោយសេរី និងយុត្តិធម៌ ដោយអ្នកបោះឆ្នោតរូបនោះ។គ. ហើយការបោះឆ្នោតដែលធ្វើឡើងដោយអ្នកបោះឆ្នោត គឺមានលក្ខណៈសេរី ។ ក្នុងន័យនោះ គណបក្សនយោបាយមិនត្រូវរំលោភបំពានលើវិធានបែបនេះ ដើម្បីគាបសង្កត់ជនពិការឲ្យបោះឆ្នោតឲ្យគណបក្សខ្លួនឡើយ ។

២០. លើកលែងតែមន្ត្រីរៀបចំការបោះឆ្នោតចេញ គឺមានតែអ្នកបោះឆ្នោតតែប៉ុណ្ណោះដែលមានសិទ្ធិចូលក្នុង " **ស្ថានីយ៍បោះឆ្នោត** " ។ គណបក្សនយោបាយត្រូវធានាថាបុគ្គលិករបស់ខ្លួនមិនចូលទៅក្នុងស្ថានីយ៍បោះឆ្នោត ហើយដើរត្រេតត្រតនៅក្នុងទីនោះឡើយ ។ មានតែភ្នាក់ងាររៀបចំការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលត្រូវស្ថិតនៅជានិច្ចនៅនឹងកន្លែងដែលគេកំណត់ឲ្យអង្គុយនៅក្នុងស្ថានីយ៍បោះឆ្នោត ហើយបំពេញភារកិច្ចរបស់ខ្លួននៅទីកន្លែងដែលខ្លួនអង្គុយនោះ ។ មិនត្រូវបង្កឲ្យមានការរំខានដោយការផ្លាស់ប្តូរទីកន្លែង ឬដូរបុគ្គលិកភ្នាក់ងារឡើយ ។

ក្រមសីលធម៌ពាក់ព័ន្ធនឹងប័ណ្ណប្រកាស និងខិតប័ណ្ណ

## ១.០ ការប្រើប្រាស់នូវក្តារបិទប្រកាសពត៌មាន

១.១ ពត៌មានទាំងអស់ពាក់ព័ន្ធនឹងការបោះឆ្នោត ឬការធ្វើប្រជាមតិ ដំណឹង ឬការផ្សព្វផ្សាយនយោបាយ ត្រូវតែបិទផ្សាយនៅលើតែក្តារបិទប្រកាសពត៌មានតែប៉ុណ្ណោះ ។

១.២ ក្តារបិទប្រកាសពត៌មានទាំងអស់នេះ ត្រូវអនុញ្ញាតឲ្យលើកធ្វើឡើងនៅតែកន្លែងមួយចំនួនប៉ុណ្ណោះ ដែលឯកភាពដោយនាយកដ្ឋានដឹកជញ្ជូនជើងគោក នគរបាល (ផ្នែកចរាចរ) ហើយនិងអាជ្ញាធរផែនការ ។

១.៣ អាជ្ញាធរផែនការ នគរបាល (ផ្នែកចរាចរ) ហើយនិងនាយកដ្ឋានដឹកជញ្ជូនជើងគោក ត្រូវឯកភាពគ្នាទៅលើទំហំ កំពស់ ហើយនិងចំនួនក្ដារបិទប្រកាសពត៌មានដែលត្រូវដាក់តាំងនៅកន្លែងកំណត់ណាមួយនោះ ។

១.៤ នាយកដ្ឋានទេសចរណ៍ និងដឹកជញ្ជូន (ផ្នែកទេសចរណ៍) បានលើកតាំងឡើងនូវក្ដារបិទប្រកាសពត៌មាន ជាអចិន្ត្រៃយ៍មួយចំនួននៅវិកធ័រា (Victoria) ។ មានតែការផ្សាយដំណឹងដែលប្រកាសពីព្រឹត្តិការណ៍ក្នុងស្រុកដូចជា សកម្មភាពអប់រំ វប្បធម៍សង្គម ឬការកំសាន្ត និងការជំរុញវិស័យទេសចរណ៍តែប៉ុណ្ណោះ ដែលត្រូវដាក់តាំងនៅលើក្ដារពត៌មានទាំងនោះ ។

១.៥ ក្ដារពត៌មានដទៃទៀត (ដែលបណ្ដោះអាសន្ន) អាចត្រូវលើកតាំង និងចែកឲ្យទៅគណបក្សនយោបាយខុសៗគ្នា ។

១.៦ ក្ដារពត៌មាននឹងត្រូវដាក់តាំងត្រឹមតែរយៈពេល១៤ថ្ងៃប៉ុណ្ណោះនៅមុនថ្ងៃបោះឆ្នោត ឬធ្វើប្រជាមតិ ។

១.៧ ក្ដារពត៌មាន និងការដាក់ផ្សព្វផ្សាយនយោបាយទាំងអស់ ត្រូវតែរើចេញដោយគណបក្សនយោបាយឲ្យបានកាន់តែឆាប់កាន់តែល្អ ហើយទោះជាក្នុងករណីណាក៏ដោយក្នុងរយៈពេល ១៤ថ្ងៃ ត្រូវរើក្ដារទាំងនេះ បន្ទាប់ពីបញ្ចប់ការបោះឆ្នោត ឬការធ្វើប្រជាមតិដោយអនុលោមទៅតាមបទបញ្ជាលេខ១៣ (២) (៣) របស់បទបញ្ជាផែនការក្រុង និងប្រទេស (ការគ្រប់គ្រងទៅលើការផ្សព្វផ្សាយ) Cap 160 ។

២.០ ការប្រើប្រាស់បដាក្រណាត់

២.១ បដាក្រណាត់ដែលងាយរុះរើចេញ ត្រូវយកមកប្រើឲ្យកាន់តែច្រើនកាន់តែល្អ ដើម្បីជំនួសប័ណ្ណប្រកាសក្រដាសដែលប្រើសម្រាប់តែបិទតែប៉ុណ្ណោះ ។

២.២ បដាក្រណាត់អាចត្រូវអនុញ្ញាតឲ្យតាំងបាន ដរាបណាមានការអនុញ្ញាតជាចាំបាច់ត្រូវគេទទួលបានពីនាយកដ្ឋានដឹកជញ្ជូនជើងគោក និងនគរបាល (ផ្នែកចរាចរ)

២.៣ គ្រប់បដាទាំងអស់ត្រូវរើចេញឲ្យកាន់តែឆាប់កាន់តែប្រសើរ ទោះជាក្នុងករណីណាក៏ដោយគឺមិនឲ្យលើសពីរយៈពេល១៤ថ្ងៃ បន្ទាប់ពីការបោះឆ្នោត ឬការធ្វើប្រជាមតិ ។

### ៣.០ ការប្រើថ្នាំលាប

៣.១ មានការហាមឃាត់ទាំងស្រុងលើការប្រើប្រាស់ថ្នាំលាប (ថ្នាំកំប៉ុងរាវ ឬថ្នាំកំប៉ុងបាញ់) ដើម្បីសរសេរ គូសចំណាំ ឬលាបគូរពាក្យស្លោកនៅតាមថ្នល់ ចិញ្ចើមថ្នល់ តាមបន្ទប់ទូរស័ព្ទ ឬអគ្គិសនី ជញ្ជាំង ឬរបង ។ល។ ទោះជាការធ្វើបែបនេះប្រើទៅលើទ្រព្យសម្បត្តិឯកជន ឬសាធារណៈក៏ដោយ ។

ការប្រព្រឹត្តិបែបនេះ គឺជាការល្មើសដែលត្រូវដាក់ទណ្ឌកម្ម ក្រោមផ្នែក១៨៣ (j) នៃក្រមព្រហ្មទណ្ឌ Cap 73 ។

### ៤.០ ប័ណ្ណប្រកាសបោះឆ្នោត ឬការធ្វើប្រជាមតិ

៤.១ ប័ណ្ណប្រកាសបោះឆ្នោត ឬការធ្វើប្រជាមតិ ត្រូវបិទនៅលើក្ដារពត៌មានពិសេសដែលលើកតាំងឡើងសម្រាប់គោលបំណងបែបនេះ ហើយដែលមានចែងនៅក្នុងកថាខណ្ឌទី១ ។

៤.២ គ្មានប័ណ្ណប្រកាស ឬក្រដាសនានាដទៃទៀត ត្រូវគេបិទលើជញ្ជាំង អាគារ ផ្លូវថ្នល់ ចិញ្ចើមថ្នល់ សរសរទូរស័ព្ទ ឬអគ្គិសនី ឬរបង ដែលទោះជាសម្បត្តិទ្រព្យឯកជន ឬសាធារណៈ ក៏ដោយ ។

ទង្វើបែបនេះ គឺជាបទល្មើសដែលអាចទទួលទណ្ឌកម្មនៅក្រោមផ្នែក១៨៣ (j) នៃក្រមព្រហ្មទណ្ឌ Cap 73 ។

### ៥.០ ការគោរពអ្នកដទៃ និងទ្រព្យសម្បត្តិរបស់គេ

៥.១ អ្នកគាំទ្រ និងសមាជិកគណបក្សនយោបាយ ត្រូវគោរពអ្នកដទៃ និងទ្រព្យសម្បត្តិរបស់គេ ហើយមិនត្រូវបង្កឲ្យមានការខូចខាតដល់ទ្រព្យសម្បត្តិឯកជន ឬសាធារណៈឡើយ ។

=====================================

# ប្រទេសហ្គាណា

(GHANA)

ក្រមសីលធម៌

នេះជាក្រមសីលធម៌សម្រាប់គណបក្សនយោបាយនៅប្រទេសហ្គាណា សម្រាប់ការបោះឆ្នោតសាធារណៈ ។ គណបក្សនយោបាយនៃប្រទេសហ្គាណា ដែលចុះឈ្មោះរួចហើយបានយល់

ដឹងពីសេចក្ដីត្រូវការឲ្យមានក្រមសីលធម៌មួយសម្រាប់សកម្មភាពរបស់ខ្លួន ក្នុងអំឡុងពេលមានការបោះឆ្នោតជាសាធារណៈ ។ តាមរយៈនេះទើបគណបក្សទាំងអស់បានស្ថាបនានូវក្រមសីលធម៌នេះ ហើយដែលត្រូវប្រកាន់ខ្ជាប់ខ្ជួន ដោយគណបក្សនយោបាយទាំងអស់ :

១. គណបក្សនយោបាយទាំងអស់ត្រូវអនុវត្តទៅតាមច្បាប់ និងវិធាននានានៃការបោះឆ្នោតដែលកំពុងតែមានអត្ថិភាព ។

២. គណបក្សនយោបាយ និងគូប្រជែងទាំងអស់ត្រូវបញ្ចេញនូវកិច្ចសហប្រតិបត្តិ និងការជួយជាចាំបាច់ដល់អាជ្ញាធរប្រតិបត្តិច្បាប់ ។

៣. ជនគ្រប់រូបមិនត្រឹមតែដឹងពីសិទ្ធិរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវគោរពនូវសិទ្ធិរបស់អ្នកដទៃទៀតផង ។

៤. បេក្ខជន និងគណបក្សនយោបាយទាំងអស់ដែលចូលរួមក្នុងការបោះឆ្នោត ត្រូវសហប្រតិបត្តិការដ៏ពេញលេញជាមួយមន្ត្រីរៀបចំការបោះឆ្នោត ហើយត្រូវធានានូវសុវត្ថិភាព និងសន្តិសុខរបស់ពួកគេ មុនពេល ក្នុងអំឡុងពេល និងបន្ទាប់ពីការបោះឆ្នោត ។

៥. យុទ្ធនាការបោះឆ្នោតត្រូវតែរៀបចំឲ្យបានល្អ ដោយធានាថាបរិយាកាសស្ងប់ស្ងាត់ និងភាតរភាព នឹងកើតមានឡើងក្នុងអំឡុងពេលបោះឆ្នោត ។

៦. គណបក្សនយោបាយមិនត្រូវធ្វើឲ្យផុះផាលនូវគំនិតយោបល់ ឬសកម្មភាពដែលទោះជាក្នុងទម្រង់ណាក៏ដោយ ដែលមានលក្ខណៈធ្វើឲ្យខូចប្រយោជន៍ដល់អធិបតេយ្យភាពបូរណភាព ឬសន្តិសុខរបស់ប្រទេសហ្កាណា ឬដល់ការថែរក្សាសណ្ដាប់ធ្នាប់សាធារណៈ ឬដល់អធិបតេយ្យភាព ឬឯករាជភាពរបស់អង្គតុលាការរបស់ប្រទេសហ្កាណា ឬក៏ធ្វើដោយបំពាន ឬនាំឲ្យមានការចំអកដល់អង្គតុលាការ ឬកងប្រដាប់អាវុធរបស់ប្រទេសហ្កាណា ឬក៏មានលក្ខណៈអសីលធម៌នោះទេ ។

៧. គណបក្សនយោបាយ បេក្ខជន ភ្នាក់ងារ ឬបេក្ខជនរបស់គណបក្សខ្លួន មិនត្រូវរារាំង ឬបំបែកការប្រជុំរៀបចំដោយបេក្ខជន និងគណបក្សប្រឆាំងនានា ឬក៏រំខានដល់បឋកថា ឬទប់ស្កាត់មិនឲ្យមានការចែកចាយនូវលិខិតដំណឹង ខិតប័ណ្ណ ហើយនិងការបិទនូវប័ណ្ណប្រកាសរបស់គណបក្សដទៃទៀតឡើយ ។

៨. គណបក្សនយោបាយត្រូវជៀសវាងនូវការរិះគន់ដល់គណបក្សនយោបាយដទៃទៀត ព្រមទាំងបេក្ខជន និងមេដឹកនាំរបស់គេទៅលើបញ្ហា ដែលគ្មានពាក់ព័ន្ធទៅនឹងសកម្មភាពរបស់គេ ។ ការរិះគន់ និងសេចក្ដីសង្កេតត្រូវតែពាក់ព័ន្ធនិងនយោបាយ និងកម្មវិធីរបស់

គណបក្សតែប៉ុណ្ណោះ ។ បឋកថា និងពាក្យស្លោកត្រូវតែថ្លៃថ្នូរ ហើយឈរលើគោល-ការណ៍នៃសីលធម៌ សុភាវធម៌ ហើយនិងភាតរៈ ។

៩. គណបក្សនយោបាយ ត្រូវបញ្ចៀសនូវបឋកថាណាដែលបង្កឲ្យមានបរិយាកាសអាប់អួរ ហើយនិងវាទប្បដិវាទ ឬជម្លោះរវាងនិកាយសាសនា សហគមន៍ ហើយនិងក្រុមជាតិ-ពន្ធុ។

១០. មេដឹកនាំផ្នែកសាធារណៈ ហើយនិងអ្នករួមចំណែកដទៃទៀតទាំងអស់ក្នុងសកម្មភាពនយោបាយ ត្រូវប្រព្រឹត្តសកម្មភាពក្នុងលក្ខណៈទទួលខុសត្រូវ ហើយនិងថ្លៃថ្នូរ ដែលអាចជួយជាប្រយោជន៍ដល់ឋានៈរបស់ខ្លួន ។ ក្នុងពេលដែលផ្សព្វផ្សាយនូវទស្សនៈ និងកម្មវិធីរបស់ខ្លួន ។ គេមិនត្រូវជ្រៀតជ្រែកទៅក្នុងសេរីភាពរបស់អ្នកដទៃ ដែលកំពុងផ្សព្វផ្សាយសកម្មភាពដូចគ្នា ពីព្រោះការធ្វើបែបនេះ គឺជាអវិជ្ជមានកម្មនៃលទ្ធិប្រជាធិបតេយ្យ។

១១. ការយកកំហឹងទល់នឹងកំហល់ពេលកំពុងមានការប្រជុំ ការដើរជាក្បួន ឬក្នុងខណៈពេលកំពុងតែមានការបោះឆ្នោត ត្រូវតែបញ្ចៀសជាដាច់ខាត ។

១២. ការកាន់អាវុធគ្រោះថ្នាក់ និងអាវុធដែលអាចបណ្តាលឲ្យស្លាប់ មិនត្រូវអនុញ្ញាតឲ្យមាន នៅក្នុងការប្រជុំជាសាធារណៈឡើយ ហើយបទបញ្ញាជាផ្លូវការលើបញ្ហានេះត្រូវតែគោរពប្រតិបត្តិឲ្យបានម៉តច្បត់ជាទីបំផុត ។ ការប្រើប្រាស់នូវជាវ និងគ្រឿងផ្ទុះដទៃទៀតនៅក្នុងការប្រជុំជាសាធារណៈ មិនត្រូវអនុញ្ញាតឲ្យមានឡើយ ។

១៣. គណបក្សនយោបាយ និងបេក្ខជនរបស់ខ្លួនត្រូវផ្តល់នូវកិច្ចសហប្រតិបត្តិការដល់មន្ត្រីរៀបចំការបោះឆ្នោតដើម្បីធានានូវការបោះឆ្នោតដោយសន្តិវិធី និងដោយរៀបរយ ហើយនិងដើម្បីធានាដល់សេរីភាពដ៏ពេញលេញដល់អ្នកបោះឆ្នោត ដើម្បីអនុវត្តសិទ្ធិបោះឆ្នោតរបស់ខ្លួនដោយគ្មានការរំខាន ឬរារាំងអ្វីទាំងអស់ ។

១៤. គណបក្សនយោបាយ និងបេក្ខជនរបស់ខ្លួនត្រូវជៀសវាងជាដាច់ខាត នូវសកម្មភាពទាំងអស់ដែលសន្មតជា " ទង្វើពុករលួយ " ហើយនិងបទល្មើសនានាដែលមាននៅក្នុងច្បាប់បោះឆ្នោត ។ ទង្វើនិងបទល្មើសទាំងអស់នោះ មានដូចជា សូកប៉ាន់អ្នកបោះឆ្នោត ការបំភិតបំភ័យអ្នកបោះឆ្នោត ការក្លែងបន្លំធ្វើជាអ្នកបោះឆ្នោត ហើយនិងការស្ទង់មើលមតិក្នុងចំងាយ៥០០ម៉ែត្រចាប់ពីស្ថានីយ៍បោះឆ្នោតទៅ ។

១៥. គណបក្សនយោបាយ បេក្ខជន ភ្នាក់ងារ ឬបុគ្គលិករបស់ខ្លួន មិនត្រូវប្រព្រឹត្តនូវការផ្តល់អំណោយ ឬរង្វាន់ពេញចិត្ត ឬក៏អន្ទោកអន្ទោងឲ្យជនណាឈរ ឬមិនឈរឈ្មោះជាបេក្ខជន ឬក៏ឲ្យដក ឬមិនដកខ្លួនចេញពីបេក្ខភាពរបស់គេឡើយ ។

១៦. គណបក្សនយោបាយ និងបេក្ខជនរបស់ខ្លួនមិនត្រូវធ្វើឲ្យការឧបត្ថម្ភគាំទ្រ ឬការជួយរបស់បុគ្គលិកនៃគណៈកម្មការរៀបចំការបោះឆ្នោតជួយជំរុញ ឬរាំងស្ទះនូវការបោះឆ្នោតដល់បេក្ខជនណាមួយឡើយ ។

១៧. គណបក្សនយោបាយ និងបេក្ខជនរបស់ខ្លួន មិនត្រូវញុះញង់ ឬលក្ខណៈឲ្យអ្នកគាំទ្រមានសមានចិត្តបំផ្លាញសន្លឹកឆ្នោត ឬបំផ្លាញគំនូសជាផ្លូវការដែលមាននៅលើសន្លឹកឆ្នោតឡើយ ។

១៨. ថ្វីបើមានចំណុចដូចខាងលើក្តី គណបក្សនយោបាយទាំងអស់ត្រូវតែបញ្ចេញយោបល់ដោយឥតសំចៃប្រឆាំងនឹងអំពើហិង្សា ។ គ្មានគណបក្សណាត្រូវបើកដៃឲ្យមានសកម្មភាពហិង្សា ដើម្បីចង្អុលបង្ហាញនូវភាពខ្លាំង ឬដើម្បីបង្អួតឧត្តមភាពនោះឡើយ ។ គ្រប់គណបក្សនយោបាយទាំងអស់ ត្រូវផ្តល់កិច្ចសហប្រតិបត្តិការដល់ទីភ្នាក់ងារប្រតិបត្តិច្បាប់ក្នុងការប្រមូលមកវិញនូវអាវុធខុសច្បាប់ ។ គ្មានគណបក្សណាត្រូវផ្តួចផ្តើមឲ្យមានការដោះលែងនូវជនដែលឃាត់ខ្លួនដោយនគរបាល ពីបទមានអាវុធក្នុងពេលធ្វើយុទ្ធនាការបោះឆ្នោត ឬនៅក្នុងមជ្ឈមណ្ឌលបោះឆ្នោត ពេលកំពុងតែមានការបោះឆ្នោត ឬនៅទីជិតខាងនៃមជ្ឈមណ្ឌលបោះឆ្នោត ក្នុងពេលកំពុងតែមានការបោះឆ្នោតទេ ។

១៩. ការឧបត្ថម្ភគាំទ្ររបស់ទីភ្នាក់ងារប្រតិបត្តិច្បាប់ដ៏ជិតបំផុត ពោលគឺនគរបាល កងកម្លាំងប្រដាប់អាវុធហត្ថាណា ក្រុមពន្លត់ភ្លើង ហើយនិងសេវាកម្មពន្ធនាគារត្រូវតែយកមកប្រើប្រាស់ដើម្បីទប់ទល់ និងទប់ស្កាត់នូវបទល្មើសដែលមានទៅលើការបោះឆ្នោត ។

២០. គណបក្សនយោបាយត្រូវតែចាប់យកការយល់ដឹងមួយ ដែលត្រូវតែទប់ទល់ការប៉ុនប៉ងនានា ក្នុងការទាញយកសន្លឹកឆ្នោតដោយសារតែឥទ្ធិពលការងាររបស់មជ្ឈមណ្ឌលបោះឆ្នោត ឬសកម្មភាពខុសច្បាប់ក្នុងមជ្ឈមណ្ឌលបោះឆ្នោត ដែលធ្វើឡើងដោយជនណាមួយនោះ ។ ហេតុដូច្នេះ សន្លឹកឆ្នោតដែលទទួលបានដោយខុសច្បាប់ នឹងពុំមានប្រសិទ្ធភាពយកជាការបានឡើយ ពីព្រោះគណៈកម្មការបោះឆ្នោតនឹងត្រូវលប់ចោលការបោះឆ្នោតនៅក្នុងមជ្ឈមណ្ឌលនោះ ។

២១. បរិយាកាសដោយសន្តិភាព និងភាតរភាព សម្រាប់ការបោះឆ្នោតមិនត្រូវរំខានដោយពាក្យចចាមអារ៉ាម ដែលសាយភាយមិនពិត ឬបណ្តាលឲ្យមានឧបាស្រ័យឆ្ពោះទៅរកការរួមគំនិតធ្វើអំពើទុច្ចរិតឡើយ ។

២២. នៅពេលប្រកាសអំពីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ធ្វើឡើងដោយគណៈកម្មការ ដើម្បីបំពេញចិត្តរបស់មតិភាគច្រើននៃគណបក្សនយោបាយ បុគ្គលដែលគេអញ្ជើញឲ្យចូលរួម និងអ្នកសង្កេតការណ៍ដែលគេទទួលស្គាល់នោះ បេក្ខជនចាញ់ឆ្នោតត្រូវសុខចិត្តចុះចាញ់ដោយកិត្តិយស ។

ដើម្បីធ្វើឲ្យក្រមសីលធម៌នេះមានការគោរពជាអតិបរមាដោយភ្នាក់ងារ និងអ្នកគាំទ្ររបស់គណបក្សនយោបាយនានានោះ ក្រមនេះត្រូវតែយល់ព្រមអនុវត្តដោយបេក្ខជនប្រធានាធិបតីគ្រប់រូប ហើយនិងប្រធានគណបក្សនយោបាយទាំងអស់ ។

ដើម្បីសម្រេចបញ្ហានេះ ក្រមនេះត្រូវចាប់ប្រតិបត្តិដោយគណៈកម្មការរៀបចំការបោះឆ្នោត ព្រមទាំងជាមួយបេក្ខជនប្រធានាធិបតីទាំងអស់ ដែលចូលរួមប្រកួតនៅក្នុងការបោះឆ្នោតឆ្នាំ១៩៩២ ហើយនិងព្រមទាំងជាមួយប្រធានគណបក្សនយោបាយ ។

ធ្វើនៅ Accra ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩២

==========================================

# ប្រទេសបង់ក្លាដែស

(BANGLADESH)

ការបោះឆ្នោតសភា (Jatiya Sangsad) ឆ្នាំ ១៩៩១

ក្រមសីលធម៌ដែលត្រូវប្រកាន់យ៉ាងខ្ជាប់ខ្ជួនដោយគណបក្សនយោបាយ

ក្រមសីលធម៌ដែលត្រូវសរសេរបញ្ចប់ឡើង បន្ទាប់ពីមានការពិភាក្សាជាមួយអ្នកតំណាងនៃគណបក្សនយោបាយចំនួន៦៧ ដែលរួមទាំងគណបក្សធំៗផងដែរនោះ គឺដើម្បីសំដៅធានានូវបរិយាកាសសន្តិភាពក្នុងអំឡុងពេលធ្វើយុទ្ធនាការបោះឆ្នោត ហើយនិងនៅថ្ងៃបោះឆ្នោត ។ គណៈកម្មការរៀបចំការបោះឆ្នោតសង្ឃឹមថា ប្រសិនបើគណបក្សនយោបាយទាំងអស់អនុវត្តតាមក្រមនេះដោយស្មោះស្ម័គ្រនោះ ពួកគេនឹងរួមវិភាគទានដល់ការរៀបចំការបោះឆ្នោតដ៏ប្រសើរមួយនៅក្នុងប្រ

ទោសរបស់ខ្លួន ។ ភាពត្រឹមត្រូវស្របច្បាប់នៃរដ្ឋាភិបាលតំណាងដែលជាប់ឆ្នោតតាមរយៈការបោះឆ្នោតបែបនេះ នឹងមិនពាក់ព័ន្ធនូវភាពមន្ទិលសង្ស័យណាមួយឡើយ ។

ក្រមសីលធម៌

១. វិធាននិងច្បាប់បោះឆ្នោតដែលកំពុងមានអត្ថិភាព គេត្រូវតែប្រកាន់ឲ្យខ្ជាប់ខ្ជួន ។

២. អ្នកប្រកួតប្រជែង និងគណបក្សនយោបាយទាំងអស់ត្រូវតែផ្តល់នូវកិច្ចសហប្រតិបត្តិការ និងការជួយនានាដ៏ចាំបាច់ដល់អាជ្ញាធរប្រតិបត្តិច្បាប់ ។

៣. ជនគ្រប់រូបត្រូវតែយល់ដឹងមិនត្រឹមតែសិទ្ធិរបស់ខ្លួនផ្ទាល់ប៉ុណ្ណោះទេ ថែមទាំងត្រូវគោរពសិទ្ធិរបស់អ្នកដទៃទៀតផងដែរ ។

៤. បេក្ខជន និងគណបក្សនយោបាយទាំងអស់ដែលចូលរួមនៅក្នុងការបោះឆ្នោត ត្រូវផ្តល់នូវកិច្ចសហប្រតិបត្តិការដល់មន្ត្រីរៀបចំការបោះឆ្នោត ហើយត្រូវធានានូវសន្តិសុខ និងសុវត្ថិភាពរបស់ពួកគេ រហូតដល់ការបោះឆ្នោតត្រូវបញ្ចប់សព្វគ្រប់ ។

៥. យុទ្ធនាការបោះឆ្នោតត្រូវតែរៀបចំឲ្យបានល្អ ដោយធានាថាបរិយាកាសសន្តិភាព និងភាតរភាព នឹងកើតឡើងក្នុងអំឡុងពេលបោះឆ្នោត ។

៦. គេមិនត្រូវធ្វើនូវអ្វីៗដែលនឹងបង្កឲ្យមានភាពតានតឹង ហើយនិងរំខានដល់បរិយាកាសភាតរភាពនៃការបោះឆ្នោតទេ ។ គណបក្សទាំងអស់ត្រូវតែជៀសវាងសុន្ទរកថាជាអសុរោះ ហើយត្រូវបង្ហាញការគោរពមតិយោបល់របស់អ្នកដទៃ។ ធ្វើដូច្នេះគឺដើម្បីឲ្យដំណើរការបោះឆ្នោតមិនប្រែក្លាយទៅជាសង្គ្រាមពាក្យសំដីឡើយ ។

៧. គេសង្ឃឹមថាពាក្យទិតៀនរបស់គូបដិបក្ខ ពិតជានឹងកើតមានឡើងក្នុងដំណើរការបោះឆ្នោត ។ ក៏ប៉ុន្តែសុន្ទរកថា ឬសេចក្តីថ្លែងការណ៍អុចអាល និងញុះញង់ ការឡកឡឺយ និងការចំអកឲ្យត្រូវតែជៀសវាង ។ គណបក្សត្រូវប្រុងប្រយ័ត្នកុំឲ្យសេចក្តីថ្លែងការណ៍ ឬសេចក្តីអង្កេតបង្កភាពតានតឹងមិនចាំបាច់ ។ ក្នុងករណីដែលស្ថានភាពអាចឲ្យមានការប៉ះទង្គិចកើតឡើង ដោយសារតែការយល់ច្រឡំរវាងគណបក្សប្រកួតប្រជែងនោះ គណៈកម្មាធិការសម្របសម្រួលការបោះឆ្នោត ដែលរួមមានអ្នកតំណាងមកពីភាគីពាក់ព័ន្ធត្រូវតែធ្វើឲ្យធូរស្បើយនូវភាពតានតឹង ហើយនិងត្រូវដោះស្រាយនូវជម្លោះនោះ ។

៨. គណបក្សនយោបាយទាំងអស់ត្រូវបញ្ចេញសំដីដ៏ឥតសំចៃប្រឆាំងនឹងអំពើហិង្សា ។ គ្មានគណបក្សណាមួយត្រូវបណ្តោយខ្លួនឲ្យធ្លាក់ទៅក្នុងទម្រង់ណាមួយ នៃសកម្មភាពហិង្សា

ហើយអំពើហិង្សាដើម្បីចង្អុលបង្ហាញនូវភាពខ្លាំងរបស់គណបក្សខ្លួន ឬដើម្បីបង្អួតបរមានុភាពនោះឡើយ ។ គណបក្សនយោបាយទាំងអស់ត្រូវផ្តល់កិច្ចសហប្រតិបត្តិការចំពោះភ្នាក់ងារប្រតិបត្តិច្បាប់ ក្នុងការប្រមូលយកអាវុធខុសច្បាប់ ។ គ្មានគណបក្សណាមួយត្រូវបង្កើតការផ្តួចផ្តើមក្នុងការដោះលែងជនដែលឃាត់ខ្លួនដោយនគរបាល ពីបទមានអាវុធក្នុងពេលយុទ្ធនាការបោះឆ្នោត ឬនៅក្នុងមជ្ឈមណ្ឌលបោះឆ្នោត ក្នុងអំឡុងពេលបោះឆ្នោត ឬនៅក្បែរស្ថានីយបោះឆ្នោតពេលកំពុងមានការបោះឆ្នោត ។

៩. គណបក្ស និងបេក្ខជនទាំងអស់ត្រូវមានឱកាសស្មើគ្នា សម្រាប់ការផ្សព្វផ្សាយ ។ ការប្រជុំការដើរជាក្បួន ហើយនិងសកម្មភាពយុទ្ធនាការបោះឆ្នោតដទៃទៀតរបស់គូបដិបក្ខ មិនអាចត្រូវគេជ្រៀតជ្រែកបានឡើយ ។

១០. ទីភ្នាក់ងារប្រតិបត្តិច្បាប់ត្រូវផ្តល់ការជួយឧបត្ថម្ភដើម្បីទប់ទល់ និងអង្កេតពិនិត្យនូវការបំពានដល់ការបោះឆ្នោតដោយប្រការណាមួយនោះ ។

១១. ការប៉ុនប៉ងទាំងពួងដើម្បីជះឥទ្ធិពលដល់ការបោះឆ្នោតដោយប្រើលុយកាក់ ឬការលួងចិត្ត ហើយនិងជួល ឬប្រើប្រាស់យានយន្តណាមួយ ដើម្បីដឹកអ្នកបោះឆ្នោត ក្រៅពីដឹកខ្លួនឯង និងគ្រួសារ គឺជាបទល្មើសនៃការបោះឆ្នោត ។ ជនគ្រប់រូបត្រូវតែយល់ដឹងពីបទល្មើសទាំងអស់នេះ ។

១២. គណបក្សនយោបាយត្រូវតែឈានដល់ការចាប់យកនូវការយល់ដឹងមួយ ដែលត្រូវតែទប់ទល់ការប៉ុនប៉ងនានា ក្នុងការទាញយកសន្លឹកឆ្នោតដោយសារតែឥទ្ធិពលការងារ របស់មជ្ឈមណ្ឌលបោះឆ្នោត ឬសកម្មភាពខុសច្បាប់ក្នុងមជ្ឈមណ្ឌលបោះឆ្នោត ដែលធ្វើឡើងដោយជនណាមួយនោះ ។ ហេតុដូច្នេះ សន្លឹកឆ្នោតដែលទទួលបានដោយខុសច្បាប់នឹងពុំមានប្រសិទ្ធភាពយកជាការបានឡើយ ពីព្រោះគណៈកម្មការបោះឆ្នោតនឹងត្រូវលុបចោលការបោះឆ្នោតនៅក្នុងមជ្ឈមណ្ឌលនោះ ។

១៣. គ្មានបេក្ខជនណាអាចផ្តល់ជាវិភាគទាន ឬមូលនិធិណាមួយដោយលក្ខការណ៍ឬដោយចំហដល់ស្ថាប័នណាមួយនៅក្នុងមណ្ឌលបោះឆ្នោតរបស់ខ្លួន រហូតដល់កាលបរិច្ឆេទនៃការបោះឆ្នោត ក្នុងគោលបំណងសម្រាប់ការធ្វើយុទ្ធនាការបោះឆ្នោត ហើយនិងដើម្បីទទួលសន្លឹកឆ្នោតនោះឡើយ ។

១៤. បរិយាកាសដោយសន្តិភាព និងភាតរភាព សម្រាប់ការបោះឆ្នោតមិនអាចត្រូវរំខានដោយពាក្យចរាមអារ៉ាម ដែលសាយភាយមិនពិត ឬបណ្តាលឲ្យមានឧបាស្រ័យឆ្ពោះទៅរកការរួមគំនិតធ្វើអំពើទុច្ចរិតទេ ។

១៥. ជំរុំបោះឆ្នោតមិនអាចត្រូវគេបោះនៅក្នុងតំបន់ហាមឃាត់ឬជិតទៅនឹងមជ្ឈមណ្ឌលបោះឆ្នោតឡើយ ហើយគេមិនអនុញ្ញាតឲ្យមានការធ្វើយុទ្ធនាការឃោសនាបោះឆ្នោតនៅក្នុងមជ្ឈមណ្ឌលបោះឆ្នោតបានឡើយ ។

១៦. បន្ថែមទៅនឹងមន្ត្រីរៀបចំការបោះឆ្នោត មានតែអ្នកបោះឆ្នោតដែលមានសិទ្ធិចូលទៅក្នុងមជ្ឈមណ្ឌលបោះឆ្នោត : គណបក្សនយោបាយត្រូវធានាថា បុគ្គលិករបស់ខ្លួនមិនចូលទៅក្នុងមជ្ឈមណ្ឌលបោះឆ្នោត ហើយដើរត្រេងត្រាងនៅក្នុងទីនោះឡើយ ។ មានតែភ្នាក់ងាររៀបចំការបោះឆ្នោត ដែលត្រូវស្ថិតនៅជានិច្ចនៅនឹងកន្លែងដែលគេកំណត់ឲ្យអង្គុយនៅក្នុងមជ្ឈមណ្ឌលបោះឆ្នោត ហើយត្រូវបំពេញភារកិច្ចរបស់ខ្លួននៅពីទីកន្លែងដែលខ្លួនអង្គុយនោះ ។

# ការយល់ដឹងអំពីយេនឌ័រ
# GENDER

## សេចក្តីផ្តើម

គោលបំណងនៃការសិក្សា GENDER

១. ដើម្បីជួយពង្រីកការយល់ដឹងពីតម្លៃនិងអត្តសញ្ញាណរបស់ខ្លួន

២. ដើម្បីបណ្តុះភាពយល់ដឹងនូវរបៀបកំណត់តួនាទីរបស់បុរសនិងស្ត្រីក្នុងសង្គម ដោយស្គាល់ពីអ្វីដែលអាចមានការផ្លាស់ប្តូរ និងប្រែប្រួល ។

៣. ដើម្បីបង្កើតឲ្យមានសមត្ថភាពក្នុងការចោទសួរ និងភាពស្ទាត់ជំនាញក្នុងការគិតគូរ ។

ប្រវត្តិខ្លះៗទាក់ទងនឹង WID & GAD

អង្គការសហប្រជាជាតិបានដំណើរការនៅឆ្នាំ ១៩៥៤ ប៉ុន្តែទិវានារីអន្តរជាតិ៨មីនា ដែលជាលទ្ធផលនៃការតស៊ូរើបំរះរបស់ស្ត្រីដើម្បីទាមទារសិទ្ធិសេរីភាពក្នុងការងារ និងការទទួលកំរៃឲ្យបានស្មើភាពជាមួយបុរស បានចាប់ផ្តើមតាំងពីថ្ងៃទី៨ ខែមីនា ឆ្នាំ១៩១១ មកម្ល៉េះ ។

មុនឆ្នាំ ១៩៧០ : គេយល់ថាការអភិវឌ្ឍន៍មិនចាំបាច់មានស្ត្រីទេ

១៩៧០ : តួនាទីស្ត្រីក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច ត្រូវបានកែសម្រួល

១៩៧៣ : នៅវ៉ាស៊ីតោន គេបញ្ចូលស្ត្រីទៅក្នុងកិច្ចអភិវឌ្ឍន៍ ដែលហៅកាត់ថា WID

១៩៧៥ : សន្និសីទអន្តរជាតិបានកំណត់ឆ្នាំអន្តរជាតិរបស់ស្ត្រី និងទសវត្សស្ត្រី (នៅទីក្រុង Mexico) ដែលមានប្រធានបទបី គឺ អភិវឌ្ឍន៍ សមភាព សន្តិភាព

១៩៨០ : សន្និសីទពិភពលោករបស់ស្ត្រីសម្រាប់ពាក់កណ្តាលទសវត្សស្ត្រី នៅទីក្រុង Copenhagen ប្រទេស Danemark បានធ្វើការត្រួតពិនិត្យលើការអនុវត្តន៍ផែនការសកម្មភាព ដែលស្តីអំពីសមភាព សន្តិភាព និងអភិវឌ្ឍន៍

១៩៨៥ : សន្និសីទស្ត្រីចុងទសវត្សនៅ Nairobi ប្រទេសខេនយ៉ា

១៩៩៥ : សន្និសីទពិភពលោកលើកទី៤របស់ស្ត្រីនៅប៉េកាំងបានលើកឡើងពីកង្វល់ស្ត្រី១២ចំណុចនៅទូទាំងពិភពលោក គឺ :

ភាពក្រីក្រ - ការអប់រំ - សុខភាព - បរិស្ថាន - វិសមភាពយេនឌ័រ និងភាពរើសអើងប្រឆាំងនឹងស្ត្រី - សិទ្ធិស្ត្រី - ការផ្សព្វផ្សាយ - អំពើហិង្សាប្រឆាំងនឹងស្ត្រី - ផលវិបាកនៃជម្លោះអាវុធ - រចនាសម្ព័ន្ធសេដ្ឋកិច្ច និងនយោបាយ - វិសមភាពក្នុងការធ្វើសេចក្តីសម្រេច និងបញ្ហាកុមារី ។

នៅរវាង ៤ ឬ ៥ឆ្នាំចុងក្រោយនេះ គេបានគិតគូរឡើងវិញពីយេនឌ័រ និងការអភិវឌ្ឍន៍ដែលហៅកាត់ថា GAD សមស្របទៅនឹងការរីកចម្រើនផ្នែកសមត្ថភាពរបស់បុរស និងស្ត្រី និងជាការពិន័ត្យឡើងវិញពីទំនាក់ទំនង ដែលមិនអាចខ្វះបានរវាងបុរស និងស្ត្រី ដែលចាំបាច់ត្រូវតែពឹងពាក់អាស្រ័យគ្នា និងបំពេញការខ្វះខាតគ្នាទៅវិញទៅមក ព្រោះភេទទាំងពីរមានទស្សនៈបទពិសោធន៍ សេចក្តីត្រូវការ និងផលប្រយោជន៍ដោយឡែកពីគ្នា ។

## ហេតុដូចម្តេចក៏ចាំបាច់ត្រូវមានស្ត្រីចូលរួមក្នុងការអភិវឌ្ឍន៍ ?

ព្រោះ :

១. ទិសដៅនៃការអភិវឌ្ឍន៍ គឺលើកស្ទួយជីវភាព និងលប់បំបាត់ភាពក្រីក្រ ។ ស្ត្រីគឺជាក្រុមដែលក្រីក្រជាងគេ មានចំនួនច្រើនជាងគេ និងរងសម្ពាធសង្គមច្រើនជាងគេ ដូច្នេះចាំបាច់ត្រូវតែចាប់ផ្តើមពីស្ត្រី ។

២. ការងាររបស់ស្ត្រីពុំទាន់បានទទួលកំរៃ និងតម្លៃសមរម្យនៅឡើយ ។

៣. រចនាសម្ព័ន រដ្ឋបាលផ្នែកសេដ្ឋកិច្ច និងនយោបាយ ដាក់ស្ត្រីឲ្យស្ថិតក្នុងស្រទាប់ក្រោមដែលពុំមានតួនាទីជាអ្នកអាចសម្រេចបាន ។

៤. មតិយោបល់របស់ស្ត្រីមិនត្រូវបានគេរាប់បញ្ចូលជាអាទិភាព និងអាចបំភ្លេចចោល ។

៥. ទស្សនៈសង្គមនៅតែបន្តឲ្យតម្លៃទាបចំពោះស្ត្រីនៅឡើយ ។

៦. ស្ត្រីគឺជាដៃម្ខាងក្នុងចំណោមដៃទាំងពីរក្នុងការអភិវឌ្ឍន៍ បើស្ត្រីមិនបានចូលរួម មានន័យថា គេពុំទាន់បានប្រើប្រាស់នូវធនធានមនុស្សដែលមានទាំងអស់នៅឡើយទេ ។

**តួនាទីនៃយេនឌ័រ**

កែប្រែសង្គមដោយសន្តិវិធី

ជំរុញការអភិវឌ្ឍន៍ដោយស្មើភាព

សង្គមកសាងទស្សនៈបែងចែកចំពោះភេទ , តែសង្គមអាចកែប្រែបានដោយសារមនុស្ស

★ យេនឌ័រ គឺជាមូលដ្ឋានគ្រឹះ និងជាហេតុផលនៃសិទ្ធិមនុស្ស

# មេរៀនទី១

# ការយល់ដឹងអំពីខ្លួនឯង (៣០នាទី)

ការណែនាំបង្ហាញខ្លួន គឺជាវិធីមួយដែលនាំឲ្យស្គាល់ខ្លួនឯង និងបង្ហាញឲ្យគេស្គាល់ខ្លួនឲ្យបានច្បាស់ ។

សំណួរថា :

- តើខ្ញុំជាអ្នកណា ? មកពីណា ? កំពុងនៅទីណា ? នឹងទៅទីណាទៀត ?
- តើខ្ញុំកំពុងធ្វើអ្វី ? ត្រូវធ្វើអ្វី ? មានការទទួលខុសត្រូវត្រឹមណា ?
- តើក្នុងជីវិតនេះ ខ្ញុំពេញចិត្តអ្វីជាងគេ ? ស្អប់អ្វីជាងគេ ?
- ត្រូវការអ្វីជាងគេសម្រាប់ជីវិត ? តើអ្វីនោះមានហើយឬនៅ ? ..........។ល។
- បើមានឱកាសផ្លាស់ប្តូរ តើចង់ផ្លាស់ប្តូរអ្វី ?

ប្រៀបធៀប : ភាពស្រឡាញ់ ភាពស្អប់ តម្រូវការចាំបាច់របស់ក្រុមអាចឲ្យយើងឃើញពីភាពខុសគ្នា និងភាពស្រដៀងគ្នា ឬអាចនិយាយថា លក្ខណៈរួមនិងលក្ខណៈដោយឡែកនៃបុគ្គល ។

សន្និដ្ឋាន : ចម្លើយទាំងនេះអាចប្រែប្រួលកាលណាគេសួរទៅនរណាម្នាក់នៅក្នុងកាលៈទេសៈខុសៗគ្នា ។

៚

# មេរៀនទី២

## ការស្គាល់យេនឌ័រ (៣០នាទី)

រកពាក្យស្លោក ឬសុភាសិត ដែលទាក់ទងនឹងបុរស ឬស្ត្រី ដាក់ជាក្រុមហើយពិនិត្យម្តងមួយ យើងនឹងឃើញពីការឲ្យតម្លៃដល់ស្ត្រី និងបុរសរបស់សង្គម ដែលលំអៀងលើភេទមួយ ។

និយមន័យនៃភេទនិងយេនឌ័រ :

ធ្វើតារាងបញ្ជីរាយលក្ខណៈដែលគេអាចសំគាល់បានថាជាស្ត្រី ឬបុរស រួចហើយបែងចែកលក្ខណៈជីវសាស្ត្រដែលមិនអាចផ្លាស់ប្តូរបាន ដែលហៅថា **ភេទ** លក្ខណៈដែលអាចផ្លាស់ប្តូរតាមភេទ កាលៈទេសៈ ទីកន្លែង សម័យកាល សភាពការណ៍ ព្រឹត្តិការណ៍ វ័យ ប្រពៃណី សាសនា . . . នោះគេហៅថា**យេនឌ័រ** ។

| ស្រី | ប្រុស |
|---|---|
| រូបរាង : តូចទ្រនាប់ សាច់រលីង គ្មានសាច់ដុំ | មាំ ធំ មានពុកមាត់ ពុកចង្កា សាច់ដុំធំ |
| ចំណង់ចំណូលចិត្ត : ចូលចិត្តស្អាត ចូលចិត្តធ្វើការផ្ទះ | ចូលចិត្តមានមិត្តភក្តិ ស៊ីផឹកសប្បាយ |
| ការងារ : ការងារស្រាល កំប៉ិកកំប៉ុកក្បែរៗផ្ទះ | ការងារធ្ងន់ ផ្លូវឆ្ងាយ |
| ចរិត : ទន់ភ្លន់ | រឹងប៉ឹង |
| ........................................ | ........................................ |

ឧទាហរណ៍ : គេតែងសួរគ្នាថា កូនអ្នកប្រុស ឬស្រី ? ស្រីប៉ុន្មាន ប្រុសប៉ុន្មាន ? នៅក្រុមនោះមានប្រុសប៉ុន្មាននាក់ ? ស្រីប៉ុន្មាននក់ ? . . . ។ គេអាចឆ្លើយបានភ្លាម ព្រោះអ្វី ?
- ព្រោះគេសំគាល់បានថា ដូចម្តេចដែលហៅថា ភេទស្រី ភេទប្រុស (ឬខ្ទើយ : គ្មានភេទ) ។

នេះគឺផ្អែកទៅលើលក្ខណៈជីវសាស្ត្រ ដែលមិនអាចប្រែប្រួលបាន និងមានពីកំណើតជាធម្មជាតិ ។

- អ្វីដែលខុសគ្នាជាលក្ខណៈជីវសាស្ត្រ ហៅថា **ភេទ**
- អ្វីដែលប្រែប្រួល ផ្លាស់ប្តូរបានហៅថា **យេនឌ័រ**
- លក្ខណៈជីវសាស្ត្រខុសគ្នា មិនមានន័យថា មានតម្លៃខុសគ្នាឡើយ ។

**ឧទាហរណ៍ :** ភាពវៃឆ្លាត : ប្រុសជប៉ុន និងប្រុសអាហ្វ្រិក ដែលមានរូបរាងខុសគ្នា តែភាពវៃឆ្លាតដោយឡែកពីគ្នា ។

កំលាំង : ស្ត្រីចិន និងស្ត្រីអាមេរិកាំង នៅពេលប្រកួតកីឡាពិភពលោក ស្ត្រីចិនទទួលមេដាយច្រើនជាងស្ត្រីអាមេរិកាំង ។

ដូចគ្នាដែរចំពោះបុរស និងស្ត្រី ដែលមានលក្ខណៈជីវសាស្ត្រខុសគ្នា គឺគេមិនអាចវាយតម្លៃខុសគ្នាថាបុរសមានតម្លៃជាង ឬស្ត្រីមានតម្លៃជាងនោះឡើយ ។ ពោលគឺគ្រាន់តែភេទទាំងពីរមានលក្ខណៈ ឬតម្លៃដោយឡែកពីគ្នាតែប៉ុណ្ណោះ ។

តម្លៃរបស់ភេទទាំងពីរកើតចេញពីភាពវៃឆ្លាត និងភាពប៉ិនប្រសប់ដោយឡែកៗពីគ្នា ។

# មេរៀនទី៣

## ការបែងចែកការងារ (៣០នាទី)

+ បែងចែកជាក្រុម (បើមានពេលគ្រប់គ្រាន់) ឧទាហរណ៍ : ក្រុមស្ត្រី ក្រុមបុរស ឬក្រុមមេឃុំ ក្រុមកសិករ ក្រុមអ្នកធ្វើការរាជការ ក្រុមរកស៊ី . . . ។ល។

+ រួចហើយលើកឡើងពីការងារ ឬកម្មវិធីដែលជួបឧបសគ្គ ឬបញ្ហាចំពោះមុខ ដោយកត់ត្រាបញ្ហាទាំងនោះ រួចហើយត្រូវជ្រើសរើសយកអាទិភាពនៃបញ្ហាដោយផ្អែកទៅលើសេចក្តីត្រូវការចាំបាច់ និងផលប៉ះពាល់ (ប៉ះពាល់អ្នកណាខ្លះ ? ភាគច្រើនឬទេ ?) ។

<u>ឧទាហរណ៍១</u> : នៅក្នុងគ្រួសារក្រីក្រមួយ បញ្ហាចំពោះមុខគឺ ខ្វះមធ្យោបាយផលិតកម្ម - ខ្វះអង្ករដាំបាយ - កូនមិនបានទៅរៀន - ខ្វះសម្លៀកបំពាក់ល្អៗ . . . ។ នៅក្នុងចំណោមបញ្ហាទាំងនេះ តើបញ្ហាណាមួយជា**អាទិភាព** ។

+ នៅពេលដែលគេរកឃើញ**អាទិភាព**នៃបញ្ហាហើយ ទើបគេកំណត់យកដំណោះស្រាយតាមលំដាប់លំដោយ ដោយបែងចែកការងារ : តើអ្នកណាអាចធ្វើអ្វីបានខ្លះ ?

<u>ឧទាហរណ៍២</u> : ដើរតួជាប្តី និងជាប្រពន្ធ រៀបរាប់ពីសកម្មភាពប្រចាំថ្ងៃរបស់គ្រួសារកសិករ ឬគ្រួសារអ្នកធ្វើការរាជការ ឬអ្នករកស៊ី . . . អាចបន្ថែមករណីដែលភរិយាមានផ្ទៃពោះ ឬកូនតូចៗច្រើន ឬជាស្ត្រីមេម៉ាយ . . . ហើយធ្វើការវិភាគលើការងាររបស់បុរស និងស្ត្រីលើការងារផលិត និងការងារក្នុងគ្រួសារ ។

+ រួចហើយវិភាគមើលថា តើស្ត្រីនិងបុរស អ្នកណាធ្វើការច្រើនជាង ? (ជាទូទៅ)

**វិភាគលើការបែងចែកការងារទៅតាមភេទ ឬយេនឌ័រ :**

សង្គមតែងកំណត់តួនាទី ការទទួលខុសត្រូវ និងសកម្មភាពឲ្យបុរស និងស្ត្រីខុសៗគ្នា ដោយផ្អែកលើទស្សនៈ" **សម ឬមិនសម** " ។

ការបែងចែកពលកម្ម ឬឋានន្តរសក្តិ ដោយសំអាងលើទស្សនៈជាប្រពៃណី ពុំត្រឹមត្រូវទេ ព្រោះវាមិនមែនជាច្បាប់ធម្មជាតិ គ្មានលក្ខណៈសកល វាតែងប្រែប្រួល ទៅតាមទីកន្លែង ស្ថានភាពជីវភាព កម្រិតសមត្ថភាព . . . ។ល។

+ ការបែងចែកពលកម្ម ឬឋានន្តរសក្តិ ភាគច្រើនស្តែងចេញពីទស្សនៈ**ភេទនិយម**របស់ក្រុមអ្នកមានអំណាចដែលបង្កប់នូវភាពលំអៀង ឬការរើសអើង ។

+ នេះមិនមែនជាក្រឹត្យក្រមធម្មជាតិទេ តែគឺជាក្រឹត្យក្រមដែលបង្កើតឡើងដោយមនុស្សក្នុងសង្គម ដើម្បីបម្រើផលប្រយោជន៍របស់ក្រុមណាមួយ ដូច្នេះវាក៏អាចប្រែប្រួលបានដោយក្រុមមនុស្សដែរ ។

+ បើពិនិត្យលើរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល សេដ្ឋកិច្ច នយោបាយ ស្ត្រីតែងស្ថិតនៅស្រទាប់ក្រោមជានិច្ចគ្រប់ជំនាន់ ធ្វើឲ្យទស្សនៈសង្គមបាក់ផ្គត់ក្នុងការវាយតម្លៃទាបទៅលើស្ត្រី ហើយតែងតែសន្និដ្ឋានដោយស្វ័យប្រវត្តិថា ស្ត្រីមិនអាចកាន់តួនាទីសំខាន់ៗបាន ។

+ បើគ្មានស្ត្រីក្នុងតួនាទីសំខាន់ទេ ហើយស្ត្រីពុំបានចូលរួមធ្វើសេចក្ដីសម្រេចទេនោះ នោះសមត្ថភាព សេចក្ដីត្រូវការ ឬផលប្រយោជន៍ស្ត្រីត្រូវបានគេបំភ្លេចចោល ។

+ បើគ្មានស្ត្រីចូលរួមក្នុងការធ្វើសេចក្ដីសម្រេចទេ មិនខុសពីការចូលរួមបរិភោគអាហារក្នុងចានរបស់កញ្ច្រោង និងក្រសារឡើយ ។

+ ការបំភ្លេចពីសមត្ថភាព សេចក្ដីត្រូវការ និងផលប្រយោជន៍ស្ត្រីមិនខុសពីគេចងបិទមាត់ (ព្រោះពុំចេះតវ៉ា) ចងជើង (ព្រោះមិនត្រូវទៅណាចោលផ្ទះ) ចងបិទភ្នែក (ព្រោះមិនចង់ឲ្យ មើលវែងឆ្ងាយ) បិទត្រចៀក (ព្រោះមិនចង់ឲ្យដឹងឮពីអ្វី) . . . ។ល។ តែការពិតគេមិនយល់ពីស្ត្រីឡើយ ។

<u>ឧទាហរណ៍៣</u> : នៅពេលដែលស្ត្រីជាប់ចំណងហើយ គេយកផ្លែឈើមកហុចឲ្យ គេពិគ្រោះការងារជាមួយនាង - គេនិយាយជជែកកំសាន្ត . . . តែនាងពុំបានចូលរួមឡើយ ។

+ តើចំណងជាអ្វី ? តើស្ត្រីពិតជាមិនចង់និយាយ មិនចង់ដឹង មិនចង់ឮ មិនចង់ដើររកការងារក្រៅផ្ទះមែនឬ ?

+ ការចងមាត់ រួចយកចំណីមកហុច ហើយថានាងមិនចេះញ៉ាំទេ តើត្រឹមត្រូវដែរឬទេ ?

+ ភាពអន្ទះសារក្នុងចិត្តកាន់តែពុះពារឡើង ធ្វើឲ្យនាងខំរើបំរះ និងស្រាយចំណងម្ដងមួយៗ រួចហើយនាងអាចធ្វើអ្វីៗបានតាមប្រាថ្នា ។

+ តើការរើបំរះ ឬការតវ៉ារបស់នាងបែបនេះខុសឬត្រូវ ?

+ ចំពោះការទៅបោះឆ្នោត គឺអ្នកបោះឆ្នោតចង់ជ្រើសរើសអ្នកដែលគិតគូរពីផលប្រយោជន៍គេ ដូច្នេះអ្នកដែលជាប់ជាតំណាងត្រូវតែស្គាល់ពីសេចក្ដីប្រាថ្នា និងផលប្រយោជន៍ម្ចាស់ឆ្នោត ។

តម្លៃនៃការងារ :

ក្នុងការងារការរកប្រាក់ចំណូល តើអ្នកណាដែលជាអ្នកទទួលបាននូវកិត្តិយស អំណាច ឬភាពមោទនៈ ក្នុងចំណោមអ្នកដែលរកប្រាក់ចំណូល និងអ្នកដែលធ្វើការងារផ្ទះ ? ។

+ តាមធម្មតាការងារផ្ទះ ដែលរាប់បញ្ចូលទាំងការទុកដាក់ថែទាំផ្ទះសំបែង ការធ្វើម្ហូបអាហារ ការថែទាំកូនចៅ និងអ្នកដែលក្នុងបន្ទុក ការបន្តពូជ . . . ពុំបានទទួលនូវកំរៃឡើយ ។

+ ភាពរវល់នឹងការងាររបស់ស្ត្រី ធ្វើឲ្យស្ត្រីគ្មានឱកាសបានចូលរួមក្នុងការងាររកកំរៃសំខាន់ៗដូចបុរសឡើយ ម្ល៉ោះហើយការផ្តល់តម្លៃនឹងអំណាចដល់ស្ត្រីក៏តិចតួចដែរ ប៉ុន្តែតើគេអាចផ្លាស់ប្តូរការងារ ឬបំពេញ ឬចែករំលែកការងារគ្នាបានឬទេ ? ដើម្បីឲ្យស្ត្រីនិងបុរសអាចទទួលបាននូវសិទ្ធិស្មើភាព ទាំងការងារផលិត និងការងារមិនមែនផលិត ។

+ ការងារផលិត រាប់ទាំងការផលិតទំនិញ សេវាកម្មទីផ្សារ ដំណើរការផលិតវត្ថុធាតុដើម នៅផ្ទះ ឬនៅកន្លែងធ្វើការដទៃទៀត ។

+ នេះមិនទាន់និយាយដល់បុរសខ្លះដែលមិនបានជួយរកស៊ី ហើយធ្វើបាបប្រពន្ធកូនទៀតផង ។

# មេរៀនទី៩

## ការទទួលបាននិងការគ្រប់គ្រង លើធនធាននិងផលប្រយោជន៍ (១ម៉ោង)

ពន្យល់ន័យ :

**ការទទួលបាន** (Access to) :

ឧទាហរណ៍៤ : សម្ភារៈដែលនៅក្នុងថ្នាក់រៀននេះ យើងអាចយកប្រើប្រាស់បានក្នុងពេលសិក្សានេះ តែវាមិនមែនជាកម្មសិទ្ធិដាច់មុខរបស់យើង ដែលយើងអាចធ្វើបានតាមចិត្តនោះទេ ។ នៅពេលសិក្សាចប់យើងយើងត្រឡប់ទៅវិញតែខ្លួន ។

របៀបនេះហៅថាអ្នកទទួលបាននូវការប្រើប្រាស់ធនធាន ឬសម្ភារៈទាំងនេះ ។

**ការត្រួតត្រា** Control of (over) **:**

**ឧទាហរណ៍ :** ខោអាវ កាបូប សម្ភារៈរបស់អ្នក ដែលអ្នកគ្រប់គ្រងថែរក្សា អ្នកមានអំណាចចាត់ចែងបាន របៀបនេះហៅថា អ្នកត្រួតត្រាបានលើធនធានទាំងនេះ ។

ឧទាហរណ៍៥ : ស្ត្រីឥណ្ឌាដែលជាភរិយាមហាសេដ្ឋី នាងមានសិទ្ធិទទួលបាននូវមរតករបស់ស្វាមី តែនាងមិនអាចត្រួតត្រាលើធនធានទាំងនោះបានទេ ។

**ធនធាន** (resource) **:** មានច្រើនយ៉ាង អាចជា

\+ **ធនធានផលិតនិងធនធានសេដ្ឋកិច្ច** រាប់ទាំងដីធ្លី - បរិក្ខារ - គ្រឿងឧបភោគបរិភោគ - ប្រាក់កាស - ឥណទាន - ពលកម្ម - ចំណូលចំណាយ - ឱកាស - ជំនាញ - ពេលវេលា . . . ។ល។

\+ **ធនធាននយោបាយ :** ភាពជាអ្នកដឹកនាំ - ការអប់រំ - ពត៌មាន - បទពិសោធន៍ក្នុងកិច្ចការសាធារណៈ - ការជឿទុកចិត្តលើខ្លួនឯង - ការជឿនិងទុកចិត្ត និងគាំទ្រពីអ្នកដទៃ . . . ។ល។

\+ ការត្រួតត្រាលើធនធាន អាស្រ័យទៅលើសមត្ថភាព និងកម្រិតនៃអំណាច ។

**ផលប្រយោជន៍និងសេចក្ដីត្រូវការ :** មានពីរយ៉ាងគឺ ចំពោះមុខនិងយូរអង្វែង ឬជាយុទ្ធសាស្ត្រ

**តម្រូវការជាក់ស្ដែង**

- រយៈពេលខ្លី (ឬមធ្យម) ឆាប់រហ័ស

ឧ. ទឹកស្អាត - អាហារ - ជម្រក - ប្រាក់ចំណូល

\+ អាចដោះស្រាយបានភ្លាមៗ

\+ ជាគន្លឹះសម្រាប់ការប្រឈមមុខនឹងឧបសគ្គដទៃទៀត

\+ អាចជាបុគ្គល ឬសង្គម

**តម្រូវការជាយុទ្ធសាស្ត្រ**

- រយៈពេលវែង យូរអង្វែងនិងមានលក្ខណៈជាយុទ្ធសាស្ត្រ

ឧ. ការលើកស្ទួយជីវភាព - តម្រូវការអប់រំ- ការអភិវឌ្ឍន៍ - សមត្ថភាព . . . ។ល។

- អាចជាបុគ្គល ឬជាសង្គម

លើកយកមកពិនិត្យ :

\+ នៅក្នុងផ្ទះស្ត្រីអាចទទួលបាន និងត្រួតត្រាលើធនធានអ្វីខ្លះ ?

បោះពុម្ពផ្សាយលើកទី១ ចំនួន ៤៦៨ក្បាល
ភ្នំពេញ, ខែកក្កដា ឆ្នាំ២០០១

First Edition
468Copies
Phnom Penh, July 2001

រក្សាសិទ្ធិ
**វិទ្យាស្ថានកម្ពុជាដើម្បីសិទ្ធិមនុស្ស**

**Copyright**
**Cambodian Institute of Human Rights**

ហាមលក់

**Not For Sale**

library.ncdd.gov.kh
015578

CIHR, #30, Street 57, Sangkat Boeng Keng Kang I, Khan Chamcar Morn,
Phnom Penh, Cambodia, P.O.Box 550, Direct Phone and Fax: (855-23) 362 739 - 210 596
Tel: 012 818 035 - 815 557, E-mail: cihr@forum.org.kh, cihr@camnet.com.kh
Web-sit http://www.ned.org/page 3/ CIHR